# ពួកជំនុំដែល
# មានសុខភាពល្អ




និពន្ធដោយលោកគ្រូ ម៉ាក ដិវើរ

CROSSWAY
WHEATON, ILLINOIS

*What Is a Healthy Church?*
*ពួកជំនុំដែលមានសុខភាពល្អ*
Copyright © 2007 by Mark E. Dever and 9Marks
រក្សាសិទ្ធិ © ២០០៧ ដោយលោកគ្រូ ម៉ាក ដិវើរ និង 9Marks
Published by Crossway
ផលិតដោយ Crossway
a publishing ministry of Good News Publishers
ព័ន្ធកិច្ចរបស់ Good News Publishers
Wheaton, Illinois 60187, U.S.A.
This edition published by arrangement with Crossway.
សៀវភៅនេះបានទទួលការអនុញ្ញាតចងក្រងដោយ Crossway។
All rights reserved.
រក្សាសិទ្ធិគ្រប់យ៉ាង។
Reprinted from *9 Marks of a Healthy Church*, Copyright © 2005 by Mark E. Dever
បោះពុម្ពតាម *9 Marks of a Healthy Church*, រក្សាសិទ្ធិ © ២០០៥ ដោយលោក ម៉ាក ដិវើរ

អ្នកបកប្រែចម្បង៖ លោក ជឿន ជីវិចន្ទា
ជំនួយការបកប្រែ៖ លោក ជួប ប៊ុនហាក់, លោក ឈាង បូរ៉ា
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ សកម្មភាពកម្ពុជា resources@actioncambodia.org
សូមថ្លែងអំណរគុណដល់៖ លោកស្រី សំ ថាវី, លោកស្រី អ៊ែវិនសិន វន្នី, លោកស្រី កង សុគន្ធរ័ត្ន, លោក ម៉ែន ជំនោ, លោក វ៉ា វចនា, លោក យឿន សុវណ្ណារ៉ា, កញ្ញា សៀង ស្រីម៉ាច និងកញ្ញា ឈឿន សុភី
អ្នករចនាក្រប៖ Josh Dennis
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក ផុន ស្រីអែម
រូបភាពក្របមកពី៖ iStock

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤, ព្រះគម្ពីរសញ្ញាថ្មីកែសម្រួលឆ្នាំ២០១៤ (គកស), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ (គគខ), ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។ គ្រប់ពាក្យនៅក្នុងអត្ថបទសម្រង់ខគម្ពីរដែល ទ្រេត គឺបានធ្វើឡើងដោយអ្នកនិពន្ធ។

For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
http://www.cambodianchristianresources.com/healthychurch/

បោះពុម្ពលើកទី១ ចំនួន៣.០០០ក្បាល គ.ស២០១៤ នៅព្រះរាជាណាចក្រកម្ពុជា

*អរព្រះគុណដល់ព្រះជាម្ចាស់*
*ដែលបានអនុញ្ញាតឲ្យខ្ញុំស្គាល់គ្រូគង្វាលដ៏ស្មោះត្រង់៖*

Harold Purdy
Wally Thomas
Ed Henegar

*សូមថ្លែងអំណរគុណដល់ The Theological Famine Relief Project របស់ The Gospel Coalition ដែលបានផ្តល់ជំនួយក្នុងការបកប្រែ និងការបោះពុម្ពសៀវភៅនេះ។*

# មាតិកា


បុព្វកថា៖ រឿងប្រៀបប្រដូច. . . . . . . . . . . . . . . . . . . . . . ៩
សេចក្តីផ្តើម៖ តើលោកអ្នកកំពុងតែស្វែងរកអ្វី
នៅក្នុងពួកជំនុំ? . . . . . . . . . . . . . . . . . . . . . . . . . . . ១៥

**ផ្នែកទី១៖ តើពួកជំនុំដែលមានសុខភាពល្អមានលក្ខណៈ យ៉ាងដូចម្តេច?**

១ គ្រីស្ទសាសនារបស់លោកអ្នក
និងពួកជំនុំរបស់លោកអ្នក . . . . . . . . . . . . . . . . .២៧
២ លក្ខណៈពួកជំនុំ និងអ្វីដែលមិនមែន
ជាលក្ខណៈពួកជំនុំ. . . . . . . . . . . . . . . . . . . . . . .៤៩
៣ ពួកជំនុំគួរប្រាថ្នាចង់បានសុខភាពល្អ . . . . . . . . . . .៦១
៤ របៀបបង្ហាញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់. . . . .៨៣

គំនិតជំនួយខ្លះៗ៖ ប្រសិនបើលោកអ្នក
មានគំនិតចង់ផ្លាស់ប្តូរពួកជំនុំ... . . . . . . . . . . . . . . . .១០០

**ផ្នែកទី២៖ សញ្ញាសម្គាល់ដ៏ចាំបាច់នៃពួកជំនុំ ដែលមានសុខភាពល្អ**

៥ សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ . . . . . . . . .១០៩
៦ ទេវវិទ្យាតាមព្រះគម្ពីរ . . . . . . . . . . . . . . . . . . . .១២១
៧ ការយល់ពីដំណឹងល្អតាមព្រះគម្ពីរ . . . . . . . . . . ១៣៣

គំនិតជំនួយខ្លះៗ៖ របៀបស្វែងរក
ពួកជំនុំមួយដែលល្អ ......................១៤០

## ផ្នែកទី៣៖ សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំ ដែលមានសុខភាពល្អ

៨ ការយល់ពីការក្លាយជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរ..១៤៩
៩ ការយល់ពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ.....១៥៩
១០ ការយល់ដ៏ត្រឹមត្រូវពីសមាជិកភាព
ពួកជំនុំតាមព្រះគម្ពីរ ..................១៦៧
១១ ការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ ..........១៨៣
១២ ការបង្កើតសិស្ស និងការលូតលាស់តាមព្រះគម្ពីរ..១៩៧
១៣ ការដឹកនាំពួកជំនុំតាមព្រះគម្ពីរ.............២០៩
សេចក្តីបញ្ចប់៖ ការអនុវត្តជាក់ស្តែង............. ២២៣
សេចក្តីបន្ថែម៖ លក្ខន្តិកៈដ៏សាមញ្ញ
ក្នុងពួកជំនុំដែលមានសុខភាពល្អ .............. ២៣១
ថ្លែងអំណរគុណជាពិសេស ................. ២៣៥

# បុព្វកថា៖ រឿងប្រៀបប្រដូច

ព្រះទ្រង់បានដាក់ចុះនូវអវយវៈនីមួយៗ ក្នុងរូបកាយតាមព្រះហឫទ័យទ្រង់ បើគ្រប់ទាំងអស់សុទ្ធតែជាអវយវៈតែ១ នោះតើរូបកាយនឹងនៅឯណា តែមានអវយវៈជាច្រើនវិញ ប៉ុន្តែរូបកាយតែ១ទេ ហើយភ្នែកពុំអាចនិយាយទៅដៃថា អញមិនត្រូវការនឹងឯងទេ ឬក្បាលនិយាយទៅជើងថាអញមិនត្រូវការនឹងឯងដែរនោះឡើយ។

— ១កូរិនថូស ១២:១៨-២១

**ក្រោយពីកម្មវិធីថ្វាយបង្គំ**ពេលព្រឹកដែលដឹកនាំដោយលោកត្រចៀក និងលោកមាត់បានបញ្ចប់ នោះលោកច្រមុះ និងលោកដៃក៏បានអង្គុយជជែកគ្នានៅក្នុងព្រះវិហារ។ ពេលនោះ លោកដៃបានប្រាប់លោកច្រមុះថា រូបលោក និងគ្រួសាររបស់លោកបានសម្រេចចិត្តស្វែងរកពួកជំនុំមួយទៀតហើយ។

លោកច្រមុះបានសួរទៅកាន់លោកដៃថា “ពិតមែនឬ? ហេតុអ្វីបានជាប្អូនសម្រេចចិត្តបែបហ្នឹង?”។

ពេលនោះលោកដៃបានឆ្លើយតបទៅវិញដោយឈ្ងោកមុខថា “ហ៎! ខ្ញុំមិនដឹងទេ”។ តាមធម្មតា គាត់ជាមនុស្សយឺតនឹងនិយាយ

ជាងសមាជិកពួកជំនុំដទៃទៀត។ រួចលោកដៃក៏បន្តទៀតថា “ខ្ញុំគិតថាដោយសារតែពួកជំនុំនេះមិនមានអ្វីដែលខ្ញុំ និងប្រពន្ធរបស់ខ្ញុំកំពុងតែស្វែងរកនោះទេ”។

លោកច្រមុះបានសួរថា “អញ្ចឹង តើប្អូនកំពុងតែស្វែងរកអ្វីនៅក្នុងពួកជំនុំ?”។

លោកច្រមុះនិយាយពាក្យទាំងនេះដោយសំឡេងក្តួលអាណិត ប៉ុន្តែ ទោះបីជាគាត់និយាយពាក្យទាំងនេះ ក៏គាត់នៅតែមិនឯកភាពនឹងចម្លើយរបស់លោកដៃដដែល។ ហើយប្រសិនបើលោកដៃ និងប្រពន្ធរបស់គាត់ មិនបានមើលឃើញថា លោកច្រមុះ និងអ្នកដឹកនាំឯទៀតដឹកនាំពួកជំនុំបានយ៉ាងល្អត្រឹមត្រូវទេ នោះពួកជំនុំក៏មិនត្រូវការគ្រួសារលោកដៃដែរ។

នៅពេលឮលោកច្រមុះសួរដូចនោះ លោកដៃបានពិចារណាបន្តិចមុននឹងគាត់ឆ្លើយ។ លោកដៃ និងប្រពន្ធរបស់គាត់ ចូលចិត្តលោកគ្រូមាត់ និងគ្រួសាររបស់គាត់។ ហើយលោកត្រចៀកដែលជាអ្នកនាំកម្មវិធីថ្វាយបង្គំក៏ជាមនុស្សល្អ មានគុណធម៌ ហើយសប្បុរសទៀត។

ចុងបញ្ចប់ លោកដៃបានឆ្លើយទាំងរអាក់រអួលថា “តាមពិតទៅខ្ញុំគិតថាយើងកំពុងតែស្វែងរកពួកជំនុំមួយដែលមនុស្សភាគច្រើនមានលក្ខណៈដូចពួកយើង”។ គាត់បានបន្តថា “ពួកយើងបាន

សាកល្បងចំណាយពេលជាមួយនឹងគ្រួសារលោកជើងដែរ ប៉ុន្តែពួកយើងហាក់ដូចជាមិនស៊ីចង្វាក់ជាមួយនឹងពួកគេទេ។ បន្ទាប់មក ពួកយើងបានចូលរួមក្រុមតូចដែលមានសុទ្ធតែគ្រួសារលោកម្រាមជើង ប៉ុន្តែ ពួកគេគិតតែនិយាយពីស្រោមជើង ស្បែកជើង និងក្លិនរបស់វាទៅវិញ ហើយយើងមិនចាប់អារម្មណ៍នឹងការនោះទេ»។

លោកច្រមុះបានមើលទៅលោកដៃម្តងនេះដោយស្រងាកចិត្ត ហើយក៏សួរថា «តើប្អូនមិនសប្បាយចិត្តទេឬអី ដែលពួកគេបានយកចិត្តទុកដាក់ទៅលើក្លិននោះ?»។

លោកដៃក៏ឆ្លើយថា «ពិតប្រាកដណាស់! ប៉ុន្តែ ពួកយើងមិនសូវខ្វល់អំពីការនោះប៉ុន្មានទេ។ បន្ទាប់មក ពួកយើងបានចូលរួមរៀននៅសាលារៀនថ្ងៃអាទិត្យដែលមានសុទ្ធតែលោកត្រចៀក លោកភ្នែក លោកច្រមុះ និងលោកមាត់។ តើបងចងចាំទេថា ពួកយើងចូលរួមបានបួនប្រាំសប្តាហ៍ដែរកាលពីប៉ុន្មានខែមុន?»។

លោកច្រមុះបាននិយាយថា «បាទ ល្អដែលប្អូនបានចូលរួមជាមួយពួកយើង»។

លោកដៃក៏តបថា «អរគុណ! ប៉ុន្តែពួកគេគ្រប់គ្នាគ្រាន់តែចង់និយាយ ស្តាប់ ហិតក្លិន ហើយភ្លក់រសជាតិតែប៉ុណ្ណោះ។ មើលទៅដូចជាពួកគេមិនចង់ធ្វើការ ហើយមិនចង់ប្រឡាក់ដៃសោះ។ និយាយអញ្ចឹង ប្រពន្ធខ្ញុំ និងខ្ញុំគិតថា យើងនឹងសាកល្បងចូលរួមជាមួយ

ពួកជំនុំថ្មីមួយនៅខាងកើតនេះ។ ពួកយើងឮថា ពួកគេចូលចិត្ត ទះដៃ និងលើកដៃសរសើរព្រះជាម្ចាស់ហើយនោះគឺជាអ្វីដែលពួក យើងចង់បានឥឡូវនេះ»។

លោកច្រមុះបានឆ្លើយតបថា «ហ៊ឺ! ខ្ញុំយល់ពីអ្វីដែលប្អូន និយាយហើយ ពួកយើងពិតជាមិនចង់ឃើញប្អូនចេញទៅទេ ប៉ុន្តែ ខ្ញុំយល់ថា ប្អូនត្រូវតែធ្វើអ្វីដែលល្អសម្រាប់ខ្លួនឯង»។

នៅពេលនោះប្រពន្ធរបស់លោកដៃដែលកំពុងជាប់មាត់សន្ទនា ជាមួយអ្នកផ្សេងទៀតនោះ ក៏បានងាកមកចូលរួមជាមួយនឹងប្ដីរបស់ នាង និងលោកច្រមុះវិញ។ លោកដៃបានពន្យល់ដោយសង្ខេបពីអ្វី ដែលគាត់ និងលោកច្រមុះទើបតែបាននិយាយ។ បន្ទាប់មក លោក ច្រមុះបានសម្ដែងនូវការសោកស្ដាយរបស់លោក ពីការចាកចេញ របស់គ្រួសារលោកដៃ។ ហើយលោកច្រមុះបាននិយាយម្ដងទៀតថា គាត់យល់ ពីព្រោះស្ដាប់ទៅដូចជាពួកជំនុំមិនបានបំពេញតម្រូវការ របស់លោកដៃ និងគ្រួសាររបស់គាត់ទេ។

ប្រពន្ធរបស់លោកដៃបានងក់ក្បាលឯកភាព។ នាងចង់ធ្វើជាគួរ សម ប៉ុន្តែតាមពិតទៅ នាងមិនមែនមិនសប្បាយចិត្តនឹងចាកចេញ នោះទេ។ ប្ដីរបស់នាងបានរិះគន់ពួកជំនុំល្មមគ្រប់គ្រាន់ហើយក្នុង រយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ អញ្ចឹងហើយ ចិត្តរបស់នាងក៏មិន ខុសពីប្ដីរបស់នាងនោះដែរ។ ទោះជាយ៉ាងនោះក្ដី ប្ដីរបស់នាងមិន

ដែលនិយាយរិះគន់ទាស់នឹងរូបកាយនៃពួកជំនុំជាចំហរនោះទេ។ តាមពិតទៅ គាត់ធ្លាប់សុំទោសពីការដែលគាត់មានគំនិតអវិជ្ជមានខ្លាំងពេកចំពោះពួកជំនុំជាច្រើនមកហើយ ប៉ុន្តែ ការត្អូញត្អែរបន្តិចបន្តួចដែលគាត់បាននិយាយចេញមកត្រង់នេះបន្តិច និងត្រង់នោះបន្តិច បានជះឥទ្ធិពលលើប្រពន្ធរបស់គាត់រួចទៅហើយ។ លោកដែគិតថា ក្រុមតូច*មាន*ការប្រកាន់បក្សពួកបន្តិច បទចម្រៀង*គឺ*ហួសសម័យបន្តិច ហើយកម្មវិធីហាក់*ដូចជា*ខុសទំនងបន្តិច។ ហើយពួកគេក៏*មិនសូវ*ពេញចិត្តលើសេចក្តីបង្រៀនដែរ។ ពួកគេមិនដឹងច្បាស់ពីមូលហេតុដែលពួកគេចង់ចេញពីពួកជំនុំនេះទេ ប៉ុន្តែ ពួកគេគិតថា ពួកជំនុំនេះមិនស៊ីចង្វាក់នឹងពួកគេសោះ។

លើសពីនោះទៅទៀត ប្រពន្ធរបស់លោកដែបានដឹងថា កូនស្រីរបស់ពួកគេមិនសូវកក់ក្តៅជាមួយនឹងក្រុមយុវជនឯទៀតនោះទេ។ គ្រប់គ្នាមានលក្ខណៈខុសប្លែកពីនាង ដូច្នេះហើយ នាងមានអារម្មណ៍ថាមិនស៊ីចង្វាក់ជាមួយនឹងពួកគេទាល់តែសោះ។

បន្ទាប់មក ប្រពន្ធរបស់លោកដែបានកោតសរសើរជាខ្លាំងដល់លោកប្រមុះ និងអ្នកដឹកនាំដទៃទៀត។ ប៉ុន្តែ ការសន្ទនាបានអូសបន្លាយយូរពេកហើយសម្រាប់លោកប្រមុះ។ មិនតែប៉ុណ្ណោះ ក្លិនទឹកអប់របស់នាងបានធ្វើឲ្យគាត់ចង់ឈ្លក់។ គាត់បានអរគុណដល់នាង អំពីការលើកទឹកចិត្តរបស់នាង ហើយក៏បានបញ្ជាក់ម្តងទៀត

ថា គាត់សោកស្ដាយណាស់ដោយបានឮពីការចាកចេញរបស់ពួកគេ រួចហើយក៏ដើរចេញទៅ។

តើមាននរណាត្រូវការគ្រួសារលោកដៃឬទេ? ពួកជំនុំនេះគិតថា ពួកគេមិនត្រូវការគ្រួសារលោកដៃនោះឡើយ។

# សេចក្តីផ្តើមៈ
# តើលោកអ្នកកំពុងតែស្វែងរកអ្វី
# នៅក្នុងពួកជំនុំ?

**តើលោកអ្នកកំពុង**តែស្វែងរកអ្វីនៅក្នុងពួកជំនុំ? ប៉ុន្មានថ្ងៃនេះ លោកអ្នកប្រហែលជាមិនបានគិតអំពីសំណួរនេះនោះទេ។ ប៉ុន្តែ ឥឡូវនេះ សូមចំណាយពេលបន្តិច ដើម្បីសួរខ្លួនឯងថា តើពួកជំនុំ ដែលល្អឥតខ្ចោះមានលក្ខណៈបែបណា? «ពួកជំនុំដែលល្អឥតខ្ចោះ គឺជាកន្លែងមួយដែលមាន...»

លោកអ្នកប្រហែលជាគិតថា ពួកជំនុំដែលល្អឥតខ្ចោះគឺជា កន្លែងមួយដែលមានតន្ត្រីពីរោះ ដោយសារពួកគេបានហាត់សម យ៉ាងល្អ។ លោកអ្នកប្រហែលជាមិនចង់ឲ្យមានតន្ត្រីសម័យទេ ប៉ុន្តែចង់ឲ្យមានភ្លេងខ្មែរបុរាណវិញ ដោយគិតថា តន្ត្រីបែបនេះពីរោះ ហើយអាចលើកតម្កើងព្រះជាម្ចាស់បានល្អជាងគេ។ ឬក៏លោកអ្នក

ប្រហែលជាចង់ឲ្យមានហ្គីតា និងស្គរ ឬក៏ឧបករណ៍ដែលទាន់សម័យ ដោយសារនោះជាអ្វីដែលបណ្ដាជនស្ដាប់តាមវិទ្យុ ដែលនោះហើយជាអ្វីដែលធ្វើឲ្យពួកគេអរសប្បាយ។

ឬប្រហែលជាលោកអ្នកគិតថា តន្ត្រីមិនសូវសំខាន់ចំពោះលោកអ្នកដូចជាសេចក្ដីអធិប្បាយនោះទេ។ លោកអ្នកចង់បានពួកជំនុំមួយដែលមានសេចក្ដីអធិប្បាយល្អ គឺជាសេចក្ដីអធិប្បាយដែលមានអត្ថន័យ តែមិនថ្កោលទោស គឺជាសេចក្ដីអធិប្បាយដែលត្រឹមត្រូវតាមព្រះគម្ពីរ តែមិនគួរឲ្យធុញទ្រាន់ គឺជាសេចក្ដីអធិប្បាយដែលងាយៗអាចអនុវត្តបាន តែមិនរើសអើង ហើយមិនមែនបែបជាក្រឹត្យវិន័យនិយមនោះទេ។ ហើយចរិតលក្ខណៈរបស់គ្រូអធិប្បាយដើរតួយ៉ាងសំខាន់នៅក្នុងសេចក្ដីអធិប្បាយរបស់គាត់។ យើងដឹងហើយថា មានគ្រូអធិប្បាយគ្រប់ប្រភេទនៅក្នុងសង្គមយើងដូចជាគ្រូអធិប្បាយបែបជាអ្នកប្រាជ្ញដ៏ម៉ឺងម៉ាត់ដែលស្រឡាញ់គោលលទ្ធិហើយមិនដែលញញឹមសោះ។ មានគ្រូអធិប្បាយកំប្លុកកំប្លែងដែលមានរឿងនិទានច្រើនរាប់មិនអស់ ហើយក៏មានគ្រូអធិប្បាយបែបជាអ្នកប្រឹក្សាយោបល់ដែលបានឆ្លងកាត់បទពិសោធន៍ជីវិតមុនយើង។ ពិតណាស់ ខ្ញុំគ្រាន់តែរៀបរាប់ត្រួសៗទេ ប៉ុន្តែពួកយើងភាគច្រើនពិតជាមានសេចក្ដីរំពឹងមួយចំនួនថា គ្រូគង្វាលគួរតែមានចរិតលក្ខណៈបែបណានោះ មិនថាអញ្ចឹង?

ឬមួយក៏ លោកអ្នកកំពុងតែស្វែងរកពួកជំនុំមួយដែលមានស្ថានភាពជីវិតដូចជាលោកអ្នកដែរ ដោយសារលោកអ្នកអាចយល់ពីពួកគេបាន។ ពួកគេយល់ពីអ្វីដែលលោកអ្នកកំពុងតែឆ្លងកាត់ ពីព្រោះពួកគេកំពុងតែឆ្លងកាត់ដូចជាលោកអ្នកដែរ។ ពួកគេទើបតែបញ្ចប់មហាវិទ្យាល័យដូចជាលោកអ្នកដែរ។ ពួកគេមានកូនតូចៗដូចជាលោកអ្នកដែរ។ ពួកគេជិតដល់ពេលចូលនិវត្តន៍ដូចជាលោកអ្នកដែរ។ ពួកគេធ្លាប់ចូលហាងជជុះដូចជាលោកអ្នកដែរ ឬក៏ធ្លាប់ចូលហាងទំនើបៗដូចជាលោកអ្នកដែរ។ ពួកគេមកពីទីក្រុងដូចជាលោកអ្នកដែរ ឬក៏ប្រហែលជាមកពីជនបទដូចជាលោកអ្នកដែរ។

ម៉្យាងទៀត ប្រហែលអ្វីដែលសំខាន់បំផុតចំពោះលោកអ្នកនៅក្នុងពួកជំនុំនោះ គឺជាពួកជំនុំមួយដែលផ្តល់ឱកាសឲ្យលោកអ្នកចូលរួមចំណែកក្នុងព័ន្ធកិច្ច ឬធ្វើការមនុស្សធម៌ផ្សេងៗ។ ប្រហែលជាលោកអ្នកចង់ដឹងថា តើពួកជំនុំនោះឲ្យតម្លៃខ្ពស់លើការផ្សាយដំណឹងល្អដែរឬទេ? តើពួកជំនុំនោះឲ្យតម្លៃខ្ពស់លើបេសកកម្មដែរឬទេ? តើពួកជំនុំនោះឲ្យតម្លៃខ្ពស់លើការជួយដល់អ្នកក្រីក្រដែរឬទេ? តើពួកជំនុំផ្តល់ឱកាសឲ្យលោកអ្នក និងគ្រួសារលោកអ្នកមានពេលវេលាប្រកបជាមួយនឹងគ្រួសារផ្សេងៗដែរឬទេ? ចុះចំណែកឯឱកាសសម្រាប់លោកអ្នក ដើម្បីនឹងជួយនៅ

ក្នុងព័ន្ធកិច្ចកុមារវិញនោះ? តើពួកជំនុំមានកម្មវិធីដែលទាក់ទាញចំណាប់អារម្មណ៍កូនតូចៗ ឬកូនវ័យជំទង់របស់លោកអ្នកដែរឬទេ?

ខ្ញុំដឹងប្រាកដថា មានមនុស្សមួយចំនួនកំពុងតែស្វែងរកពួកជំនុំមួយដែលស្ដាប់ឮសំឡេងព្រះវិញ្ញាណបរិសុទ្ធរៀងរាល់ថ្ងៃ។ ព្រះវិញ្ញាណជាអ្នកនាំផ្លូវយើង ដូច្នេះហើយ លោកអ្នកចង់បានពួកជំនុំមួយដែលឆាប់នឹងស្ដាប់ឮសំឡេងរបស់ទ្រង់ ឆាប់នឹងមើលឃើញកិច្ចការរបស់ទ្រង់ ហើយឆាប់នឹងជឿលើកិច្ចការដ៏អស្ចារ្យដែលទ្រង់ធ្វើ។ លោកអ្នកប្រាកដជាធុញទ្រាន់នឹងការដែលនៅក្បែរអ្នកដែលពន្លត់ព្រះវិញ្ញាណ និងអ្នកដែលស្រឡាញ់ទំនៀមទំលាប់ចាស់ៗនៅក្នុងពួកជំនុំ។ លោកអ្នកប្រហែលជាគិតថា “ព្រះវិញ្ញាណកំពុងតែធ្វើកិច្ចការថ្មីៗ! ទ្រង់កំពុងតែប្រទានឲ្យយើងនូវបទចម្រៀងថ្មីៗ!»។

ប្រហែលជាលោកអ្នកកំពុងតែស្វែងរកពួកជំនុំមួយដូចពួកជំនុំចាស់របស់លោកអ្នក។ ទោះបើលោកអ្នកមិនធ្លាប់និយាយអញ្ចឹងក៏ដោយ ប្រសិនបើលោកអ្នកសាំុថ្មីកនឹងពួកជំនុំដែលមើលទៅដូចជាទំនើប ឬដូចជាកន្លែងថ្វាយបង្គំដ៏ចាស់បុរាណមួយ ឬដូចហាងកាហ្វេ នោះវាមិនពិបាកយល់ពីមូលហេតុដែលលោកអ្នកចង់បានពួកជំនុំដូចពីមុន ដោយសារមនុស្សទូទៅចង់បានអ្វីដែលពួកគេធ្លាប់មាន។ នៅពេលដែលយើងរើចេញពីផ្ទះរបស់ឪពុកម្ដាយ

យើង តើយើងមិនមានអារម្មណ៍នឹកស្រណោះដល់ទិដ្ឋភាព ក្លិន ឬសំឡេងដែលឪពុកម្ដាយរបស់យើងបានធ្វើទេឬ?

យើងមិនអាចថា ការចង់បានបែបនេះសុទ្ធតែជាការអាក្រក់ទេ តាមពិតភាគច្រើនអាចរាប់ថាជាការល្អ ប៉ុន្តែ ខ្ញុំលើកចំណុចខាងលើនេះឡើង ដើម្បីឲ្យលោកអ្នកចាប់ផ្ដើមគិតអំពីលក្ខណៈរបស់ពួកជំនុំដែលលោកអ្នកគិតថាសំខាន់។

តើលោកអ្នកកំពុងតែស្វែងរកពួកជំនុំបែបណា? ពួកជំនុំមួយដែលមានភាពរួសរាយរាក់ទាក់ ពួកជំនុំមួយដែលមានភាពឆេះឆួល ពួកជំនុំមួយដែលឥតពុតត្បុត ពួកជំនុំមួយដែលមានសមាជិកច្រើន ពួកជំនុំមួយដែលមានភាពជិតស្និទ្ធ ពួកជំនុំមួយដែលមានភាពទាន់សម័យ ពួកជំនុំមួយដែលមានភាពរំភើប ឬពួកជំនុំមួយដែលមានភាពប្ដូរផ្ដាច់?

តើពួកជំនុំគួរតែមានលក្ខណៈបែបណា?

## ប្រធានបទមួយសម្រាប់គ្រីស្ទបរិស័ទទាំងអស់

នៅជំពូកបន្ទាប់ៗនេះ ខ្ញុំបានសរសេរពីអ្វីដែលព្រះគម្ពីរបានចែងពីលក្ខណៈដែលពួកជំនុំគួរតែមាន ប៉ុន្តែ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកអ្នកពិចារណាទៅមើលថា ហេតុអ្វីបានជាខ្ញុំសួរ*លោកអ្នក*ថា តើពួកជំនុំគួរតែមានលក្ខណៈបែបណាជាពិសេសនោះ ប្រសិនបើលោកអ្នក

មិនមែនជាគ្រូគង្វាលផងនោះ។ តើសៀវភៅស្ដីពីពួកជំនុំដែលមានសុខភាពល្អ មិនមែនជាសៀវភៅសម្រាប់គ្រូគង្វាល និងអ្នកដឹកនាំពួកជំនុំតែប៉ុណ្ណោះទេឬ?

បាទ ពិតប្រាកដណាស់ សៀវភៅនេះគឺសម្រាប់គ្រូគង្វាល ប៉ុន្ដែវាក៏សម្រាប់គ្រីស្ទបរិស័ទគ្រប់រូបផងដែរ។ ចូរចងចាំថា *អ្នកនិពន្ធព្រះគម្ពីរសញ្ញាថ្មី និពន្ធសម្រាប់គ្រីស្ទបរិស័ទគ្រប់រូប មិនគ្រាន់តែសម្រាប់គ្រូគង្វាលនោះទេ*។ នៅពេលដែលពួកជំនុំនៅស្រុកកាឡាទីបានចាប់ផ្ដើមស្ដាប់សេចក្ដីបង្រៀនគ្រូខុសឆ្គង នោះលោក ប៉ុល បានសរសេរសំបុត្រទៅពួកគេថា៖ «ខ្ញុំឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ ដែលទ្រង់ហៅអ្នករាល់គ្នាមកក្នុងព្រះគុណនៃព្រះគ្រីស្ទ ជាឆាប់ម្ល៉េះ» (កាឡាទី ១:៦)។

តើពាក្យថា «អ្នករាល់គ្នា» ដែលលោក ប៉ុល ឲ្យពន្យល់បកស្រាយពីសេចក្ដីបង្រៀនខុសឆ្គងនៅក្នុងពួកជំនុំកាឡាទី សំដៅលើនរណា? លោក ប៉ុល មិនមែនសំដៅទៅលើតែគ្រូគង្វាលប៉ុណ្ណោះទេ ប៉ុន្ដែក៏សំដៅទៅលើរូបកាយពួកជំនុំទាំងមូលផងដែរ។ លោកអ្នកប្រ-ហែលជាឆ្ងល់ថា ហេតុអ្វីបានជាគាត់មិនសរសេរទៅកាន់អ្នកដឹកនាំពួកជំនុំថា «ឈប់បង្រៀនសេចក្ដីបង្រៀនខុសឆ្គងនោះទៀតទៅ!» ក៏ប៉ុន្ដែ គាត់មិនមែនសរសេរទៅកាន់តែអ្នកដឹកនាំប៉ុណ្ណោះនោះទេ គឺគាត់សរសេរទៅកាន់ពួកជំនុំទាំងមូល ដោយគាត់បានសុំឲ្យពួកជំនុំ

ទាំងមូលបញ្ឈប់សេចក្តីបង្រៀនខុសឆ្គងនោះ។

ដូចគ្នានេះដែរ នៅពេលដែលពួកជំនុំនៅក្នុងទីក្រុងកូរិនថូស អនុញ្ញាតឲ្យអំពើកំផិតបន្តកើតមានឡើងដោយមិនព្រមកែតម្រង់អ្នកនោះនៅក្នុងចំណោមពួកគេលោក ប៉ុល បាននិយាយទៅកាន់ពួកជំនុំដោយផ្ទាល់ (១កូរិនថូស ៥)។ គាត់មិនបានប្រាប់គ្រូគង្វាល ឬក៏អ្នកដឹកនាំឲ្យទទួលខុសត្រូវលើបញ្ហានោះទេ។ ប៉ុន្តែ គាត់បានប្រាប់ពួកជំនុំឲ្យទទួលខុសត្រូវលើបញ្ហានោះវិញ។

សំបុត្រភាគច្រើននៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺមានលក្ខណៈដូច្នេះឯង។

ខ្ញុំជឿថា គ្រូគង្វាលនៅពួកជំនុំសតវត្សរ៍ទី១ទាំងនោះបានស្តាប់ដំបូន្មាន នៅពេលដែលលោក ប៉ុល និងលោក ពេត្រុស លោក យ៉ាកុប និងលោក យ៉ូហាន បានទូន្មានពួកជំនុំរបស់ពួកគេ។ ហើយខ្ញុំជឿទៀតថា គ្រូគង្វាលបានផ្តួចផ្តើម ហើយបាននាំមុខក្នុងការឆ្លើយតបទៅនឹងគ្រប់ទាំងសេចក្តីបង្រៀនដែលពួកសាវ័កបានបង្រៀននៅក្នុងសំបុត្ររបស់ពួកគេ។ ដូច្នេះ ខ្ញុំជឿថា ខ្ញុំបានធ្វើតាមគំរូរបស់ពួកសាវ័ក នៅពេលដែលខ្ញុំនិពន្ធសៀវភៅនេះសម្រាប់*លោកអ្នក* ទោះបើលោកអ្នកជាគ្រូគង្វាល ឬគ្រាន់តែជាសមាជិកក្តី ដោយសារព្រះជាម្ចាស់ឲ្យសមាជិកទាំងអស់រួមចំណែកទទួលខុសត្រូវលើសុខភាពរបស់ពួកជំនុំរបស់ពួកគេ។ នៅទីបំផុត

*លោកអ្នក*និងសមាជិកពួកជំនុំទាំងអស់ត្រូវទទួលខុសត្រូវចំពោះព្រះជាម្ចាស់ពីស្ថានភាពពួកជំនុំរបស់លោកអ្នក គឺមិនមែនគ្រាន់តែគ្រូគង្វាល និងអ្នកដឹកនាំដទៃទៀតរបស់*លោកអ្នក*ត្រូវទទួលខុសត្រូវនោះទេ។

ប្រាកដណាស់ គ្រូគង្វាលរបស់លោកអ្នកនឹងត្រូវឈរនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ ហើយត្រូវរៀបរាប់ពីរបៀបដែលពួកគេបានដឹកនាំពួកជំនុំ (ហេព្រើរ ១៣:១៧)។ ក៏ប៉ុន្តែ យើងម្នាក់ៗដែលជាសិស្សរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនឹងត្រូវរៀបរាប់ទូលដល់ទ្រង់ថា តើយើង*បានប្រជុំ*គ្នាជាទៀងទាត់ជាមួយពួកជំនុំដែរឬអត់ *បានកំឡា*ចិត្តពួកគេឲ្យមានសេចក្តីស្រឡាញ់ ហើយប្រព្រឹត្តការល្អដែរឬអត់ ហើយ*បានតយុទ្ធ*ដើម្បីកាន់ឲ្យខ្ជាប់តាមសេចក្តីបង្រៀនដ៏ត្រឹមត្រូវនៃសេចក្តីសង្ឃឹមនៃដំណឹងល្អដែរឬក៏អត់ (ហេព្រើរ ១០:២៣-២៥)។

មិត្តអើយ! ប្រសិនបើមិត្តហៅខ្លួនឯងថាជាគ្រីស្ទបរិស័ទ ប៉ុន្តែមិត្តគិតថាសៀវភៅស្តីអំពីពួកជំនុំដែលមានសុខភាពល្អ គឺជាសៀវភៅសម្រាប់តែអ្នកដឹកនាំពួកជំនុំ ឬសម្រាប់តែពួកអ្នកប្រាជ្ញខាងឯព្រះគម្ពីរ ហើយមិត្តបែរជាចូលចិត្តអានតែសៀវភៅអំពីជីវិតជាគ្រីស្ទបរិស័ទវិញ នោះប្រហែលជាមិត្តត្រូវឈប់សិន ហើយពិចារណាឡើងវិញថា តើព្រះគម្ពីរចែងពីលក្ខណៈរបស់គ្រីស្ទបរិស័ទដោយបែបណាឲ្យពិតប្រាកដនោះ។ យើងនឹងគិតអំពីការនេះបន្ថែម

ទៀតនៅក្នុងជំពូក១។

បន្ទាប់មក យើងនឹងពិចារណាថា តើពួកជំនុំមានលក្ខណៈយ៉ាងដូចម្តេច (ជំពូក២)? តើបំណងព្រះហឫទ័យចម្បងរបស់ព្រះជាម្ចាស់ចំពោះពួកជំនុំគឺជាអ្វី (ជំពូក៣)? ហើយតើហេតុអ្វីបានជាពួកជំនុំត្រូវតែចុះចូល ហើយត្រាប់តាមព្រះគម្ពីរ (ជំពូក៤)?

ប្រសិនបើលោកអ្នកបានឯកភាពរួចហើយថា ពួកជំនុំត្រូវតែចុះចូល ហើយត្រាប់តាមព្រះគម្ពីរ ដើម្បីបង្ហាញពីសិរីល្អរបស់ព្រះជាម្ចាស់ នោះលោកអ្នកអាចរំលងទៅជំពូក៥តែម្តង ដែលខ្ញុំបានសរសេរចំណុចប្រាំបួនយ៉ាងទាក់ទងនឹងសុខភាពរបស់ពួកជំនុំ។ ឱ! ព្រះអម្ចាស់អើយ! សូមទ្រង់ប្រើការសញ្ជឹងគិតរបស់យើងទាំងអស់គ្នាស្តីពីពួកជំនុំដែលមានសុខភាពល្អ ដើម្បីរៀបចំកូនក្រមុំរបស់ទ្រង់សម្រាប់ថ្ងៃយាងមកវិញរបស់ទ្រង់។ (អេភេសូរ ៥:២៥-៣២)

ផ្នែកទី១

# តើពួកជំនុំដែលមានសុខភាពល្អមានលក្ខណៈយ៉ាងដូចម្ដេច?

ជំពូក១

# គ្រីស្ទសាសនារបស់លោកអ្នក និង ពួកជំនុំរបស់លោកអ្នក

**ពេលខ្លះ ក្រុម**ធ្វើព័ន្ធកិច្ចនៅតាមមហាវិទ្យាល័យបានអញ្ជើញខ្ញុំឲ្យចែកចាយទៅកាន់សិស្សរបស់ពួកគេ។ ជួនកាលខ្ញុំចាប់ផ្ដើមចែកចាយដូច្នេះថា៖ «ប្រសិនបើ អ្នករាល់គ្នាហៅខ្លួនឯងថាជាគ្រីស្ទបរិស័ទ ប៉ុន្តែអ្នករាល់គ្នាមិនមែនជាសមាជិកនៃពួកជំនុំណាមួយដែលអ្នករាល់គ្នាចូលរួមជាទៀងទាត់ទេ នោះខ្ញុំបារម្ភថា អ្នករាល់គ្នានឹងទៅស្ថាននរក»។

មើលទៅ ការនិយាយដូច្នោះពិតជាទាក់ទាញចំណាប់អារម្មណ៍ពីពួកគេមែន។

តើខ្ញុំគ្រាន់តែនិយាយដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីពួកគេឬ? ទេខ្ញុំគិតថាមិនដូច្នោះឡើយ។ តើខ្ញុំកំពុងតែបន្លាចពួកគេ ដើម្បីឲ្យពួកគេចូលជាសមាជិកពួកជំនុំឬ? ទេ មិនពិតទេ។ តើខ្ញុំកំពុងតែនិយាយថា ការចូលធ្វើជាសមាជិកពួកជំនុំណាមួយអាចធ្វើឲ្យ

បុគ្គលនោះក្លាយជាគ្រីស្ទបរិស័ទឬ? ប្រាកដណាស់ មិនមែនដូច្នេះទេ! ចូរបោះចោលសៀវភៅ ឬដេញអ្នកចែកចាយណាដែលនិយាយបែបហ្នឹងចេញទៅ។

អញ្ចឹង តើហេតុអ្វីបានជាខ្ញុំចាប់ផ្ដើមដោយការព្រមានបែបនេះ? នេះគឺដោយសារតែខ្ញុំចង់ឲ្យពួកអ្នកស្ដាប់មើលឃើញថា ពួកគេពិតជាត្រូវការពួកជំនុំតាមតំបន់ដែលមានសុខភាពល្អជាបន្ទាន់ក្នុងនាមជាគ្រីស្ទបរិស័ទ ក៏ដូចជាចង់ឲ្យពួកគេចាប់ផ្ដើមមានចិត្តស្រឡាញ់ពួកជំនុំដូចព្រះគ្រីស្ទ និងសិស្សរបស់ទ្រង់។

សព្វថ្ងៃនេះ មានគ្រីស្ទបរិស័ទជាច្រើននៅប្រទេសលោកខាងលិច និងកន្លែងផ្សេងទៀតគិតថា ការធ្វើជាគ្រីស្ទបរិស័ទគ្រាន់តែជាការមានទំនាក់ទំនងផ្ទាល់ជាមួយព្រះជាម្ចាស់ប៉ុណ្ណោះ ហើយមិនចាំបាច់មានអ្វីផ្សេងទៀតឡើយ។ ជាទូទៅ ពួកគេដឹងថា ទំ-នាក់ទំនងនេះតម្រូវឲ្យពួកគេរស់នៅក្នុងរបៀបមួយដែលត្រឹមត្រូវ។ ប៉ុន្តែ ក្ដីបារម្ភរបស់ខ្ញុំគឺថា គ្រីស្ទបរិស័ទជាច្រើនមិនបានដឹងថា ការមានទំនាក់ទំនងជាមួយព្រះជាម្ចាស់គឺតម្រូវឲ្យពួកគេមានទំនាក់-ទំនងជាមួយអ្នកជឿជាច្រើនទៀតនោះទេ។ ទំនាក់ទំនងជាមួយអ្នកជឿ ជាទំនាក់ទំនង ដែលព្រះគ្រីស្ទបានបង្កើតមករវាងយើង និងរូបកាយរបស់ទ្រង់ដែលជាពួកជំនុំនោះឯង។ ព្រះជាម្ចាស់មិនមានព្រះហឫទ័យឲ្យយើងគ្រាន់តែជ្រើសរើសគ្រីស្ទបរិស័ទខ្លះៗ

ក្នុងចំណោមគ្រីស្ទបរិស័ទជាច្រើនមកធ្វើជាមិត្តរបស់យើងនោះទេ ប៉ុន្តែទ្រង់មានបំណងព្រះហឫទ័យឲ្យយើងមានទំនាក់ទំនងជាមួយនឹងក្រុមមនុស្ស ទោះបីជាពួកគេគួរឲ្យស្រឡាញ់ក្តី ឬក៏មិនគួរឲ្យស្រឡាញ់ក្តី។

ហេតុអ្វីបានជាខ្ញុំបារម្ភថា លោកអ្នកនឹងទៅស្ថាននរក ប្រសិនបើលោកអ្នកហៅខ្លួនឯងថាជាគ្រីស្ទបរិស័ទមួយរូប ប៉ុន្តែលោកអ្នកមិនមែនជាសមាជិកនៃពួកជំនុំក្នុងតំបន់ដែលលោកអ្នកចូលរួមជាប្រចាំទេ? សូមគិតជាមួយនឹងខ្ញុំត្រង់នេះបន្តិចថា “តើគ្រីស្ទបរិស័ទមានលក្ខណៈយ៉ាងដូចម្តេច?”។

## លក្ខណៈរបស់គ្រីស្ទបរិស័ទ

ដំបូងបង្អស់ គ្រីស្ទបរិស័ទគឺជាបុគ្គលម្នាក់ដែលទទួលបានការអត់ទោសបាប ហើយបានជាមេត្រីនឹងព្រះជាម្ចាស់ដ៏ជាព្រះវរបិតាតាមរយៈព្រះយេស៊ូវគ្រីស្ទ។ ការនេះកើតឡើងនៅពេលដែលបុគ្គលម្នាក់នោះប្រែចិត្តពីបាបរបស់ខ្លួន ហើយដាក់ជំនឿរបស់គាត់ទៅលើជីវិតដ៏គ្រប់លក្ខណ៍ ការសុគតជំនួស និងការមានព្រះជន្មរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទដែលជាព្រះរាជបុត្រានៃព្រះជាម្ចាស់។

បើនិយាយម្យ៉ាងទៀត គ្រីស្ទបរិស័ទគឺជាអ្នកដែលទទួលស្គាល់

ថា គាត់មិនអាចសង្គ្រោះខ្លួនឯងបានដោយអំពើល្អរបស់ខ្លួនឡើយ។ ហើយគាត់ត្រូវទទួលស្គាល់ទៀតថា គាត់បានពលីជីវិតដើម្បីថ្វាយបង្គំ ហើយនិងស្រឡាញ់អ្វីផ្សេងទៀតជាជាងព្រះជាម្ចាស់ ហើយការទាំងនោះសុទ្ធតែជាការរឹងទទឹងទាស់នឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ដែលទ្រង់បានបើកសម្ដែងឲ្យគាត់ឃើញយ៉ាងច្បាស់។ ឧទាហរណ៍៖ គាត់ថ្វាយបង្គំ ហើយស្រឡាញ់មុខរបរគ្រួសារ របស់របរដែលលុយអាចទិញបាន ទស្សនៈរបស់អ្នកដទៃកិត្តិយសគ្រួសារ សហគមន៍ ការផ្គាប់ចិត្តដល់ព្រះរបស់សាសន៍ដទៃដែលមិនមែនជាព្រះពិត វិញ្ញាណនៅលោកីយ៍ ឬការល្អដែលមនុស្សអាចធ្វើបាន។ គាត់ក៏ត្រូវទទួលស្គាល់ផងដែរថា អ្វីៗដែលគាត់ថ្វាយបង្គំ ហើយស្រឡាញ់ជាជាងព្រះជាម្ចាស់ ទាំងអស់នោះគឺជាចៅហ្វាយដែលនាំឲ្យគាត់ធ្លាក់ចូលនរកផ្ទួនៗ គឺនរកនៅលោកីយ៍នេះផង និងនរកក្រោយពីគាត់ស្លាប់ទៅផង។ សេចក្ដីស្រេកឃ្លានរបស់ចៅហ្វាយគាត់នៅក្នុង*ជីវិតនេះ*មិនចេះស្កប់ស្កល់ទេ។ ហើយចៅហ្វាយគាត់បានបង្កឲ្យព្រះជាម្ចាស់ចាក់សេចក្ដីក្រោធដ៏យុត្តិធម៌របស់ទ្រង់ទៅលើគាត់*ក្រោយពេលដែលគាត់ស្លាប់*។ គ្រីស្ទបរិស័ទបានស្គាល់ពីសេចក្ដីក្រោធដ៏យុត្តិធម៌ដែលជាសេចក្ដីស្លាប់ និងការជំនុំជម្រះទាំងនោះខ្លះហើយតាមរយៈទុក្ខវេទនាក្នុងលោកីយ៍នេះ។

ដូច្នេះ គ្រីស្ទបរិស័ទដឹងថា ប្រសិនបើគាត់ត្រូវស្លាប់យប់នេះ

ហើយត្រូវឈរនៅចំពោះព្រះជាម្ចាស់ ហើយប្រសិនបើព្រះជាម្ចាស់មានបន្ទូលសួរថា «ហេតុអ្វីយើងគួរតែអនុញ្ញាតឲ្យឯងចូលនគរស្ថានសួគ៌របស់យើង?» នោះគ្រីស្ទបរិស័ទនឹងឆ្លើយតបវិញថា «ទ្រង់មិនគួរអនុញ្ញាតឲ្យទូលបង្គំចូលទេ ដ្បិតទូលបង្គំមានបាប ហើយជំពាក់បំណុលទ្រង់ដែលទូលបង្គំមិនអាចសងវិញបាន»។ ប៉ុន្តែគាត់នឹងមិនឈប់និយាយត្រឹមនោះទេ។ គាត់នឹងបន្តទៀតថា «ប៉ុន្តែ ដោយសារសេចក្ដីមេត្តាករុណា និងសេចក្ដីសន្យាដ៏អស្ចារ្យរបស់ទ្រង់ ទូលបង្គំពឹងអាងលើព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានខ្វាយជំនួសទូលបង្គំ ដោយបង់លោះបាបទូលបង្គំ ហើយបានបំពេញនូវសេចក្ដីតម្រូវដ៏សុចរិត និងបរិសុទ្ធរបស់ទ្រង់ ព្រមទាំងបានដកសេចក្ដីក្រោធរបស់ទ្រង់ទាស់នឹងបាបទូលបង្គំចេញ»។

យោងតាម ការទូលអង្វរឲ្យព្រះជាម្ចាស់ប្រកាសថា គាត់សុចរិតដោយសារព្រះគ្រីស្ទ នោះមានន័យថា គាត់គឺជាម្នាក់ដែលបានរកឃើញដើមចមនៃសេរីភាពរួចពីទាសភាពនៃការបម្រើអំពើបាប។ ព្រះក្លែងក្លាយមិនដែលស្ដាប់ស្គាល់នឹងបុណ្យដែលមនុស្សឧទិស្ទឲ្យឡើយ ប៉ុន្តែព្រះជាម្ចាស់ស្ដាប់ព្រះទ័យនឹងអ្វីដែលព្រះគ្រីស្ទបានធ្វើ នេះមានន័យថា អ្នកដែលព្រះគ្រីស្ទបានទិញឲ្យរួចពីការជំនុំជម្រះ គឺពិតជាមានសេរីភាពហើយពេលនេះ។ នេះជាលើកដំបូងហើយ ដែលគ្រីស្ទបរិស័ទមានសេរីភាព ដើម្បីនឹងបដិសេធអំពើបាប។

ការបដិសេធនេះមិនមែនមានន័យថា គាត់យកអំពើបាបណាមួយផ្សេងទៀតមកដាក់ជំនួសនោះទេ ប៉ុន្តែមានន័យថា គាត់យកព្រះវិញ្ញាណបរិសុទ្ធមកដាក់ជំនួសវិញ។ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងប្រទានឲ្យគាត់មានចិត្តចង់បានព្រះយេស៊ូវគ្រីស្ទ និងការដឹកនាំរបស់ទ្រង់នៅក្នុងជីវិត។ លោក អ័ដាម បានព្យាយាមរុញព្រះជាម្ចាស់ចេញពីបល្ល័ង្កចិត្តរបស់គាត់ ហើយលើកខ្លួនឯងជាព្រះវិញ ប៉ុន្តែគ្រីស្ទបរិស័ទអរសប្បាយដែលព្រះគ្រីស្ទគង់លើបល្ល័ង្កចិត្តរបស់គាត់។ គាត់ពិចារណាពីជីវិតនៃការចុះចូលដ៏គ្រប់លក្ខណ៍របស់ព្រះយេស៊ូវទៅនឹងបំណងព្រះហឫទ័យ និងព្រះបន្ទូលរបស់ព្រះវរបិតាទ្រង់ ហើយគាត់រកវិធីធ្វើតាម ដើម្បីឲ្យគាត់កាន់តែមានលក្ខណៈដូចជាព្រះសង្គ្រោះរបស់គាត់ថែមទៀត។

ចំណុចទីមួយ គ្រីស្ទបរិស័ទគឺជាម្នាក់ដែលបានជាមេត្រីនឹងព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ទ។ ព្រះគ្រីស្ទបានរំដោះគាត់ចេញពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ ហើយឥឡូវព្រះជាម្ចាស់បានរាប់គាត់ជាសុចរិតនៅចំពោះទ្រង់។ ទ្រង់ត្រាស់ហៅគាត់ឲ្យរស់នៅក្នុងជីវិតមួយដែលសុចរិត ហើយរស់នៅដោយសង្ឃឹមថា ថ្ងៃមួយគាត់នឹងចូលក្នុងវត្តមានរបស់ទ្រង់នៅនគរស្ថានសួគ៌។

ប៉ុន្តែ វាមិនទាន់ចប់ត្រឹមហ្នឹងទេ! ចំណុចទីពីរ ដោយសារតែគាត់បានជាមេត្រីជាមួយនឹងព្រះជាម្ចាស់ ដូច្នេះគាត់ក៏បានជា

មេត្រីជាមួយនឹងរាស្ត្ររបស់ទ្រង់ផងដែរ។ តើលោកអ្នកចងចាំពីរឿងដំបូងនៅក្នុងព្រះគម្ពីរបន្ទាប់ពីការធ្លាក់ក្នុងអំពើបាប និងការដែលព្រះជាម្ចាស់បណ្តេញលោក អ័ដាម និងនាង អេវ៉ា ចេញពីសួនច្បារអេដែនដែរឬទេ? រឿងដែលកើតឡើងបន្ទាប់ពីការធ្លាក់ចុះនោះ គឺជារឿងដែលមនុស្សម្នាក់បានសម្លាប់មនុស្សម្នាក់ទៀតពោលគឺលោក កាអ៊ីន បានសម្លាប់លោក អេបិល។ ប្រសិនបើការដែលយើងព្យាយាមរុញព្រះជាម្ចាស់ចេញពីបល្ល័ង្កចិត្ត ពិតជាការដែលព្យាយាមដាក់ខ្លួនយើងនៅលើបល្ល័ង្កនោះ នោះយើងនឹងមិនអនុញ្ញាតឲ្យអ្នកផ្សេងទៀតយកវាចេញពីយើងបានឡើយ។ គឺយើងមិនផ្តល់ឱកាសឲ្យទេសូម្បីតែម្តង។ ការដែលលោក អ័ដាម ផ្តាច់មេត្រីភាពជាមួយនឹងព្រះជាម្ចាស់បានបណ្តាលឲ្យមនុស្សផ្សេងៗដាច់មេត្រីភាពនឹងព្រះជាម្ចាស់ដែរ។ ការនេះបណ្តាលឲ្យមនុស្សម្នាក់ៗគិតតែពីខ្លួនឯង។

ដូច្នេះ វាមិនគួរឲ្យមានការភ្ញាក់ផ្អើលនោះទេ ពេលដែលព្រះយេស៊ូវមានបន្ទូលថា “គ្រប់ទាំងគម្ពីរក្រឹត្យវិន័យ និងគម្ពីរហោរាមានឫសគល់ចេញពីបទបញ្ញត្តិទាំងពីរនេះឯង”៖ ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង និងត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង (សូមអានម៉ាថាយ ២២:៣៤-៤០)។ បទបញ្ញត្តិទាំងពីរប្រការនេះដើរទន្ទឹម

គ្នា។ បញ្ញត្តិទីមួយបណ្តាលឲ្យមានបញ្ញត្តិទីពីរ ហើយបញ្ញត្តិទីពីរ ជាភស្តុតាងបញ្ជាក់ពីបញ្ញត្តិទីមួយ។

ដូច្នេះ តាមរយៈព្រះគ្រីស្ទ ការដែលបានជាមេត្រីនឹងព្រះជាម្ចាស់ គឺមានន័យថា យើងបានជាមេត្រីនឹងអ្នកឯទៀតដែលបានជាមេត្រី នឹងព្រះជាម្ចាស់ដែរ។ នៅក្នុងកន្លះជំពូកដំបូងនៃកណ្ឌអេភេសូរ ជំពូក២លោក ប៉ុល បានពណ៌នាពីសេចក្តីសង្គ្រោះដ៏អស្ចារ្យដែល ព្រះជាម្ចាស់បានប្រទានមកឲ្យយើងតាមរយៈព្រះគ្រីស្ទយេស៊ូវ។ បន្ទាប់មក គាត់បានពណ៌នាពីអត្ថន័យនៃទំនាក់ទំនងរវាងពួក សាសន៍យូដា និងពួកសាសន៍ដទៃ និងរវាងអស់អ្នកដែលជឿលើ ព្រះគ្រីស្ទនៅក្នុងកន្លះជំពូកចុងក្រោយនៃកណ្ឌអេភេសូរជំពូក២ ដដែលនោះ។ គាត់បានសរសេរថា៖

> ដ្បិតទ្រង់ជាស្ពានមេត្រីនៃយើងរាល់គ្នា ទ្រង់បានធ្វើឲ្យទាំង២រួម គ្នាតែ១ ហើយបានរុះជញ្ជាំងដែលខ័នកណ្តាលចេញ....ដើម្បី ឲ្យបានយកទាំង២មក បង្កើតជាមនុស្សថ្មីតែ១ក្នុងព្រះអង្គទ្រង់ ដោយតាំងជាស្ពានមេត្រីឲ្យ ហើយឲ្យទ្រង់បានផ្សះផ្សាទាំង ២នឹងព្រះ ក្នុងរូបកាយតែ១ ដោយសារឈើឆ្កាង ព្រមទាំង រំងាប់សេចក្តីសំអប់គ្នា ដោយឈើឆ្កាងនោះឯង។ (អេភេសូរ ២:១៤-១៦)

ដូច្នេះ អស់អ្នកដែលជារបស់ព្រះជាម្ចាស់ គឺជា “ជាតិតែ១” និងជា “ពួកបរិសុទ្ធ ជាពួកដំណាក់ព្រះ” (អេភេសូរ ២:១៩)។ ព្រះជាម្ចាស់បាន “ផ្គុំ” យើងភ្ជាប់ជាមួយព្រះគ្រីស្ទឲ្យទៅជា “វិហារបរិសុទ្ធ” តែមួយ (អេភេសូរ ២:២១)។ ជំពូកនេះមានពាក្យប្រៀបធៀបល្អៗជាច្រើនដែលយើងអាចលើកឡើងមកពណ៌នាបាន។

## គ្រួសារ សេចក្ដីប្រកប និងរូបកាយ

ការដែលយើងសញ្ជឹងគិតទៅលើពាក្យថា *ពួកដំណាក់* ដែលជាពាក្យប្រៀបធៀបអាចនឹងជួយឲ្យយើងយល់ឃើញថា ការដែលយើងបានជាមេត្រីនឹងព្រះជាម្ចាស់ក៏មានន័យថា យើងបានជាមេត្រីជាមួយរាស្ត្រផ្សេងៗទៀតផងដែរ។ ប្រសិនបើលោកអ្នកជាក្មេងកំព្រា នោះលោកអ្នកមិនមែនជ្រើសរើសឪពុកម្ដាយមកចិញ្ចឹមទេ ប៉ុន្តែពួកគាត់ទេដែលជ្រើសរើសលោកអ្នកមកចិញ្ចឹមនោះ។ ប្រសិនបើឪពុកម្ដាយដែលរើសយកលោកអ្នកមកចិញ្ចឹមមាននាមត្រកូលថា សុខ នោះលោកអ្នកឥឡូវក៏មាននាមត្រកូលសុខដែរ ហើយអាចចូលរួមញ៉ាំអាហារជាមួយគ្រួសារត្រកូលសុខដែលមានឪពុកម្ដាយ និងកូនៗទាំងអស់។ នៅពេលយប់ លោកអ្នកគេងក្នុងផ្ទះជាមួយគ្រួសារត្រកូលសុខ។ នៅពេលដែលគ្រូនៅសាលាហៅបញ្ជីឈ្មោះវត្តមាន ហើយហៅចំត្រកូល “សុខ” នោះលោកអ្នកក៏លើកដៃ

ដូចជាបងប្រុសរបស់លោកអ្នកបានលើកពីមុនលោកអ្នក ហើយដូចជាប្អូនស្រីរបស់លោកអ្នក ដែលនឹងលើកដៃបន្ទាប់ពីលោកអ្នកដែរ។ ហើយលោកអ្នកធ្វើដូច្នេះមិនមែនដោយសារតែលោកអ្នកបានសម្រេចចិត្តថានឹងដើរតួនាទីជំនួសមុខឲ្យត្រកូលសុខនោះទេ ប៉ុន្តែដោយសារតែមានមនុស្សម្នាក់បានទៅមណ្ឌលកុមារកំព្រា ហើយនិយាយថា "ឯងនឹងក្លាយជាកូនយើងក្នុងគ្រួសារត្រកូលសុខ"។ នៅថ្ងៃនោះ លោកអ្នកបានក្លាយជាកូនរបស់មនុស្សម្នាក់នោះ ហើយជាបងប្អូនរបស់អ្នកផ្សេងទៀតក្នុងគ្រួសារនោះដែរ។

ដូចគ្នានេះដែរ ពេលដែលលោកអ្នកក្លាយជាកូនចិញ្ចឹមរបស់ព្រះជាម្ចាស់នោះលោកអ្នកលែងជាកូនរបស់លោកីយ៍ទៀតហើយ ហើយយកនាមតាមព្រះគ្រីស្ទដែលយកយើងមកចិញ្ចឹម គឺ "គ្រីស្ទ-បរិស័ទ" (អេភេសូរ ១:៥)។ ឥឡូវនេះ លោកអ្នកជាសមាជិកមួយនៃគ្រួសាររបស់ព្រះជាម្ចាស់។ "ព្រះអង្គដែលញែកមនុស្សជាបរិសុទ្ធ និងអស់អ្នកដែលព្រះអង្គបានញែកជាបរិសុទ្ធមានព្រះវរបិតាតែមួយទេ" (ហេព្រើរ ២:១១ គកស)។

ហើយនេះមិនមែនជាគ្រួសារដែលមានបញ្ហាដែលសមាជិកគ្រួសារឈប់រស់នៅជាមួយគ្នា ឬឈប់ទាក់ទងគ្នានោះទេ។ វាជាសេចក្ដីប្រកបមួយ។ នៅពេលដែលព្រះជាម្ចាស់ "បានហៅអ្នករាល់គ្នាមកឲ្យមានសេចក្ដីប្រកបនឹងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវ

គ្រីស្ទ ជាព្រះអម្ចាស់នៃយើង» (១កូរិនថូស ១:៩) ទ្រង់ក៏បានហៅលោកអ្នកឲ្យមាន «សេចក្តីប្រកប» ជាមួយនឹងគ្រួសារទាំងមូលដែរ (១កូរិនថូស ៥:២)។

ហើយសេចក្តីប្រកបនេះមិនគ្រប់លក្ខណ៍នោះទេ។ សេចក្តីប្រកបនេះជារូបកាយមួយដែលមិនគ្រាន់តែចងភ្ជាប់គ្នាដោយការសម្រេចចិត្តរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ចងភ្ជាប់គ្នាលើសពីការសម្រេចចិត្តរបស់មនុស្សទៅទៀត គឺចងភ្ជាប់គ្នាដោយអង្គព្រះគ្រីស្ទ និងកិច្ចការរបស់ទ្រង់ថែមទៀតផង។ បើសមាជិកនៃគ្រួសារនេះនិយាយថា «ខ្ញុំមិនមែនជាសមាជិកគ្រួសារនេះទេ» ការដែលនិយាយដូច្នេះប្រៀបដូចជាមនុស្សឆ្កួតដែលកាត់ដៃ ឬច្រមុះរបស់ខ្លួនចោលអញ្ចឹង។ លោក ប៉ុល បាននិយាយទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូសថា «ភ្នែកពុំអាចនិយាយទៅដៃថា អញមិនត្រូវការនឹងឯងទេ ឬក្បាលនិយាយទៅជើងថា អញមិនត្រូវការនឹងឯងដែរនោះឡើយ» (១កូរិនថូស ១២:២១)។

សរុបសេចក្តីមក យើងមិនអាចឆ្លើយសំណួរដែលថា *«តើគ្រីស្ទ-បរិស័ទមានលក្ខណៈយ៉ាងដូចម្តេច?»* បានដោយមិននិយាយពីពួកជំនុំនោះទេ ជាពិសេសបើយើងចង់ឆ្លើយឲ្យត្រូវតាមព្រះគម្ពីរ។ មិនតែប៉ុណ្ណោះ ការផ្តោតទៅលើពាក្យប្រៀបធៀបតែមួយសម្រាប់ពួកជំនុំ គឺជាការពិបាក ពីព្រោះព្រះគម្ពីរសញ្ញាថ្មីប្រើពាក្យប្រៀបធៀប

ច្រើនដូចជា៖ គ្រួសារ និងសេចក្ដីប្រកប រូបកាយ និងកូនក្រមុំ បណ្ដាជន និងព្រះវិហារ ស្ត្រីនិងកូនរបស់នាង។ ព្រះគម្ពីរសញ្ញាថ្មីមិនដែលលើកឡើងពី គ្រីស្ទបរិស័ទពិតដែល*មិនមានទម្លាប់*ប្រកបគ្នាជាមួយនឹងពួកជំនុំក្នុងតំបន់នោះទេ។ ពួកជំនុំជារាស្ត្ររបស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រីស្ទ។

## ការចូលរួមក្នុងពួកជំនុំ

នៅពេលដែលមនុស្សម្នាក់ក្លាយជាគ្រីស្ទបរិស័ទ ការដែលគាត់ចូលរួមជាមួយពួកជំនុំក្នុងតំបន់មិនមែនដោយសារតែវាជាទម្លាប់ដែលនាំឲ្យគាត់រីកចម្រើនខាងឯវិញ្ញាណនោះទេ ប៉ុន្តែ គាត់ចូលរួមជាមួយពួកជំនុំក្នុងតំបន់ ព្រោះនេះជាការបង្ហាញពីការដែលព្រះគ្រីស្ទ*បានធ្វើឲ្យគាត់ក្លាយជា*សមាជិកម្នាក់ក្នុងរូបកាយព្រះគ្រីស្ទ។ ការដែលយើងនៅជាប់ជាមួយនឹងព្រះគ្រីស្ទមានន័យថា យើងនៅជាប់ជាមួយនឹងគ្រីស្ទបរិស័ទគ្រប់រូបផងដែរ។ ប៉ុន្តែ ការរួបរួមជាសកលនោះដាច់ខាតត្រូវតែមានភាពរស់រវើកនៅក្នុងពួកជំនុំក្នុងតំបន់។

ពេលខ្លះអ្នកប្រាជ្ញខាងព្រះគម្ពីរបែងចែកពួកជំនុំសកល និងពួកជំនុំក្នុងតំបន់ដាច់ពីគ្នា។ ពួកជំនុំសកលសំដៅលើគ្រីស្ទបរិស័ទទាំងអស់នៅគ្រប់ទីកន្លែងក្នុងគ្រប់សម័យកាល ហើយពួកជំនុំក្នុងតំបន់សំដៅលើអស់អ្នកដែលប្រជុំគ្នានៅក្បែរកន្លែងដែលលោកអ្នក

រស់នៅ ដើម្បីនឹងស្ដាប់ព្រះបន្ទូល និងដើម្បីទទួលពិធីជ្រមុជទឹក ក៏ដូចជាពិធីលៀងព្រះអម្ចាស់។ ព្រះគម្ពីរសញ្ញាថ្មីមានរៀបរាប់ពីពួកជំនុំសកលតែម្ដងម្កាលទេ (កណ្ឌគម្ពីរ ម៉ាថាយ ១៦:១៨ និង អេភេសូរ) តែភាគច្រើនព្រះគម្ពីរសញ្ញាថ្មីមានរៀបរាប់ច្រើនពីពួកជំនុំតាមតំបន់វិញ ឧទាហរណ៍៖ នៅពេលដែលសាវ័ក ប៉ុល សរសេរថា "ផ្ញើមកពួកជំនុំនៃព្រះ នៅក្រុងកូរិនថូស" ឬ "ផ្ញើមកពួកជំនុំទាំងប៉ុន្មាន នៅស្រុកកាឡាទី" ត្រង់នេះគាត់សំដៅលើពួកជំនុំតាមតំបន់។

អ្វីដែលលើកឡើងនៅខាងក្រោមនេះគឺខ្លាំងបន្តិច ប៉ុន្ដែវាសំខាន់ណាស់។ ទំនាក់ទំនងរវាង*សមាជិកភាពនៅក្នុងពួកជំនុំសកល* និង *សមាជិកភាពនៅក្នុងពួកជំនុំតាមតំបន់* គឺមានលក្ខណៈដូចគ្នាច្រើនទៅនឹងទំនាក់ទំនងរវាង *សេចក្ដីសុចរិតដែលព្រះជាម្ចាស់ប្រទានឲ្យយើងតាមរយៈជំនឿ* និង *ការអនុវត្តសេចក្ដីសុចរិតជាក់ស្ដែងនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង*។ នៅពេលដែលយើងក្លាយជាគ្រីស្ទបរិស័ទដោយជំនឿ នោះព្រះជាម្ចាស់រាប់យើងជាសុចរិត។ ប៉ុន្ដែទ្រង់នៅតែត្រាស់ហៅយើងឲ្យរស់នៅដោយសុចរិត។ បុគ្គលណាដែលអរសប្បាយក្នុងការរស់នៅដោយទុច្ចរិត នោះគេអាចចោទជាសំណួរថា តើគាត់ពិតជាបានទទួលសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទកាលពីដំបូងដែរឬអត់ (សូមមើល រ៉ូម ៦:១-១៨; ៨:៥-

១៤; យ៉ាកុប ២:១៤-១៥)។ ចំពោះអ្នកដែលបដិសេធមិនប្ដេជ្ញាចូលរួមក្នុងសមាជិកពួកជំនុំក្នុងតំបន់ណាមួយ ក៏មិនខុសនឹងអ្នកដែលអរសប្បាយក្នុងការរស់នៅដោយទុច្ចរិតដែរ។ ការប្ដេជ្ញាចិត្តចូលរួមជាមួយពួកជំនុំក្នុងតំបន់ នោះគឺជាផលផ្លែនៃជំនឿ។ ការនោះបញ្ជាក់ពីអ្វីដែលព្រះគ្រីស្ទបានធ្វើ។ ប្រសិនបើលោកអ្នកមិនចាប់អារម្មណ៍ក្នុងការប្ដេជ្ញាចិត្តចូលរួមក្រុមគ្រីស្ទបរិស័ទដែលជឿលើដំណឹងល្អ និងបង្រៀនតាមព្រះគម្ពីរទេ នោះសូមសួរខ្លួនឯងថា តើខ្ញុំជាអវយវៈមួយនៃរូបកាយព្រះគ្រីស្ទដែរឬក៏អត់។ សូមអានកណ្ឌហេព្រើរ ១០:២៣-២៧ ដោយយកចិត្តទុកដាក់៖

> ត្រូវឲ្យយើងរាល់គ្នាកាន់ខ្ជាប់ តាមសេចក្ដីបន្ទាល់របស់សេចក្ដីសង្ឃឹមនោះ ឥតរវើរវាយ ដ្បិតព្រះដែលបានសន្យានោះ ទ្រង់ស្មោះត្រង់ ហើយត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ ដ្បិតក្រោយដែលយើងបានទទួលស្គាល់សេចក្ដីពិតហើយ បើយើងធ្វើបាបស្ម័គ្រពីចិត្តទៀត នោះគ្មានយញ្ញបូជាណា សំរាប់នឹងលោះបាប

ទៀតទេ មានតែរង់ចាំ ដោយស្វែងខ្លាចចំពោះសេចក្ដីជំនុំជំរះ និងសេចក្ដីសហ័សនៃភ្លើង ដែលរៀបនឹងឆេះដល់អស់ទាំងពួកទាស់ទទឹងផងប៉ុណ្ណោះ។

បើយើងមានទំនាក់ទំនងយ៉ាងជាក់លាក់ច្បាស់លាស់ជាមួយព្រះជាម្ចាស់ ការនោះនឹងមានឥទ្ធិពលទៅលើការរស់នៅរបស់យើងជាប្រចាំថ្ងៃ ទោះបើការសម្រេចចិត្តនោះមានការយឺតយ៉ាវ ឬមិនគ្រប់លក្ខណ៍ក៏ដោយ។ ព្រះជាម្ចាស់ពិតជាបំផ្លាស់បំប្រែរាស្ត្ររបស់ទ្រង់ប្រាកដមែន។ តើនោះមិនមែនជាដំណឹងល្អទេឬអី? ដូច្នេះ មិត្តអើយ! សូមកុំឲ្យត្រឡប់ជាក្ដៅមិនក្ដៅត្រជាក់មិនត្រជាក់ដោយមានគំនិតមិនច្បាស់លាស់ណាមួយដែលថា លោកអ្នកទទួលបានសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទ ទោះបើជីវិតរស់នៅរបស់លោកអ្នកមិនពេញដោយសេចក្ដីសុចរិតក៏ដោយ។ ដូចគ្នានេះដែរ កុំស្មានថាលោកអ្នកជាសមាជិកពួកជំនុំសកលនោះឡើយ បើលោកអ្នកមិនមែនជាសមាជិកនៃពួកជំនុំក្នុងតំបន់ណាមួយ។

ជាទូទៅ គ្រីស្ទបរិស័ទដ៏ពិត សង់ជីវិតរបស់ខ្លួនឡើងនៅក្នុងជីវិតអ្នកជឿដទៃទៀតតាមរយៈការប្រកបដ៏រឹងមាំជាមួយពួកជំនុំក្នុងតំបន់ លើកលែងតែក្នុងស្ថានភាពដែលមិនមានអ្នកជឿនៅជុំវិញគាត់ប៉ុណ្ណោះ។ គាត់ដឹងថាគាត់មិនទាន់គ្រប់លក្ខណ៍នៅឡើយទេ។ គាត់

នៅតែធ្វើបាប ហើយត្រូវការការកែតម្រង់ ក៏ដូចជាសេចក្ដីបង្រៀនរបស់ពួកជំនុំក្នុងតំបន់។ ហើយពួកជំនុំក្នុងតំបន់ក៏ត្រូវការគាត់ដែរ។

នៅពេលដែលយើងប្រជុំគ្នាថ្វាយបង្គំព្រះជាម្ចាស់ ហើយបង្ហាញសេចក្ដីស្រឡាញ់ ព្រមទាំងធ្វើល្អចំពោះគ្នាទៅវិញទៅមក នោះយើងបង្ហាញនៅក្នុងជីវិតពិតជាក់ស្ដែងថា ព្រះជាម្ចាស់បានផ្សះផ្សាយើងនឹងព្រះអង្គទ្រង់ ហើយទ្រង់ក៏បានផ្សះផ្សាយើងរវាងគ្នានឹងគ្នាផងដែរ។ យើងបានបង្ហាញដល់លោកីយ៍ថា ព្រះជាម្ចាស់ពិតជា*បានបំផ្លាស់បំប្រែ*យើងមែន ហើយការនេះមិនមែនដោយសារយើងទន្ទេញខគម្ពីរបានច្រើន អធិស្ឋានរាល់ពេលញ៉ាំបាយ ថ្វាយតង្វាយចេញពីប្រាក់ចំណូលរបស់យើង ឬក៏ស្ដាប់វិទ្យុគ្រីស្ទបរិស័ទនោះទេ ប៉ុន្តែដោយសារយើងបង្ហាញពីបំណងចិត្តក្នុងការទ្រាំទ្រការអត់ទោស ហើយថែមទាំងស្រឡាញ់ពួកជំនុំក្នុងតំបន់ ទោះបើពួកយើងនៅតែប្រព្រឹត្តិបាបក្ដី។

លោកអ្នកនិងខ្ញុំមិនអាចបង្ហាញសេចក្ដីស្រឡាញ់ អំណរអរមេត្រីភាព អត់ធ្មត់ ឬសប្បុរសដោយអង្គុយនៅលើកោះតែម្នាក់ឯងបាននោះទេ។ តែយើងអាចបង្ហាញការណាមួយខាងលើនេះចំពោះមនុស្សដែលយើងបានប្ដេជ្ញាថានឹងស្រឡាញ់បាន ក្នុងកាលដែលពួកគេមិនមានលក្ខណៈគួរឲ្យយើងស្រឡាញ់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅតែស្រឡាញ់ពួកគេដដែល។

នៅពេលដែលពួកជំនុំប្ដេជ្ញាចិត្តស្រឡាញ់គ្នាទៅវិញទៅមក ក្នុងកាលដែលពួកយើងនៅតែជាមនុស្សដែលប្រព្រឹត្តិបាប នោះនឹងបណ្ដាលឲ្យលោកីយ៍ឃើញពីដំណឹងល្អយ៉ាងច្បាស់។ ពួកជំនុំបង្ហាញពីដំណឹងល្អដែលលោកីយ៍អាចមើលឃើញនឹងភ្នែកបាន នៅពេលដែលពួកជំនុំអត់ទោសឲ្យគ្នាទៅវិញទៅមកដូចដែលព្រះគ្រីស្ទបានអត់ទោសឲ្យពួកគេ និងនៅពេលដែលពួកគេបានប្ដេជ្ញាចំពោះគ្នាទៅវិញទៅមកដូចដែលព្រះគ្រីស្ទបានប្ដេជ្ញាចំពោះពួកគេ ហើយនៅពេលដែលពួកគេលះបង់ជីវិតជំនួសគ្នាទៅវិញទៅមកដូចដែលព្រះគ្រីស្ទបានលះបង់ព្រះជន្មរបស់ទ្រង់ជំនួសពួកគេដែរ។

របៀបដែលយើងបង្ហាញពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាមួយគ្នា គឺខុសប្លែកពីរបៀបដែលមនុស្សតែម្នាក់បង្ហាញពីដំណឹងល្អ។

ជាញឹកញាប់ ខ្ញុំឮគ្រីស្ទបរិស័ទនិយាយអំពីអំណោយទានខាងឯវិញ្ញាណខុសៗគ្នារបស់ពួកគេ។ ប៉ុន្តែ ខ្ញុំឆ្ងល់ណាស់ថា តើពួកគេបានពិចារណាញឹកញាប់ប៉ុណ្ណាពីការដែលព្រះជាម្ចាស់បានប្រទាននូវអំណោយទានជាច្រើន ហើយជាក់លាក់ ដើម្បីឲ្យពួកគេប្រើអំណោយទានទាំងនោះ ទុកជាយានក្នុងការកែតម្រង់គ្រីស្ទបរិស័ទដទៃទៀតដែលបានប្រព្រឹត្តិបាបនៅក្នុងពួកជំនុំ។ អំពើបាបរបស់ខ្ញុំផ្តល់ឱកាសដល់លោកអ្នក ដើម្បីនឹងអនុវត្តអំណោយទានរបស់លោកអ្នក។

ដូច្នេះ សូមប្រមូលក្រុមមនុស្សមួយក្រុមដែលមានទាំងប្រុស ទាំងស្រី ក្មេង និងចាស់ ស្បែកស និងស្បែកខ្មៅ ជនជាតិអាស៊ី និងជនជាតិអាហ្វ្រិក អ្នកមាន និងអ្នកក្រ អ្នកមានចំណេះដឹង និងអ្នកអត់ចំណេះដឹងដែលមានគ្រប់ទាំងទេពកោសល្យ អំណោយទាន និងជំនាញខុសៗគ្នា។ ប៉ុន្ដែ សូមឲ្យប្រាកដថា *ពួកគេ*ដឹងថា ពួកគេមានបញ្ហា និងមានបាប ហើយទទួលសេចក្ដីសង្គ្រោះដោយសារតែព្រះគុណមួយប៉ុណ្ណោះ។ ដូច្នេះ តើយើងហៅពួកគេថាយ៉ាងដូចម្ដេច? យើងហៅថាពួកជំនុំ!

ប្រសិនបើ លោកអ្នកមានបំណងចិត្តចង់ស្រឡាញ់គ្រីស្ទបរិស័ទ *គ្រប់ៗរូប* ជាដំបូង ខ្ញុំសូមស្នើឲ្យលោកអ្នកប្ដេជ្ញាចិត្តចូលរួមជាមួយនឹងពួកជំនុំក្នុងតំបន់ដែលពួកគេមានពេញដោយចំណុចខ្សោយ និងភាពល្ងីល្ងើជាមុនសិន។ សូមប្ដេជ្ញាចិត្តរួបរួមជាមួយពួកគេយ៉ាងតិចឲ្យបានរយៈពេល៨០ឆ្នាំ ទោះបីជាត្រូវឆ្លងកាត់ទុក្ខលំបាក ឬការស្រណុកសុខស្រួលយ៉ាងណាក៏ដោយ។ បន្ទាប់ពីលោកអ្នកបានចំណាយពេល៨០ឆ្នាំជាមួយពួកគេរួចហើយ នោះលោកអ្នកនឹងបានចម្រើនឡើងខាងឯសេចក្ដីស្រឡាញ់ចំពោះគ្រីស្ទបរិស័ទគ្រប់ៗរូបជាមិនខាន។

## ការរៀបរាប់ពីអំពើ

តើនរណាជាអ្នកទទួលខុសត្រូវក្នុងការសម្រេចថា តើពួកជំនុំគួរតែមានលក្ខណៈបែបណានោះ? តើគ្រូគង្វាល និងអ្នកដឹកនាំពួកជំនុំជាអ្នកទទួលខុសត្រូវឬ? ពិតប្រាកដណាស់។ ចុះចំណែកគ្រីស្ទបរិស័ទដទៃទៀតវិញ? ពិតប្រាកដណាស់ ពួកគេក៏អញ្ចឹងដែរ។ ក្នុងនាមជាគ្រីស្ទបរិស័ទមួយរូប យើងត្រូវយកចិត្តទុកដាក់លើជីវិត និងសុខភាពរបស់រូបកាយព្រះគ្រីស្ទ ដែលជាពួកជំនុំនោះឯង។ វាមានន័យថា យើងត្រូវយកចិត្តទុកដាក់ថា តើអ្វីទៅជាពួកជំនុំ ហើយពួកជំនុំគួរតែមានលក្ខណៈបែបណា ដោយព្រោះលោកអ្នកជាសមាជិកម្នាក់នៃពួកជំនុំនោះ។

ពិតប្រាកដណាស់ យើងថែរក្សាពួកជំនុំ ដោយព្រោះពួកជំនុំជារូបកាយនៃព្រះអង្គសង្គ្រោះរបស់យើង។ តើលោកអ្នកបានកត់សម្គាល់លើពាក្យដែលព្រះយេស៊ូវបានប្រើជាមួយនឹងលោកសុល (លោកជាអ្នកបៀតបៀនគ្រីស្ទបរិស័ទដែលក្រោយមកគេហៅលោកថា ប៉ុល) នៅពេលដែលទ្រង់លេចមកតទល់នឹងលោកនៅតាមផ្លូវទៅឯទីក្រុងដាម៉ាសដែរឬទេ? “សុល នែសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ?” (កិច្ចការ ៩:៤)។ ព្រះយេស៊ូវបានរាប់រូបអង្គទ្រង់ដូចជាពួកជំនុំរបស់ទ្រង់ ម្ល៉ោះហើយបានជាទ្រង់ហៅពួកជំនុំថាជារូបអង្គទ្រង់ផ្ទាល់! ឱ! អ្នកជឿរាល់គ្នាអើយ! តើមាន

រាប់ខ្លួនឲ្យដូចជាពួកអ្នកដែលព្រះគ្រីស្ទបានរាប់រូបអង្គទ្រង់ដែរឬទេ? តើចិត្តរបស់លោកអ្នកមានសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅដូចគ្នាទៅនឹងព្រះហឫទ័យរបស់ទ្រង់ដែរឬទេ?

ថ្មីៗនេះ ខ្ញុំបានទទួលសំបុត្រមួយច្បាប់ពីគ្រូគង្វាលម្នាក់ ហើយនៅក្នុងសំបុត្រនោះគាត់បានបង្ហាញពីបំណងចិត្តនៃការចង់ឲ្យសមាជិកពួកជំនុំដឹងថា តើពួកជំនុំគួរតែមានលក្ខណៈបែបណា។ លោកគ្រូដែលមានការបន្ទាបខ្លួនម្នាក់នេះចង់ឲ្យពួកជំនុំជួយកែតម្រង់គាត់ពេលគាត់ធ្វើខុសខណៈដែលគាត់ដឹកនាំពួកគេទៅកាន់ព្រះគុណ និងការគោរពប្រតិបត្តិដល់ព្រះ។ គ្រូគង្វាលនេះយល់ពីគំរូនៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានច្បាស់ណាស់។ គាត់យល់ថាថ្ងៃមួយ ព្រះជាម្ចាស់នឹងហៅគាត់ឲ្យរៀបរាប់ពីរបៀបដែលគាត់បានដឹកនាំពួកជំនុំរបស់គាត់។ ហើយដូចជាអ្នកគង្វាលដ៏ស្មោះត្រង់ម្នាក់ដែរ គាត់ចង់ឲ្យកូនចៀមទាំងអស់នៅក្នុងក្រោលរបស់គាត់ដឹងថា ថ្ងៃមួយព្រះជាម្ចាស់នឹងហៅពួកគេម្នាក់ម្ដងៗឲ្យរៀបរាប់ពីរបៀបដែលពួកគេបានស្រឡាញ់គ្នាទៅវិញទៅមក និងពីរបៀបដែលពួកគេបានស្រឡាញ់គាត់ដែរ។

ព្រះជាម្ចាស់នឹងសួរសមាជិកនីមួយៗនៃរូបកាយថា៖ «តើឯងបានអរសប្បាយជាមួយនឹងសមាជិកនៃរូបកាយខ្ញុំ នៅពេលដែលពួកគេអរសប្បាយ ដែរឬទេ? តើឯងបានយំសោកជាមួយនឹងអ្នក

ដែលឃំសោកដែរឬទេ? តើឯងបានប្រព្រឹត្តចំពោះអវយវៈដែលខ្សោយជាងឯងឲ្យដូចជាអវយវៈមួយដែលឯងមិនអាចខ្វះបានដែរឬទេ? ហើយតើឯងបានផ្តល់កិត្តិយសពិសេសដល់អវយវៈដែលមនុស្សភាគច្រើនមិនឲ្យតម្លៃខ្ពស់ដែរឬទេ? តើឯងបានលើកកិត្តិយសមួយទ្វេជាពីរដល់អ្នកដឹកនាំ និងអ្នកបង្រៀនឯងដែរឬទេ?» (សូមអាន ១កូរិនថូស ១២:២២-២៦ និង១ធីម៉ូថេ ៥:១៧)

អ្នកជឿរាល់គ្នាអើយ! តើបានត្រៀមខ្លួនរួចជាស្រេច សម្រាប់ថ្ងៃដែលព្រះជាម្ចាស់នឹងហៅអ្នករាល់គ្នាឲ្យរៀបរាប់ពីរបៀបដែលអ្នករាល់គ្នាបានស្រឡាញ់ និងបម្រើពួកជំនុំ រួមទាំងអ្នកដឹកនាំពួកជំនុំរបស់អ្នករាល់គ្នាហើយឬនៅ? តើអ្នករាល់គ្នាជ្រាបទេថា ព្រះជាម្ចាស់មានបន្ទូលថា ពួកជំនុំគួរតែមានលក្ខណៈបែបណា?

ចំណែកឯគ្រូគង្វាលវិញ តើលោកគ្រូមានបានរៀបចំហ្វូងចៀមរបស់លោកគ្រូសម្រាប់ការដែលពួកគេត្រូវរៀបរាប់ចំពោះព្រះជាម្ចាស់ ដោយបង្រៀនពួកគេឲ្យដឹងថា ពួកជំនុំគួរតែមានលក្ខណៈបែបណាហើយឬនៅ? តើលោកគ្រូបានបង្រៀនពួកគេទេថា ព្រះជាម្ចាស់នឹងសួរពួកគេថា តើពួកគេបានជឿដំណឹងល្អយ៉ាងរឹងមាំដែរឬអត់?

ជំពូក២

# លក្ខណៈពួកជំនុំ និងអ្វីដែលមិនមែនជាលក្ខណៈពួកជំនុំ

**នៅក្នុងសេចក្តីផ្តើម** ខ្ញុំបានសួរថា តើលោកអ្នកកំពុងតែស្វែងរកអ្វីនៅក្នុងពួកជំនុំ? ហើយក៏បានសួរដែរថា តើព្រះគម្ពីរលើកឡើងថា ពួកជំនុំគួរតែមានលក្ខណៈបែបណា? ប៉ុន្តែខ្ញុំមិនទាន់បានឆ្លើយសំណួរទាំងនេះនៅឡើយទេ។ ពិតប្រាកដណាស់ សំណួរទាំងនេះគឺជាសំណួរពិបាកឆ្លើយ ហើយសព្វថ្ងៃនេះ គ្រីស្ទបរិស័ទកំពុងស្វែងរកលក្ខណៈខុសៗគ្នាជាច្រើនដែលត្រូវតែចិត្តពួកគេនៅក្នុងពួកជំនុំ។

## កិច្ចសន្ទនាមួយដ៏គួរឲ្យភ្ញាក់ផ្អើល

ក្នុងអំឡុងពេលដែលខ្ញុំសិក្សានៅថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ខ្ញុំនឹកចាំពីកិច្ចសន្ទនាមួយជាមួយនឹងមិត្តម្នាក់ដែលធ្វើការឲ្យព័ន្ធកិច្ចគ្រីស្ទ-

បរិស័ទមួយដែលព័ន្ធកិច្ចនោះមិននៅក្រោមចំណុះពួកជំនុំណាមួយនោះទេ។ គាត់និងខ្ញុំបានចូលរួមក្នុងពួកជំនុំតែមួយជាមួយគ្នាអស់រយៈពេលពីរបីឆ្នាំដែរ។ ប៉ុន្តែនៅពេលដែលខ្ញុំបានធ្វើជាសមាជិកនៅក្នុងពួកជំនុំនោះ មិត្តរបស់ខ្ញុំមិនបានធ្វើជាសមាជិកនៅក្នុងពួកជំនុំនោះទេ។ តាមពិត គាត់គ្រាន់តែមកថ្វាយបង្គំនៅព្រឹកថ្ងៃអាទិត្យតែប៉ុណ្ណោះ ហើយមិនតែប៉ុណ្ណោះគាត់ចូលមកថ្វាយបង្គំនៅពាក់កណ្ដាលកម្មវិធី គឺដល់ពេលគ្រូអធិប្បាយបាត់ទៅហើយ។

ថ្ងៃមួយ ខ្ញុំបានសម្រេចចិត្តសួរគាត់ពីការចូលរួមមិនអស់ពីចិត្តពីថ្លើមរបស់គាត់។ គាត់បានឆ្លើយថា «ខ្ញុំមិនសូវទទួលបានអ្វីសោះពីកម្មវិធីដទៃទៀត»។

ខ្ញុំក៏បានសួរទៀតថា «តើឯងធ្លាប់បានគិតពីការធ្វើជាសមាជិកក្នុងពួកជំនុំនេះដែរទេ?»

គាត់បែរជាមានការភ្ញាក់ផ្អើលជាខ្លាំងពីសំណួររបស់ខ្ញុំ ហើយគាត់បានតបមកវិញថា «ស្អីគេ! ធ្វើជាសមាជិកពួកជំនុំ? ខ្ញុំពិតជាមិនដឹងថាហេតុអ្វីខ្ញុំត្រូវធ្វើជាសមាជិកពួកជំនុំនេះទេ។ ខ្ញុំដឹងច្បាស់ថា ខ្ញុំមកទីនេះដើម្បីអ្វី ហើយអ្នកទាំងនេះនឹងធ្វើឲ្យជីវិតខាងឯវិញ្ញាណរបស់ខ្ញុំរីកចម្រើនឃឹតតែប៉ុណ្ណោះទេ»។

តាមដែលខ្ញុំបានឃើញគឺថា គាត់មិនបាននិយាយពាក្យទាំងនោះដោយការមាក់ងាយនោះទេ ប៉ុន្តែគាត់និយាយដោយ

ចេញពីចិត្តពិតត្រង់ក្នុងនាមជាគ្រូប្រកាសដំណឹងល្អដ៏មានអំណោយទានម្នាក់ គឺគាត់មិនចង់ចំណាយពេលរបស់ព្រះជាម្ចាស់ដោយឥតប្រយោជន៍ សូម្បីតែមួយម៉ោងក៏មិនបានដែរ។ មើលទៅខ្ញុំឃើញថា គាត់ពិតជាបានផ្តល់គំនិតខ្លះៗទៅលើលក្ខណៈដែលគាត់កំពុងតែស្វែងរកនៅក្នុងពួកជំនុំរួចទៅហើយ។ និយាយរួមទៅអ្វីដែលគាត់បានគិតក្នុងការចង់បាននោះមិនទាក់ទងជាមួយនឹងសមាជិកនៅក្នុងពួកជំនុំនោះទេ។ គាត់ចង់បានតែកន្លែងមួយដែលគាត់អាចស្តាប់នូវសេចក្តីអធិប្បាយដែលល្អចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអាចធ្វើឲ្យជីវិតខាងឯវិញ្ញាណរបស់គាត់មានភាពរស់រវើកឡើងពេញមួយសប្តាហ៍ហ្នឹង។

ប៉ុន្តែ ពាក្យសម្តីរបស់គាត់នៅតែឮខ្ទរក្នុងគំនិតរបស់ខ្ញុំគឺពាក្យថា «អ្នកទាំងនោះនឹងធ្វើឲ្យជីវិតខាងឯវិញ្ញាណរបស់ខ្ញុំរីកចម្រើនយឺតតែប៉ុណ្ណោះ»។ មានការជាច្រើនដែលខ្ញុំចង់និយាយ ប៉ុន្តែអ្វីដែលខ្ញុំបាននិយាយនោះគឺថា «ប៉ុន្តែឯងមានធ្លាប់គិតទេថា ប្រសិនបើឯងធ្វើជាសមាជិកម្នាក់ក្នុងចំណោមពួកគេទាំងនោះ ពិតប្រាកដ ពួកគេអាចនឹងធ្វើឲ្យឯងរីកចម្រើនយឺតខាងឯវិញ្ញាណ ប៉ុន្តែឯងអាចនឹងជួយពួកគេឲ្យរីកចម្រើនលឿនបាន។ តើឯងធ្លាប់បានគិតថា ការនោះអាចជាចំណែកមួយនៃផែនការរបស់ព្រះជាម្ចាស់សម្រាប់ពួកគេនិងសម្រាប់ឯងដែរឬទេ?»។

ខ្ញុំក៏ចង់បានពួកជំនុំមួយដែលខ្ញុំអាចស្ដាប់សេចក្ដីអធិប្បាយដែលល្អជារៀងរាល់អាទិត្យដែរ។ ប៉ុន្ដែពាក្យថា “រូបកាយរបស់ព្រះគ្រីស្ទ” មានអត្ថន័យលើសពីនោះទៅទៀត មិនថាអញ្ចឹង?

## ពួកជំនុំគឺជារាស្ដ្ររបស់ព្រះជាម្ចាស់

ពួកជំនុំមិនមែនគ្រាន់តែមក ដើម្បីស្ដាប់ការអធិប្បាយ ឬទទួលការលើកទឹកចិត្តខាងវិញ្ញាណនោះទេ។ ពួកជំនុំគឺជារាស្ដ្ររបស់ព្រះជាម្ចាស់ ហើយជារាស្ដ្រនៃការតាំងសញ្ញាថ្មីដែលទ្រង់បានទិញដោយព្រះលោហិតរបស់ព្រះយេស៊ូវ។ អញ្ចឹងហើយបានជាលោកប៉ុល មានប្រសាសន៍ថា “ព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំហើយបានប្រគល់ព្រះអង្គទ្រង់ជំនួសផង” (អេភេសូរ ៥:២៥)។ ព្រះយេស៊ូវបានប្រគល់ព្រះអង្គទ្រង់ជំនួសមនុស្សដើម្បីឲ្យពួកគេក្លាយទៅជារាស្ដ្ររបស់ទ្រង់។

ហេតុដូច្នេះហើយបានជាពួកជំនុំដែលខ្ញុំជាគ្រូគង្វាលនៅទីនោះមិនបានចាប់ផ្ដើមជួបជុំគ្នានៅព្រឹកថ្ងៃអាទិត្យដោយគ្រាន់តែនិយាយ “ស្វាគមន៍មកកាន់ពួកជំនុំ កាពីតូលហៀលបាប់ទីស្ទ (Capitol Hill Baptist Church)” តែប៉ុណ្ណោះនោះទេ ប៉ុន្ដែពួកយើងនិយាយថា “ស្វាគមន៍មកកាន់ពួកជំនុំ កាពីតូលហៀលបាប់ទីស្ទ ដែលជា*ផ្នែកមួយនៃរាស្ដ្ររបស់ព្រះជាម្ចាស់*” វិញ។ យើងគឺជាផ្នែកមួយនៃរាស្ដ្រ

របស់ទ្រង់ដែលជួបជុំគ្នា។ ពិតមែនហើយ ការជ្រើសរើសពាក្យក្នុង ការស្វាគមន៍ គឺជារឿងដ៏តូចតាចទេ ប៉ុន្តែយើងចង់លើកឡើងពីការ ពិតដ៏ធំធេងមួយ គឺថាពួកជំនុំក្នុងតំបន់គឺជាផ្នែកមួយនៃរាស្ត្ររបស់ ទ្រង់ ដូច្នេះហើយបានជាយើងលើកឡើងពីការពិតដ៏ធំធេងនេះ សូម្បីតែក្នុងពាក្យស្វាគមន៍របស់យើងរៀងរាល់ថ្ងៃអាទិត្យក៏ដោយ។

ការដែលយើងចងចាំថា ពួកជំនុំគឺជារាស្ត្ររបស់ព្រះជាម្ចាស់ អាចជួយឲ្យយើងស្គាល់នូវអ្វីដែលសំខាន់ និងអ្វីដែលមិនសំខាន់។ ខ្ញុំដឹងថា ខ្ញុំត្រូវការការរំឭកបែបនេះ។ ឧទាហរណ៍ ទំនោររបស់ខ្ញុំគឺ ខ្ញុំ តែងតែអនុញ្ញាតឲ្យប្រភេទតន្ត្រីដែលពួកជំនុំមួយប្រគំ ជាអ្នកកំណត់ ពីអារម្មណ៍ដែលខ្ញុំមានចំពោះពួកជំនុំនោះ។ ជាធម្មតា ប្រភេទតន្ត្រី ដែលពួកជំនុំមួយប្រគំ គឺជាចំណុចដំបូងគេដែលយើងនឹងកត់ សម្គាល់ពីពួកជំនុំនោះ ហើយទំនោររបស់យើង បណ្ដែតបណ្ដោយ ដោយប្រើអារម្មណ៍ទៅលើតន្ត្រីនោះ។ តន្ត្រីអាចធ្វើឲ្យយើងមាន *អារម្មណ៍*ល្អ ឬមិនល្អបាន។ ប៉ុន្តែ តើគេនឹងនិយាយយ៉ាងម៉េចអំពី សេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះព្រះគ្រីស្ទ និងចំពោះរាស្ត្ររបស់ទ្រង់ ប្រសិនបើខ្ញុំសម្រេចចិត្តចាកចេញពីពួកជំនុំដោយព្រោះតែប្រភេទនៃ តន្ត្រីនោះ? ឬតើគេនឹងនិយាយយ៉ាងម៉េច ពីសេចក្ដីស្រឡាញ់របស់ ខ្ញុំចំពោះព្រះគ្រីស្ទ និងចំពោះរាស្ត្ររបស់ទ្រង់ ប្រសិនបើខ្ញុំដែលជា គ្រូគង្វាល បដិសេធគំនិតរបស់សមាជិកភាគច្រើនដែលចូលចិត្ត

ក្លេងបុរាណ ព្រោះតែខ្ញុំគិតថា ពួកជំនុំគួរតែរៀបចំតន្ត្រីឲ្យទាន់សម័យនោះ? យើងអាចនិយាយថា អូ៎! ខ្ញុំបានភ្លេចថា ប្រភេទតន្ត្រីមិនសំខាន់ដូចជាការមានទំនាក់ទំនងជាមួយរាស្ត្ររបស់ព្រះជាម្ចាស់។

ដូចគ្នានេះដែរ ព្រះគម្ពីរក៏បានបង្រៀនផងដែរថា គ្រីស្ទបរិស័ទគួរយកចិត្តទុកដាក់លើសកម្មភាពដែលកើតឡើងនៅក្នុងពួកជំនុំ ក៏ដូចជាអ្វីៗដែលពួកគេ*ធ្វើ*ផងដែរ។ តាមពិតទៅ យើងនឹងពិភាក្សាអំពីសកម្មភាពដែលបានកើតឡើងនៅក្នុងពួកជំនុំចាប់ពីពាក់កណ្ដាលសៀវភៅនេះទៅ។

តើយើងអាចថ្លឹងថ្លែងពីការទាំងពីរនេះយ៉ាងដូចម្ដេច ដើម្បីឲ្យមានតុល្យភាពរវាង ការយកចិត្តទុកដាក់ទៅលើរាស្ត្ររបស់ព្រះជាម្ចាស់ និងការយកចិត្តទុកដាក់ទៅលើអ្វីដែលពួកគេធ្វើ? ប្រសិនបើនេះជាសៀវភៅស្ដីអំពីរបៀបដែលគ្រីស្ទបរិស័ទថែទាំគ្រួសារវិញ នោះយើងនឹងរៀបរាប់អំពី*ការធ្វើ*កិច្ចការជាក់លាក់មួយចំនួនដូចជា ការញុំាអាហារជាមួយគ្នា ការអានព្រះបន្ទូលជាមួយគ្នា ការលេងសើចជាមួយគ្នា ការអធិស្ឋានឲ្យគ្នាទៅវិញទៅមក និងកិច្ចការផ្សេងៗទៀតហើយ។ ប៉ុន្តែគ្រប់ទាំងការពិភាក្សា ខ្ញុំសង្ឃឹមថាយើងទាំងអស់គ្នានឹងចងចាំថា ឪពុកម្ដាយនៅតែអាចធ្វើខុស ហើយក្មេងគឺនៅតែជាក្មេង។ គ្រួសារមិនមែនជាស្ថាប័នមួយនោះទេ ប៉ុន្តែ គ្រួសារជាមនុស្សមួយក្រុម។

ដូចគ្នានេះដែរ ពួកជំនុំក៏ជាក្រុមមនុស្សដែរ។ តើមានពួកជំនុំណាមួយដែលមិនបានបំពេញនូវសេចក្តីរំពឹងទុករបស់លោកអ្នកដែរឬទេ ទាក់ទងទៅនឹងអ្វីដែលពួកគេធ្វើ ទោះបើពួកគេធ្វើតាម ឬមិនធ្វើតាមអ្វីដែលព្រះគម្ពីរបានចែងអំពីរបៀបដឹកនាំក្នុងពួកជំនុំ (ខ្ញុំនឹងរៀបរាប់ពីប្រធានបទនេះបន្ថែមនៅជំពូកក្រោយៗ)? ប្រសិនបើដូច្នោះមែន សូមចងចាំថា នេះគឺជារាស្ត្ររបស់ព្រះជាម្ចាស់ដែលកំពុងតែរីកចម្រើនលូតលាស់ក្នុងព្រះគុណ។ ចូរស្រឡាញ់ពួកគេ បម្រើពួកគេ ហើយអត់ធ្មត់ជាមួយនឹងពួកគេចុះ។ ជាថ្មីម្តងទៀត សូមពិចារណាទៅលើទំនាក់ទំនងរបស់គ្រួសារ។ នៅពេលណាដែលឪពុកម្តាយ បងប្អូន ឬកូនៗរបស់លោកអ្នកមិនបានបំពេញនូវក្តីរំពឹងរបស់លោកអ្នក តើលោកអ្នកនឹងបណ្តេញពួកគេចេញពីគ្រួសារភ្លាមៗឬ? ខ្ញុំសង្ឃឹមថា លោកអ្នកនឹងអត់ទោស ហើយអត់ធ្មត់ជាមួយនឹងពួកគេ។ តាមពិត បើពួកគេដែលជាសមាជិកគ្រួសារលោកអ្នកមិនបានបំពេញនូវក្តីរំពឹងរបស់លោកអ្នក នោះលោកអ្នកប្រហែលជាត្រូវសួរខ្លួនឯងថា តើខ្ញុំគួរតែសម្របសម្រួលក្តីរំពឹងរបស់ខ្ញុំឬយ៉ាងណា? ដូចគ្នានេះដែរ យើងគួរតែសួរខ្លួនឯងថា តើយើងត្រូវស្រឡាញ់សមាជិកពួកជំនុំយ៉ាងម៉េច ហើយត្រូវអត់ធ្មត់ជាមួយនឹងពួកគេយ៉ាងម៉េច ក្នុងការដែលពួកគេមានគំនិតយោបល់ខុសពីយើង ឬពួកគេមិនបានបំពេញនូវក្តីរំពឹងរបស់យើង ឬក៏ពួកគេបានធ្វើបាប

ទាស់នឹងយើងនោះ។ ចុះតើលោកអ្នក ក៏ដូចជារូបខ្ញុំមិនដែលប្រព្រឹត្ត បាបទាស់នឹងព្រះជាម្ចាស់ ហើយទ្រង់អត់ទោសឲ្យយើងទេឬអី?

ពិតមែន យើងគួរតែដាក់ព្រំខណ្ឌចំពោះការដែលយើងរស់នៅក្នុងចំណោមពួកជំនុំ។ មានពួកជំនុំមួយចំនួនដែលលោកអ្នកប្រហែលជាមិនគួរនឹងចូលជាសមាជិក ឬមិនគួរធ្វើជាគ្រូគង្វាល ឬក៏បន្តធ្វើជាសមាជិកតទៅទៀតឡើយ។ យើងនឹងពិចារណាអំពីរឿងនេះបន្ថែមទៀតនៅក្នុងផ្នែកទី២ដែលនិយាយពីសញ្ញាសម្គាល់ដ៏ចាំបាច់នៃពួកជំនុំ។ រឿងដែលសំខាន់នោះគឺថា ពួកជំនុំគឺជារាស្ត្ររបស់ព្រះជាម្ចាស់។ ហើយអ្វីដែលយើងកំពុងតែស្វែងរក ឬអ្វីដែលយើងសួរថា តើពួកជំនុំគួរតែមានលក្ខណៈយ៉ាងណានោះ យើងត្រូវតែយកតាមសេចក្ដីពិតនេះដែលចេញព្រះគម្ពីរ។

## រាស្ត្ររបស់ព្រះជាម្ចាស់ មិនមែនស្ថិតិ

ខ្ញុំចង់លើកពីសេចក្ដីពិតមួយទៀត ដើម្បីការពារលោកអ្នកពីគំនិតខុសឆ្គងមួយទៀតដែលមនុស្សមួយចំនួនមានលើពួកជំនុំ ភាគច្រើនគ្រូគង្វាលជាអ្នកមានគំនិតបែបនេះ។ ពួកជំនុំមិនមែនជាស្ថិតិទេ តែជារាស្ត្ររបស់ព្រះជាម្ចាស់វិញ។

នៅពេលដែលខ្ញុំសិក្សានៅថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ខ្ញុំចាំថាខ្ញុំបានប្រទះឃើញសំបុត្រប្រឹក្សាយោបល់មួយច្បាប់ដែលសរសេរ

ដោយលោក ចន ប្រោន (John Brown) លោកជាគ្រូគង្វាលម្នាក់នៅក្នុងសតវត្សរ៍ទី១៩។ លោកបានសរសេរសំបុត្រនោះទៅកាន់សិស្សរបស់លោកម្នាក់ដែលទទួលការចាក់ប្រេងតាំងឲ្យដឹកនាំពួកជំនុំតូចមួយ។ នៅក្នុងសំបុត្រនោះ លោក ចន ប្រោន បានសរសេរថា៖

> ខ្ញុំស្គាល់ពីអំនួតដែលនៅក្នុងចិត្តរបស់ប្អូន ហើយក៏ដឹងដែរថា ប្អូនតូចចិត្តដែលពួកជំនុំរបស់ប្អូនតូច បើប្រៀបធៀបទៅនឹងពួកជំនុំរបស់បងប្អូនស្ងួនភ្ងារបស់ប្អូនដែលនៅជុំវិញ។ ប៉ុន្តែសូមជឿទុកចិត្តលើពាក្យមនុស្សចាស់ម្នាក់នេះថា នៅពេលដែលប្អូនចូលទៅដើម្បីនឹងរៀបរាប់ពីទំនួលខុសត្រូវរបស់ប្អូនលើពួកជំនុំដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅឯទីជំនុំជម្រះមុខបល្ល័ង្ក នោះប្អូននឹងគិតថា ប្អូនមានសមាជិកល្មមគ្រប់គ្រាន់ហើយ។[១]

នៅពេលដែលខ្ញុំគិតពីពួកជំនុំដែលព្រះជាម្ចាស់ប្រទានឲ្យខ្ញុំមើលការខុសត្រូវ ខ្ញុំដឹងពីទម្ងន់នៅថ្ងៃដែលខ្ញុំត្រូវរៀបរាប់ចំពោះព្រះជាម្ចាស់។ តើខ្ញុំចង់ឲ្យមានសមាជិកច្រើននៅក្នុងពួកជំនុំខ្ញុំដែរឬទេ? តើខ្ញុំចង់ឲ្យពួកជំនុំខ្ញុំមានប្រជាប្រិយភាពដែរឬទេ? តើខ្ញុំចង់ឲ្យពួកជំនុំខ្ញុំជា

---

១. មកពី James Hay and Henry Belfrage, *Memoir of the Rev. Alexander Waugh* (Edinburgh: William Oliphant and Son, ឆ្នាំ១៨៣៩), ទំព័រ៦៤-៦៥។

ពួកជំនុំមួយដែលមើលទៅគួរឲ្យទាក់ទាញដែរឬទេ?

តើខ្ញុំគ្រាន់តែអត់ទ្រាំ ហើយអត់ឱនឲ្យពួកជំនុំ ដើម្បីរកឱកាសកែតម្រង់ពួកគេឲ្យមានលក្ខណៈដូចចិត្តខ្ញុំឬ? នេះមិនមែនមានន័យថា ការដែលមានបំណងចិត្តសម្រាប់អនាគតពួកជំនុំគឺជាការអាក្រក់នោះទេ ប៉ុន្តែ យើងត្រូវសួរខ្លួនឯងថា តើបំណងចិត្តរបស់ខ្ញុំនោះកំពុងតែនាំឲ្យខ្ញុំមិនអើពើនឹងពួកបរិសុទ្ធដែលនៅជុំវិញខ្ញុំ នាពេលបច្ចុប្បន្ននេះដែរឬទេ ទោះបីជាពួកគេធ្វើឲ្យខ្ញុំខឹងក៏ដោយនោះ?

ខ្ញុំគួរនឹងចងចាំថា ទោះបើមិនសូវមានមនុស្សចូលរួម ហើយអ្នកចូលរួមភាគច្រើនមានវ័យចំណាស់ ក៏ខ្ញុំនៅតែមានឱកាសនឹងជួយមនុស្សដែលអង្គុយនៅមុខខ្ញុំរៀងរាល់ថ្ងៃអាទិត្យ ប្រយោជន៍ឲ្យពួកគេបានសង្គ្រោះដែរ។ ខ្ញុំគួរតែបន្តស្រឡាញ់ ហើយបម្រើពួកជំនុំដ៏តូចតាចនេះ ទោះបើពួកគេមិនគ្រាប់តាមព្រះគម្ពីរក្នុងការចាត់តាំងឲ្យមានក្រុមចាស់ទុំ ទោះបើពួកគេស្រឡាញ់តែប្រពៃណីបុរាណ ហើយជ្រើសរើសបទចម្រៀងមិនត្រូវតាមចិត្តរបស់ខ្ញុំ ហើយទោះបើចំណុចទាំងបីនេះជារនាំងដល់គោលបំណងរបស់ខ្ញុំដែលមានចំពោះពួកជំនុំ។ ការស្រឡាញ់ពួកជំនុំជាការពិបាកសម្រាប់មនុស្សគ្រប់ៗរូប មិនមែនគ្រាន់តែសម្រាប់គ្រូគង្វាលប៉ុណ្ណោះទេ។ មនុស្សជាច្រើនគ្រាន់តែទ្រាំនឹងពួកជំនុំ ដើម្បីរកឱកាសកែនូវអ្វីដែលគេមិនចូលចិត្តឲ្យទៅតាមអ្វីដែលគេចង់បានវិញ។

ពួកជំនុំ គឺជាភរិយារបស់ព្រះជាម្ចាស់ មិនមែនជាស្តិតិនោះទេ។ ពួកជំនុំគឺជារូបកាយដែលជាប់នៅក្នុងព្រះគ្រីស្ទដែលទ្រង់ជាសិរសា។ ពួកជំនុំគឺជាគ្រួសារដែលផ្សារភ្ជាប់គ្នាដោយសារព្រះជាម្ចាស់ទទួលពួកគេធ្វើជាកូនចិញ្ចឹមតាមរយៈព្រះគ្រីស្ទ។

ខ្ញុំអធិស្ឋានសូមឲ្យយើងដែលជាគ្រូគង្វាលកាន់តែទទួលស្គាល់ពីទំនួលខុសត្រូវធំធេងចំពោះហ្វូងចៀមដែលព្រះជាម្ចាស់បានដាក់ឲ្យយើងធ្វើជាអ្នកគង្វាលឲ្យបានកាន់តែខ្លាំងឡើងៗ។

ប៉ុន្តែ ខ្ញុំក៏អធិស្ឋានសូមឲ្យលោកអ្នកដែលជាគ្រីស្ទបរិស័ទ មិនថាចាស់ទុំ ឬក្មេងខ្ចីខាងឯជំនឿទេ កាន់តែទទួលស្គាល់ពីទំនួលខុសត្រូវរបស់លោកអ្នកឲ្យខ្លាំងឡើងៗក្នុងការស្រឡាញ់ ការបម្រើ ការលើកទឹកចិត្ត និងការជួយកែតម្រង់ដល់សមាជិកពួកជំនុំដែលធ្វើខុស។ ខ្ញុំសង្ឃឹមថា លោកអ្នកបានដឹងហើយពីកំហុសរបស់លោក កាអ៊ីន ក្នុងការមិនទទួលខុសត្រូវលើប្អូនគាត់ក្នុងនាមជាសមាជិកគ្រួសារម្នាក់ ដោយឆ្លើយដោះសាទៅកាន់ព្រះជាម្ចាស់យ៉ាងគំរោះគំរើយថា «តើទូលបង្គំជាអ្នកឃ្វាលប្អូនរបស់ទូលបង្គំឬ?»។ ប៉ុន្តែ លើសពីការទទួលខុសត្រូវបងប្អូនខាងសាច់ឈាមរបស់លោកអ្នក ខ្ញុំសង្ឃឹមថា លោកអ្នកនឹងទទួលស្គាល់ថា លោកអ្នកមានទំនួលខុសត្រូវចំពោះបងប្អូនប្រុសស្រីដែលជាគ្រួសារក្នុងពួកជំនុំរបស់លោកអ្នកខ្លាំងជាង។

បណ្ដាជនដែលអង្គុយនៅជុំវិញព្រះអង្គ គេទូលព្រះអង្គថា៖ «មើល៍ ម្ដាយ និងបងប្អូនរបស់លោកគ្រូ មករកលោកគ្រូនៅខាងក្រៅ!»។ ព្រះអង្គមានបន្ទូលតបថា៖ «តើអ្នកណាជាម្ដាយ និងជាបងប្អូនរបស់ខ្ញុំ?» ព្រះអង្គទតទៅអស់អ្នកដែលអង្គុយនៅជុំវិញព្រះអង្គ រួចមានព្រះបន្ទូលថា៖ «អ្នកទាំងនេះហើយជាម្ដាយ និងបងប្អូនរបស់ខ្ញុំ! ដ្បិតអ្នកណាដែលធ្វើតាមព្រះហឫទ័យរបស់ព្រះ អ្នកនោះជាបងប្អូនប្រុសស្រី និងជាម្ដាយរបស់ខ្ញុំ»។ (ម៉ាកុស ៣:៣២-៣៥ គកស)

ជំពូក៣

# ពួកជំនុំគួរប្រាថ្នាចង់បានសុខភាពល្អ

**ប្រសិនបើលោកអ្នក**ជាឪពុកម្តាយដែលជាគ្រីស្ទបរិស័ទ តើលោកអ្នកប្រាថ្នាចង់បានអ្វីសម្រាប់កូនៗរបស់លោកអ្នក? ប្រសិនបើលោកអ្នកជាកូនដែលជាគ្រីស្ទបរិស័ទ តើលោកអ្នកប្រាថ្នាចង់បានអ្វីសម្រាប់គ្រួសាររបស់លោកអ្នក?

លោកអ្នកប្រហែលជាប្រាថ្នាចង់ឲ្យគ្រួសាររបស់ខ្លួនរីកចម្រើនខាងឯលក្ខណសម្បត្តិមួយចំនួនដូចជា សេចក្តីស្រឡាញ់ អំណរ ភាពស្អាតស្អំ សេចក្តីរួបរួម និងការកោតខ្លាចចំពោះព្រះជាម្ចាស់។ លោកអ្នកប្រហែលជាអាចគិតពីលក្ខណសម្បត្តិមួយចំនួន ប៉ុន្តែយើងនឹងព្យាយាមសរុបលក្ខណសម្បត្តិទាំងអស់នោះមកត្រឹមពាក្យមួយគឺពាក្យថា*សុខភាពល្អ*។ លោកអ្នកចង់បានគ្រួសារមួយដែលមានសុខភាពល្អ គឺជាគ្រួសារដែលចុះសម្រុងគ្នា រួមរស់ជាមួយគ្នា

និងចេះស្រឡាញ់គ្នា ស្របតាមអ្វីដែលព្រះជាម្ចាស់បានរៀបចំចាត់ចែងឲ្យក្រុមគ្រួសារនោះយកទៅអនុវត្ត។

ចំណែកឯ ពួកជំនុំរបស់យើងក៏ដូច្នោះដែរ។ ខ្ញុំសូមលើកទឹកចិត្តឲ្យគ្រីស្ទបរិស័ទគួរប្រាថ្នាចង់បានពួកជំនុំដែលមានសុខភាពល្អ មិនថាយើងជាគ្រូគង្វាល ឬសមាជិកពួកជំនុំនោះទេ។

ប្រហែលជាមានពាក្យដើម្បីនឹងពណ៌នាថា ពួកជំនុំគួរតែមានលក្ខណៈបែបណាប្រសើរជាងពាក្យ “សុខភាពល្អ” នេះទៅទៀត ដោយសារយើងកំពុងនិយាយអំពីមនុស្សដែលព្រះរាជបុត្រាដ៏គង់នៅអស់កល្បជានិច្ច ជាស្ដេចលើអស់ទាំងស្ដេច និងព្រះអម្ចាស់លើអស់ព្រះអម្ចាស់បានទិញពួកគេដោយព្រះលោហិតរបស់ទ្រង់។ តើពាក្យថា *សុខភាពល្អ* គឺជាពាក្យដ៏ល្អបំផុតដែលខ្ញុំអាចយកមកពណ៌នាពីពួកជំនុំឬ? ទោះជាយ៉ាងណា ខ្ញុំចូលចិត្តពាក្យ *សុខភាពល្អ* ពីព្រោះពាក្យនេះទាក់ទងនឹងរូបកាយដែលមានជីវិតរស់នៅ ហើយលូតលាស់ទៅតាមដំណើររបស់វា។ រូបកាយនេះប្រហែលជាមានបញ្ហាខ្លះដែរ ដ្បិតវាមិនទាន់បានល្អឥតខ្ចោះនៅឡើយទេ។ ប៉ុន្តែវាកំពុងតែឈានទៅរកភាពល្អឥតខ្ចោះនោះហើយ។ វាកំពុងធ្វើនូវអ្វីដែលវាគួរតែធ្វើ ដ្បិតព្រះបន្ទូលកំពុងតែនាំផ្លូវវា។

ជាញឹកញាប់ ខ្ញុំប្រាប់ពួកជំនុំរបស់ខ្ញុំថា នៅពេលដែលយើងនិយាយពីការតយុទ្ធជាមួយនឹងបាបក្នុងជីវិតរបស់យើង នោះយើង

ត្រូវដឹងថា លក្ខណៈខុសគ្នារវាងអ្នកជឿ និងអ្នកមិនជឿគឺមិនមែនត្រង់ថា អ្នកមិនជឿប្រព្រឹត្តបាប តែអ្នកជឿមិនប្រព្រឹត្តបាបនោះទេ។ លក្ខណៈខុសគ្នានោះគឺត្រង់ថា តើយើងឈរនៅខាងណានៅក្នុងការតយុទ្ធនោះ។ អ្នកជឿឈរនៅខាងព្រះជាម្ចាស់ប្រឆាំងនឹងបាប ប៉ុន្តែអ្នកមិនជឿឈរខាងបាបប្រឆាំងនឹងព្រះជាម្ចាស់។ យើងអាចនិយាយម្យ៉ាងវិញទៀតថា អ្នកជឿនឹងប្រព្រឹត្តបាប ប៉ុន្តែនៅពេលពួកគេប្រព្រឹត្តបាប ពួកគេនឹងបែរទៅរកព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់ ហើយទូលថា «សូមជួយទូលបង្គំក្នុងការតយុទ្ធទាស់នឹងបាបនេះផង»។ ប៉ុន្តែសម្រាប់អ្នកមិនជឿវិញ ទោះបីជាពួកគេទទួលស្គាល់បាបរបស់ខ្លួនក៏ដោយ ក៏ពួកគេនៅតែនិយាយថា «ខ្ញុំចង់បានបាបរបស់ខ្ញុំជាជាងចង់បានព្រះជាម្ចាស់ទៅទៀត»។

ពួកជំនុំដែលមានសុខភាពល្អ មិនមែនជាពួកជំនុំដែលល្អឥតខ្ចោះ ហើយមិនប្រព្រឹត្តបាបនោះទេ។ ពួកគេមិនទាន់បានដោះស្រាយគ្រប់ទាំងបញ្ហាបាននៅឡើយទេ។ ប៉ុន្តែពួកគេជាពួកជំនុំដែលបន្តការព្យាយាមឈរនៅខាងព្រះជាម្ចាស់ក្នុងការតយុទ្ធទាស់នឹងសេចក្តីប៉ងប្រាថ្នាដែលព្រះជាម្ចាស់មិនសព្វព្រះហឫទ័យ ក៏ដូចជាទាស់នឹងការបោកបញ្ឆោតនៃលោកីយ៍ សាច់ឈាម និងសាតាំង។ ពួកគេជាពួកជំនុំមួយដែលបន្តការខំប្រឹងគ្រាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។

សូមអនុញ្ញាតឲ្យខ្ញុំផ្តល់ជូនលោកអ្នកនូវនិយមន័យមួយដែលច្បាស់ជាងនេះ ហើយបន្ទាប់មកយើងនឹងពិនិត្យមើលបទគម្ពីរមួយចំនួនដែលគាំទ្រនិយមន័យនេះ៖ *ពួកជំនុំដែលមានសុខភាពល្អគឺជាពួកជំនុំដែលបន្តការឆ្លុះបញ្ចាំងឲ្យឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ច្រើនឡើងៗដូចទៅនឹងចរិតលក្ខណៈដែលទ្រង់បានបើកសម្តែងឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។*

ដូច្នេះ ប្រសិនបើមានគ្រូគង្វាលម្នាក់សួរខ្ញុំថា តើពួកជំនុំប្រភេទណាដែលខ្ញុំចង់លើកទឹកចិត្តឲ្យគាត់ប្រាថ្នាចង់បាន នោះខ្ញុំប្រហែលជានឹងឆ្លើយថា «ខ្ញុំលើកទឹកចិត្តឲ្យលោកគ្រូប្រាថ្នាចង់បានពួកជំនុំមួយដែលមានសុខភាពល្អ គឺជាពួកជំនុំដែលបន្តការឆ្លុះបញ្ចាំងឲ្យឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់កាន់តែច្រើនឡើងៗដូចទៅនឹងចរិតលក្ខណៈដែលទ្រង់បានបើកសម្តែងឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់»។

ចុះចំណែកឯអ្នកជឿវិញ តើខ្ញុំប្រហែលជានឹងលើកទឹកចិត្តឲ្យលោកអ្នកចូលរួម បម្រើ និងខំអត់ធ្មត់ជាមួយពួកជំនុំប្រភេទណា? ចម្លើយគឺពួកជំនុំដែលមានសុខភាពល្អ ជាពួកជំនុំដែលបន្តការឆ្លុះបញ្ចាំងឲ្យឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់កាន់តែច្រើនឡើងៗដូចទៅនឹងចរិតលក្ខណៈដែលទ្រង់បានបើកសម្តែងឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។

បើលោកអ្នកបានអានយ៉ាងយកចិត្តទុកដាក់ នោះលោកអ្នកច្បាស់ជា កត់សម្គាល់ឃើញថា ខ្ញុំបានប្រើពាក្យ “ប្រហែល” ម្តងហើយម្តងទៀត។ ខ្ញុំមានមូលហេតុពីរយ៉ាងដែលខ្ញុំប្រើពាក្យ “ប្រ-ហែល”។ ទីមួយ ខ្ញុំមិនចង់ណែនាំថា នេះគឺជាវិធី*តែមួយគត់*សម្រាប់យើង ដើម្បីនឹងពណ៌នាថាពួកជំនុំគួរតែមានលក្ខណៈបែបណានោះទេ។ ពេលយើងស្ថិតនៅក្នុងស្ថានភាពផ្សេង ឬគោលបំណងផ្សេង នោះយើងប្រហែលជាឲ្យនិយមន័យបែបផ្សេងមួយទៀតដែរ។ ប្រហែលជាមានអ្នកនិពន្ធ ណាម្នាក់ចង់ឆ្លើយតបទាស់ទៅនឹងក្រឹត្យវិន័យនិយម ឬសេចក្តីអាសអាភាសនៅក្នុងពួកជំនុំ ដូច្នេះហើយគាត់នឹងចាប់ផ្តើមឲ្យនិយមន័យដោយលើកឡើងថា “លក្ខណៈសំខាន់បំផុតដែលពួកជំនុំយើងគួរផ្តោតលើ គឺការយកឈើឆ្កាងជាគោល”។ ខ្ញុំនឹងឯកភាពដោយបន្លឺថា “អាម៉ែន” ត្រង់ចំណុចនេះ។ ឬក៏ប្រហែលជាមានអ្នកនិពន្ធម្នាក់ផ្សេងទៀតចង់ឆ្លើយតបទាស់ទៅនឹងការដែលពួកជំនុំមិនយកចិត្តទុកដាក់ទៅនឹងព្រះបន្ទូលក្នុងករណីនេះ គាត់នឹងដាស់តឿនពួកជំនុំឲ្យយកព្រះគម្ពីរជាគោល។ នោះខ្ញុំនឹងឯកភាពដោយបន្លឺថា “អាម៉ែន” ម្តងទៀត។

ទីពីរ ខ្ញុំមិនចង់សន្មតថា មិនមាននរណាម្នាក់អាចពន្យល់បានប្រសើរជាងអ្វីដែលខ្ញុំកំពុងតែព្យាយាមពន្យល់នោះទេ។ អ្វីដែលខ្ញុំបានសរសេរនេះ គឺជាអ្វីដែលល្អបំផុតដែលខ្ញុំអាចធ្វើបាននៅពេល

នេះ ដើម្បីនឹងពន្យល់ពីអ្វីដែលខ្ញុំជឿថាជាគោលដៅស្នូលរបស់ពួកជំនុំស្របតាមព្រះគម្ពីរ។ គោលដៅស្នូលនោះគឺ ការឆ្លុះបញ្ចាំងឲ្យឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ដូចទៅនឹងចរិតលក្ខណៈដែលទ្រង់បានបើកសម្ដែងឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។

តើមានគ្រីស្ទបរិស័ទណា ដែលមិនចង់ធ្វើតាមគោលដៅស្នូលនេះ?

## ព្រះគម្ពីរធ្វើឲ្យយើងមានគ្រប់ទាំងចំណេះ

ការដែលយើងកាន់តែមានចរិតលក្ខណៈដូចជាព្រះជាម្ចាស់ដូចដែលទ្រង់បានបើកសម្ដែងឲ្យយើងឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ មានន័យថា យើងត្រូវរៀនព្រះបន្ទូលរបស់ទ្រង់។ ហេតុអ្វីបានជាយើងត្រូវត្រាប់តាមព្រះបន្ទូល ហើយមិនធ្វើតាមអ្វីដែលអ្នកដទៃនិយាយថាវិធីមួយនេះមានប្រសិទ្ធភាព នៅពេលដែលយើងសម្រេចថាពួកជំនុំរបស់យើង *គួរធ្វើអ្វី* និង *គួរមាន*លក្ខណៈបែបណានោះ? នៅក្នុងសំបុត្រទីពីររបស់លោក ប៉ុល ផ្ញើទៅកាន់លោក ធីម៉ូថេ ដែលជាគ្រូគង្វាលនៃពួកជំនុំនៅក្នុងទីក្រុងអេភេសូរ លោក ប៉ុល បានប្រាប់លោក ធីម៉ូថេ ថា ព្រះគម្ពីរនឹងធ្វើឲ្យគាត់ «មានចំណេះសម្រាប់ធ្វើការល្អគ្រប់ជំពូក» (គកស)។ ប្រសិនបើមានអ្វីមួយដែលពួកជំនុំយើងគិតថា ពួកគេគួរតែធ្វើ ប៉ុន្តែពួកគេមិនបានឃើញវាមាននៅ

ក្នុងព្រះបន្ទូលទេ នោះលោក ប៉ុល និយាយខុសហើយ ដោយសារយើងមិនអាចថា ព្រះគម្ពីរធ្វើឲ្យយើងមានគ្រប់ទាំងចំណេះសម្រាប់នឹងធ្វើ «ការល្អគ្រប់ជំពូក» នោះទេ។

តើនោះមានន័យថា ខ្ញុំកំពុងតែនិយាយថា យើងមិនគួរប្រើខួរក្បាលដ៏ល្អដែលព្រះជាម្ចាស់បានប្រទានឲ្យយើងទេឬ? ទេ មិនដូច្នោះទេ! ខ្ញុំគ្រាន់តែនិយាយថា សូមឲ្យយើងចាប់ផ្ដើមស្វែងយល់ពីព្រះគម្ពីរ ហើយចាំមើលថា យើងនឹងរកឃើញអ្វីខ្លះ។

ខ្ញុំចង់ពិនិត្យមើលត្រួសៗទៅលើព្រឹត្តិការណ៍ចំនួនប្រាំមួយនៅក្នុងសាច់រឿងនៃព្រះគម្ពីរដែលនឹងជួយឲ្យយើងឃើញនូវអ្វីដែលយើងចង់ឲ្យពួកជំនុំកាន់តែឆ្លុះបញ្ចាំងឲ្យឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ច្រើនឡើងៗដូចទៅនឹងចរិតលក្ខណៈដែលទ្រង់បានបើកសម្ដែងឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ព្រះគម្ពីរពិតជាបានប្រាប់រឿងមួយដល់យើងមែន។ រឿងនេះមានឈុតតូចៗច្រើនរាប់មិនអស់ ប៉ុន្តែឈុតតូចៗទាំងអស់នេះមានចំណែកនៅក្នុងរឿងធំតែមួយ។ គោលដៅនៃការសង្ខេបនេះគឺ ស្វែងយល់ពីអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យពួកជំនុំធ្វើ និងលក្ខណៈបែបណាដែលពួកគេគួរមាន។

# រូបអង្គព្រះជាម្ចាស់សំខាន់បំផុត

## ១) ការបង្កើត

នៅក្នុងកណ្ឌលោកុប្បត្តិ ព្រះជាម្ចាស់បានបង្កើតរុក្ខជាតិ និងសត្វ "តាមពូជ" របស់វានីមួយៗ។ គ្រប់ទាំងផ្លែស្វាយគឺមកពីពូជស្វាយផ្សេងទៀត ហើយគ្រប់ទាំងសេះគឺមកពីពូជសេះផ្សេងទៀត។ ចំពោះមនុស្សវិញ ព្រះគម្ពីរប្រាប់ថា "ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង" (លោកុប្បត្តិ ១:២៦)។ ដូច្នេះ ព្រះជាម្ចាស់មិនបានបង្កើតមនុស្សមកតាមពូជមនុស្សណាផ្សេងទៀតនោះទេ។ ព្រះជាម្ចាស់បានបង្កើតមនុស្សមកដូចរូបអង្គទ្រង់និងមានភាពដូចទ្រង់។ មនុស្សឆ្លុះបញ្ចាំងពីលក្ខណៈរបស់ព្រះជាម្ចាស់ក្នុងរបៀបដ៏ពិសេសមួយ។

ដោយសារតែព្រះជាម្ចាស់បានបង្កើតយើងយ៉ាងពិសេសដូច *រូបអង្គ*នៃទ្រង់ ដូច្នេះមនុស្សត្រូវតែឆ្លុះបញ្ចាំងពីទ្រង់ និងសិរីល្អរបស់ទ្រង់ក្នុងលក្ខណៈមួយដ៏ពិសេសនៅចំពោះអ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមក។ ដូចជាកូនដែលមានចរិតលក្ខណៈដូចឪពុករបស់ខ្លួន ហើយដើរតាមជំហានរបស់ឪពុកខ្លួនយ៉ាងដូច្នោះដែរ (លោកុប្បត្តិ ៥:១; លូកា ៣:៣៨) ព្រះជាម្ចាស់បានបង្កើតមនុស្សមកឲ្យធ្វើជាអ្នក*តំណាងឲ្យ*ចរិតលក្ខណៈរបស់ទ្រង់ ហើយឲ្យពួកគេ

គ្រប់គ្រងអ្វីៗដែលទ្រង់បានបង្កើតមក៖ “ហើយឲ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅលើផែនដីផង” (លោកុប្បត្តិ ១:២៦)។

## ២) ការធ្លាក់ក្នុងអំពើបាប

ប៉ុន្តែ មនុស្សបានសម្រេចចិត្តមិនព្រមធ្វើជាអ្នកតំណាងឲ្យការគ្រប់គ្រងរបស់ព្រះជាម្ចាស់ទេ។ ពួកគេបានបះបោរទាស់នឹងព្រះជាម្ចាស់ ហើយបានធ្វើជាអ្នកតំណាងឲ្យការគ្រប់គ្រងខ្លួនឯងវិញ។ ដូច្នោះហើយបានជាព្រះជាម្ចាស់ប្រទាននូវអ្វីដែលពួកគេចង់បាន ហើយបានបណ្តេញពួកគេចេញពីព្រះវត្តមានរបស់ទ្រង់។ ដោយសារមនុស្សបានប្រព្រឹត្តបាប នោះមានន័យថា គេមិនអាចចូលទៅជិតព្រះជាម្ចាស់ដោយខ្លួនឯងបានតទៅទៀតទេ។

តើមនុស្សនៅតែមានលក្ខណៈដូចរូបអង្គព្រះជាម្ចាស់ឬទេ ទោះបើពួកគេបានធ្លាក់ក្នុងអំពើបាប? ពិតណាស់ ពួកគេនៅតែមាន! កណ្ឌលោកុប្បត្តិបានបញ្ជាក់ម្តងទៀតថា ព្រះជាម្ចាស់បានបង្កើតមនុស្សមកដូច “រូបអង្គ” ទ្រង់ (លោកុប្បត្តិ ៥:១; ៩:៦)។ ប៉ុន្តែឥឡូវ រូបអង្គទ្រង់ដែលនៅក្នុងយើង បានខូចហើយ។ យើងអាចប្រៀបធៀបការឆ្លុះបញ្ចាំងពីរូបអង្គទ្រង់នេះទៅនឹងកញ្ចក់ឆ្លុះដែល

បានប្រេះស្រាំ ដូច្នេះហើយ វាបង្ហាញរូបភាពដ៏អាក្រក់ខុសពីរូបភាពដើម។ យើងនៅតែឆ្លុះបញ្ចាំងពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ដដែល ទោះបើយើងប្រព្រឹត្តបាបក៏ដោយ។ ប៉ុន្តែ ការឆ្លុះបញ្ចាំងនោះ គឺជាការបង្ហាញពីលក្ខណៈពិត និងលក្ខណៈមិនពិតរបស់ទ្រង់មកលាយឡំគ្នា។ អ្នកប្រាជ្ញខាងព្រះគម្ពីរប្រើពាក្យដូចនេះថា មនុស្សបានត្រឡប់ជា “ជាប់ទោស” ហើយ “ខូច”។

## ៣) សាសន៍អ៊ីស្រាអែល

ដោយសារសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ ទ្រង់មានផែនការមួយដើម្បី*សង្គ្រោះ*មនុស្សមួយក្រុម ក៏ដូចជា*ប្រើ*ពួកគេឲ្យសម្រេចនូវគោលបំណងដើមរបស់ទ្រង់សម្រាប់អ្វីៗដែលទ្រង់បានបង្កើតមក។ គោលបំណងនោះគឺការបង្ហាញឲ្យឃើញពីសិរីល្អរបស់ទ្រង់។ ព្រះជាម្ចាស់បានសន្យានឹងបុរសម្នាក់ឈ្មោះ អាប់រ៉ាម ថាទ្រង់នឹងប្រទានពរដល់គាត់ និងកូនចៅរបស់គាត់។ ហើយពួកគេក៏នឹងក្លាយទៅជាព្រះពរដល់គ្រប់ទាំងគ្រួសារនៅលើផែនដី (លោកុប្បត្តិ ១២:១-៣)។ ទ្រង់បានហៅពួកគេថា “សាសន៍បរិសុទ្ធ” និង “នគរដែលសុទ្ធតែជាសង្ឃ” (និក្ខមនំ ១៩:៥-៧)។ នេះមានន័យថា ព្រះជាម្ចាស់បានញែកពួកគេទុក ដើម្បីនឹងបង្ហាញ ហើយឆ្លុះបញ្ចាំងពីចរិតលក្ខណៈរបស់ទ្រង់ និងសិរីល្អរបស់ទ្រង់ដល់សាសន៍ដទៃ

ទៀតដោយការធ្វើតាមក្រឹត្យវិន័យដែលទ្រង់បានប្រទានដល់ពួកគេ (ដូចដែលលោក អ័ដាម គួរតែបានធ្វើដែរ)។ ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់សាសន៍អ៊ីស្រាអែលឲ្យពួកគេបង្ហាញដល់លោកីយ៍ពីលក្ខណៈរបស់ទ្រង់ "ចូរឲ្យឯងរាល់គ្នាញែកខ្លួនចេញ ហើយឲ្យនៅជាបរិសុទ្ធចុះ ដ្បិតអញជាបរិសុទ្ធ" (លេវីវិន័យ ១១:៤៤; ១៩:២; ២០:៧)។

ព្រះជាម្ចាស់ថែមទាំងបានហៅសាសន៍នេះថាជា "កូន" របស់ទ្រង់ទៀតផង ដ្បិតក្នុងប្រពៃណីសម័យនោះ គេរំពឹងថា កូននឹងដើរតាមគន្លងរបស់ឪពុក (និក្ខមនំ ៤:២២-២៣)។ ហើយទ្រង់ក៏បានសន្យាថានឹងគង់នៅជាមួយនឹង "កូន" មួយនេះនៅក្នុងទឹកដីដែលទ្រង់នឹងប្រទានដល់ពួកគេ។ នេះគឺជាឱកាសដែលសាសន៍នេះអាចបង្ហាញពីសិរីល្អរបស់ព្រះជាម្ចាស់ដល់សាសន៍ដែលនៅជុំវិញពួកគេបាន (១ពង្សាវតារក្សត្រ ៨:៤១-៤៣)។

ប៉ុន្តែ ព្រះជាម្ចាស់ក៏បានព្រមានដល់ "កូន" នេះដែរថា ប្រសិនបើគេមិនស្ដាប់បង្គាប់ ហើយមិនបង្ហាញពីចរិតលក្ខណៈបរិសុទ្ធរបស់ទ្រង់ទេ នោះទ្រង់នឹងបណ្ដេញគេចេញពីទឹកដីនោះ។ និយាយឲ្យខ្លីទៅ "កូន" នេះមិនបានស្ដាប់បង្គាប់ទេ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់បណ្ដេញគេចេញពីព្រះវត្តមានរបស់ទ្រង់ និងចេញពីទឹកដីនោះ។

## ៤) ព្រះគ្រីស្ទ

មេរៀនដ៏សំខាន់មួយពីពួកអ៊ីស្រាអែលជំនាន់ដើមគឺថា មនុស្សមានបាបមិនអាចបង្ហាញពីរូបអង្គព្រះជាម្ចាស់បានយ៉ាងគ្រប់លក្ខណ៍ដោយខ្លួនឯងនោះទេ ទោះបីជាពួកគេមានក្រឹត្យវិន័យរបស់ទ្រង់ មានទឹកដីរបស់ទ្រង់ និងមានព្រះវត្តមានរបស់ទ្រង់ក៏ដោយ។ រឿងរបស់ពួកអ៊ីស្រាអែលនេះគួរតែធ្វើឲ្យយើងម្នាក់ៗបន្ទាបខ្លួនចុះ។ មានតែព្រះជាម្ចាស់ទេដែលអាចបង្ហាញពីរូបអង្គទ្រង់បានយ៉ាងគ្រប់លក្ខណ៍ ហើយមានតែព្រះជាម្ចាស់ទេដែលអាចសង្គ្រោះយើងចេញពីបាប និងសេចក្តីស្លាប់បាន។

ដូច្នេះហើយ ព្រះជាម្ចាស់បានបញ្ជូនព្រះរាជបុត្រាតែមួយរបស់ទ្រង់ឲ្យ “ប្រសូតមកមានរូបជាមនុស្ស” (ភីលីព ២:៧)។ កូនស្ងួនភ្ងាមួយអង្គនេះជាកូនដែលព្រះវរបិតាសព្វព្រះហឫទ័យណាស់ ទ្រង់បានចុះចូលទាំងស្រុងទៅនឹងការដឹកនាំ និងនគររបស់ព្រះជាម្ចាស់។ កូនស្ងួនភ្ងាមួយអង្គនេះបានធ្វើនូវអ្វីដែលលោក អ័ដាម មិនបានធ្វើ គឺទ្រង់មិនព្រមធ្វើតាមការល្បួងរបស់សាតាំងទេ។ ទ្រង់បានមានបន្ទូលទៅកាន់មេល្បួង ខណៈដែលទ្រង់កំពុងតមអាហារនៅក្នុងទីរហោស្ថានថា៖ “មនុស្សមិនមែនរស់ ដោយសារតែនំប័ុងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ” (ម៉ាថាយ ៤:៤)។

ព្រះយេស៊ូវបានធ្វើនូវអ្វីដែលអ៊ីស្រាអែលមិនបានធ្វើ។ ទ្រង់រស់នៅដោយប្រតិបត្តិតាមក្រឹត្យវិន័យ និងបំណងព្រះហឫទ័យរបស់ព្រះវរបិតាទាំងស្រុង។ «ខ្ញុំមិនធ្វើអ្វីដោយអាងខ្លួនខ្ញុំទេ គឺខ្ញុំនិយាយសេចក្តីទាំងនេះ តាមតែព្រះវរបិតាបានបង្រៀនខ្ញុំវិញ» (យ៉ូហាន ៨:២៨ ហើយសូមមើលបន្ថែមនៅកណ្ឌយ៉ូហាន ៦:៣៨; ១២:៤៩)។

ដោយសារព្រះរាជបុត្រានេះបានឆ្លុះបញ្ចាំងពីរូបអង្គព្រះវរបិតាទ្រង់យ៉ាងឥតខ្ចោះ ដូច្នេះទ្រង់អាចមានបន្ទូលទៅកាន់លោក ភីលីព ជាសិស្សទ្រង់ថា «អ្នកណាដែលឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ» (យ៉ូហាន ១៤:៩)។

ព្រះវរបិតាយ៉ាងណា នោះព្រះរាជបុត្រាក៏យ៉ាងនោះដែរ។

នៅពេលអ្នកនិពន្ធកណ្ឌគម្ពីរសំបុត្រនៅសញ្ញាថ្មីបានគិតពីអ្វីដែលបានកើតឡើងទាក់ទងនឹងព្រះយេស៊ូវ នោះពួកគេបានពណ៌នាពីទ្រង់ថាជា «រូបអង្គនៃព្រះដ៏មើលមិនឃើញ» (កូល៉ុស ១:១៥) ហើយជា «រស្មីភ្លឺនៃសិរីល្អរបស់ព្រះ និងជារូបភាពអង្គព្រះសុទ្ធសាធ» (ហេព្រើរ ១:៣ គកស)។ ព្រះយេស៊ូវគ្រីស្ទប្រៀបដូចជាលោក អ័ដាមថ្មី និងអ៊ីស្រាអែលថ្មី ពីព្រោះទ្រង់បានស្តារនូវរូបអង្គរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងមនុស្សឡើងវិញ។

ប៉ុន្តែ ព្រះគ្រីស្ទមិនគ្រាន់តែបានបង្ហាញពីភាពបរិសុទ្ធដ៏ឧត្តម

របស់ព្រះជាម្ចាស់តាមរយៈការប្រតិបត្តិតាមក្រឹត្យវិន័យតែប៉ុណ្ណោះទេ ទ្រង់ថែមទាំងបានបង្ហាញពីសេចក្តីស្រឡាញ់ និងក្តីមេត្តាករុណាដ៏ឧត្តមរបស់ព្រះជាម្ចាស់តាមរយៈការសុគតនៅលើឈើឆ្កាងជំនួសមនុស្សមានបាប ដែលជាការបង់ថ្លៃដល់ទោសនៃអំពើបាបដែលពួកគេសមតែនឹងទទួលទៀតផង (យ៉ូហាន ១៧:១-៣)។ ការបូជាជំនួសនេះគឺជាអ្វីដែលព្រះគម្ពីរសញ្ញាចាស់បានចង្អុលទៅរកតាំងពីដើមរៀងមក។ សូមគិតពីសត្វដែលព្រះជាម្ចាស់យកទៅសម្លាប់ដើម្បីគ្របបាំងភាពអាក្រាតរបស់លោក អ័ដាម និងនាងអេវ៉ា បន្ទាប់ពីពួកគេបានធ្វើបាប។ សូមគិតពីពេលដែលព្រះជាម្ចាស់បានប្រទានចៀមឈ្មោលមួយក្បាលដល់លោក អ័ប្រាហាំ និងអ៊ីសាក ដើម្បីសង្គ្រោះអ៊ីសាក។ សូមគិតពីលោក យ៉ូសែប ជាកូនដែលត្រូវបងៗបង្កើតរបស់គាត់បោះបង់ចោល ហើយលក់ទៅស្រុកឆ្ងាយ ដូច្នោះហើយគាត់អាចធ្វើជាអ្នកសង្គ្រោះសម្រាប់ជាតិសាសន៍មួយ។ សូមគិតដល់រាស្ត្រអ៊ីស្រាអែលដែលពួកគេបានលាបឈាមចៀមនៅលើក្របទ្វារផ្ទះរបស់ពួកគេ ដើម្បីឲ្យកូនច្បងរបស់ពួកគេរួចជីវិត។ សូមគិតពីពួកគ្រួសារអ៊ីស្រាអែលដែលពួកគេបាននាំយកតង្វាយសម្រាប់លោះបាបមកដាក់នៅទីលានព្រះវិហារ រួចពួកគេបានដាក់ដៃនៅលើក្បាលសត្វ ហើយបន្ទាប់មកពួកគេក៏អារកសត្វនោះដោយនិយាយថា "ឈាមសត្វដែលខ្វាយនោះ

គួរតែជាឈាមរបស់ខ្ញុំ»។ សូមគិតពីសម្ដេចសង្ឃដែលគាត់ចូលក្នុងទីបរិសុទ្ធបំផុតម្ដងមួយឆ្នាំ ដើម្បីថ្វាយយញ្ញបូជាលោះបាបជំនួសសាសន៍អ៊ីស្រាអែល។ សូមគិតពីសេចក្ដីសន្យាដែលហោរាអេសាយ លើកឡើង៖ «តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជាដោយសារស្នាមរំពាត់នៅអង្គទ្រង់» (អេសាយ ៥៣:៥)។

ការទាំងអស់នេះ និងការជាច្រើនទៀត គឺចង្អុលទៅរកព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានយាងទៅឯឈើឆ្កាងក្នុងនាមជាកូនចៀមនៃព្រះជាម្ចាស់ទុកជាយញ្ញបូជា។ ដូចគ្នានេះដែរ ព្រះយេស៊ូវបានមានបន្ទូលបញ្ជាក់ដល់សិស្សរបស់ទ្រង់នៅឯបន្ទប់ខាងលើថា ទ្រង់បានយាងទៅដើម្បីនឹងផ្ដល់នូវ «សញ្ញាថ្មីមួយ ដែលតាំងដោយនូវឈាមទ្រង់» សម្រាប់អស់អ្នកណាដែលប្រែចិត្តហើយទទួលជឿទ្រង់។

## ៥) ពួកជំនុំ

យើងបានស្លាប់ក្នុងអំពើបាបរបស់យើង ប៉ុន្តែទ្រង់បានប្រោសយើងឲ្យមានជីវិតរស់ឡើងវិញ នៅពេលដែលយើងជ្រមុជក្នុងការសុគត

និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ ដូច្នេះហើយ លោក ប៉ុល ប្រកាសថា «ដ្បិតអ្នករាល់គ្នាសុទ្ធតែជាកូនព្រះ ដោយសារជំនឿ ជឿដល់ព្រះគ្រីស្ទយេស៊ូវ ព្រោះអស់អ្នកដែលបានទទួលបុណ្យ ជ្រមុជក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានប្រដាប់កាយដោយព្រះគ្រីស្ទ ហើយ» (កាឡាទី ៣:២៦-២៧)។ «ហើយដោយព្រោះអ្នករាល់ គ្នាជាកូន បានជាព្រះទ្រង់ចាត់ព្រះវិញ្ញាណនៃព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងចិត្តអ្នករាល់គ្នា ឲ្យបន្លឺឡើងថា អ័ប្បា ព្រះវរបិតាអើយ» (កាឡាទី ៤:៦)។

តើកូនរបស់ព្រះជាម្ចាស់ដ៏ច្រើនទាំងនេះត្រូវធ្វើអ្វីខ្លះ? យើងត្រូវ បង្ហាញនូវ*ចរិតលក្ខណៈ*របស់ព្រះរាជបុត្រា និងព្រះវរបិតាដែលទ្រង់ គង់នៅឯនគរស្ថានសួគ៌ ហើយយើងក៏ត្រូវបង្ហាញនូវ*ភាពដូច*ជាព្រះ ព្រមទាំងរូបអង្គ និង*សិរីល្អ*របស់ទ្រង់ផងដែរ។

ព្រះយេស៊ូវប្រាប់យើងឲ្យធ្វើជា «អ្នកផ្សះផ្សា» ដោយព្រោះ ព្រះវរបិតាទ្រង់បានផ្សះផ្សាយើងជាមួយនឹងទ្រង់តាមរយៈយញ្ញ-បូជារបស់ព្រះរាជបុត្រាទ្រង់ (ម៉ាថាយ ៥:៩)។

ព្រះយេស៊ូវប្រាប់យើងឲ្យ «ស្រឡាញ់ពួកខ្មាំងសត្រូវរបស់យើង» ដោយព្រោះព្រះវរបិតារបស់យើងដែលគង់នៅឯនគរស្ថានសួគ៌ទ្រង់ បានស្រឡាញ់យើង ទោះបើពីមុនមក យើងជាខ្មាំងសត្រូវរបស់ទ្រង់ ក៏ដោយ (ម៉ាថាយ ៥:៤៤; រ៉ូម ៥:៨)។

ព្រះយេស៊ូវប្រាប់យើងឲ្យ “ស្រឡាញ់គ្នាទៅវិញទៅមក” ដោយព្រោះទ្រង់ស្រឡាញ់យើងបានជាទ្រង់ប្រទានជីវិតរបស់ទ្រង់ផ្ទាល់ដល់យើង ហើយចេញពីការដែលយើងស្រឡាញ់គ្នាទៅវិញទៅមកអាចបង្ហាញដល់លោកីយ៍ឃើញថា ទ្រង់មានលក្ខណៈបែបណា (យ៉ូហាន ១៣:៣៤-៣៥)។

ព្រះយេស៊ូវអធិស្ឋានឲ្យយើងបាន “រួមមកតែមួយ” ដ្បិតទ្រង់និងព្រះវរបិតាទ្រង់ក៏រួមមកតែមួយដែរ (យ៉ូហាន ១៧:២០-២៣)។

ព្រះយេស៊ូវប្រាប់យើង “ឲ្យបានគ្រប់លក្ខណ៍” ដូចដែលព្រះវរបិតារបស់យើងដែលគង់នៅឯនគរស្ថានសួគ៌ទ្រង់គ្រប់លក្ខណ៍ដែរ (ម៉ាថាយ ៥:៤៨)។

ព្រះយេស៊ូវប្រាប់យើងឲ្យធ្វើជា “អ្នកនេសាទមនុស្ស” និងអ្នកបង្កើតសិស្សនៅក្នុងគ្រប់ទាំងសាសន៍ (ម៉ាថាយ ៤:១៩; ២៨:១៩)។ ទ្រង់បានចាត់ឲ្យយើងទៅដូចដែលព្រះវរបិតាចាត់ទ្រង់ឲ្យមកដែរ (យ៉ូហាន ២០:២១)។

ព្រះវរបិតាយ៉ាងណា នោះព្រះរាជបុត្រាក៏យ៉ាងនោះ ហើយពួកកូនរបស់ទ្រង់ក៏ដូច្នោះដែរ។ ព្រះជាម្ចាស់បានសម្អាតអំពើបាបរាស្ត្ររបស់ទ្រង់ដោយព្រះលោហិតរបស់ព្រះគ្រីស្ទ ព្រមទាំងប្រទានឲ្យពួកគេមានចិត្តថ្មីតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហេតុដូច្នេះហើយបានជាពួកគេចាប់ផ្តើមស្តាររូបអង្គដ៏ល្អឥតខ្ចោះរបស់ទ្រង់ឡើងវិញ។

ព្រះគ្រីស្ទជាផលដំបូងរបស់យើង (១កូរិនថូស ១៥:២៣)។ ទ្រង់បានដោះស្បៃចោល ហើយបានបើកផ្លូវឲ្យពួកជំនុំមើលឃើញរូបអង្គរបស់ព្រះវរបិតាម្តងទៀត (២កូរិនថូស ៣:១៤, ១៦)។ ឥឡូវនេះ យើងមើលឃើញរូបអង្គទ្រង់ដោយជំនឿ ហើយ «យើងកំពុងតែផ្លាស់ប្រែទៅ ឲ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ» (២កូរិនថូស ៣:១៨)។

តើលោកអ្នកចង់ឃើញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ពួកជំនុំដែលសរុបមកត្រឹមតែពីរខនេះដែរឬទេ? លោក ប៉ុលបានមានប្រសាសន៍ថា៖

> ដើម្បីឲ្យពួកគ្រប់គ្រង និងពួកមានអំណាចនៅស្ថានដ៏ខ្ពស់ បានស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងណាស់ ដោយសារពួកជំនុំ តាមគំនិតសំរេចតាំងពីអស់កល្បរៀងមក ដែលទ្រង់បានគិតស្រេចក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើង។ (អេភេសូរ ៣:១០-១១)

តើពួកជំនុំអាចបង្ហាញពីប្រាជ្ញាដ៏មានជាច្រើនយ៉ាងនៃព្រះជាម្ចាស់ដោយរបៀបណា? មានតែព្រះដែលមានគ្រប់ទាំងប្រាជ្ញាទេដែលអាចបង្កើតនូវផ្លូវមួយដើម្បីជួយសម្រួលរវាងសេចក្តីស្រឡាញ់ និងភាពយុត្តិធម៌របស់ទ្រង់ ខណៈដែលទ្រង់សង្គ្រោះមនុស្សមានបាបដែល

ពួកគេបានដាច់ទំនាក់ទំនងចេញពីទ្រង់ និងពីគ្នាទៅវិញទៅមកហើយនោះ។ ហើយមានតែព្រះដែលមានគ្រប់ទាំងប្រាជ្ញាទេដែលអាចបង្កើតនូវផ្លូវមួយដើម្បីនឹងផ្លាស់ប្ដូរពីចិត្តរឹងដូចថ្មឲ្យក្លាយជាចិត្តទន់ដែលចេះស្រឡាញ់ ហើយនិងសរសើរតម្កើងទ្រង់។ ចូរឲ្យពួកទេវតាទាំងមូលឃើញ ហើយស្ញប់ស្ញែងពីការអស្ចារ្យនេះ។

## ៦) សិរីល្អ

យើងនឹងកាន់តែឆ្លុះបញ្ចាំងរូបអង្គទ្រង់បានយ៉ាងឥតខ្ចោះ នៅពេលដែលយើងមើលឃើញទ្រង់កាន់តែច្បាស់ក្នុងសិរីល្អទ្រង់៖ «ប៉ុន្តែយើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង» (១យ៉ូហាន ៣:២)។ យើងនឹងបានបរិសុទ្ធដូចជាទ្រង់ មានសេចក្ដីស្រឡាញ់ដូចជាទ្រង់ និងរួមមកតែមួយដូចជាទ្រង់។ ខគម្ពីរនេះមិនបានសន្យាថា យើងនឹងក្លាយជាព្រះនោះទេ។ តែខគម្ពីរនេះសន្យាថាព្រលឹងរបស់យើងនឹងបញ្ចេញពន្លឺយ៉ាងចិញ្ចាចចិញ្ចែងជាមួយនឹងចរិតលក្ខណៈ និងសិរីល្អរបស់ទ្រង់ដែលប្រៀបដូចជាកញ្ចក់ដ៏ល្អឥតខ្ចោះបែរតម្រង់ទៅរកព្រះអាទិត្យអញ្ចឹង។

# ការសង្ខេបរឿងឡើងវិញ

តើលោកអ្នកតាមសាច់រឿងនេះទាន់ឬទេ? ខ្ញុំចង់សង្ខេបរឿងនេះឡើងវិញ។ ព្រះជាម្ចាស់បានបង្កើតលោកីយ៍នេះ និងមនុស្សមកដើម្បីបង្ហាញពីសិរីល្អរបស់ទ្រង់។ លោក អ័ដាម និងនាង អេវ៉ាគួរតែបានបង្ហាញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ ប៉ុន្ដែពួកគេមិនបានបង្ហាញពីចរិតលក្ខណៈរបស់ទ្រង់នោះទេ។ ហើយសាសន៍អ៊ីស្រាអែលក៏មិនបានបង្ហាញពី ចរិតលក្ខណៈរបស់ទ្រង់ដែរ។ ហេតុដូច្នេះហើយបានជា ព្រះជាម្ចាស់បញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ដើម្បីនឹងបង្ហាញពីចរិតលក្ខណៈដែលពេញដោយសេចក្ដីស្រឡាញ់ ភាពបរិសុទ្ធរបស់ទ្រង់ ក៏ដូចជាដើម្បីនឹងលុបចោលនូវសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ដែលទាស់នឹងបាបនៃលោកីយ៍នេះ។ ក្នុងព្រះគ្រីស្ទ ព្រះជាម្ចាស់បានយាងមក ដើម្បីបង្ហាញពីលក្ខណៈរបស់ព្រះជាម្ចាស់ ហើយក្នុងព្រះគ្រីស្ទ ព្រះជាម្ចាស់បានយាងមកដើម្បីសង្គ្រោះមនុស្សលោក។

ឥឡូវនេះ ព្រះជាម្ចាស់បានត្រាស់ហៅពួកជំនុំដែលបានទទួលជីវិតរបស់ព្រះគ្រីស្ទ និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ឲ្យបង្ហាញពីចរិតលក្ខណៈនិងសិរីល្អរបស់ទ្រង់ដល់ចក្រវាឡទាំងមូល។ ពួកគេអាចបង្ហាញពីចរិតលក្ខណៈរបស់ទ្រង់ដោយការធ្វើបន្ទាល់ទាំងពាក្យសម្ដី និងការប្រព្រឹត្ដដែលបង្ហាញពីព្រះបញ្ញាញាណរបស់ទ្រង់ និង

កិច្ចការខាងឯសេចក្ដីសង្គ្រោះរបស់ទ្រង់ថែមទៀតផង។

មិត្តអើយ! តើមិត្តកំពុងតែស្វែងរកអ្វីនៅក្នុងពួកជំនុំ? តើមិត្តកំពុងតែស្វែងរកពួកជំនុំមួយដែលមានតន្ត្រីពីរោះឬ? ឬពួកជំនុំដែលមានបរិយាកាសដែលពេញដោយព្រឹត្តិការណ៍សប្បាយៗច្រើនឬ? ឬពួកជំនុំដែលមានលំដាប់កម្មវិធីថ្វាយបង្គំតាមបែបបុរាណឬ? ចុះចំណែកឯពួកជំនុំដែលមានលក្ខណៈដូចនេះវិញ៖

*ពួកជំនុំដែលសុទ្ធតែជាអ្នកបះបោរដែល*
*ទទួលបានការអត់ទោស...*
*ហើយព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ប្រើពួកគេ*
*ដើម្បីបង្ហាញសិរីល្អរបស់ទ្រង់...*
*ដល់អស់ទាំងពួកពលបរិវារនៅស្ថានសួគ៌...*
*ដោយព្រោះពួកគេនិយាយសេចក្ដីពិតអំពីទ្រង់...*
*ហើយពួកគេមើលទៅកាន់តែមានលក្ខណៈដូចជាទ្រង់បន្តិចម្តងៗ ពោលគឺកាន់តែបរិសុទ្ធ កាន់តែមានសេចក្តីស្រឡាញ់ក៏ដូចជាកាន់តែមានការរួបរួមមកតែមួយវិញ?*

ជំពូក៤

# រៀបបង្ហាញពីចរិតលក្ខណៈ របស់ព្រះជាម្ចាស់

**ខ្ញុំសូមសារភាពថា** ខ្ញុំមិនពូកែខាងកិច្ចការនៅក្នុងផ្ទះនោះទេ សូម្បីតែការធ្វើធ្នើរដាក់សៀវភៅ ការតខ្សែធុងបាស និងការស្វែងយល់ពីប៊ូតុងទូរស័ព្ទលើតុរបស់ខ្ញុំថាតើ វាមានដំណើរការយ៉ាងម៉េចនោះ ក៏មិនចេះដែរ។ សូម្បីតែកូនសៀវភៅណែនាំពីរបៀបប្រើប្រាស់ភាគច្រើន ក៏ខ្ញុំយល់ថាវាមិនជួយអ្វីដល់ខ្ញុំប៉ុន្មាននោះដែរ។ ជារឿយៗ ខ្ញុំត្រូវសុំជំនួយពីសមាជិកគ្រួសាររបស់ខ្ញុំ និងមិត្តភក្តិខ្ញុំឲ្យជួយធ្វើកិច្ចការដូចនេះនៅក្នុងផ្ទះខ្ញុំ។

ខ្ញុំអរគុណដល់ព្រះជាម្ចាស់ដែលទោះបីខ្ញុំមិនសូវពូកែក៏វាមិនមែនជាឧបសគ្គដល់ខ្ញុំក្នុងការធ្វើតាមសៀវភៅណែនាំដ៏សំខាន់ជាងគេគឺព្រះគម្ពីរនោះទេ។ ហើយព្រះគម្ពីរបានចែងយ៉ាងច្បាស់-លាស់ពីរបៀបដែលពួកជំនុំគួរបង្ហាញពីចរិតលក្ខណៈដ៏ឧត្តមរបស់

ព្រះជាម្ចាស់។ គោលការណ៍គ្រឹះនៅត្រង់នេះសំខាន់ណាស់៖ យើងត្រូវតែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយយើងត្រូវប្រតិបត្តិតាមព្រះបន្ទូលនោះ។ គោលការណ៍នេះមានតែពីរចំណុចប៉ុណ្ណោះគឺ ស្តាប់ហើយប្រតិបត្តិតាម។

យើងបង្ហាញឲ្យគេឃើញនូវចរិតលក្ខណៈ និងសិរីល្អរបស់ព្រះជាម្ចាស់តាមរយៈការស្តាប់ និងការប្រតិបត្តិតាមព្រះបន្ទូលរបស់ទ្រង់។ ការដែលយើងធ្វើបែបនេះ គឺដូចគ្នាទៅនឹងតួនាទីរបស់រាជទូតស្តេច ក៏ដូចជាកូនល្អអញ្ចឹងដែរ។

សូមស្រមៃពីកូនម្នាក់ដែលឪពុករបស់គាត់បានធ្វើដំណើរទៅប្រទេសឆ្ងាយ ហើយបន្ទាប់មកឪពុកនោះបានសរសេរសំបុត្របួនប្រាំច្បាប់ផ្ញើមកដល់គាត់ ដោយបង្គាប់កូនគាត់ពីរបៀបដែលគាត់ត្រូវបន្តត្រកូលគ្រួសារ និងរបៀបដែលគាត់ត្រូវធ្វើមុខជំនួញគ្រួសារ។ ប៉ុន្តែឧបមាថា កូននោះមិនដែលអានសំបុត្រឪពុករបស់គាត់សោះ។ តើកូននោះអាចនឹងចេះធ្វើជាតំណាងឪពុក និងតំណាងជាអ្នកជំនួញរបស់ឪពុកបានយ៉ាងដូចម្ដេច? គាត់មិនអាចធ្វើតំណាងបានទេ។ ដូចគ្នានេះដែរ ពួកជំនុំតាមតំបន់ដែលមិនយកចិត្តទុកដាក់នឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏នឹងមិនអាចធ្វើជាតំណាងរបស់ទ្រង់បានដែរ។

# មនុស្សពីរប្រភេទ

ចាប់តាំងពីព្រះជាម្ចាស់បានបណ្តេញលោក អ័ដាម ចេញពីសួនច្បារអេដែនដោយព្រោះគាត់មិនបានប្រតិបត្តិតាមព្រះបន្ទូលរបស់ទ្រង់មក មនុស្សបានបែកខ្ញែកជាពីរក្រុម គឺក្រុមដែលប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងក្រុមដែលមិនប្រតិបត្តិតាម។ លោក ណូអេ បានប្រតិបត្តិតាម ប៉ុន្តែពួកដែលជាអ្នកសង់ក្រុងបាបិលមិនបានប្រតិបត្តិតាមទេ។ លោក អ័ប្រាហាំ បានប្រតិបត្តិតាម ប៉ុន្តែស្តេចផារ៉ោនមិនបានប្រតិបត្តិតាមទេ។ ស្តេច ដាវីឌ បានប្រតិបត្តិតាម ប៉ុន្តែកូនៗរបស់ទ្រង់ភាគច្រើនមិនបានប្រតិបត្តិតាមទេ។ លោក សាខេ បានប្រតិបត្តិតាម ប៉ុន្តែលោក ពីឡាត់ មិនបានប្រតិបត្តិតាមទេ។ លោក ប៉ុល បានប្រតិបត្តិតាម ប៉ុន្តែពួកអ្នកដែលតាំងខ្លួនជាមហាសាវ័កមិនបានប្រតិបត្តិតាមទេ។

យើងអាចមើលឧទាហរណ៍ជាច្រើនទៀតនៅក្នុងប្រវត្តិសាស្រ្តពួកជំនុំ។ លោកគ្រូ អាថានេហ្សីស៍ (Athanasius) បានប្រតិបត្តិតាមព្រះបន្ទូល ប៉ុន្តែលោកគ្រូ អេរីអឺស៍ (Arius) មិនបានប្រតិបត្តិតាមនោះទេ។ លោកគ្រូ លូសើរ (Luther) បានប្រតិបត្តិតាម ប៉ុន្តែពួកកាតូលិកទីក្រុងរ៉ូម (Rome) មិនបានប្រតិបត្តិតាមនោះទេ។ លោកគ្រូ ម៉េឆិន (Machen) បានប្រតិបត្តិតាម ប៉ុន្តែលោកគ្រូ ហ្វូសឌិក (Fosdick) មិនបានប្រតិបត្តិតាមនោះទេ។

ខ្ញុំមិនប្រាកដថា ខ្ញុំអាចមើលឃើញចិត្តរបស់អស់លោកដែលខ្ញុំបានដកស្រង់ឈ្មោះពួកគាត់ចេញពីប្រវត្តិសាស្ត្រច្បាស់ដូចជាព្រះជាម្ចាស់ទតឃើញនោះទេ។ ប៉ុន្តែប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរ*ពិតជា*បានបង្ហាញឲ្យយើងថា អ្វីដែលញែករាស្ត្ររបស់ព្រះជាម្ចាស់ពីគ្រូក្លែងក្លាយ និងអ្នកមិនជឿគឺ រាស្ត្ររបស់ព្រះជាម្ចាស់ស្ដាប់ព្រះបន្ទូលទ្រង់ហើយប្រព្រឹត្តតាមព្រះបន្ទូលនោះ។ ឯអ្នកផ្សេងទៀតគេមិនធ្វើដូចនោះទេ។

នេះហើយជាអ្វីដែលលោក ម៉ូសេ បានព្យាយាមបង្រៀនយ៉ាងអស់ពីចិត្តដល់សាសន៍អ៊ីស្រាអែលនៅក្នុងកណ្ឌចោទិយកថា នៅពេលដែលលោកឈរនៅក្បែរទឹកដីសន្យា ជាមួយពួកគេជាលើកទីពីរ។ លោកចាប់ផ្ដើមប្រាប់ពួកគេថា លោកបានឈរនៅក្បែរទឹកដីសន្យានេះ ជាមួយឪពុកម្ដាយពួកគេកាលពី៤០ឆ្នាំមុន ប៉ុន្តែឪពុកម្ដាយរបស់ពួកគេមិនបានស្ដាប់បង្គាប់នោះទេ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់ដាក់បណ្ដាសាដល់ឪពុកម្ដាយរបស់ពួកគេឲ្យស្លាប់នៅក្នុងទីរហោស្ថាន។ យើងអាចសង្ខេបសុន្ទរកថាបីដែលលោក ម៉ូសេ បាននិយាយជិត៣០ជំពូកយ៉ាងសា-មញ្ញដូចនេះ៖ “ចូរស្ដាប់! ចូរឮ! ចូរកត់ចុះ! សូមចងចាំនូវអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូល។ ទ្រង់ជាអ្នកដែលបានរំដោះឯងចេញពីចំណងនៅស្រុកអេស៊ីព្ទ! ហេតុដូច្នេះហើយ ឯងត្រូវស្ដាប់

ទ្រង់»។ នៅក្នុងកណ្ឌចោទិយកថា ៣០:១៩ លោក ម៉ូសេ បាន សង្ខេបនូវអ្វីដែលគាត់បាននិយាយដោយសង្កត់ធ្ងន់ទៅលើបញ្ញត្តិ មួយនេះ៖ «ដូច្នេះចូររើសយកជីវិតចុះ»។

រាស្ត្ររបស់ព្រះជាម្ចាស់នឹងរកឃើញជីវិតតាមរយៈការស្តាប់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងការប្រតិបត្តិតាមព្រះបន្ទូលនោះ តែប៉ុណ្ណោះ។ របៀបនៃការរកជីវិត វាសាមញ្ញណាស់។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្រាប់ពួកជំនុំនៅសញ្ញាថ្មី មិន ខុសគ្នាពីអ្វីដែលលោក ម៉ូសេ បាននិយាយទៅកាន់ពួកអ៊ីស្រាអែល នោះទេ។ ទ្រង់សង្គ្រោះយើងចេញពីចំណងនៃបាប និងសេចក្តី ស្លាប់នៅពេលដែលយើងស្តាប់ព្រះបន្ទូលរបស់ទ្រង់ ហើយទទួល ជឿទ្រង់ (រ៉ូម ១០:១៧)។ ឥឡូវ យើងត្រូវស្តាប់ព្រះបន្ទូលរបស់ ទ្រង់ ហើយប្រតិបត្តិតាម។ ការដែលយើងស្តាប់ ហើយប្រតិបត្តិ តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះមានន័យថា យើងកាន់តែ ឆ្លុះបញ្ចាំងពីចរិតលក្ខណៈ និងសិរីល្អរបស់ទ្រង់។

ប្រហែលជាមានមនុស្សមួយចំនួនជំទាស់ថា «ការនោះស្តាប់ ទៅដូចជាយើងគិតតែពីខ្លួនឯង។ តើព្រះជាម្ចាស់មិនមែនត្រាស់ហៅ ពួកជំនុំឲ្យគិតពីអ្នកដទៃ ដូចជាការចេញទៅធ្វើបេសកកម្មទេឬអី? ឬផ្តោតទៅលើការផ្សាយដំណឹងល្អទេឬអី?»។ ពិតប្រាកដណាស់ ព្រះជាម្ចាស់បានត្រាស់ហៅពួកជំនុំឲ្យធ្វើកិច្ចការទាំងនេះ។ នេះ

ជាចំណែកមួយនៃការបង្ហាញឲ្យឃើញពី ចរិតលក្ខណៈរបស់ព្រះជាម្ចាស់។ ព្រះយេស៊ូវបានមានព្រះបន្ទូលថា “ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នក ឲ្យធ្វើជាអ្នកនេសាទមនុស្សវិញ” (ម៉ាថាយ ៤:១៩ គកស)។ ព្រះយេស៊ូវបានមានព្រះបន្ទូលស្រដៀងគ្នានេះនៅកន្លែងផ្សេងទៀតក្នុងព្រះគម្ពីរថា “ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ ដូចជាព្រះវរបិតាបានចាត់ឲ្យខ្ញុំមកដែរ” (យ៉ូហាន ២០:២១)។ នៅពេលដែលយើងធ្វើបេសកកម្ម ហើយផ្សាយដំណឹងល្អ ព្រមទាំងធ្វើកិច្ចការសម្រាប់នគរព្រះ នោះមានន័យថា យើងកំពុងយកតម្រាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចដែលកណ្ឌម៉ាថាយ ៤:១៩; យ៉ូហាន ២០:២១ និងបទគម្ពីរជាច្រើនទៀតបានលើកឡើង។ យើងមិនមែនធ្វើបេសកកម្មផ្សាយដំណឹងល្អ ឬធ្វើកិច្ចការសម្រាប់នគរព្រះដោយសារតែពួកបណ្ឌិតទេវវិទ្យាមួយចំនួនបានគិតពីការទាំងនេះឡើងនោះទេ។ ហើយយើងក៏មិនមែនធ្វើបេសកកម្ម ផ្សាយដំណឹងល្អ ឬធ្វើកិច្ចការសម្រាប់នគរព្រះដោយសារតែយើងទាំងអស់គ្នាឯកភាពថា ការទាំងនេះជាគំនិតល្អមួយនោះដែរ។ ប៉ុន្តែ យើងធ្វើបេសកកម្មផ្សាយដំណឹងល្អ ហើយធ្វើកិច្ចការខាងឯនគរព្រះជាម្ចាស់ *ដោយសារតែព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្គាប់ឲ្យយើងធ្វើកិច្ចការទាំងនេះ។*

តាមពិតទៅ យើងមិនគួរបែងចែកប្រវត្តិសាស្ត្រនៅត្រឹមតែចន្លោះរវាងអ្នកដែលផ្សាយដំណឹងល្អ និងអ្នកដែលមិនផ្សាយដំណឹងល្អ

នោះទេ។ នោះមិនមែនជា*លក្ខណៈចម្បង*របស់ពួកជំនុំទេ។ យើងបែងចែកមនុស្សជាពីរក្រុម គឺអ្នកដែលស្តាប់ព្រះជាម្ចាស់ និងអ្នកមិនស្តាប់ព្រះជាម្ចាស់។

ហេតុដូច្នេះហើយបានជាលោក **ម៉ាថាយ** បានប្រាប់ពីអ្វីដែលព្រះយេស៊ូវបានមានព្រះបន្ទូលទៅកាន់សាតាំងថា មនុស្សរស់ដោយសារ «គ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ ៤:៤)។ ហើយគាត់ក៏បានប្រាប់ពីព្រះបន្ទូលចុងក្រោយដែលព្រះយេស៊ូវមានព្រះបន្ទូលទៅកាន់សិស្សរបស់ទ្រង់ គឺឲ្យពួកគេទៅបង្កើតសិស្សនៅគ្រប់ទាំងសាសន៍ដោយធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេព្រមទាំង «បង្រៀន ឲ្យគេកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង» (ម៉ាថាយ ២៨:២០)។

ហេតុដូច្នេះហើយបានជាលោក **ម៉ាកុស** បានប្រាប់ពីរឿងប្រៀបប្រដូចរបស់ព្រះយេស៊ូវស្តីអំពីគ្រាប់ពូជដែលបានដាំនៅលើដីបួនប្រភេទខុសៗគ្នា។ នេះជារឿងប្រៀបប្រដូចមួយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ (ម៉ាកុស ៤)។ អ្នកខ្លះនឹងទទួលព្រះបន្ទូល ហើយអ្នកខ្លះទៀតនឹងមិនទទួលទេ។

ហេតុដូច្នេះហើយបានជាលោក **លូកា** បានរាប់ខ្លួនលោកថាជាសាក្សីដែលបានឃើញផ្ទាល់នឹងភ្នែក និងជាអ្នកបម្រើព្រះបន្ទូល (លូកា ១:២)។ មូលហេតុនេះហើយបានជាលោកប្រាប់ពីសេចក្តី

សន្យារបស់ព្រះយេស៊ូវថា៖ «មានពរហើយ អស់អ្នកដែលស្ដាប់ព្រះបន្ទូល ហើយប្រព្រឹត្តិតាម» (លូកា ១១:២៨ គកស)។

ហេតុដូច្នេះហើយបានជាលោក **យ៉ូហាន** បានប្រាប់ពីព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូវទៅកាន់លោក ពេត្រុស ដោយទ្រង់មានព្រះបន្ទូលដដែលៗបីដងថា «ចូរឲ្យចំណើដល់កូនចៀមខ្ញុំស៊ីផង» (យ៉ូហាន ២១:១៥-១៧)។ តើអ្វីជាចំណើរបស់ពួកគេ? ចំណើរបស់ពួកគេគឺជាព្រះបន្ទូលនៃព្រះជាម្ចាស់។

ហេតុដូច្នេះហើយបានជា នៅពេលដែលពួកជំនុំដំបូងក្នុងកណ្ឌ **កិច្ចការ**បានប្រជុំគ្នា នោះពួកគេ «ក៏នៅតែព្យាយាមក្នុងសេចក្ដីបង្រៀនរបស់ពួកសាវ័ក ហើយក្នុងសេចក្ដីប្រកបគ្នា ព្រមទាំងការកាច់នំបុ័ង និងសេចក្ដីអធិស្ឋានផង» (កិច្ចការ ២:៤២)។

ហេតុដូច្នេះហើយបានជាលោក ប៉ុល បានប្រាប់ដល់ពួកជំនុំទីក្រុង**រ៉ូម**ថា៖ «ជំនឿកើតឡើងដោយសេចក្ដីដែលបានឮ ហើយសេចក្ដីដែលបានឮនោះ គឺដោយសារព្រះបន្ទូលរបស់ព្រះគ្រីស្ទ» (រ៉ូម ១០:១៧ គកស)។

ហេតុដូច្នេះហើយបានជាលោកប្រាប់ដល់ពួកជំនុំ**កូរិនថូស**ថា «ដំណឹងពីឈើឆ្កាង» ជា «ព្រះចេស្ដានៃព្រះ» ដល់យើងដែលកំពុងតែបានសង្គ្រោះ (១កូរិនថូស ១:១៨) ដ្បិត «ព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះអស់អ្នកដែលជឿ ដោយសារសេចក្ដី

ល្ងីល្ងើដែលយើងប្រកាសនោះវិញ» (១កូរិនថូស ១:២១ គកស)។ ហេតុដូច្នេះហើយបានជា ក្រោយមកលោកបានប្រាប់ដល់ពួកជំនុំដដែលនោះថា លោកមិនបាន «រកចំណេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ» ក៏មិនបាន «បំភ្លៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ» ប៉ុន្តែលោក «និយាយដោយអស់ពីចិត្ត» សម្រាប់ជាប្រយោជន៍ដ៏នៅអស់កល្បជានិច្ចដល់ពួកគេ (២កូរិនថូស ២:១៧; ៤:២)។

ហេតុដូច្នេះហើយបានជាលោកប្រាប់ដល់ពួកជំនុំនៅស្រុក **កាឡាទី**ថា «បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ» (កាឡាទី ១:៩)។

ហេតុដូច្នេះហើយបានជាលោក ប៉ុល ប្រាប់ដល់ពួកជំនុំទីក្រុង **អេភេសូរ**ថា «នៅក្នុងព្រះអង្គ អ្នករាល់គ្នាក៏បានឮព្រះបន្ទូលនៃសេចក្ដីពិតដែរ គឺជាដំណឹងល្អអំពីសេចក្ដីសង្គ្រោះសម្រាប់អ្នករាល់គ្នា» (អេភេសូរ ១:១៣ គគខ)។ លោកក៏បានប្រាប់ពួកគេផងដែរថាព្រះជាម្ចាស់៖ «បានប្រទានឲ្យអ្នកខ្លះធ្វើជាសាវ័ក អ្នកខ្លះជាហោរា អ្នកខ្លះជាអ្នកផ្សាយដំណឹងល្អ អ្នកខ្លះជាគ្រូគង្វាល ហើយអ្នកខ្លះជាគ្រូបង្រៀន ដើម្បីនាំឲ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍សម្រាប់កិច្ចការបម្រើ ហើយស្អាងព្រះកាយរបស់ព្រះគ្រីស្ទឡើង រហូតដល់យើងទាំង

អស់គ្នាបានរួបរួមនៅក្នុងជំនឿ ហើយបានស្គាល់ព្រះរាជបុត្រារបស់ព្រះ ទៅជាមនុស្សពេញវ័យ និងដល់ខ្នាតកម្ពស់នៃសេចក្ដីពោរពេញរបស់ព្រះគ្រីស្ទ» (អេភេសូរ ៤:១១-១៣ គកស)។

ហេតុដូច្នេះហើយបានជាលោកប្រាប់ដល់ពួកជំនុំក្រុង**ភីលីព**ថា ដោយសារតែចំណោងរបស់លោក៖ «បងប្អូនភាគច្រើនដែលមានការជឿជាក់ក្នុងព្រះអម្ចាស់ដោយសារចំណោងរបស់ខ្ញុំ គេហ៊ានផ្សាយព្រះបន្ទូលកាន់តែខ្លាំងឡើង ដោយឥតភ័យខ្លាច» (ភីលីព ១:១៤ គកស)។

ហេតុដូច្នេះហើយបានជាលោកប្រាប់ដល់ពួកជំនុំក្រុង**កូល៉ុស**ថា៖ «ចូរឲ្យព្រះបន្ទូលរបស់ព្រះគ្រីស្ទសណ្ឋិតនៅក្នុងអ្នករាល់គ្នាជាបរិបូរ។ ចូរបង្រៀន ហើយទូន្មានគ្នាទៅវិញទៅមកដោយប្រាជ្ញាគ្រប់យ៉ាង» (កូល៉ុស ៣:១៦ គកស)។

ហេតុដូច្នេះហើយ បានជាលោកប្រាប់ដល់ ពួកជំនុំក្រុង**ថែស្សាឡូនីច**ថា៖ «យើងអរព្រះគុណព្រះជាម្ចាស់ឥតឈប់ឈរ ដោយព្រោះពេលដែលអ្នករាល់គ្នាបានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយើងបានប្រកាស អ្នករាល់គ្នាមិនបានទទួលទុកជាពាក្យរបស់មនុស្សទេ ផ្ទុយទៅវិញទុកជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតប្រាកដមែន ដែលធ្វើការនៅក្នុងអ្នករាល់គ្នាដែលជឿ» (១ថែស្សាឡូនីច ២:១៣ គគខ)។ ហេតុដូច្នេះហើយបាន

ជាក្រោយមកទៀត លោកបានទូន្មានពួកគេថា៖ «ដូច្នេះ បងប្អូនអើយ! ចូរឈរឲ្យមាំមួន ហើយកាន់តាមសេចក្តីដែលយើងបានបង្រៀនអ្នករាល់គ្នាចុះ ទោះបីដោយពាក្យសំដី ឬសំបុត្រក្តី។» (២ថែស្សាឡូនីច ២:១៥ គគខ)។

ហេតុដូច្នេះហើយបានជាលោក ប៉ុល ប្រាប់ដល់លោក **ធីម៉ូថេ** ដែលជាសិស្សរបស់លោកថា អ្នកត្រួតត្រា (ចាស់ទុំ) ដែលលោកជ្រើសរើសសម្រាប់ពួកជំនុំត្រូវតែ «ប្រសប់នឹងការបង្រៀន» ហើយជាមួយគ្នានោះដែរ អ្នកជំនួយដែលបម្រើនៅក្នុងពួកជំនុំរបស់លោក «ត្រូវជាអ្នកកាន់តាមសេចក្តីអាថ៌កំបាំង របស់ជំនឿ ដោយបញ្ញាចិត្តដ៏ស្អាត» (១ធីម៉ូថេ ៣:២, ៩)។ នៅក្នុងសំបុត្របន្ទាប់ទៀតលោក ប៉ុល បានប្រាប់ដល់លោក ធីម៉ូថេ ថា ការងាររបស់លោកគឺត្រូវផ្តោតលើចំណុចស្នូលនេះ៖

> ចូរប្រកាសព្រះបន្ទូល ហើយខិតខំប្រកាសមិនថា ត្រូវពេល ឬខុសពេលឡើយ ចូរទូន្មាន ស្តីបន្ទោស លើកទឹកចិត្ត និងបង្រៀនដោយសេចក្តីអត់ធ្មត់គ្រប់បែបយ៉ាង ដ្បិតនឹងមានគ្រាមួយដែលពួកគេលែងស្តាប់សេចក្តីបង្រៀនត្រឹមត្រូវទៀត ហើយ ផ្ទុយទៅវិញ ពួកគេនឹងប្រមូលគ្រូជាច្រើនសម្រាប់ខ្លួនឯងទៅតាមសេចក្តីប៉ងប្រាថ្នា ដើម្បីឲ្យនិយាយអ្វីដែល

ត្រចៀករបស់ពួកគេរមាស់ចង់ស្តាប់ ពួកគេនឹងបែរត្រចៀកចេញពីសេចក្តីពិត រួចបែរទៅស្តាប់រឿងព្រេងវិញ។ (២ធីម៉ូថេ ៤:២-៤ គគខ)

ហេតុដូច្នេះហើយបានជាលោកអរសប្បាយជាមួយនឹងលោក **ទីតុស** ដោយសារព្រះជាម្ចាស់បាន «សម្តែងចេញឲ្យស្គាល់ព្រះបន្ទូល ដោយការប្រកាសប្រាប់ដែលផ្ញើទុកនឹងខ្ញុំ (ប៉ុល) តាមបង្គាប់របស់ព្រះជាព្រះសង្គ្រោះនៃយើង» (ទីតុស ១:៣ គកស)។

ហេតុដូច្នេះហើយបានជាលោក ប៉ុល លើកទឹកចិត្តលោកភីលេម៉ូន ឲ្យសកម្មក្នុងការចែកចាយ «ជំនឿ» របស់លោក។ ពាក្យ «ជំនឿ» នេះមិនសំដៅទៅលើស្ថានភាពដែលប្រែប្រួលទៅតាមអារម្មណ៍នោះទេ តែសំដៅលើសំណុំនៃគោលជំនឿដ៏ជាក់លាក់ (ភីលេម៉ូន ១:៦)។

ហេតុដូច្នេះហើយបានជាអ្នកនិពន្ធកណ្ឌ**ហេព្រើរ**បានព្រមានថា «ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់មានជីវិត មានអំណាច ហើយមុតជាងដាវមុខពីរដែលចាក់ទម្លុះរហូតដល់កាត់ព្រលឹង និងវិញ្ញាណ ព្រមទាំងសន្លាក់ឆ្អឹង និងខួរឆ្អឹងឲ្យដាច់ចេញពីគ្នា រួចវិនិច្ឆ័យទាំងគំនិត និងបំណងចិត្តទៀតផង» (ហេព្រើរ ៤:១២ គគខ)។

ហេតុដូច្នេះហើយបានជាលោក **យ៉ាកុប** រំឭកមិត្តអ្នកអានរបស់

លោកថា ព្រះជាម្ចាស់ “ទ្រង់បានបង្កើតយើងរាល់គ្នាមកតាមព្រះហឫទ័យទ្រង់ ដោយសារព្រះបន្ទូលដ៏ពិត” ហើយ “ចូរឲ្យអ្នករាល់គ្នាប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឲ្យគ្រាន់តែស្តាប់ប៉ុណ្ណោះ ហើយបញ្ឆោតខ្លួនវិញនោះឡើយ” (យ៉ាកុប ១:១៨, ២២)។

ហេតុដូច្នេះហើយបានជាលោក **ពេត្រុស** រំឭកដល់ពួកបរិសុទ្ធដែលបានខ្ចាត់ខ្ចាយទៅតាមតំបន់ជាច្រើនថា “ព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ ជាព្រះបន្ទូលរបស់ព្រះដែលរស់នៅហើយស្ថិតស្ថេរ” (១ពេត្រុស ១:២៣ គកស) ហើយលោកក៏បានរំឭកផងដែរថា “ព្រះបន្ទូលនៃព្រះអម្ចាស់ នោះនៅជាប់អស់កល្បជានិច្ចវិញ” (១ពេត្រុស ១:២៥)។ អញ្ចឹងហើយបានជាលោកនិយាយនៅក្នុងសំបុត្រទីពីររបស់លោកផងដែរថា “គ្មានពាក្យទំនាយណាក្នុងគម្ពីរ ដែលស្រាយបានតាមតែចិត្តនោះឡើយ ដ្បិតសេចក្តីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយ ដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្តាលវិញ” (២ពេត្រុស ១:២០-២១)។

ហេតុដូច្នេះហើយបានជាលោក **យ៉ូហាន** បានសរសេរថា “តែអ្នកណាដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្តីស្រឡាញ់នៃព្រះបានពេញខ្នាត នៅក្នុងអ្នកនោះហើយ គឺដោយ

សេចក្តីនោះឯង ដែលយើងដឹងថា យើងនៅក្នុងទ្រង់ អ្នកណាដែលថាខ្លួននៅក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តដូចជាទ្រង់ដែរ» (១យ៉ូហាន ២:៥-៦)។ ហេតុដូច្នេះហើយបានជាលោកសរសេរថា «នេះហើយជាសេចក្តីស្រឡាញ់ គឺយើងត្រូវប្រព្រឹត្តតាមបញ្ញត្តិរបស់ព្រះអង្គ» (២យ៉ូហាន ១:៦ គគខ)។ ហេតុដូច្នេះហើយបានជាលោកប្រកាសថា «គ្មានសេចក្តីណាដែលនាំឲ្យខ្ញុំអរសប្បាយ លើសជាងសេចក្តីនេះទេ គឺដែលឮនិយាយថា ពួកកូនខ្ញុំកំពុងតែប្រព្រឹត្តតាមសេចក្តីពិតនោះឯង» (៣យ៉ូហាន ១:៤)។

ហេតុដូច្នេះហើយបានជាលោក **យូដាស** បានសរសេរស្ទើរតែពេញមួយសំបុត្ររបស់លោក ដើម្បីនឹងដាស់តឿនដល់អ្នកអានសំបុត្ររបស់លោកឲ្យចេះប្រុងប្រយ័ត្ន ហើយហ៊ានទាស់នឹងគ្រូក្លែងក្លាយ (យូដាស ១:៤-១៦)។ លោកថែមទាំងសន្យាថា ព្រះជាម្ចាស់នឹងយាងមក «ដើម្បីជំនុំជម្រះមនុស្សទាំងអស់ ហើយរំឭកមនុស្សទមិឡល្មើសទាំងប៉ុន្មានឲ្យដឹងខ្លួន ពីគ្រប់ទាំងអំពើទមិឡល្មើសដែលគេបានប្រព្រឹត្ត តាមរបៀបទមិឡល្មើស និងពីអស់ទាំងសេចក្តីអាក្រក់ ដែលមនុស្សទមិឡល្មើសមានបាបទាំងនោះ បានពោលទាស់នឹងព្រះអង្គ» (យូដាស ១:១៥ គកស)។

ហេតុដូច្នេះហើយបានជាលោក យ៉ូហាន កោតសរសើរពួកជំនុំទីក្រុងភីឡាដិលភានៅក្នុងកណ្ឌ**វិវរណៈ**ថា «អញស្គាល់ការដែល

ឯងធ្វើហើយ...ទោះបើឯងមានអំណាចតែបន្តិចក៏ដោយ គង់តែបានកាន់តាមពាក្យអញដែរ ហើយមិនបានលះបង់ឈ្មោះអញទេ» (វិវរណៈ ៣:៨)។

* * *

មិត្តអើយ! ពួកជំនុំមានជីវិតដោយសារពួកគេស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពួកគេអាចបំពេញគោលបំណងរបស់ព្រះជាម្ចាស់បាន តាមរយៈការអនុវត្ត និងការបង្ហាញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់ពួកគេ។ កិច្ចការរបស់ពួកជំនុំគឺស្ដាប់ ហើយធ្វើតាមព្រះបន្ទូល តែប៉ុណ្ណឹងឯង។ ការដែលពួកជំនុំព្យាយាមស្វែងយល់ពីវិធីដើម្បីឲ្យ "ទាន់សម័យ" ឬមាន "យុទ្ធសាស្ត្រល្អ" ឬ "យល់ចិត្តអ្នកដទៃ" ឬក៏គិតយ៉ាងហ្មត់ចត់ មិនមែនជាផលលំបាកចម្បងដែលពួកជំនុំបច្ចុប្បន្ននេះប្រឈមមុខនោះទេ។ តែផលលំបាកចម្បងគឺ ការស្មោះត្រង់ទៅនឹងព្រះបន្ទូល ដោយត្រូវស្ដាប់ ទុកចិត្ត ហើយប្រតិបត្តិតាមព្រះបន្ទូលនោះឯង។

នៅក្នុងន័យនេះ យើងប្រៀបដូចជាសាសន៍អ៊ីស្រាអែលដែលកំពុងត្រៀមខ្លួននឹងចូលទឹកដីសន្យា។ ព្រះជាម្ចាស់កំពុងតែមានព្រះបន្ទូលមកកាន់យើងថា "ពួកជំនុំអើយ! ចូរស្ដាប់ ហើយប្រព្រឹត្តតាមចុះ!" ប៉ុន្តែយើងបានទទួលអ្វីដែលពិសេសជាងសាសន៍យូដា ដោយសារយើងបានទទួលការបើកសម្ដែងពីព្រះជាម្ចាស់

យ៉ាងពេញលេញនៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទ ហើយយើងមានព្រះវិញ្ញាណនៃព្រះរាជបុត្រាទ្រង់ ដែលនេះគឺជាការបោះត្រា និងជាសេចក្ដីសន្យាពីសេចក្ដីសង្គ្រោះសម្រាប់យើង។

## ចូរបន្តស្ដាប់

សរុបមក រឿងទាំងអស់នេះជាមូលហេតុដែលយើងចង់បន្តស្ដាប់នៅពេលដែលយើងបន្តទៅប៉ុន្មានជំពូកចុងក្រោយនៃសៀវភៅនេះ។ តើមានអ្វីទៀតដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបង្រៀនយើងនៅក្នុងព្រះបន្ទូលទ្រង់ទាក់ទងនឹងពួកជំនុំដែលមានសុខភាពល្អ? ខ្ញុំសង្ឃឹមថា សញ្ញាសម្គាល់ប្រាំបួនយ៉ាងនៃពួកជំនុំដែលមានសុខភាពល្អដែលយើងនឹងពិភាក្សាឥឡូវនេះ មិនមែនគ្រាន់តែខ្ញុំដែលមានគំនិតដូចនេះនោះទេ ប៉ុន្តែជាគំនិតដែលស្របតាមព្រះគម្ពីរ។ ទាំងនេះគឺគ្រាន់តែជាការខិតខំប្រឹងប្រែងរបស់ខ្ញុំ ដើម្បីនឹងដាស់តឿន*យើងទាំងអស់គ្នា*ឲ្យបន្តស្ដាប់តទៅទៀត។ សូមមើលតារាងមាតិកាឡើងវិញ នោះលោកអ្នកនឹងឃើញពីគោលបំណងខ្ញុំក្នុងការត្រាប់*តាមព្រះគម្ពីរ*៖ សេចក្ដីអធិប្បាយ*តាមអត្ថន័យព្រះគម្ពីរ* ទេវវិទ្យា*តាមព្រះគម្ពីរ* ការយល់ពីដំណឹងល្អ*តាមព្រះគម្ពីរ* ការយល់ពីការប្រែចិត្តជឿលើព្រះយេស៊ូវ*តាមព្រះគម្ពីរ* ការយល់ពីសមាជិកភាពពួកជំនុំ*តាមព្រះគម្ពីរ* ការដាក់វិន័យពួកជំនុំ*តាមព្រះគម្ពីរ* ។ល។

ទោះបីលោកអ្នកមិនឯកភាពនឹងអ្វីដែលខ្ញុំនឹងនិយាយនៅក្នុងជំពូកតទៅទៀតនេះក៏ដោយ ក៏ខ្ញុំសង្ឃឹមថា មូលហេតុដែលលោកអ្នកមិនឯកភាពគឺដោយសារតែលោកអ្នកគិតថា ខ្ញុំនិយាយខុសពីព្រះគម្ពីរ។ ឬនិយាយមួយបែបទៀត ខ្ញុំសង្ឃឹមថាលោកអ្នកនឹងយកគំនិតតាមព្រះគម្ពីរ ក្នុងការគិតពីអ្វីដែលពួកជំនុំក្នុងតំបន់គួរធ្វើ និងពីលក្ខណៈដែលពួកជំនុំគួរមាន។

# គំនិតជំនួយខ្លះៗ៖ ប្រសិនបើលោកអ្នកមានគំនិត ចង់ផ្លាស់ប្តូរពួកជំនុំ...

## *មុនពេលដែលលោកអ្នកសម្រេចចិត្តផ្លាស់ប្តូរពួកជំនុំ៖*

១. សូមអធិស្ឋាន។

២. សូមអនុញ្ញាតឲ្យគ្រូគង្វាលរបស់លោកអ្នកដឹងពីគំនិតរបស់លោកអ្នក មុនពេលដែលលោកអ្នកផ្លាស់ប្តូរទៅពួកជំនុំមួយផ្សេងទៀត ឬមុនពេលដែលលោកអ្នកសម្រេចចិត្តថានឹងផ្លាស់ប្តូរទីលំនៅទៅទីក្រុង ឬខេត្តមួយផ្សេងទៀត រួចមកសុំយោបល់ពីគាត់។

៣. សូមថ្លឹងថ្លែងដោយគិតពីមូលហេតុពិតប្រាកដរបស់លោកអ្នក។ តើបំណងចិត្តរបស់លោកអ្នកក្នុងការផ្លាស់ប្តូរនោះដោយសារតែ មានជម្លោះជាមួយនឹងអ្នកឯទៀត ឬដោយសារតែការខកចិត្តនឹងអ្វីមួយ? ប្រសិនបើលោកអ្នកចង់ផ្លាស់ប្តូរដោយសារតែសេចក្តីបង្រៀនក្នុងពួកជំនុំខុសពីអ្វីដែលលោកអ្នកជឿ តើសេចក្តីបង្រៀនទាំងនោះខុសខ្លាំង ឬក៏ខុសតែបន្តិចបន្តួច?

៤. សូមផ្សះផ្សាទំនាក់ទំនងដែលប្រេះស្រាំ ដោយប្រើគ្រប់សន្តិវិធីដែលលោកអ្នកអាចធ្វើបាន។

៥. សូមពិចារណាពីរបៀបដែលព្រះជាម្ចាស់កំពុងតែធ្វើការនៅក្នុងពួកជំនុំរបស់លោកអ្នក ដែលជាភស្តុតាងនៃព្រះគុណទ្រង់។ ប្រសិនបើលោកអ្នកមិនឃើញមានភស្តុតាងពីព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងពួកជំនុំទេ នោះលោកអ្នកគួរពិនិត្យមើលចិត្តគំនិតរបស់លោកអ្នកម្តងទៀត (ម៉ាថាយ ៧:៣-៥)។

៦. សូមបន្ទាបខ្លួន! សូមទទួលស្គាល់ថា លោកអ្នកមិនមានព័ត៌មានគ្រប់ចំណុចនោះទេ ហើយសូមវាយតម្លៃមនុស្ស និងស្ថានភាពដោយសេចក្តីស្រឡាញ់ (កុំស្មានថាពួកគេមានចេតនាអាក្រក់ចំពោះលោកអ្នក)។

## *ប្រសិនបើលោកអ្នកចេញទៅ*

១. សូមកុំបំបែកបំបាក់ពួកជំនុំ។

២. សូមប្រយ័ត្ន កុំផ្សព្វផ្សាយភាពមិនពេញចិត្តរបស់លោកអ្នកនោះឡើយ សូម្បីតែក្នុងចំណោមមិត្តភក្តិជិតស្និទ្ធរបស់លោកអ្នកក៏ដោយ។ សូមកុំបង្កើតឲ្យមានឧបសគ្គណាមួយមករារាំងការរីកចម្រើនខាងឯវិញ្ញាណនៅក្នុងពួកជំនុំឡើយ។ សូម*កុំនិយាយដើម*គេឲ្យសោះ។

៣. សូមអធិស្ឋាន ហើយឲ្យពរដល់ពួកជំនុំ និងអ្នកដឹកនាំ។ សូមរកឱកាសជាក់លាក់ ដើម្បីធ្វើការនេះតាមដែលអាចធ្វើបាន។

៤. ប្រសិនបើលោកអ្នកទទួលការឈឺចាប់ នោះចូរលោកអ្នកអត់ទោសដូចជាព្រះជាម្ចាស់បានអត់ទោសដល់លោកអ្នកដែរ។

ផ្នែកទី២

# សញ្ញាសម្គាល់ដ៏ចាំបាច់នៃពួកជំនុំដែលមានសុខភាពល្អ

# សញ្ញាសម្គាល់ដ៏ចាំបាច់នៃពួកជំនុំ ដែលមានសុខភាពល្អ

**យើងបានសម្រេចចិត្ត**រួចទៅហើយថា យើងចង់បានពួកជំនុំដែលមានសុខភាពល្អ។ យើងចង់បានពួកជំនុំដែលកាន់តែឆ្លុះ-បញ្ចាំងពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់បន្តិចម្តងៗដូចដែលព្រះជាម្ចាស់បានបើកសម្តែងចរិតលក្ខណៈទាំងនោះ នៅក្នុងព្រះបន្ទូលទ្រង់។ ទោះបីពួកជំនុំមានសមាជិកច្រើន ឬតិច នៅទីក្រុង ឬជនបទ បុរាណ ឬទាន់សម័យ ហើយទោះបីពួកគេជួបប្រជុំនៅផ្ទះ ឬអាគារធំៗ សាលារៀន ឬនៅមុខហាងក៏ដោយ ចូរឲ្យពួកគេបង្ហាញដល់លោកីយ៍ឃើញថា តើព្រះដែលពេញដោយសេចក្តីស្រឡាញ់ និងបរិសុទ្ធរបស់យើងទ្រង់មានលក្ខណៈបែបណា។ សូមឲ្យពួកគេបង្ហាញពីសិរីល្អដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ដោយពាក្យសម្តី និងការប្រព្រឹត្ត។

ដូច្នេះ សំណួរដែលយើងត្រូវពិចារណាគឺថា *តើអ្វីជាសញ្ញា*

*សម្គាល់នៃពួកជំនុំដែលមានសុខភាពល្អ?*

ប្រសិនបើយើងនិយាយអំពីការរក្សារាងកាយឲ្យមានសុខភាពល្អ នោះការសន្ទនារបស់យើងនឹងនិយាយពីការញ៉ាំកម្រិតអាហារដែលមានតុល្យភាព ការធ្វើលំហាត់ប្រាណ និងការទទួលទានដំណេកគ្រប់គ្រាន់ជាដើម។ល។ ចុះចំណែកឯរូបកាយពួកជំនុំវិញ?

នៅក្នុងវគ្គនេះ និងវគ្គបន្ទាប់ ខ្ញុំនឹងនិយាយអំពីសញ្ញាសម្គាល់ប្រាំបួនយ៉ាងនៃពួកជំនុំដែលមានសុខភាពល្អ។ សញ្ញាសម្គាល់ទាំងអស់នេះ មិនមែនបញ្ជាក់ពីលក្ខណៈទាំងអស់នៃពួកជំនុំដែលមានសុខភាពល្អនោះទេ។ ហើយក៏មិនមែនមានន័យថា សញ្ញាសម្គាល់ទាំងប្រាំបួននេះជាលក្ខណៈសំខាន់បំផុតអំពីពួកជំនុំនោះដែរ។ ឧទាហរណ៍៖ តាមប្រវត្តិសាស្រ្តយើងដឹងថា ពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ ក៏ជាផ្នែកដ៏ចាំបាច់នៃពួកជំនុំដែលធ្វើតាមព្រះគម្ពីរដែរ ប៉ុន្តែខ្ញុំមិនលើកយកពិធីទាំងពីរនេះមកពិភាក្សានៅទីនេះទេ ពីព្រោះពួកជំនុំសឹង១០០ភាគរយសុទ្ធតែមានបំណងនឹងអនុវត្តពិធីទាំងពីរនេះរួចទៅហើយ។ សញ្ញាសម្គាល់ប្រាំបួនយ៉ាងដែលខ្ញុំបានលើកឡើងនៅក្នុងសៀវភៅនេះ គឺជាសញ្ញាសម្គាល់ដែលលោកអ្នកអាចបែងចែកដាច់ពីគ្នារវាងពួកជំនុំដែលមានសុខភាពល្អហើយត្រឹមត្រូវតាមព្រះគម្ពីរ និងពួកជំនុំដែលមានជំងឺ។ យើងកម្រនឹងឃើញមានសញ្ញាសម្គាល់ទាំងប្រាំបួននេះនៅក្នុងពួកជំនុំនៅ

បច្ចុប្បន្ននេះណាស់។ ដូច្នេះហើយ យើងត្រូវតែយកចិត្តទុកដាក់ឲ្យបានខ្លាំងលើសញ្ញាសម្គាល់ទាំងនេះ ហើយត្រូវបណ្ដុះវាឲ្យមាននៅក្នុងពួកជំនុំរបស់យើង។

នៅក្នុងវគ្គនេះ ខ្ញុំនឹងពណ៌នាពីសញ្ញាសម្គាល់បីយ៉ាងដែលខ្ញុំរាប់ថាជាសញ្ញាសម្គាល់*ដ៏ចាំបាច់*នៃពួកជំនុំដែលមានសុខភាពល្អ។ សញ្ញាសម្គាល់ដ៏ចាំបាច់ទាំងបីនេះ គឺពិតជាសំខាន់ណាស់។ ប្រសិនបើ ពួកជំនុំខ្វះនូវសញ្ញាសម្គាល់ដ៏ចាំបាច់ទាំងបីនេះ ដូចជាសេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ ទេវវិទ្យាតាមព្រះគម្ពីរ និងការយល់ពីដំណឹងល្អតាមព្រះគម្ពីរ នោះសុខភាពរបស់ពួកជំនុំនោះនឹងធ្លាក់ចុះយ៉ាងលឿន។ តាមពិតទៅ ពួកជំនុំនោះប្រហែលជានឹងស្លាប់ក្នុងពេលដ៏ឆាប់ ទោះបីទ្វាររបស់ពួកជំនុំនោះនៅបើកចំហក៏ដោយ។

គួរឲ្យសោកស្ដាយណាស់ ដែលប្រវត្តិសាស្ត្រពួកជំនុំមានគំរូរាប់មិនអស់ពីគ្រូគង្វាលដែលចង់ឲ្យពួកជំនុំរបស់ខ្លួនកាន់តែទាន់សម័យ ដោយព្យាយាមបន្ថែមបន្ថយសញ្ញាសម្គាល់មួយក្នុងចំណោមសញ្ញាសម្គាល់ទាំងបីតាមប្រាជ្ញារបស់ខ្លួន ទោះបើពួកគេមិនបានធ្វើក្នុងគោលបំណងអាក្រក់ក៏ដោយ។ បើនិយាយឲ្យខ្លី ពួកគេព្យាយាមធ្វើជាអ្នកមានប្រាជ្ញាជាងព្រះជាម្ចាស់។ មិត្តអើយ! កុំឲ្យដើរតាមគន្លងរបស់ពួកគេឡើយ។

ប្រសិនបើមានមនុស្សម្នាក់ទូរស័ព្ទមកខ្ញុំ ហើយសួរខ្ញុំថា តើគាត់

គួរតែទទួលការងារជាគ្រូគង្វាលនៅពួកជំនុំមួយដែលមិនចង់ឲ្យគាត់អធិប្បាយតាមអត្ថន័យព្រះគម្ពីរឬអត់ នោះខ្ញុំនឹងប្រហែលជាលើកទឹកចិត្តមិនឲ្យគាត់ទទួលតំណែងនោះទេ។ ប្រសិនបើមានអ្នកជឿម្នាក់ទូរស័ព្ទមកខ្ញុំ ហើយនិយាយថា មានគេបង្រៀនដំណឹងល្អខុសឆ្គងជាបន្តបន្ទាប់នៅក្នុងពួកជំនុំរបស់គាត់ នោះខ្ញុំទំនងជាលើកទឹកចិត្តឲ្យគាត់ពិចារណាក្នុងការផ្លាស់ប្តូរពួកជំនុំនេះហើយ។

ហេតុអ្វីបានជាខ្ញុំនិយាយ ពីការនេះយ៉ាងខ្លាំងបែបនេះ? យោងតាមហេតុផលដូចគ្នានេះ ខ្ញុំនឹងមិនលើកទឹកចិត្តនរណាម្នាក់ឲ្យទៅភោជនីយដ្ឋានដែលមិនមានអាហារ ប៉ុន្តែមានតែរូបភាពអាហារទៅវិញនោះទេ។ មានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់តែមួយប៉ុណ្ណោះដែលអាចផ្តល់ជីវិតបាន!

ជំពូក៩

# សញ្ញាសម្គាល់ដ៏ចាំបាច់នៃពួកជំនុំ ដែលមានសុខភាពល្អ៖ សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ

**ប្រសិនបើពួកជំនុំ**ដែលមានសុខភាពល្អ គឺជាពួកជំនុំដែលកាន់តែបង្ហាញឲ្យឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ច្រើនឡើងៗ ដូចដែលទ្រង់បានបើកសម្តែងឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ នោះចំណុចដ៏ជាក់ច្បាស់ក្នុងការចាប់ផ្តើមសង់ពួកជំនុំដែលមានសុខភាពល្អ គឺត្រូវដាស់តឿនហៅសមាជិកឲ្យស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រភពនៃជីវិត និងសុខភាព។ ព្រះបន្ទូលនោះឯងដែលបានផ្តល់ចំណីបំប៉ន អភិវឌ្ឍន៍ និងរក្សាការពារពួកជំនុំឲ្យយល់ដឹងពីដំណឹងល្អ។

## លក្ខណៈនៃសេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ

លក្ខណៈនេះមានន័យថា ទាំងគ្រូគង្វាល ទាំងពួកជំនុំត្រូវតែប្តេជ្ញាទៅនឹងសេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ។ សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរជាប្រភេទនៃសេចក្តីអធិប្បាយដែល *លាតត្រដាង*ឲ្យឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គ្រូគង្វាលនឹងយកអត្ថបទព្រះបន្ទូលជាក់លាក់ណាមួយពីព្រះគម្ពីរមកពន្យល់អត្ថបទព្រះបន្ទូលនោះ បន្ទាប់មកយកអត្ថន័យនៃអត្ថបទព្រះបន្ទូលឲ្យពួកជំនុំអនុវត្តនៅក្នុងជីវិតរបស់ពួកគេ។ វាជាប្រភេទនៃសេចក្តីអធិប្បាយដែលមានប្រសិទ្ធភាពជាងគេក្នុងការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅកាន់រាស្ត្ររបស់ទ្រង់ ក៏ដូចជាទៅកាន់អ្នកដែលមិនមែនជារាស្ត្ររបស់ទ្រង់។ ការប្តេជ្ញាអធិប្បាយតាមអត្ថន័យព្រះគម្ពីរ គឺជាការប្តេជ្ញាស្តាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។

សេចក្តីអធិប្បាយមានច្រើនប្រភេទ ឧទាហរណ៍ដូចជា សេចក្តីអធិប្បាយតាមប្រធានបទ គឺជាសេចក្តីអធិប្បាយដែលប្រមូលផ្តុំខគម្ពីរមួយខ ឬច្រើនខទាក់ទងនឹងប្រធានបទជាក់លាក់ណាមួយ ដូចជា ប្រធានបទស្តីពីការអធិស្ឋាន ឬប្រធានបទស្តីពីការថ្វាយតង្វាយ។ សេចក្តីអធិប្បាយមួយប្រភេទទៀត គឺជាសេចក្តីអធិប្បាយដោយយកជីវប្រវត្តិរបស់បុគ្គលណាម្នាក់នៅក្នុងព្រះគម្ពីរមកសិក្សា

ដើម្បីបង្ហាញពីព្រះគុណរបស់ព្រះជាម្ចាស់ ចេញពីគំរូនៃសេចក្ដីសង្ឃឹម និងភាពស្មោះត្រង់របស់បុគ្គលម្នាក់នោះ។ ហើយប្រភេទនៃសេចក្ដីអធិប្បាយទាំងពីរអាចមានប្រយោជន៍ចំពោះពួកជំនុំពេលខ្លះបាន។ ប៉ុន្ដែទោះជាយ៉ាងណា គ្រូគង្វាលគួរតែមានទម្លាប់ក្នុងការពន្យល់ ហើយផ្ដល់ការអនុវត្ដចេញពីព្រះបន្ទូលពីមួយកណ្ឌទៅមួយកណ្ឌ ដ្បិតព្រះបន្ទូលគឺជារបបអាហារប្រចាំថ្ងៃរបស់ពួកជំនុំ។

ការអធិប្បាយតាមអត្ថន័យព្រះគម្ពីរ មានន័យថា ពួកជំនុំជឿថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានអំណាចលើជីវិតរបស់ពួកគេ។ ការអធិប្បាយបែបនេះបង្ហាញថា រាស្ដ្ររបស់ទ្រង់*គួរតែ*ឮព្រះបន្ទូល ហើយ*ចាំបាច់*ត្រូវតែឮព្រះបន្ទូលនោះ បើមិនដូច្នោះទេ ពួកជំនុំរបស់យើងនឹងអត់បានទទួលនូវអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យនឹងប្រើសម្រាប់កែច្នៃយើងឲ្យដូចរូបអង្គទ្រង់នោះឡើយ។ ហើយវាក៏បង្ហាញដែរថា ព្រះជាម្ចាស់សព្វព្រះទ័យឲ្យពួកជំនុំរៀនទាំងពីព្រះគម្ពីរសញ្ញាថ្មី និងសញ្ញាចាស់ ព្រមទាំងរៀនពីគ្រប់ទាំងប្រភេទនៃកណ្ឌគម្ពីរដូចជាកណ្ឌក្រឹត្យវិន័យ កណ្ឌប្រវត្តិសាស្ដ្រ កណ្ឌសុភាសិត កណ្ឌហោរា កណ្ឌដំណឹងល្អ និងកណ្ឌសំបុត្រ។ គ្រូអធិប្បាយដែលអធិប្បាយតាមអត្ថន័យព្រះគម្ពីរដែលអធិប្បាយឲ្យចប់ពីមួយកណ្ឌទៅមួយកណ្ឌ ក៏ដូចជាផ្លាស់ប្ដូរសេចក្ដីអធិប្បាយរបស់គាត់ជាទៀងទាត់រវាងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ឬ

ជ្រើសរើសប្រភេទនៃកណ្ឌគម្ពីរផ្សេងៗគ្នា នោះខ្ញុំជឿថា គាត់ប្រៀប ដូចជាម្ដាយម្នាក់ដែលផ្ដល់អាហារដល់កូនពីគ្រប់ទាំងក្រុមនៃអាហារ មិនមែនគ្រាន់តែផ្ដល់អាហារដែលពួកគេចូលចិត្តពីរបីមុខនោះទេ។

អំណាចនៃការអធិប្បាយរបស់គ្រូគង្វាលមិនមែនកើតចេញពី ខ្លួនគាត់នោះទេ ប៉ុន្តែកើតចេញពីព្រះបន្ទូលរបស់ទ្រង់តែប៉ុណ្ណោះ។ សូម្បីតែព្រះជាម្ចាស់ក៏មិនបានប្រទានបេសកកម្មមួយដល់ពួក ហោរានៅសញ្ញាចាស់ និងពួកសាវ័កនៅសញ្ញាថ្មីឲ្យចេញទៅ ហើយអធិប្បាយតាមចិត្តខ្លួននោះទេ តែទ្រង់ឲ្យពួកគាត់អធិប្បាយ តាមព្រះបន្ទូលរបស់ទ្រង់។ ដូច្នេះ គ្រូអធិប្បាយសព្វថ្ងៃនេះនៅតែ មានអំណាចក្នុងការអធិប្បាយពីព្រះជាម្ចាស់ដរាបណាពួកគាត់ អធិប្បាយតាមព្រះបន្ទូលរបស់ទ្រង់។

## លក្ខណៈនៃសេចក្ដីអធិប្បាយដែល មិនតាមអត្ថន័យព្រះគម្ពីរ

ប្រហែលជាមាននរណាម្នាក់ប្រកាសដោយរីករាយថា ព្រះបន្ទូល របស់ព្រះជាម្ចាស់មានអំណាច ហើយថែមទាំងប្រកាសទៀតថា ព្រះគម្ពីរក៏គ្មានកំហុសដែរ។ ក៏ប៉ុន្តែ ប្រសិនបើនៅក្នុងការអនុវត្ត ជាក់ស្ដែង ម្នាក់នោះមិនបានអធិប្បាយតាមអត្ថន័យព្រះគម្ពីរទេ (ដោយចេតនាក្ដី ឬដោយអចេតនាក្ដី) នោះមានន័យថា គាត់បដិ-

សេចការអះអាងរបស់គាត់ហើយ។

ពេលខ្លះ មនុស្សមួយចំនួនយល់ច្រឡំពីសេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរថា វាទាក់ទងទៅនឹងរបៀបរបស់គ្រូអធិប្បាយតែប៉ុណ្ណោះ។ ប៉ុន្តែ សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរមិនសូវទាក់ទងទៅនឹងរបៀបអធិប្បាយនោះទេ។ ដូចដែលមានអ្នកផ្សេងទៀតបានសង្កេតឃើញថា សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរមិនទាក់ទងប៉ុន្មានទៅនឹង*របៀបនៃការអធិប្បាយ*នោះទេ ប៉ុន្តែវាទាក់-ទងទៅនឹង*របៀបនៃការជ្រើសរើស*អ្វីដែលគ្រូអធិប្បាយត្រូវយកមកចែកចាយ។ តើព្រះគម្ពីរជាអ្នកកំណត់ខ្លឹមសារនៃសេចក្តីអធិប្បាយរបស់យើង ឬមានអ្វីផ្សេងទៀតជាអ្នកកំណត់? សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរមិនសម្គាល់ទៅលើរបៀបណាមួយនោះទេ។ របៀបចែកចាយមានលក្ខណៈខុសៗគ្នា ប៉ុន្តែសញ្ញាសម្គាល់របស់វាគឺថា វាជាសេចក្តីអធិប្បាយដែលទាក់ទងនឹងសេចក្តីពិតចេញពីព្រះគម្ពីរ។

មនុស្សមួយចំនួនយល់ច្រឡំពីសេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរជាមួយនឹងការអានព្រះគម្ពីរមួយខ ហើយបន្ទាប់មកអធិ-ប្បាយលើប្រធានបទមួយដែលទាក់ទងនឹងខគម្ពីរនោះតែបន្តិចបន្តួចប៉ុណ្ណោះ។ ប៉ុន្តែ នៅពេលដែលគ្រូអធិប្បាយយកប្រធានបទមួយទៅដាស់តឿនពួកជំនុំ ដោយជ្រើសរើសយកតែអត្ថបទគម្ពីរ

ដែលគាំទ្រគំនិតរបស់គាត់ នោះគាត់គ្រាន់តែអាចអធិប្បាយពីអ្វីដែលគាត់ដឹងរួចទៅហើយតែប៉ុណ្ណោះ។ ហើយពួកជំនុំគ្រាន់តែរៀនបាននូវអ្វីដែលគ្រូអធិប្បាយបានដឹងហើយតែប៉ុណ្ណោះ។ សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរមានសេចក្តីតម្រូវច្រើនលើសពីនោះទៅទៀត។ វាតម្រូវឲ្យមានការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នទៅលើបរិបទនៃអត្ថបទព្រះបន្ទូល ព្រោះគោលដៅនៃសេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរគឺ ធ្វើយ៉ាងណាឲ្យគោលគំនិតនៃអត្ថបទគម្ពីរទៅជាគោលគំនិតនៃការអធិប្បាយ។ នៅពេលដែលគ្រូអធិប្បាយដាស់តឿនពួកជំនុំដោយអធិប្បាយអត្ថបទមួយនៃព្រះគម្ពីរនៅក្នុងបរិបទរបស់វា (គោលគំនិតនៃអត្ថបទគម្ពីរ គឺជាគោលគំនិតនៃសេចក្តីអធិប្បាយរបស់គាត់) នោះទាំងគ្រូអធិប្បាយទាំងពួកជំនុំនឹងស្តាប់ឮសេចក្តីបង្រៀនពីព្រះជាម្ចាស់ ពីព្រោះពេលដែលគ្រូអធិប្បាយរៀបចំសេចក្តីអធិប្បាយគាត់មិនបានធ្វើតាមចិត្តគំនិតរបស់គាត់នោះទេ ប៉ុន្តែគាត់ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងព្រះបន្ទូលរបស់ទ្រង់វិញ។ គាត់មានបំណងនិយាយតាមតែអត្ថន័យព្រះគម្ពីរតែប៉ុណ្ណោះ។ ឧទាហរណ៍គាត់នឹងនិយាយថា “នៅសប្តាហ៍ក្រោយ យើងនឹងសិក្សានៅកណ្ឌលូកាជំពូក១ និងអ្វីដែលព្រះជាម្ចាស់មានសម្រាប់យើងនៅក្នុងកណ្ឌលូកាជំពូក១។ ហើយនៅសប្តាហ៍បន្ទាប់ទៀត យើងនឹងសិក្សានៅ

កណ្ឌលូកាជំពូក២ និងអ្វីដែលព្រះជាម្ចាស់មានសម្រាប់យើងនៅក្នុងកណ្ឌលូកាជំពូក២...។ល។»

របៀបនៃសេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ មិនខុសប្លែកពីដំណើរជីវិតជាគ្រីស្ទបរិស័ទរបស់យើងនោះទេ គឺចាប់តាំងពីព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យប្រែចិត្តដំបូង រហូតដល់ការដែលព្រះវិញ្ញាណបរិសុទ្ធបង្ហាញឲ្យយើងឃើញកំហុសរបស់យើងថ្មីៗនេះ។ គ្រប់ទាំងជំហាននៃការរីកចម្រើនរបស់យើងក្នុងព្រះគុណនៃព្រះជាម្ចាស់ គឺកើតឡើងនៅពេលដែលយើងបានឮអ្វីថ្មីៗពីព្រះជាម្ចាស់ដែលយើងមិនធ្លាប់បានស្ដាប់ឮពីមុនមក។

ព័ន្ធកិច្ចរបស់គ្រូអធិប្បាយត្រូវតែពោរពេញដោយការចុះចូលទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចរបៀបខាងលើនេះ។ ប៉ុន្តែសូមចងចាំថា ពួកជំនុំគឺជាអ្នកទទួលខុសត្រូវ ហើយត្រូវប្រាកដថា គ្រូអធិប្បាយរបស់ពួកគេពិតជាចុះចូលទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់មែន។ នៅក្នុងកណ្ឌម៉ាថាយជំពូក១៨ យើងឃើញថាព្រះយេស៊ូវក៏បានឯកភាពដែរថា ទំនួលខុសត្រូវនៃការសម្រេចចិត្តចុងក្រោយទៅលើអ្វីដែលកើតឡើងនៅក្នុងពួកជំនុំ ត្រូវធ្វើឡើងដោយ សមាជិកពួកជំនុំ។ ហើយលោក ប៉ុល ក៏ឯកភាពយ៉ាងដូច្នេះដែរ នៅក្នុងកណ្ឌកាឡាទីជំពូក១។ ដូច្នេះ ពួកជំនុំមិនត្រូវអនុញ្ញាតឲ្យនរណាម្នាក់មើលការខុសត្រូវលើជីវិតខាងឯវិញ្ញាណរបស់ខ្លួននោះ

ទេ ខណៈដែលម្នាក់នោះមិនបានបង្ហាញពីការប្តេជ្ញាក្នុងការស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងបង្រៀនព្រះបន្ទូលរបស់ទ្រង់សោះ។ បើដូច្នោះ វានឹងរាំងស្ទះដល់ការរីកចម្រើនរបស់ពួកគេជាមិនខាន។ វាប្រាកដណាស់ថា ពួកជំនុំនឹងមិនចម្រើនវ័យខាងឯវិញ្ញាណឲ្យលើសហួសពីវ័យខាងឯវិញ្ញាណរបស់គ្រូគង្វាលនោះទេ។ ហើយមិនយូរមិនឆាប់ ពួកជំនុំនឹងមានទំនោរទៅរកលក្ខណសម្បត្តិរបស់គ្រូគង្វាលនោះ ជាជាងទៅរករូបអង្គនៃព្រះជាម្ចាស់ជាក់ជាមិនខាន។

## របៀបដែលព្រះជាម្ចាស់តែងតែធ្វើការ

ព្រះជាម្ចាស់តែងតែបង្កើតរាស្ត្ររបស់ទ្រង់មកតាមរយៈព្រះបន្ទូលរបស់ព្រះអង្គ។ ចាប់តាំងពីការបង្កបង្កើតដំបូងនៅក្នុងលោកុប្បត្តិជំពូក១រហូតដល់ការត្រាស់ហៅលោក អាប់រ៉ាម នៅកណ្តាលោកុប្បត្តិជំពូក១២ យើងឃើញថា ព្រះជាម្ចាស់តែងតែបង្កើតរាស្ត្ររបស់ទ្រង់តាមរយៈព្រះបន្ទូលរបស់ទ្រង់។ ហើយចាប់តាំងពីការបើកសម្តែងឲ្យឃើញឆ្អឹងស្ងួតហែងនៅច្រកភ្នំនៅកណ្តាអេសេគាលជំពូក៣៧ រហូតដល់ការយាងមកនៃព្រះបន្ទូលដ៏រស់ គឺជាព្រះយេស៊ូវគ្រីស្ទ យើងក៏ឃើញដែរថា ព្រះជាម្ចាស់តែងតែបង្កើតរាស្ត្ររបស់ទ្រង់ដោយព្រះបន្ទូលរបស់ទ្រង់។ ដូចដែលលោក ប៉ុល បានសរសេរទៅកាន់ពួកជំនុំទីក្រុងរ៉ូមថា “ដូច្នេះ ជំនឿកើតឡើងដោយសេចក្តីដែលបាន

ឮ ហើយសេចក្ដីដែលបានឮនោះ គឺដោយសារព្រះបន្ទូលរបស់ព្រះគ្រីស្ទ» (រ៉ូម ១០:១៧ គកស)។ ឬដូចដែលលោកបានសរសេរទៅកាន់ពួកជំនុំទីក្រុងកូរិនថូសថា៖ «ដ្បិតដោយព្រោះព្រះទ្រង់បានសំរេចតាមប្រាជ្ញានៃទ្រង់ថា មនុស្សលោកនឹងរកស្គាល់ព្រះដោយអាងប្រាជ្ញាខ្លួនមិនបានទេ បានជាទ្រង់សព្វព្រះហឫទ័យនឹងជួយសង្គ្រោះអស់អ្នកដែលជឿ ដោយសារសេចក្ដីល្ងង់ល្ងើវិញ គឺជាការប្រកាសដំណឹងល្អ» (១កូរិនថូស ១:២១)។

ជាទូទៅ សេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ គឺជាប្រភពនៃការរីកចម្រើនដ៏ពិតប្រាកដនៅក្នុងពួកជំនុំ។ លោក ម៉ាទីន លូសើរ (Martin Luther) យល់ឃើញថា ការអធិប្បាយ ឬការសិក្សាព្រះបន្ទូលយ៉ាងប្រុងប្រយ័ត្ន គឺជាចំណុចចាប់ផ្ដើមនៃការបំផ្លាស់បំប្រែមនុស្ស និងសង្គមជាតិ។ ដូចគ្នានេះដែរ យើងត្រូវតែប្ដេជ្ញាដើម្បីឲ្យឃើញប្រាកដថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់កំពុងតែបំផ្លាស់បំប្រែពួកជំនុំរបស់យើង។

## ការវិលបែរទៅរកអត្ថន័យពិតនៃការថ្វាយបង្គំឡើងវិញ

ខ្ញុំបានទៅបង្រៀនវគ្គសិក្ខាសាលាមួយពេញមួយថ្ងៃ ស្ដីអំពីពួកព្យួរីតិននិយម (Puritanism) នៅឯពួកជំនុំមួយនៅទីក្រុងឡុងដ៍។ នៅអំឡុងពេលសិក្ខាសាលានោះ ខ្ញុំបានលើកឡើងត្រង់ចំណុច

មួយថា ពួកព្យូរីតិន (Puritan) បានចំណាយពេលប្រមាណជាពីរម៉ោង ដើម្បីស្ដាប់ការអធិប្បាយ។ សមាជិកនៅក្នុងថ្នាក់នោះបានចំហមាត់ដោយការភ្ញាក់ផ្អើល ហើយគាត់សួរខ្ញុំថា “តើគេទុកពេលប៉ុន្មានសម្រាប់ថ្វាយបង្គំ?”។ ច្បាស់ណាស់ថា គាត់យល់ច្រឡំថា ការស្ដាប់សេចក្ដីអធិប្បាយមិនរាប់ថាជាការថ្វាយបង្គំនោះទេ។ ខ្ញុំបានឆ្លើយតបវិញថា ពួកជំនុំប្រូតេស្តង់ជនជាតិអង់គ្លេសជាច្រើននាក់នៅសតវត្សមុនបានជឿថា ផ្នែកដែលចាំបាច់បំផុតនៃការថ្វាយបង្គំគឺ *ការឮ*ព្រះបន្ទូលព្រះជាម្ចាស់ជាភាសាដើមរបស់ពួកគេ និង*ការឆ្លើយតប*ទៅនឹងព្រះបន្ទូលនោះនៅក្នុងជីវិតរបស់ពួកគេ។ សូមចងចាំថា មានមនុស្សជាច្រើនបានពលីជីវិត ដើម្បីប្រកាសព្រះបន្ទូល។ ការច្រៀងចម្រៀង គឺមិនសំខាន់ចំពោះពួកគេដូចការស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះទេ។

ដូចគ្នានេះដែរ ពួកជំនុំរបស់យើងត្រូវតែស្ដារការយកព្រះបន្ទូលជាអាទិភាពចម្បងនៅពេលយើងថ្វាយបង្គំ។ តន្ត្រីគឺជាការឆ្លើយតបមួយទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលជាការតម្រូវតាមព្រះគម្ពីរដែរ ប៉ុន្តែតន្ត្រីដែលព្រះជាម្ចាស់បានប្រទានឲ្យយើង គឺទ្រង់មិនប្រទានមកដើម្បីឲ្យយើងសង់ពួកជំនុំលើនោះទេ។ ពួកជំនុំដែលយកតន្ត្រីជាអាទិភាពចម្បង ប្រៀបបានទៅនឹងផ្ទះដែលគេសង់ឡើងលើខ្សាច់ដែលងាយនឹងរលំ។

អ្នកជឿរាល់គ្នាអើយ! សូមអធិស្ឋានឲ្យគ្រូគង្វាលលោកអ្នកឲ្យប្ដេជ្ញាចិត្ត ដើម្បីនឹងសិក្សាព្រះគម្ពីរយ៉ាងហ្មត់ចត់ យ៉ាងប្រុងប្រយ័ត្ន និងយ៉ាងអស់ពីចិត្ត។ សូមអធិស្ឋានទូលសុំព្រះជាម្ចាស់ឲ្យដឹកនាំគាត់យល់ពីព្រះបន្ទូលទ្រង់ ហើយអនុវត្តព្រះបន្ទូលនោះនៅក្នុងជីវិតរបស់គាត់ ព្រមទាំងចេះបង្រៀនឲ្យពួកជំនុំយកព្រះបន្ទូលនោះទៅអនុវត្តផងដែរ (ចូរមើល លូកា ២៤:២៧; កិច្ចការ ៦:៤; អេភេសូរ ៦:១៩-២០)។ មិនតែប៉ុណ្ណោះ សូមទុកពេលវេលាសម្រាប់គ្រូគង្វាលរបស់លោកអ្នកឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យគាត់មានពេលវេលាល្មមក្នុងការរៀបចំសេចក្ដីអធិប្បាយឲ្យបានល្អ។ សេចក្ដីអធិប្បាយជាមូលដ្ឋានគ្រឹះនៃការដឹកនាំពួកជំនុំ។ ដូច្នេះ សូមលើកទឹកចិត្តគ្រូគង្វាលរបស់លោកអ្នកដោយប្រាប់គាត់ថា ការដែលគាត់ស្មោះត្រង់ទៅនឹងព្រះបន្ទូលបានធ្វើឲ្យលោកអ្នករីកចម្រើនខាងឯវិញ្ញាណ។

គ្រូគង្វាលរាល់គ្នាអើយ! សូមអធិស្ឋានពីការនេះសម្រាប់ខ្លួនឯងដែរ។ សូមអធិស្ឋានសម្រាប់ពួកជំនុំដែលនៅជិតៗលោកអ្នក នៅក្នុងទីក្រុងរបស់លោកអ្នក នៅក្នុងប្រទេសជាតិលោកអ្នក និងពួកជំនុំនៅជុំវិញពិភពលោកទាំងមូល ឲ្យពួកគេខំអធិប្បាយ និងបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងដែរ។ ជាទីបញ្ចប់ សូមអធិស្ឋានឲ្យពួកជំនុំរបស់យើងប្ដេជ្ញាដោយយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូល

របស់ព្រះជាម្ចាស់ដែលគ្រូគង្វាលអធិប្បាយតាមអត្ថន័យព្រះគម្ពីរ ដើម្បីឲ្យព្រះជាម្ចាស់កែតម្រង់របៀបវារៈរបស់ពួកជំនុំនីមួយៗកាន់តែច្រើនឡើងទៅតាមរបៀបវារៈរបស់ទ្រង់នៅក្នុងព្រះគម្ពីរ។ ការប្ដេជ្ញាក្នុងការអធិប្បាយតាមអត្ថន័យព្រះគម្ពីរ គឺជាសញ្ញាសម្គាល់ដ៏ចាំបាច់មួយនៃពួកជំនុំដែលមានសុខភាពល្អ។

ជំពូក៦

# សញ្ញាសម្គាល់ដ៏ចាំបាច់នៃពួកជំនុំដែលមានសុខភាពល្អ៖ ទេវវិទ្យាតាមព្រះគម្ពីរ

**តើលោកអ្នកគិតថា** ពាក្យដែលមានអក្សរទ្រេតទាំងនេះមានន័យដូចម្ដេច៖ “ប៉ុន្តែ យើងដឹងថា កាលណាទ្រង់លេចមក *នោះយើងនឹងបានដូចជាទ្រង់* ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង” (១យ៉ូហាន ៣:២)។

ប្រសិនបើលោកអ្នកបានអានសាច់រឿងនៅក្នុងកណ្ឌគម្ពីរយ៉ូហានទី១ជំពូក៣ យ៉ាងយកចិត្តទុកដាក់ នោះលោកអ្នកប្រហែលជានឹងឃើញថា ពាក្យទាំងនេះចង្អុលបង្ហាញពីរបៀបដែលពួកជំនុំនឹងឆ្លុះបញ្ចាំងពីចរិតលក្ខណៈដ៏បរិសុទ្ធ និងពេញដោយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ដែលមិនស្ថិតក្រោមឥទ្ធិពលបាបទៀតឡើយ នៅគ្រាចុងក្រោយ។

ពួកមរមន (Mormons) កាត់ស្រាយឃ្លា "យើងនឹងបានដូចជាទ្រង់" ឲ្យមានន័យថា "យើងទាំងអស់គ្នានឹងក្លាយជាព្រះ"។

តើមានអ្វីខុសប្លែកគ្នារវាងការកាត់ស្រាយទាំងពីរនេះ? ការកាត់ស្រាយមួយគឺពឹងផ្អែកលើទេវវិទ្យាតាមព្រះគម្ពីរទាំងស្រុង ប៉ុន្តែការកាត់ស្រាយមួយទៀតគឺមិនពឹងផ្អែកលើទេវវិទ្យាតាមព្រះគម្ពីរនោះទេ។

នៅក្នុងជំពូកមុន យើងបាននិយាយថា សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ គឺចាំបាច់ណាស់សម្រាប់សុខភាពពួកជំនុំ។ ប៉ុន្តែគ្រប់ទាំងវិធីសាស្ត្រទាំងអស់ ទោះបើវាល្អក៏ដោយ ក៏នៅតែមានគេយកវាទៅប្រើក្នុងរបៀបខុសឆ្គងដែរ។ ពួកជំនុំរបស់យើងមិនគួរយកចិត្តទុកដាក់តែពី*របៀប*ដែលគ្រូបង្រៀនយើងប៉ុណ្ណោះទេ ប៉ុន្តែយើងក៏គួរតែយកចិត្តទុកដាក់ពី*អ្វី*ដែលគាត់បង្រៀនយើងដែរ។ ដូច្នោះហើយបានជាសញ្ញាសម្គាល់ដ៏ចាំបាច់ទីពីរនៃពួកជំនុំដែលមានសុខភាពល្អ គឺទេវវិទ្យាតាមព្រះគម្ពីរ។ បើមិនដូច្នោះទេ យើងនឹងកាត់ស្រាយខគម្ពីរនីមួយៗទៅតាមអ្វីដែលយើងចង់បានហើយ។

## ភាពត្រឹមត្រូវ

យើងគួរតែស្រឡាញ់ភាពត្រឹមត្រូវ គឺភាពត្រឹមត្រូវក្នុងការដែលយើងយល់ពីព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរ និងរបៀបដែលទ្រង់មានទំ-

នាក់ទំនងជាមួយនឹងយើង។ លោក ប៉ុល ប្រើពាក្យ “ត្រឹមត្រូវ” ច្រើនដងក្នុងសំបុត្ររបស់លោកទៅកាន់លោក ធីម៉ូថេ និងលោក ទីតុស។ ពាក្យនេះមានន័យថា “មិនមានកំហុស” “អាចទុកចិត្តបាន” និងពេញដោយ “ភាពស្មោះត្រង់”។ ពាក្យឫសក្នុងភាសាដើមទាក់ទងនឹងពាក្យខាងឱសថសាស្ត្រដែលមានន័យថា ភាពពេញដោយកម្លាំង និងសុខភាពល្អ។ ដូច្នេះ ទេវវិទ្យាដែលត្រឹមត្រូវតាមព្រះគម្ពីរ គឺជាទេវវិទ្យាដែលស្មោះត្រង់ទៅនឹងសេចក្ដីបង្រៀននៃព្រះគម្ពីរទាំងមូល។ ហើយក៏ជាទេវវិទ្យាដែលកាត់ស្រាយខគម្ពីរនីមួយៗស្របតាមសាច់រឿងនៃព្រះគម្ពីរទាំងមូលយ៉ាងត្រឹមត្រូវ ហើយអាចទុកចិត្តបាន។

នៅក្នុងសំបុត្រទីមួយរបស់លោក ប៉ុល ទៅកាន់លោក ធីម៉ូថេ លោកលើកឡើងថា “សេចក្ដីបង្រៀនដ៏*ត្រឹមត្រូវ*” គឺជាសេចក្ដីបង្រៀនដែលតាមដំណឹងល្អ ហើយទាស់នឹងពួកទមិឡល្មើស និងពួកដែលមានបាប (១ធីម៉ូថេ ១:១០-១១)។ ក្រោយមកទៀត លោក ប៉ុល បានប្រៀបធៀបសេចក្ដីបង្រៀនក្លែងក្លាយជាមួយនឹង “ពាក្យសំដីដែល*ត្រឹមត្រូវ* គឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង និងជាសេចក្ដីបង្រៀនដែលត្រឹមត្រូវ តាមសេចក្ដីគោរពប្រតិបត្តិដល់ព្រះ” (១ធីម៉ូថេ ៦:៣)។

នៅក្នុងសំបុត្រទីពីររបស់លោកទៅកាន់លោក ធីម៉ូថេ លោក

ប៉ុល បានដាស់តឿនគាត់ថា៖ «ចូរកាន់តាមពាក្យដ៏*ត្រឹមត្រូវ*ដែលអ្នកបានឮពីខ្ញុំ ដោយជំនឿ និងសេចក្តីស្រឡាញ់ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ» (២ធីម៉ូថេ ១:១៣ គកស)។ បន្ទាប់មក លោកបានដាស់តឿនលោក ធីម៉ូថេ ទៀតថា៖ «ដ្បិតនឹងមានគ្រាមក ដែលគេមិនទ្រាំទ្រនឹងសេចក្ដីបង្រៀនដ៏*ត្រឹមត្រូវ*ទេ គឺគេនឹងមានត្រចៀករមាស់ ហើយនិងហៅគ្រូកាន់តែច្រើនឡើង មកបង្រៀនឲ្យត្រូវចិត្ត» (២ធីម៉ូថេ ៤:៣)។

នៅពេលដែលលោក ប៉ុល សរសេរទៅកាន់គ្រូគង្វាលវ័យក្មេងម្នាក់ទៀត គឺលោក ទីតុស លោកបានចែកចាយនូវក្តីបារម្ភស្រដៀងគ្នានេះដែរ។ លោក ប៉ុល លើកឡើងថា គ្រប់ទាំងមនុស្សដែលលោកទីតុស តែងតាំងឲ្យធ្វើជាចាស់ទុំក្នុងពួកជំនុំ គេត្រូវតែ «កាន់ខ្ជាប់តាមព្រះបន្ទូលដ៏ពិត ដូចជាបានបង្រៀនមកយើងហើយ ដើម្បីឲ្យអាចនឹងកំសាន្តចិត្តគេ ដោយសេចក្តីបង្រៀនដ៏*ត្រឹមត្រូវ* ហើយឲ្យបានផ្ចាញ់ដល់ពួកអ្នកដែលស្រដីទទឹង» (ទីតុស ១:៩)។ លោកត្រូវតែស្តីបន្ទោសដល់ពួកគ្រូក្លែងក្លាយ «ដើម្បីឲ្យគេមានជំនឿ*ត្រឹមត្រូវ*វិញ» (ទីតុស ១:១៣ គកស)។ លោក ទីតុស ត្រូវតែ «និយាយតែសេចក្តីណា ដែលសំណាំនឹងសេចក្តីបង្រៀនដ៏*ត្រឹមត្រូវ*» (ទីតុស ២:១)។

គ្រូគង្វាលគួរតែបង្រៀនសេចក្តីបង្រៀនណាដែលត្រឹមត្រូវ គឺបង្រៀនសេចក្តីបង្រៀនណាដែលអាចទុកចិត្តបាន ត្រឹមត្រូវ ហើយ

ស្មោះត្រង់ទៅនឹងព្រះគម្ពីរ។ ហើយពួកជំនុំត្រូវទទួលខុសត្រូវក្នុងការជួយប្រាប់ដល់គ្រូគង្វាលរបស់ខ្លួនឲ្យបង្រៀនសេចក្ដីបង្រៀនដែលត្រឹមត្រូវ។

## ភាពរួបរួម ភាពខុសគ្នា និងសេចក្ដីស្រឡាញ់

យើងនឹងមិនលាតត្រដាងពីសេចក្ដីបង្រៀនដ៏ត្រឹមត្រូវនៅជំពូកនេះនោះទេ ដ្បិតបើយើងធ្វើដូចនេះ យើងនឹងត្រូវនិយាយអំពីព្រះគម្ពីរទាំងមូលឡើងវិញ។ ប៉ុន្ដែនៅក្នុងការអនុវត្តជាក់ស្ដែង ពួកជំនុំត្រូវសម្រេចថា តើមានចំណុចត្រង់ណាខ្លះដែលពួកជំនុំត្រូវឯកភាពគ្នា ចំណុចត្រង់ណាដែលពួកជំនុំអាចអនុញ្ញាតឲ្យមានភាពមិនចុះសម្រុងគ្នា ហើយនៅចំណុចត្រង់ណាខ្លះទៀតដែលពួកជំនុំអាចអនុញ្ញាតឲ្យមានសេរីភាពពេញលេញបាន។

នៅក្នុងពួកជំនុំដែលខ្ញុំបម្រើនៅឯរដ្ឋធានី វ៉ាស៊ីនតោនឌីស៊ី យើងតម្រូវឲ្យសមាជិកគ្រប់គ្នាជឿថា ពួកគេបានសេចក្ដីសង្រ្គោះតាមរយៈព្រះយេស៊ូវគ្រីស្ទតែមួយប៉ុណ្ណោះ។ យើងក៏ជឿផងដែរថា យើងយល់ដូចគ្នាទៅលើពិធីបុណ្យជ្រមុជទឹករបស់អ្នកជឿ (ឬស្រដៀងគ្នា) ហើយយើងក៏មានការយល់ដឹងដូចគ្នា (ឬស្រដៀងគ្នា) ពីរចនា-សម្ព័ន្ធរបស់ពួកជំនុំ (មានន័យថានរណាមានសិទ្ធិធ្វើសេចក្ដីសម្រេចចុងក្រោយ)។ ការឯកភាពគ្នាលើរបៀបធ្វើពិធីបុណ្យជ្រមុជទឹក និង

រចនាសម្ព័ន្ធរបស់ពួកជំនុំ វាមិនមែនជាការចាំបាច់ដែលទាក់ទងនឹងសេចក្តីសង្គ្រោះនោះទេ ប៉ុន្តែការឯកភាពលើការនោះអាចជួយហើយអាចធ្វើឲ្យជីវិតពួកជំនុំមានសុខភាពល្អបាន។

ប៉ុន្តែ ពួកជំនុំរបស់យើងអនុញ្ញាតឲ្យមានគំនិតខុសៗគ្នាលើចំណុចខ្លះៗដែលទាក់ទងនឹងសេចក្តីបង្រៀនក្នុងព្រះគម្ពីរដែលមិនមែនជាចំណុចចាំបាច់ក្នុងការទទួលសេចក្តីសង្គ្រោះ និងជីវិតប្រចាំថ្ងៃរបស់ពួកជំនុំ។ ឧទាហរណ៍ យើងទាំងអស់គ្នាឯកភាពថាព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញ ប៉ុន្តែមានទស្សនៈខុសៗគ្នាជាច្រើនពីការយាងត្រឡប់មកវិញរបស់ទ្រង់។

ចុងក្រោយ ពួកជំនុំរបស់យើងអនុញ្ញាតឲ្យមានសេរីភាពពេញទីលើចំណុចដែលព្រះគម្ពីរមិនបានលើកឡើងចំៗ ឬមិនមែនជាចំណុចស្នូល ដូចជាការដែលប្រជាជនមានសិទ្ធិប្រើប្រាស់អាវុធដើម្បីការពារខ្លួន ឬសំណួរថា តើនរណាសរសេរកណ្ឌហេព្រើរជាដើម។

មានគោលការណ៍មួយនៅក្នុងការទាំងអស់នេះ៖ បើកាលណាយើងចូលកាន់តែកៀកចំណុចស្នូលនៃជំនឿរបស់យើង នោះយើងរំពឹងចង់បានភាពរួបរួមកាន់តែខ្លាំងឡើងនៅក្នុងការយល់ដឹងពីជំនឿរបស់យើង គឺរំពឹងចង់បានភាពរួបរួមនៅក្នុងសេចក្តីបង្រៀនតាមព្រះគម្ពីរដ៏ត្រឹមត្រូវ។ ពួកជំនុំជំនាន់ដើមនិយាយដូច្នេះថា៖ ក្នុង

សេចក្តីបង្រៀនដ៏ចាំបាច់ ត្រូវតែមានជំនឿរួមមួយ ហើយក្នុងសេចក្តីបង្រៀនដែលមិនចាំបាច់ នោះយើងអាចជឿខុសៗគ្នា ហើយក្នុងគ្រប់ការទាំងអស់ ត្រូវមានសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក។

## សេចក្តីបង្រៀនដ៏ស្មុគស្មាញ ឬដ៏ចម្រូងចម្រាស

ពួកជំនុំដែលមានការប្តេជ្ញាទៅនឹងសេចក្តីបង្រៀនដ៏ត្រឹមត្រូវ នឹងប្តេជ្ញាបង្រៀនសេចក្តីបង្រៀនតាមព្រះគម្ពីរដែលពួកជំនុំជាច្រើនមិនបង្រៀន។ ចំពោះយើង សេចក្តីបង្រៀនមួយចំនួនប្រហែលជាមើលទៅដូចជាពិបាក ឬមើលទៅដូចជាធ្វើឲ្យពួកជំនុំបែកបាក់ ប៉ុន្តែ យើងអាចទុកចិត្តបានថា ព្រះជាម្ចាស់បានរួមបញ្ចូលសេចក្តីបង្រៀនទាំងនោះនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ដោយព្រោះសេចក្តីបង្រៀនទាំងនោះជាមូលដ្ឋានគ្រឹះ ដើម្បីយល់ពីកិច្ចការរបស់ទ្រង់ក្នុងការសង្គ្រោះ។

ព្រះវិញ្ញាណបរិសុទ្ធមិនមែនល្ងង់ទេ។ ប្រសិនបើទ្រង់បើកសម្តែងអ្វីមួយនៅក្នុងព្រះគម្ពីររបស់ទ្រង់សម្រាប់លោកីយ៍ទាំងមូលអាន ហើយពួកជំនុំគិតថា មិនគួរបង្រៀនសេចក្តីនោះទេ នោះមានន័យថា ពួកគេរាប់ខ្លួនឯងថា មានជាអ្នកប្រាជ្ញាជាងព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលនិយាយអំពីប្រធានបទដែលពិបាកទទួល តើពួកគេគួរតែប្រើប្រាជ្ញាដោយប្រុងប្រយ័ត្នក្នុងនាមជាគ្រូគង្វាលដែរឬទេ? ពិតប្រា-

កដណាស់ ពួកគេគួរតែប្រើ។ តើពួកគេមិនគួរបង្រៀនពីប្រធានបទដ៏ពិបាកនោះទាំងស្រុងឬ? ទេ មិនដូចនោះទេ។ ប្រសិនបើយើងចង់បានពួកជំនុំដែលដឹកនាំដោយសេចក្តីបង្រៀនត្រឹមត្រូវពីព្រះគម្ពីរ នោះយើងត្រូវតែបង្រៀនសេចក្តីទាំងអស់ដែលមាននៅក្នុងព្រះគម្ពីរ។

ឧទាហរណ៍ គេមិនបង្រៀនពីការរើសតាំងរបស់ព្រះជាម្ចាស់តាមព្រះគម្ពីរ ដោយព្រោះគេលើកឡើងថា សេចក្តីបង្រៀននេះស្មុគស្មាញ ហើយងាយនឹងភាន់ច្រឡំណាស់។ ទោះបីសេចក្តីបង្រៀននោះស្មុគស្មាញ ឬងាយនឹងភាន់ច្រឡំក៏ដោយ តែសេចក្តីបង្រៀននោះគឺស្របតាមព្រះគម្ពីរយ៉ាងពិតប្រាកដមែន។ ទោះបីជាយើងមិនយល់ពីសេចក្តីបង្រៀននៃការរើសតាំងរបស់ព្រះជាម្ចាស់ទាំងស្រុងក៏ដោយ ក៏យើងត្រូវតែចាំថា វាមានសារៈសំខាន់ណាស់ ព្រោះសេចក្តីសង្គ្រោះរបស់យើងគឺមកពីព្រះជាម្ចាស់ទាំងស្រុង មិនមែនមកពីខ្លួនយើងនោះទេ។ មានសំណួរសំខាន់ៗមួយចំនួនដែលព្រះគម្ពីរផ្តល់ចម្លើយឲ្យ ប៉ុន្តែជារឿយៗ ពួកជំនុំមើលរំលងដូចជា៖

- តើមនុស្សយើងជាមនុស្សល្អ ឬជាមនុស្សអាក្រក់? តើពួកគេគ្រាន់តែត្រូវការការលើកទឹកចិត្ត និងការលើកតម្កើងខ្លួនឯង ឬក៏ពួកគេត្រូវការការអត់ទោស និងជីវិតថ្មី?
- តើព្រះយេស៊ូវបានសម្រេចអ្វីខ្លះ តាមរយៈការសុគតនៅលើឈើឆ្កាង? តើទ្រង់ពិតជាបានបំពេញគ្រប់លក្ខខណ្ឌទៅនឹងសេចក្តី

ក្រោចដ៏យុត្តិធម៌របស់ព្រះវរបិតាហើយឬនៅ ឬមួយទ្រង់គ្រាន់តែធ្វើជាគំរូពីការពលីខ្លួនឯងសម្រាប់អ្នកដើរតាមទ្រង់តែប៉ុណ្ណោះទេឬ?

- តើមានអ្វីកើតឡើងនៅពេលដែលនរណាម្នាក់ប្រែចិត្ត ហើយជឿលើព្រះគ្រីស្ទ?
- ប្រសិនបើយើងជាគ្រីស្ទបរិស័ទពិតមែន តើយើងអាចដឹងប្រាកដទេថា ព្រះជាម្ចាស់នឹងបន្តយកព្រះទ័យទុកដាក់ចំពោះយើង? ប្រសិនបើដូច្នោះមែន តើទ្រង់បន្តយកព្រះទ័យទុកដាក់ចំពោះយើងដោយពឹងផ្អែកលើភាពស្មោះត្រង់របស់យើង ឬពឹងផ្អែកលើភាពស្មោះត្រង់របស់ទ្រង់?

សំណួរទាំងអស់នេះ មិនមែនសម្រាប់តែអ្នកប្រាជ្ញខាងឯព្រះគម្ពីរដែលចូលចិត្តសៀវភៅ ឬសម្រាប់សិស្សសាលាព្រះគម្ពីរថ្មីថ្មោងនោះទេ។ សំណួរទាំងអស់នេះ គឺសំខាន់សម្រាប់គ្រីស្ទ-បរិស័ទគ្រប់រូប។ ពួកយើងដែលជាគ្រូគង្វាលដឹងថា របៀបនៃការដឹកនាំពួកជំនុំរបស់យើងនឹងមានការខុសប្លែកខ្លាំង ប្រសិនបើចម្លើយរបស់យើងទៅនឹងសំណួរណាមួយខាងលើមានការប្រែប្រួលនោះ។ ភាពស្មោះត្រង់ចំពោះព្រះបន្ទូលទាមទារឲ្យយើងបង្រៀនអំពីចំណុចទាំងនេះឲ្យបានច្បាស់លាស់ និងពេញដោយអំណាច។ ភាពស្មោះត្រង់ចំពោះព្រះបន្ទូល និងបំណងចិត្តក្នុងការបង្ហាញឲ្យមនុស្សលោកឃើញនូវចរិតលក្ខណៈរបស់ព្រះជាម្ចាស់ នោះ

ទាមទារឲ្យយើងបង្រៀនអំពីចំណុចទាំងនេះឲ្យបានច្បាស់លាស់ និងពេញដោយអំណាច។

សូមពិចារណា៖ ប្រសិនបើយើងចង់បានពួកជំនុំដែលបង្ហាញឲ្យមនុស្សលោកឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ តើយើងមិនចង់ដឹងគ្រប់ទាំងអ្វីដែលទ្រង់បានបើកសម្ដែងឲ្យឃើញអំពីអង្គទ្រង់នៅក្នុងព្រះគម្ពីរទេឬអី? ប្រសិនបើយើងមិនចង់ដឹងទេ តើការនោះបង្ហាញពីទស្សនៈរបស់យើងចំពោះចរិតលក្ខណៈរបស់ទ្រង់យ៉ាងដូចម្ដេច?

## ការប្រឆាំងនឹងអធិបតេយ្យរបស់ព្រះជាម្ចាស់

ការដែលយើងយល់ដឹង ពីអ្វីដែលព្រះគម្ពីរបានបង្រៀនអំពីព្រះជាម្ចាស់មានសារៈសំខាន់ណាស់។ នៅក្នុងព្រះគម្ពីរបានចែងថាព្រះជាម្ចាស់ជាព្រះអាទិករ និងជាព្រះដ៏ជាម្ចាស់។ ប៉ុន្តែពេលខ្លះមនុស្សបដិសេធអធិបតេយ្យរបស់ទ្រង់ ហើយសូម្បីតែនៅក្នុងពួកជំនុំក៏ដូច្នោះដែរ។ នៅពេលដែលពួកអ្នកដែលអះអាងថា ខ្លួនជាគ្រីស្ទបរិស័ទ ប៉ុន្តែពួកគេប្រឆាំងនឹងអធិបតេយ្យរបស់ព្រះជាម្ចាស់នៅក្នុងការបង្កើត ឬក្នុងការសង្គ្រោះ នោះពួកគេកំពុងតែបដិសេធទ្រង់ ហើយបែរទៅថ្វាយបង្គំរូបព្រះផ្សេងៗវិញ ទាំងអួតពីការនោះទៀតផង។ គ្រីស្ទបរិស័ទប្រាកដជានឹងសួរសំណួរទាក់ទងនឹងអធិបតេយ្យរបស់

ព្រះជាម្ចាស់។ ក៏ប៉ុន្តែការដែលបុគ្គលណាម្នាក់បដិសេធយ៉ាងដាច់អហង្ការមិនចេះចប់ចេះហើយពីអធិបតេយ្យរបស់ព្រះជាម្ចាស់ វាគឺជាការដែលយើងគួរបារម្ភ។ បើយើងធ្វើពិធីបុណ្យជ្រមុជទឹកឲ្យមនុស្សបែបហ្នឹង នោះមានន័យថា យើងកំពុងតែធ្វើពិធីបុណ្យជ្រមុជទឹកឲ្យមនុស្សដែលមិនទាន់ជឿទាំងស្រុងទៅលើព្រះជាម្ចាស់ហើយ។ បើយើងរាប់បញ្ចូលមនុស្សបែបហ្នឹងនៅក្នុងសមាជិកភាព នោះមានន័យថា យើងរាប់បុគ្គលនោះដូចជាគាត់កំពុងតែទុកចិត្តលើព្រះជាម្ចាស់ ប៉ុន្តែតាមពិតទៅ គាត់អត់ទុកចិត្តលើទ្រង់សោះ។

ការប្រឆាំងបែបនេះ វាគ្រោះថ្នាក់ណាស់សម្រាប់គ្រីស្ទបរិស័ទគ្រប់រូប ប៉ុន្តែវាកាន់តែគ្រោះថ្នាក់ជាងនោះទៅទៀតចំពោះអ្នកដឹកនាំពួកជំនុំ។ នៅពេលដែលពួកជំនុំតែងតាំងអ្នកដឹកនាំដែលសង្ស័យពីអធិបតេយ្យរបស់ព្រះជាម្ចាស់ ឬតែងតាំងអ្នកដឹកនាំដែលយល់ខុសពីសេចក្តីបង្រៀនរបស់ព្រះគម្ពីរ នោះពួកជំនុំបានយកគំរូពីអ្នកដឹកនាំដែលមិនមានបំណងនឹងទុកចិត្តព្រះជាម្ចាស់ហើយ។ ហើយគាត់នឹងក្លាយជាឧបសគ្គដល់ការរីកចម្រើនរបស់ពួកជំនុំនោះ។

សព្វថ្ងៃនេះ នៅក្នុងប្រទេសលោកខាងលិច វប្បធម៌សម្ភារៈនិយមជំរុញឲ្យពួកជំនុំយល់ច្រឡំពី កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធថាជាការផ្សព្វផ្សាយទីផ្សារ ហើយពួកគេបង្វែរការផ្សាយដំណឹងល្អទៅជាការផ្សាយពាណិជ្ជកម្មវិញ។ មនុស្សបានធ្វើឲ្យសេចក្តីពិត

នៃភាពជាព្រះរបស់ព្រះជាម្ចាស់ខូច ហើយពួកគេបានរាប់ទ្រង់ដូចជាមនុស្សវិញ។ នៅក្នុងសម័យកាលបែបនេះ ពួកជំនុំដែលមានសុខភាពល្អត្រូវតែអធិស្ឋានឲ្យអ្នកដឹកនាំរបស់ខ្លួនយល់ពីអធិបតេយ្យរបស់ព្រះជាម្ចាស់តាមរយៈព្រះគម្ពីរ និងតាមបទពិសោធន៍ផ្ទាល់ខ្លួន។ ពួកជំនុំក៏គួរតែអធិស្ឋានផងដែរឲ្យអ្នកដឹកនាំរបស់ពួកគេរក្សានូវការប្ដេជ្ញាយ៉ាងពេញទំហឹងទៅនឹងសេចក្ដីបង្រៀនដ៏ត្រឹមត្រូវពេញលេញតាមព្រះគម្ពីរ។ គេអាចសម្គាល់ពួកជំនុំដែលមានសុខភាពល្អតាមរយៈសេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ និងតាមរយៈទេវវិទ្យាតាមព្រះគម្ពីរ។

ជំពូក៧

# សញ្ញាសម្គាល់ដ៏ចាំបាច់នៃពួកជំនុំដែលមានសុខភាពល្អ៖ ការយល់ពីដំណឹងល្អតាមព្រះគម្ពីរ

**ពួកជំនុំរបស់យើង**ត្រូវតែមានភាពរឹងមាំទៅនឹងផ្នែកដ៏ពិសេសមួយនៃទេវវិទ្យាតាមព្រះគម្ពីរ ហើយផ្នែកដ៏ពិសេសនោះគឺ ការយល់ពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទតាមព្រះគម្ពីរទាំងស្រុង។ ដំណឹងល្អគឺជាចំណុចស្នូលនៃជំនឿគ្រីស្ទបរិស័ទ ហេតុដូច្នេះហើយ វាគួរតែជាចំណុចស្នូលនៃពួកជំនុំរបស់យើងដែរ។

ពួកជំនុំដែលមានសុខភាពល្អ គឺជាពួកជំនុំដែលមានជំនឿដូចគ្នាលើដំណឹងល្អដ៏អស្ចារ្យនៃសេចក្ដីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ ទោះបើសមាជិកពួកជំនុំជាកូនក្មេង មនុស្សចាស់ ពេញវ័យឬមិនពេញវ័យខាងឯវិញ្ញាណក្ដី។ គ្រប់ទាំងបទគម្ពីរនៅក្នុងព្រះគម្ពីរចង្អុលបង្ហាញពីដំណឹងល្អ ឬពីផ្នែកខ្លះនៃដំណឹងល្អ។ ដូច្នេះ

ហើយ ពួកជំនុំប្រជុំគ្នាពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ដើម្បីនឹងស្តាប់ដំណឹងល្អម្តងហើយម្តងទៀត។ នៅពេលដែលយើងយល់ច្បាស់ពីដំណឹងល្អតាមព្រះគម្ពីរ នោះវានឹងមានឥទ្ធិពលលើគ្រប់ទាំងសេចក្តីអធិប្បាយ គ្រប់ទាំងសកម្មភាពនៃពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ គ្រប់ទាំងបទចម្រៀង គ្រប់ទាំងសេចក្តីអធិស្ឋាន និងគ្រប់ទាំងការសន្ទនារបស់យើង។ ពួកជំនុំដែលមានសុខភាពល្អនឹងអធិស្ឋាន ហើយចង់ស្គាល់ដំណឹងល្អនោះឲ្យកាន់តែស៊ីជម្រៅលើសជាងអ្វីៗទាំងអស់។

ហេតុអ្វីបានជាដូច្នោះ? ពីព្រោះសង្ឃឹមនៃដំណឹងល្អជាសង្ឃឹមនៃការស្គាល់សិរីល្អរបស់ព្រះជាម្ចាស់ដែលភ្លឺចាំងពីព្រះភក្ត្រព្រះគ្រីស្ទ (២កូរិនថូស ៤:៤-៦)។ សង្ឃឹមនៃដំណឹងល្អជាសង្ឃឹមនៃការមើលទ្រង់ឃើញយ៉ាងជាក់ច្បាស់ ហើយស្គាល់ទ្រង់ ដូចជាទ្រង់ស្គាល់យើងយ៉ាងជាក់ច្បាស់ដែរ (១កូរិនថូស ១៣:១២)។ សង្ឃឹមនៃដំណឹងល្អជាសង្ឃឹមដែលយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះដែរ (១យ៉ូហាន ៣:២)។

## ចំណុចស្នូលនៃដំណឹងល្អ

ដំណឹងល្អមិនមែនជាដំណឹងដែលប្រាប់ថា យើងអត់មានបញ្ហាអ្វីនោះទេ។ វាមិនមែនជាដំណឹងដែលថា ព្រះជាម្ចាស់ជាសេចក្តីស្រ-

ឡាញ់ ហើយវាក៏មិនមែនជាដំណឹងដែលថា ព្រះយេស៊ូវសព្វព្រះទ័យនឹងធ្វើជាមិត្តសម្លាញ់យើងនោះដែរ។ វាមិនមែនជាដំណឹងដែលថា ទ្រង់មានផែនការដ៏អស្ចារ្យសម្រាប់ជីវិតរបស់យើងនោះទេ។ ប៉ុន្តែ ដំណឹងល្អ គឺជាដំណឹងដែលថា ព្រះយេស៊ូវគ្រីស្ទបានសុគតនៅលើឈើឆ្កាងទុកជាយញ្ញបូជាជំនួសមនុស្សមានបាប ហើយទ្រង់បានរស់ពីសុគតឡើងវិញដែលបានបើកផ្លូវឲ្យយើងបានជាមេត្រីនឹងព្រះជាម្ចាស់ឡើងវិញ។ វាជាដំណឹងដែលថា ព្រះដ៏ជាចៅក្រមដែលនឹងជំនុំជម្រះមនុស្សលោក នឹងត្រឡប់ជាព្រះវរបិតាដែលយើងអាចមានទំនាក់ទំនងនឹងទ្រង់បាន ប្រសិនបើយើងប្រែចិត្ត ហើយទទួលជឿលើទ្រង់ (បើចង់យល់ឲ្យបានលម្អិត សូមមើលជំពូក១)។

មានចំណុចបួនយ៉ាងដែលខ្ញុំព្យាយាមចងចាំ នៅពេលណាដែលខ្ញុំផ្សាយដំណឹងល្អ មិនថាផ្សាយនៅកន្លែងឯកជន ឬនៅទីសាធារណៈក្តី។ ចំណុចទាំងនោះគឺ (១) ព្រះជាម្ចាស់ (២) មនុស្ស (៣) ព្រះគ្រីស្ទ និង (៤) ការឆ្លើយតប។ ឬម្យ៉ាងទៀត ខ្ញុំសួរខ្លួនឯងថា៖

- តើខ្ញុំបានពន្យល់ហើយឬនៅថា ព្រះជាម្ចាស់ជាព្រះអាទិកររបស់យើងដែលទ្រង់បរិសុទ្ធ ហើយគ្រប់គ្រងលើអ្វីៗទាំងអស់?
- តើខ្ញុំបានបញ្ជាក់ច្បាស់ហើយឬនៅថា យើងជាមនុស្សដែល

ព្រះជាម្ចាស់បានបង្កើតមកយ៉ាងអស្ចារ្យដូចរូបអង្គទ្រង់ ក៏ប៉ុន្តែយើងបានបាត់សភាពដើម ត្រឡប់ជាមានបាប ហើយបានបែកចេញពីទ្រង់?

- តើខ្ញុំបានពន្យល់ហើយឬនៅថា ព្រះយេស៊ូវជានរណា ហើយទ្រង់បានសម្រេចអ្វីខ្លះ? ហើយតើខ្ញុំបានពន្យល់ហើយឬនៅថា ព្រះយេស៊ូវជាមនុស្សផងជាព្រះផង ហើយទ្រង់ឈរនៅចន្លោះមនុស្ស និងព្រះជាម្ចាស់ ក្នុងនាមជាអ្នកជំនួសយើង ហើយទ្រង់ជាព្រះអម្ចាស់ដែលរស់ពីសុគតឡើងវិញ?
- ជាចុងក្រោយ ទោះបើខ្ញុំបានចែកចាយពីការទាំងអស់នេះរួចហើយក៏ដោយ តើខ្ញុំបាននិយាយច្បាស់ទេថា បុគ្គលម្នាក់ៗត្រូវតែឆ្លើយ-តបទៅនឹងដំណឹងល្អ ហើយគាត់ត្រូវតែជឿលើដំណឹងល្អនេះ ព្រមទាំងបែរចេញពីបាប និងជីវិតអាត្មានិយមរបស់គាត់?

ពេលខ្លះ យើងចង់ប្រកាសតែពីអត្ថប្រយោជន៍ដ៏ពិតតែមួយចំនួននៃដំណឹងល្អ ជាជាងប្រកាសពីដំណឹងល្អទាំងមូល។ ហើយអត្ថប្រយោជន៍ទាំងនោះ ទំនងជាអ្វីដែលអ្នកមិនជឿតែងតែប្រាថ្នាចង់បានដូចជា អំណរ សុភមង្គល ភាពស្កប់ចិត្ត ការឲ្យតម្លៃលើខ្លួនឯង ឬសេចក្តីស្រឡាញ់។ ប៉ុន្តែ ការដែលយើងចែកចាយពីអត្ថប្រយោជន៍ទាំងនេះឡើងថាជាដំណឹងល្អ នោះមានន័យថា យើងចែកចាយ*តែផ្នែកខ្លះ*នៃសេចក្តីពិតតែប៉ុណ្ណោះ។ លោក ជេ. អាយ. ផាកឃើរ (J. I. Packer) បានលើកឡើងថា “សេចក្តីពិត

តែពាក់កណ្ដាល គឺមិនមែនជាសេចក្ដីពិតនោះទេ តែជាការកុហកទៅវិញ»។[១]

តាមពិត យើងមិនមែនគ្រាន់តែត្រូវការអំណរ មេត្រីភាព ឬគោលដៅនៃជីវិតតែប៉ុណ្ណោះទេ គឺយើងត្រូវការព្រះជាម្ចាស់ផ្ទាល់។ ដោយសារយើងជាមនុស្សមានបាបដែលត្រូវទទួលការជំនុំជម្រះពីព្រះជាម្ចាស់ នោះយើងពិតជាត្រូវការការអត់ទោសពីទ្រង់លើសជាងអ្វីៗទាំងអស់ទៅទៀត។ យើងត្រូវការជីវិតខាងឯវិញ្ញាណ។ នៅពេលដែលយើងប្រកាសដំណឹងល្អមិនបានគ្រប់ជ្រុងជ្រោយទេ នោះយើងគ្រាន់តែសុំឲ្យមានអ្នកជឿក្លែងក្លាយ និងតារាងបញ្ជីឈ្មោះសមាជិកពួកជំនុំច្រើនឥតន័យប៉ុណ្ណោះ។ ទាំងអ្នកជឿក្លែងក្លាយ ទាំងបញ្ជីឈ្មោះសមាជិកដ៏ច្រើនឥតន័យនេះ ធ្វើឲ្យការប្រកាសដំណឹងល្អដល់លោកីយ៍ជុំវិញយើងកាន់តែពិបាកឡើងៗ។

## ការហៀរហូរនៃដំណឹងល្អ

នៅពេលដែលពួកជំនុំមួយមានសុខភាពល្អ ហើយសមាជិកពួកជំនុំនោះស្គាល់ ហើយស្រឡាញ់ដំណឹងល្អលើសអ្វីៗផ្សេងទៀត នោះពួកគេនឹងកាន់តែចង់ផ្សាយដំណឹងល្អនោះដល់លោកីយ៍។ លោកចច ដាប់បលយូ. ទ្រូអេត (George W. Truett) ដែលជាអ្នក

១. ដកស្រង់ពី “សេចក្ដីផ្ដើម” នៃសៀវភៅ *The Death of Death in the Death of Christ* (Edinburgh: Banner of Truth, ១៩៥៩, បោះពុម្ពលើកទី២ ឆ្នាំ១៩៨៣), ទំព័រ២។

ដឹកនាំគ្រីស្ទបរិស័ទដ៏អស្ចារ្យម្នាក់នៅជំនាន់មុន ហើយជាគ្រូគង្វាលនៅពួកជំនុំហ្វើសត៍បាប់ទីស្ទ (First Baptist Church) នៅក្រុងដាឡាស់ (Dallas) ក្នុងរដ្ឋតិចសាស់ (Texas) នៃសហរដ្ឋអាមេរិក បានលើកឡើងថា៖

> ការចោទប្រកាន់ដ៏ធំបំផុតដែលអ្នកអាចយកមកទាស់ប្រឆាំងនឹងពួកជំនុំមួយ...គឺថា ពួកជំនុំបែបនោះខ្វះនូវចិត្តឆេះឆួល និងសេចក្តីក្តួលអាណិតដល់ព្រលឹងមនុស្សដែលបាត់បង់។ ពួកជំនុំគឺគ្មានអ្វីល្អប្រសើរជាងក្រុមមួយដែលបង្រៀនពីសីលធម៌នោះទេ ប្រសិនបើសេចក្តីក្តួលអាណិតរបស់ពួកគេចំពោះព្រលឹងដែលបាត់បង់មិនមានភាពខ្លាំងក្លា ហើយប្រសិនបើពួកគេមិនចេញទៅ ដើម្បីប្រកាសពីផ្លូវនៃសេចក្តីសង្គ្រោះរបស់ព្រះយេស៊ូវគ្រីស្ទដល់ព្រលឹងដែលបាត់បង់ទេនោះ។[២]

សព្វថ្ងៃនេះ សមាជិកនៃពួកជំនុំរបស់យើងចំណាយពេលជាមួយនឹងអ្នកមិនជឿនៅក្នុងផ្ទះរបស់ពួកគេ នៅការិយាល័យរបស់ពួកគេ និងនៅផ្ទះអ្នកជិតខាងពួកគេច្រើនជាងការដែលពួកគេចំណាយពេលជាមួយនឹងគ្រីស្ទបរិស័ទដទៃទៀតនៅរៀងរាល់ថ្ងៃអាទិត្យទៅទៀត។ ធម្មតា ការផ្សាយដំណឹងល្អមិនមែនជាការដែលយើងអញ្ជើញនរណាម្នាក់មកព្រះវិហារនោះទេ។ យើងម្នាក់ៗមានដំណឹង

---

២. លោក George W. Truett, *A Quest for Souls* (New York: Harper & Brothers, ឆ្នាំ១៩១៧), ទំព័រ៦៧។

ដ៏អស្ចារ្យពីសេចក្តីសង្គ្រោះនៅក្នុងព្រះគ្រីស្ទ។ ចូរយើងកុំដូរដំណឹងល្អនេះជាមួយនឹងអ្វីផ្សេងទៀតឡើយ។ នៅថ្ងៃនេះ សូមចែកចាយពីដំណឹងល្អទៅ!

ពួកជំនុំដែលមានសុខភាពល្អស្គាល់ដំណឹងល្អ ហើយក៏ចែក-ចាយពីដំណឹងល្អនោះ។

## គំនិតជំនួយខ្លះៗ៖
## របៀបស្វែងរកពួកជំនុំមួយដែលល្អ

១. សូមអធិស្ឋាន។

២. សូមប្រឹក្សាយោបល់ពីគ្រូគង្វាលដែលកោតខ្លាចព្រះជាម្ចាស់ ឬពីពួកចាស់ទុំ។

៣. សូមរក្សាអាទិភាពរបស់លោកអ្នកឲ្យត្រឹមត្រូវតាមព្រះគម្ពីរ។

- ពួកជំនុំនោះត្រូវតែជឿដំណឹងល្អតាមព្រះគម្ពីរ ហើយអធិប្បាយដំណឹងល្អនោះឲ្យបានច្បាស់ ព្រមទាំងអនុវត្តដំណឹងល្អនៅក្នុងជីវិតរបស់ពួកគេឲ្យបានត្រឹមត្រូវដែរ។ ប្រសិនបើពួកជំនុំខ្វះផ្នែកណាមួយក្នុងចំណោមផ្នែកទាំងបីនេះ នោះពួកជំនុំនោះស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ណាស់។
- សេចក្ដីអធិប្បាយនៅក្នុងពួកជំនុំត្រូវតែស្មោះត្រង់ទៅនឹងព្រះគម្ពីរដែលដាស់តឿនឲ្យសមាជិកលូតលាស់ខាងឯវិញ្ញាណ។ លោកអ្នកមិនអាចលូតលាស់ខាងឯវិញ្ញាណ បើលោកអ្នកចូលរួមក្នុងពួកជំនុំដែលមិនយកព្រះបន្ទូលជាគោល។
- អ្វីដែលសំខាន់ផងដែរនោះគឺលោកអ្នកត្រូវគិតថា តើពួកជំនុំនោះរៀបចំពិធីបុណ្យជ្រមុជទឹក ពិធីលៀងព្រះអម្ចាស់ ការក្លាយជាសមាជិកពួកជំនុំ និងការដាក់វិន័យដល់ពួកជំនុំដោយរបៀបណា ហើយត្រូវគិតដែរថា តើនរណាមានសិទ្ធិក្នុងការសម្រេចចិត្តចុងក្រោយក្នុងការទាំងអស់នេះ។

- សរុបមក សូមអានជំពូក៥ដល់ជំពូក១៣នៅក្នុងសៀវភៅនេះ!

៤. សូមសួរខ្លួនឯងនូវសំណួរបែបរិភាគដូចជា៖

- តើខ្ញុំនឹងចង់ស្វែងរកដៃគូជីវិតដែលរីកចម្រើនពេញវ័យឡើងក្រោមការបង្ហាត់បង្រៀនរបស់ពួកជំនុំនេះដែរឬទេ?
- តើកូនរបស់ខ្ញុំនឹងមើលឃើញលក្ខណសម្បត្តិអ្វីខ្លះនៅក្នុងពួកជំនុំនេះ? តើពួកគេនឹងមើលឃើញពីលក្ខណៈរបស់ពួកជំនុំដូចដែលមានចែងក្នុងព្រះគម្ពីរ ឬមើលឃើញតែលក្ខណៈដែលដូចគ្នានឹងលោកីយ៍?
- តើខ្ញុំរីករាយនឹងអញ្ជើញអ្នកមិនជឿមកពួកជំនុំនេះដែរឬទេ? តើពួកគេអាចនឹងស្តាប់ឮដំណឹងល្អយ៉ាងច្បាស់ ហើយមើលឃើញជីវិតរស់នៅរបស់ពួកជំនុំស៊ីគ្នាទៅនឹងដំណឹងល្អដែរឬទេ? តើពួកជំនុំនឹងមានចិត្តស្វាគមន៍ ហើយឈោងចាប់អ្នកមិនជឿដែរឬទេ?
- តើពួកជំនុំនេះជាកន្លែងដែលខ្ញុំអាចធ្វើព័ន្ធកិច្ចបានដែរឬទេ?

៥. សូមគិតទៅលើទីតាំងនៃពួកជំនុំ។ តើចម្ងាយពីផ្ទះរបស់លោកអ្នកទៅកាន់ពួកជំនុំដែលលោកអ្នកត្រូវជិះទៅមកជាញឹកញាប់ដើម្បីចូលរួមកម្មវិធីផ្សេងៗនោះ ធ្វើឲ្យលោកអ្នកបាក់ទឹកចិត្តលែងចង់ទៅទៀត ឬក៏លោកអ្នកពេញចិត្តនឹងទៅទៀត? ប្រសិនបើលោកអ្នកផ្លាស់ទីលំនៅទៅកន្លែងថ្មី នោះចូរព្យាយាមកំណត់រកទីតាំងពួកជំនុំមួយដែលល្អជាមុនសិន មុនពេលលោកអ្នកទិញ ឬជួលផ្ទះ។

ផ្នែកទី៣

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ

**ដរាបណាដែល**សញ្ញាសម្គាល់ទាំងប្រាំបួនដែលខ្ញុំបានរៀបរាប់នៅក្នុងសៀវភៅនេះគឺត្រឹមត្រូវតាមព្រះគម្ពីរ នោះសញ្ញាសម្គាល់ទាំងនេះនឹងមានអំណាចលើពួកជំនុំរបស់ព្រះគ្រីស្ទ។ ប៉ុន្តែលក្ខណៈខុសប្លែកគ្នារវាងសញ្ញាសម្គាល់*ដ៏ចាំបាច់* និងសញ្ញាសម្គាល់*ដ៏សំខាន់* គួរតែបានរំឭកយើងថា ការញែកជាបរិសុទ្ធនៅក្នុងជីវិតពួកជំនុំ ក៏ដូចជានៅក្នុងជីវិតបុគ្គលម្នាក់ៗ គឺកើតឡើងបន្តិចម្ដងៗ។ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យអត់ធ្មត់ជាមួយនឹងពួកជំនុំរបស់យើង ដូចដែលទ្រង់ត្រាស់ហៅយើងឲ្យមានការអត់ធ្មត់ក្នុងការចិញ្ចឹមបីបាច់កូនរបស់យើងដែរ។

អ្វីដែលខ្ញុំរាប់ថាសញ្ញាសម្គាល់*សំខាន់* គឺមានសារៈសំខាន់មែន ជាពិសេស នៅពេលដែលយើងគិតពីសញ្ញាសម្គាល់នីមួយៗដាច់ដោយឡែកពីគ្នា។ ប៉ុន្តែ បើពួកជំនុំបាត់សញ្ញាសម្គាល់សំខាន់ទាំងនេះ នោះយើងមិនចាំបាច់ចាកចេញពីពួកជំនុំនោះទេ (ប៉ុន្តែ

ពេលខ្លះ ជាល្អបើយើងចេញ)។ ពួកជំនុំដែលគ្មានសញ្ញាសម្គាល់ដ៏សំខាន់ទាំងនេះ ក៏អាចជាកន្លែងដែលយើងត្រូវអធិស្ឋានឲ្យ ជាកន្លែងដែលយើងត្រូវអត់ធ្មត់ និងជាកន្លែងដែលយើងត្រូវបង្ហាញនូវគំរូល្អមួយតាមរយៈជីវិតផ្ទាល់ខ្លួនរបស់យើង។

ប្រសិនបើគ្រូគង្វាលសួរខ្ញុំថា តើគាត់គួរតែអត់ធ្មត់នឹងរចនាសម្ព័ន្ធអ្នកដឹកនាំដែលមិនត្រឹមត្រូវតាមព្រះគម្ពីរយូរប៉ុណ្ណា ឬប្រសិនបើអ្នកជឿម្នាក់សួរខ្ញុំថា តើគាត់គួរតែធ្វើមើលមិនឃើញការដែលពួកជំនុំមិនបានអនុវត្តវិន័យពួកជំនុំយូរប៉ុណ្ណា ឬអ្នកជំនួយម្នាក់ក្នុងពួកជំនុំសួរខ្ញុំថា តើគាត់គួរតែទ្រាំទ្រនឹងតួនាទីសមាជិកដែលគ្មានភាពច្បាស់លាស់យូរប៉ុណ្ណា នោះខ្ញុំប្រហែលជានឹងលើកទឹកចិត្តអ្នកទាំងនោះឲ្យអត់ធ្មត់ អធិស្ឋាន ធ្វើជាគំរូល្អ ស្រឡាញ់ ហើយរង់ចាំសិន។ ការរីកចម្រើនត្រូវការពេលវេលា។ ពួកជំនុំជាមនុស្សដែលព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យអត់ទោសឲ្យ លើកទឹកចិត្ត បម្រើ ហើយពេលខ្លះដាស់តឿនដោយចិត្តសុភាព។ លើសពីនោះទៀត ទ្រង់ត្រាស់ហៅយើងឲ្យស្រឡាញ់ថ្នាក់ថ្នមដល់ពួកគេ។

នៅលើលោកនេះមិនមានគ្រីស្ទបរិស័ទគ្រប់លក្ខណ៍ទេ ហើយក៏មិនមានពួកជំនុំដែលគ្រប់លក្ខណ៍ដែរ។ សូម្បីតែពួកជំនុំដែលល្អបំផុតក៏មិនទាន់គ្រប់លក្ខណ៍ដែរ។ ទោះបើពួកជំនុំមានការចាត់ចែងត្រឹមត្រូវ ការអធិប្បាយពេញដោយភាពក្លាហាន ការថ្វាយដោយ

ភាពលះបង់ ការបង្រៀនត្រឹមត្រូវតាមគោលលទ្ធិក៏ដោយ ក៏មិនអាចធានាបានថា ពួកជំនុំនឹងរីកចម្រើននោះដែរ។ ប៉ុន្តែ ពួកជំនុំអាចនឹងមានសុខភាពល្អជាងស្ថានភាពបច្ចុប្បន្ននេះ។ យើងនឹងមិនដែលទទួលបានជ័យជម្នះទាំងស្រុងលើអំពើបាបនៅក្នុងជីវិតនេះនោះទេ ប៉ុន្តែក្នុងនាមជាកូនដ៏ពិតរបស់ព្រះជាម្ចាស់ យើងនឹងមិនឈប់តយុទ្ធប្រឆាំងនឹងអំពើបាបនោះឡើយ។ ដូចគ្នានេះដែរ ពួកជំនុំក៏មិនត្រូវឈប់តយុទ្ធដែរ។ គ្រីស្ទបរិស័ទគ្រប់រូប ជាពិសេសគ្រូគង្វាល និងអ្នកដឹកនាំពួកជំនុំ គួរតែទន្ទឹងរង់ចាំ ហើយខំប្រឹងធ្វើការ ដើម្បីនឹងឃើញពួកជំនុំកាន់តែមានសុខភាពល្អ។

ជំពូក៨

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ៖ ការយល់ពីការក្លាយជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរ

**នៅក្នុងការប្រជុំ**លើកដំបូងរបស់ពួកជំនុំខ្ញុំនៅឆ្នាំ១៨៧៨ ពួកជំនុំខ្ញុំបានសម្រេចយកគោលលទ្ធិនៃជំនឿមួយសម្រាប់ពួកជំនុំរបស់ពួកគេ។ ពួកគេបានយកគោលលទ្ធិនៃជំនឿរបស់ ញូវហាំសៀ (*New Hampshire Confession of Faith*) នៅឆ្នាំ១៨៣៣ មកកែសម្រួលឲ្យវាកាន់តែរឹងមាំជាងមុន។ មាត្រាទី៨ នៃគោលលទ្ធិនៃជំនឿរបស់ពួកគេមានដូចតទៅ៖

> យើងជឿថា ការប្រែចិត្ត និងជំនឿ គឺជាតួនាទីដ៏បរិសុទ្ធ ហើយជាព្រះគុណផងដែរដែលយើងមិនអាចបំបែកចេញពីគ្នាបាន។ ហើយព្រះវិញ្ញាណបរិសុទ្ធនៃព្រះជាម្ចាស់ដែលបានធ្វើឲ្យយើង

> បានកើតជាថ្មី ទ្រង់បានបណ្ដាលឲ្យយើងប្រែចិត្ត ព្រមទាំងមានជំនឿ។ នៅពេលនោះ យើងបានទទួលស្គាល់ទោសកំហុស ស្ថានភាពគ្រោះថ្នាក់ និងភាពមិនអាចជួយខ្លួនឯងបានរបស់យើង។ ហើយយើងក៏ទទួលស្គាល់ថាសេចក្ដីសង្គ្រោះមានតែនៅក្នុងព្រះគ្រីស្ទប៉ុណ្ណោះ។ ដូច្នេះ យើងបានបែរទៅរកព្រះជាម្ចាស់ដោយការសោកស្ដាយពីកំហុសរបស់យើង ការលន់តួ និងការទូលអង្វរសុំក្ដីមេត្តាករុណាពីទ្រង់ ខណៈពេលដែលយើងទទួលស្គាល់ថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺជាហោរា ជាសង្ឃ និងជាស្ដេចរបស់យើង។ ហើយយើងក៏ពឹងផ្អែកលើទ្រង់តែមួយគត់ ដោយជឿជាក់ថា ទ្រង់គឺជាព្រះសង្គ្រោះដ៏ពេញលេញរបស់យើង។

ទោះបើគោលលទ្ធិនៃជំនឿនេះមានអាយុកាលយូរលង់ក៏ដោយ ក៏សេចក្ដីពិតពីព្រះគម្ពីរក្នុងឯកសារនេះនៅតែជាសេចក្ដីពិតដដែល។ យើងអាចកត់សម្គាល់ពួកជំនុំមួយដែលមានសុខភាពល្អបាន តាម-រយៈការយល់ពីការក្លាយជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរ។

## កិច្ចការរបស់យើង

គោលលទ្ធិនៃជំនឿនេះចាប់ផ្ដើមដោយការត្រាស់ហៅនៃព្រះគម្ពីរឲ្យប្រែចិត្ត ហើយជឿ។ នៅពេលដែលព្រះយេស៊ូវបានចាប់ផ្ដើមព័ន្ធកិច្ចដំបូងរបស់ទ្រង់ ទ្រង់បានបង្គាប់ថា “ចូរប្រែចិត្ត ហើយជឿ

ជំណឹងល្អចុះ» (ម៉ាកុស ១:១៥)។ និយាយឲ្យសាមញ្ញទៅ ការក្លាយជាគ្រីស្ទបរិស័ទគឺស្មើគ្នានឹងការប្រែចិត្ត ហើយជឿ។

បន្ទាប់មក គោលលទ្ធិនៃជំនឿនេះបានពណ៌នាបន្ថែមទៀតពីលក្ខណៈនៃការប្រែចិត្ត និងជំនឿ។ គោលលទ្ធិនៃជំនឿនេះរៀបរាប់ថា យើង «បែរ» ទៅរកព្រះជាម្ចាស់ ចេញពីបាបរបស់យើង យើង «ទទួល» ព្រះគ្រីស្ទ ហើយយើង «ពឹងផ្អែក» លើទ្រង់តែមួយអង្គគត់ថា ទ្រង់ជាព្រះអង្គសង្គ្រោះដ៏គ្រប់លក្ខណ៍។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី មានពេញទៅដោយការពណ៌នាពីមនុស្សមានបាបដែលគេបានចាកចេញពីបាបរបស់ខ្លួន ទទួលព្រះគ្រីស្ទ ហើយពឹងផ្អែកលើទ្រង់។ សូមគិតពីប្រវត្តិលោក លេវី ដែលជាអ្នកយកពន្ធ។ គាត់បានលាចេញពីមុខងារជាអ្នកយកពន្ធ ដើម្បីដើរតាមព្រះគ្រីស្ទវិញ។ ឬគិតអំពីរឿងរបស់ស្ត្រីនៅមាត់អណ្ដូង។ ឬគិតពីរឿងរបស់មេទ័ពនៃពួកទីក្រុងរ៉ូម។ ឬគិតពីរឿងលោក ពេត្រុស លោក យ៉ាកុប និងលោក យ៉ូហាន។ ឬគិតពីលោក សុល ដែលជាអ្នកបៀតបៀនគ្រីស្ទបរិស័ទ ហើយក្រោយមកមានឈ្មោះថា ប៉ុល ដែលបានក្លាយជាសាវ័កដល់ពួកសាសន៍ដទៃ។ ព្រះគម្ពីរសញ្ញាថ្មីរៀបរាប់ពីមនុស្សបែបហ្នឹងជាច្រើននាក់ទៀត។ ពួកគេម្នាក់ៗបានបែរទៅរកព្រះយេស៊ូវ ទុកចិត្តទ្រង់ ហើយដើរតាមទ្រង់។ នោះឯងជាការក្លាយជាគ្រីស្ទបរិស័ទ។

ការក្លាយជាគ្រីស្ទបរិស័ទ មិនមែនជាការសូត្រគោលជំនឿ

ការអធិស្ឋាន ការសន្ទនា និងការក្លាយជាពួកបស្ទិមប្រទេសនោះទេ។ ហើយការក្លាយជាគ្រីស្ទបរិស័ទក៏មិនមែនជាការឈានដល់វ័យកំណត់ណាមួយ ការចូលរៀននៅថ្នាក់ណាមួយ ឬការឆ្លងកាត់នូវពិធីផ្សេងៗដើម្បីឲ្យក្លាយជាមនុស្សពេញវ័យ ហើយវាក៏មិនមែនកើតឡើងបន្តិចម្តងៗនោះទេ។ ប៉ុន្តែការក្លាយជាគ្រីស្ទបរិស័ទគឺជាការវិលបែរជីវិតទាំងស្រុងរបស់យើងពីការខំប្រឹងឲ្យបានរាប់ជាសុចរិតដោយខ្លួនឯង មកឯការរាប់ជាសុចរិតតាមរយៈព្រះគ្រីស្ទ ហើយវិលបែរពីការត្រួតត្រាខ្លួនឯង មកឲ្យព្រះជាម្ចាស់សោយរាជ្យ ហើយនិងវិលបែរពីការថ្វាយបង្គំរូបព្រះ មកថ្វាយបង្គំព្រះជាម្ចាស់វិញ។

## ការក្លាយជាគ្រីស្ទបរិស័ទគឺជាកិច្ចការដែលព្រះជាម្ចាស់ធ្វើក្នុងយើង

ប៉ុន្តែ សូមកត់សម្គាល់ពីចំណុចផ្សេងៗដែលគោលលទ្ធិនៃជំនឿនេះបានលើកឡើងផងដែរពីការក្លាយជាគ្រីស្ទបរិស័ទ។ យើងបែរទៅរកព្រះជាម្ចាស់ដោយព្រោះ «យើងបានទទួលស្គាល់ទោសកំហុស ស្ថានភាពគ្រោះថ្នាក់ និងភាពមិនអាចជួយខ្លួនឯងបានរបស់យើង។ ហើយយើងក៏ទទួលស្គាល់ថាសេចក្តីសង្គ្រោះមានតែនៅក្នុងព្រះគ្រីស្ទប៉ុណ្ណោះ»។ តើការនេះកើតឡើងយ៉ាងដូចម្តេច? តើនរណាធ្វើឲ្យយើងទទួលស្គាល់? គឺជា «ព្រះវិញ្ញាណបរិសុទ្ធនៃ

ព្រះជាម្ចាស់ដែលបានធ្វើឲ្យយើងបានកើតជាថ្មី ទ្រង់បានបណ្តាលឲ្យយើងប្រែចិត្ត ព្រមទាំងមានជំនឿ»។ គោលលទ្ធិនៃជំនឿនេះដកស្រង់ចេញពីខគម្ពីរពីរ ដើម្បីគាំទ្រគំនិតនេះ៖

> កាលបានឮសេចក្តីនោះហើយ នោះគេបាត់មាត់ ក៏ត្រឡប់ជាសរសើរដល់ព្រះវិញថា «ដូច្នេះ ព្រះទ្រង់ក៏ប្រោសប្រទានការប្រែចិត្តដល់ពួកសាសន៍ដទៃ ឲ្យគេមានជីវិតដែរហ្ន៎»។ (កិច្ចការ ១១:១៨)

> ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ។ (អេភេសូរ ២:៨)

ប្រសិនបើយើងយល់ថា យើងក្លាយជាគ្រីស្ទបរិស័ទបានដោយខ្លួនឯង មិនមែនព្រះជាម្ចាស់ជាអ្នកដែលធ្វើឲ្យយើងជាគ្រីស្ទបរិស័ទនោះទេ នោះយើងយល់ពីការក្លាយជាគ្រីស្ទបរិស័ទខុសហើយ។ ប្រាកដណាស់ ការក្លាយជាគ្រីស្ទបរិស័ទ ត្រូវបូករួមជាមួយនឹងសកម្មភាពរបស់យើងក្នុងនោះដែរ ដូចដែលយើងបានពិភាក្សារួចហើយ។ ប៉ុន្តែ ការក្លាយជាគ្រីស្ទបរិស័ទ គឺលើសពីនោះទៅទៀត។ ព្រះគម្ពីរបង្រៀនថា យើងត្រូវតែទទួលចិត្តថ្មី និងគំនិតថ្មី

ពីព្រះជាម្ចាស់ ហើយវិញ្ញាណរបស់យើងក៏ត្រូវទទួលជីវិតពីទ្រង់ផងដែរ។ យើងមិនអាចធ្វើការទាំងនេះបានដោយខ្លួនឯងនោះទេ។ ការផ្លាស់ប្រែដែលមនុស្សគ្រប់រូបត្រូវការ គឺការផ្លាស់ប្រែដ៏ធំក្រៃលែងដែលមានតែព្រះជាម្ចាស់មួយអង្គប៉ុណ្ណោះដែលអាចធ្វើវាបាន។ ទ្រង់ជាអង្គដែលបានបង្កើតយើងលើកដំបូង ដូច្នេះមានតែទ្រង់ទេដែលអាចបង្កើតយើងជាថ្មីម្តងទៀតបាន។ ទ្រង់បានប្រទានកំណើតពីធម្មជាតិដល់យើង ដូច្នេះមានតែទ្រង់ប៉ុណ្ណោះដែលអាចប្រទានកំណើតថ្មីដល់យើងបាន។ យើងត្រូវការព្រះជាម្ចាស់ធ្វើឲ្យយើងក្លាយជាគ្រីស្ទបរិស័ទ។

លោកគ្រូអធិប្បាយម្នាក់នៅសតវត្សរ៍ទី១៩ ដែលមានឈ្មោះថា ឆាល ស្ពើរជិន (Charles Spurgeon) បាននិទានរឿងមួយពីការដែលគាត់កំពុងតែដើរតាមផ្លូវមួយនៅក្នុងទីក្រុងឡុងដ៍ (London) ហើយនៅពេលនោះមានបុរសស្រវឹងស្រាម្នាក់ដើរមកជិតគាត់ ហើយផ្អែកលើបង្គោលភ្លើងក្បែរនោះ បន្ទាប់មកគាត់បាននិយាយថា «នែ៎! លោក ស្ពើរជិន ខ្ញុំជាម្នាក់ដែលលោកបាននាំឲ្យក្លាយជាគ្រីស្ទបរិស័ទ!»។

លោក ស្ពើរជិន បានឆ្លើយតបថា «ប្រាកដណាស់ លោកជាអ្នកជឿតាមខ្ញុំមែន ពីព្រោះមើលទៅលោកមិនមែនជាអ្នកជឿតាមព្រះអម្ចាស់នោះទេ!»។

## ផលផ្លែល្អ និងមិនល្អ

នៅពេលដែលពួកជំនុំយល់ខុសពីសេចក្តីបង្រៀនរបស់ព្រះគម្ពីរ ស្តីពីការក្លាយជាគ្រីស្ទបរិស័ទ នោះពួកជំនុំងាយនឹងមានសមាជិកដែលរាប់ខ្លួនថា ជាអ្នកដែលបានថ្វាយខ្លួន ប៉ុន្តែអ្នកទាំងនោះមិនមានការផ្លាស់ប្រែដ៏ជាក់លាក់ដូចដែលព្រះគម្ពីរបានចែងពីការក្លាយជាគ្រីស្ទបរិស័ទដ៏ពិតនោះទេ។

នៅពេលមនុស្សក្លាយជាគ្រីស្ទបរិស័ទពិតប្រាកដ នោះអ្នកខ្លះមានបទពិសោធន៍ពុះកញ្ជ្រោលខាងឯអារម្មណ៍ ប៉ុន្តែអ្នកខ្លះអត់មាននោះទេ។ ប៉ុន្តែ អ្វីដែលចាំបាច់នោះគឺ *ការមាន*ផលផ្លែជាភស្តុតាង។ តើជីវិតរបស់ពួកជំនុំបានបង្ហាញឲ្យឃើញពីភស្តុតាងនៃការផ្លាស់ប្រែដែរឬទេ? ម្យ៉ាងទៀត តើពួកគេកំពុងតែព្យាយាមដោះនិស្ស័យចាស់ចេញ ហើយពាក់និស្ស័យថ្មីមកវិញដែរឬទេ? តើសមាជិកពួកជំនុំបំណងនឹងប្រឆាំងទាស់នឹងបាបរបស់ពួកគេទេ ទោះបើពួកគេនៅតែចំពប់ដួលក៏ដោយនោះ? តើពួកគេបង្ហាញនូវចំណាប់អារម្មណ៍ថ្មីក្នុងការប្រកបជាមួយនឹងគ្រីស្ទបរិស័ទដទៃទៀតដែរឬទេ? ហើយតើពួកគេបង្ហាញនូវគោលបំណងថ្មីក្នុងការចំណាយពេលជាមួយនឹងអ្នកមិនជឿដែរឬទេ? តើពួកគេកំពុងតែចាប់ផ្តើមឆ្លើយតបទៅនឹងការល្បួងល និងការប្រឈមមុខផ្សេងៗដែលខុសប្លែកពីរបៀបដែលពួកគេធ្លាប់ធ្វើ កាលដែលពួកគេមិនទាន់

ជាអ្នកជឿដែរឬទេ?

នៅពេលដែលពួកជំនុំយល់បានត្រឹមត្រូវពីការក្លាយជាគ្រីស្ទបរិស័ទ នោះពួកគេនឹងបង្ហាញវាឲ្យឃើញមិនគ្រាន់តែនៅក្នុងសេចក្តីអធិប្បាយប៉ុណ្ណោះទេ ប៉ុន្តែពួកគេនឹងបង្ហាញវាឲ្យឃើញនៅក្នុងសេចក្តីតម្រូវរបស់ពួកជំនុំសម្រាប់ពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ទៀតផង។ ពួកជំនុំនឹងកាន់តែប្រុងប្រយ័ត្នក្នុងការធ្វើពិធីទាំងពីរនេះ។ គ្រូគង្វាលនឹងមិនទទួលសម្ពាធក្នុងការធ្វើពិធីបុណ្យជ្រមុជទឹកដល់អ្នកដែលចង់ទទួលពិធីជ្រមុជទឹកយ៉ាងឆាប់រហ័ស និងដោយគ្មានការពិនិត្យពិច័យនោះឡើយ។

នៅពេលដែលពួកជំនុំយល់បានត្រឹមត្រូវពីការក្លាយជាគ្រីស្ទបរិស័ទ នោះវានឹងមានឥទ្ធិពលទៅលើក្តីរំពឹងរបស់ពួកគេចំពោះសមាជិកភាព។ ពួកគេនឹងមិនអនុញ្ញាតមនុស្សថ្មីៗមកធ្វើជាសមាជិកភ្លាមៗនោះទេ។ ប៉ុន្តែ ពួកជំនុំប្រហែលនឹងបើកឲ្យពួកគេចូលរៀនថ្នាក់សមាជិកថ្មី ហើយតម្រូវឲ្យពួកគេចែកចាយពីទីបន្ទាល់របស់ខ្លួនព្រមទាំងពន្យល់ពីដំណឹងល្អជាដើម។

នៅពេល ដែលពួកជំនុំយល់បានត្រឹមត្រូវពី ការក្លាយជាគ្រីស្ទបរិស័ទ នោះពួកគេនឹងរាប់អំពើបាបរបស់សមាជិកថា ជារឿងធ្ងន់ធ្ងរ។ ពួកគេជួយកែតម្រង់គ្នាពេលនរណាម្នាក់ធ្វើខុស លើកទឹកចិត្តគ្នា និងស្តីបន្ទោសគ្នាម្តងម្កាល។ ចំពោះពួកគេ នេះមិន

មានអ្វីប្លែកនោះទេ តែជាគឺជារឿងធម្មតាវិញ។ ពួកគេនឹងអនុវត្តវិន័យពួកជំនុំ ហើយយើងនឹងពិចារណាលើការនេះនៅក្នុងជំពូក១២។

ការយល់ពីអ្វីដែលព្រះគម្ពីរបង្រៀនពីការក្លាយជាគ្រីស្ទបរិស័ទគឺជាសញ្ញាសម្គាល់ដ៏សំខាន់មួយក្នុងចំណោមសញ្ញាសម្គាល់ជាច្រើនទៀតនៃពួកជំនុំដែលមានសុខភាពល្អ។

ជំពូក៩

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ៖ ការយល់ពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ

**មកដល់ពេលនេះ** យើងបានពណ៌នាពីពួកជំនុំដែលមានសុខភាពល្អដោយសារពួកជំនុំនោះមានសេចក្តីអធិប្បាយតាមព្រះគម្ពីរ ទេវវិទ្យាតាមព្រះគម្ពីរ និងការយល់ពីដំណឹងល្អ និងការក្លាយជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរ។ នេះមានន័យថា នៅពេលដែលពួកជំនុំមិនបង្រៀនព្រះគម្ពីរ និងសេចក្តីបង្រៀនដ៏ត្រឹមត្រូវទេ នោះពួកជំនុំនឹងមិនមានសុខភាពល្អទេ។

តើពួកជំនុំដែលឈឺមានលក្ខណៈយ៉ាងដូចម្តេច? ពួកជំនុំដែលមិនមានសុខភាពល្អ គឺជាពួកជំនុំមួយដែលគ្រូគង្វាលអធិប្បាយតាមចិត្តគំនិតខ្លួនឯង។ ហើយអ្វីដែលកាន់តែយ៉ាប់ជាងនេះទៅ

ទៀតនោះគឺថា សេចក្ដីអធិប្បាយទាំងនោះបង្រៀនតែពីការអប់រំផ្នែកសីលធម៌ ហើយធ្វើឲ្យអ្នកស្ដាប់គិតតែពីខ្លួនឯង។ ចំណែកឯដំណឹងល្អវិញ គេអធិប្បាយមិនខុសពីអ្វីដែលគេហៅថា "ខ្លួនទីពឹងខ្លួន" នោះទេ។ គេរាប់ការក្លាយជាគ្រីស្ទបរិស័ទថាជាសកម្មភាពមួយនៃការខិតខំប្រឹងប្រែងរបស់មនុស្សទៅវិញ។ ហើយកាន់តែអាក្រក់ជាងនោះទៅទៀត វប្បធម៌នៅក្នុងពួកជំនុំដែលមិនមានសុខភាពល្អមួយចំនួន គឺមិនខុសអ្វីពីវប្បធម៌លោកីយ៍ជុំវិញពួកគេនោះឡើយ។

ពួកជំនុំបែបនេះមិនបានប្រកាសពីដំណឹងដ៏អស្ចារ្យនៃសេចក្ដីសង្គ្រោះនៅក្នុងព្រះយេស៊ូវគ្រីស្ទទេ ហើយក៏មានបញ្ហាជាច្រើនលើសពីនេះទៅទៀត។

## ការយល់ពីការផ្សាយដំណឹងល្អ តាមរយៈការយល់ពីការក្លាយជាគ្រីស្ទបរិស័ទ

ការយល់ពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ គឺជាសញ្ញាសម្គាល់ដ៏សំខាន់មួយទៀតនៃពួកជំនុំដែលមានសុខភាពល្អ។ នៅពេលដែលយើងបែរទៅពិចារណាលើសញ្ញាសម្គាល់ដ៏សំខាន់មួយនេះ នោះយើងគួរពិចារណាថា តើទស្សនៈរបស់យើងចំពោះសញ្ញាសម្គាល់មួយនេះនឹងជួយឲ្យយើងយល់ពីសញ្ញាសម្គាល់មុនៗបានច្រើនប៉ុណ្ណា ជាពិសេសនោះគឺការយល់ពីការក្លាយជាគ្រីស្ទបរិស័ទ។

ម៉្យាងវិញទៀត ប្រសិនបើគំនិតរបស់យើងទទួលឥទ្ធិពលខ្លាំងពីអ្វីដែលព្រះគម្ពីរបង្រៀនយើងអំពីព្រះជាម្ចាស់ និងពីរបៀបដែលទ្រង់ធ្វើការ ពីដំណឹងល្អ និងពីអ្វីដែលមនុស្សមានបាបត្រូវការបំផុត នោះយើងនឹងកាន់តែយល់បានត្រឹមត្រូវពីការផ្សាយដំណឹងល្អ។ ហើយយើងនឹងជួយលើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យផ្សាយដំណឹងល្អតាមរយៈការបង្រៀន និងការសញ្ជឹងគិតលើដំណឹងល្អផ្ទាល់ មិនមែនតាមរយៈការរៀនពីវិធីសាស្ត្រផ្សាយដំណឹងល្អនោះទេ។

ខ្ញុំតែងតែសប្បាយចិត្តនៅពេលដែលខ្ញុំឮអ្នកជឿថ្មីៗនិយាយថា ពួកគេទទួលសេចក្តីសង្គ្រោះដោយសារព្រះគុណ។ លោកអ្នកប្រហែលជាបានឮពីទីបន្ទាល់នៅក្នុងរយៈពេលពីរបីខែនេះដែលរៀបរាប់ថា ការក្លាយជាគ្រីស្ទបរិស័ទជាកិច្ចការរបស់ព្រះជាម្ចាស់ (អេភេសូរ ២:៨-៩)។ អ្នកជឿថ្មីៗតែងតែលើកឡើងថា «ខ្ញុំបានវង្វេងសូន្យឈឹងនៅក្នុងបាប ប៉ុន្តែព្រះជាម្ចាស់...»

ប៉ុន្តែ ប្រសិនបើពួកជំនុំមិនយកចិត្តទុកដាក់លើអ្វីដែលព្រះគម្ពីរបានរៀបរាប់ អំពីកិច្ចការរបស់ព្រះជាម្ចាស់ ក្នុងការបំផ្លាស់បំប្រែមនុស្សឲ្យក្លាយជាគ្រីស្ទបរិស័ទ នោះការផ្សាយដំណឹងល្អ បានក្លាយជាការធ្វើអ្វីតាមតែចិត្តយើងដើម្បីនឹងធ្វើឲ្យមានការលន់តួទទួលជឿតែមាត់។ សញ្ញាមួយដែលបង្ហាញថា ពួកជំនុំមិនយល់បានត្រឹមត្រូវតាមព្រះគម្ពីរពីការក្លាយជាគ្រីស្ទបរិស័ទ និងការផ្សាយដំណឹងល្អគឺ

ថា ចំនួននៃសមាជិករបស់ពួកជំនុំនោះមានច្រើនជាងចំនួននៃអ្នកចូលរួមពិតប្រាកដ។ ពួកជំនុំបែបនេះគួរតែសួរខ្លួនឯងថា ហេតុអ្វីបានជាការផ្សាយដំណឹងល្អរបស់យើងបង្កើតបានចំនួនសមាជិកដ៏ច្រើនដែលមិនសូវមានទម្លាប់ចូលរួមថ្វាយបង្គំនៅព្រះវិហារ តែពួកគេមានអារម្មណ៍ខ្លួនឯងថា ពួកគេបានសង្គ្រោះ។ តើយើងបានប្រាប់ពួកគេថា ភាពជាសិស្សនៅក្នុងព្រះគ្រីស្ទមានន័យយ៉ាងដូចម្ដេច? តើយើងបានបង្រៀនអ្វីខ្លះដល់ពួកគេអំពីព្រះជាម្ចាស់ បាប និងលោកីយ៍?

ការយល់ពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ គឺសំខាន់ណាស់ចំពោះសមាជិកទាំងអស់នៃពួកជំនុំ ប៉ុន្តែវាកាន់តែសំខាន់ទៅទៀតចំពោះអ្នកដឹកនាំដែលមានទំនួលខុសត្រូវលើការបង្រៀន។

## តើអ្វីទៅជាការផ្សាយដំណឹងល្អ?

យោងទៅតាមព្រះគម្ពីរ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្ទបរិស័ទមកឲ្យយកចិត្តទុកដាក់ ទូលអង្វរ និងផ្លាស់ប្តូរផ្នត់គំនិតអ្នកមិនជឿ (២កូរិនថូស ៥:១១)។ ហើយយើងត្រូវធ្វើដូច្នោះដោយ “សម្តែងសេចក្តីពិត” ដែលមានន័យថា “លះចោលអស់ទាំងការលាក់កំបាំងដែលគួរខ្មាស” (២កូរិនថូស ៤:២)។

និយាយឲ្យស្រួលស្តាប់ទៅ ការផ្សាយដំណឹងល្អមិនមែនជាការធ្វើអ្វីតាមតែចិត្តយើង ដើម្បីធ្វើឲ្យមនុស្សម្នាក់សម្រេចចិត្តទទួល

ជឿព្រះគ្រីស្ទនោះទេ ហើយក៏មិនមែនជាការដាក់បញ្ចូលនូវការយល់ឃើញរបស់យើងបន្ថែមលើដំណឹងល្អនោះដែរ។ មិនមានបុគ្គលណាម្នាក់អាចបង្កើតឲ្យមានកំណើតខាងវិញ្ញាណដោយខ្លួនឯងបានទេ បើទោះជាលោក អេសេគាល ព្យាយាមដាក់ភ្ជាប់ឆ្អឹងសពដ៏ស្ងួតហែងឲ្យជាប់គ្នាដោយខ្លួនគាត់ ដើម្បីឲ្យឆ្អឹងនោះក្លាយជាមនុស្សម្នាក់ក៏មិនអាចដែរ (អេសេគាល ៣៧) ឬដូចជាលោក នីកូដេម បើគាត់ព្យាយាមកើតជាថ្មីខាងវិញ្ញាណដោយខ្លួនឯងនោះក៏មិនអាចទៅរួចដែរ (យ៉ូហាន ៣)។

លើសពីនេះទៅទៀត ការផ្សាយដំណឹងល្អ វាមិនដូចគ្នាទៅនឹងការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួននោះទេ។ ការផ្សាយដំណឹងល្អមិនដូចគ្នានឹងការបង្ហាញពីការការពារជំនឿដោយសមហេតុសមផលនោះដែរ។ វាក៏មិនមែនជាការធ្វើកិច្ចការមនុស្សធម៌នោះដែរ។ កិច្ចការទាំងបីនេះអាចដើរទន្ទឹមគ្នាជាមួយនឹងការផ្សាយដំណឹងល្អបាន ប៉ុន្តែកិច្ចការទាំងបីនេះមិនមែនជាការផ្សាយដំណឹងល្អនោះទេ។ យើងក៏មិនគួរយល់ច្រឡំពីការផ្សាយដំណឹងល្អជាមួយនឹងលទ្ធផលនៃការផ្សាយដំណឹងល្អឡើយ។ បើដូច្នោះមែននោះ យើងនឹងមានគំនិតខុសឆ្គងថា យើងបានផ្សាយដំណឹងល្អយ៉ាងជោគជ័យ តែនៅពេលដែលនរណាម្នាក់ក្លាយជាគ្រីស្ទបរិស័ទ។

ការផ្សាយដំណឹងល្អ គឺជាការនិយាយចេញជាពាក្យសម្ដី ហើយ

ជាការចែកចាយដំណឹង។ មួយវិញទៀត ការផ្សាយដំណឹងល្អ គឺជាការស្មោះត្រង់ចំពោះព្រះជាម្ចាស់ដោយចែកចាយពីអ្វីដែលយើងបានពិភាក្សានៅក្នុងជំពូក៨ថា ព្រះគ្រីស្ទបានរៀបចំផ្លូវមួយសម្រាប់ព្រះដ៏បរិសុទ្ធ និងមនុស្សមានបាប ឲ្យបានជាមេត្រីនឹងគ្នាតាមរយៈការសុគត និងការរស់ពីសុគតឡើងវិញរបស់ទ្រង់។ ព្រះជាម្ចាស់នឹងធ្វើឲ្យមនុស្សក្លាយជាគ្រីស្ទបរិស័ទដ៏ពិតប្រាកដ នៅពេលដែលយើងចែកចាយដំណឹងល្អនេះ (សូមមើលយ៉ូហាន ១:១៣; កិច្ចការ ១៨:៩-១០)។ សរុបមក ការផ្សាយដំណឹងល្អជាការចែកចាយដំណឹងល្អដោយសេរី ហើយជាការទុកចិត្តលើព្រះជាម្ចាស់ឲ្យទ្រង់បំផ្លាស់បំប្រែមនុស្សឲ្យក្លាយជាគ្រីស្ទបរិស័ទ (សូមមើល កិច្ចការ ១៦:១៤)។ «ឯសេចក្តីសង្គ្រោះ នោះកើតមកតែពីព្រះយេហូវ៉ាទេ» (យ៉ូណាស ២:១០; យ៉ូហាន ១:១២-១៣)។

## របៀបផ្សាយដំណឹងល្អ

នៅពេលដែលខ្ញុំផ្សាយដំណឹងល្អ ខ្ញុំព្យាយាមបង្ហាញឲ្យអ្នកមិនជឿយល់នូវសេចក្តីបីយ៉ាង មុនពេលដែលពួកគេសម្រេចចិត្តជឿលើដំណឹងល្អ៖

- ការសម្រេចចិត្តជឿគឺត្រូវលះបង់ខ្ពស់ ដូច្នេះពួកគេត្រូវពិចារណាឲ្យបានល្អិតល្អន់ (សូមមើល លូកា ៩:៦២)។

- ការសម្រេចចិត្តជឿគឺត្រូវសម្រេចជាបន្ទាន់ ដូច្នេះត្រូវសម្រេចចិត្តឲ្យបានឆាប់ (សូមមើល លូកា ១២:២០)។

- ការសម្រេចចិត្តជឿរបស់យើងគឺមានតម្លៃណាស់ ដូច្នេះលោកអ្នកគួរសម្រេចចិត្តជឿ (សូមមើល យ៉ូហាន ១០:១០)។

អ្វីដែលបានរៀបរាប់ខាងលើនេះគឺជាសារដែលយើងចាំបាច់ត្រូវប្រាប់ដល់គ្រួសារ និងមិត្តភក្តិឲ្យដឹង។ នេះគឺជាសារដែលយើងចាំបាច់ត្រូវតែប្រាប់ពួកជំនុំទាំងមូលឲ្យដឹង។

មានធនធានល្អៗជាភាសាអង់គ្លេសមួយចំនួនស្ដីពីការផ្សាយដំណឹងល្អដែលបានបោះពុម្ពរួចហើយ។ ដើម្បីពិចារណាពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងការយល់ពីដំណឹងល្អរបស់យើង និងវិធីសាស្ត្រក្នុងការផ្សាយដំណឹងល្អដែលយើងប្រើ ខ្ញុំសូមណែនាំសៀវភៅរបស់លោក វីល មិតហ្ស៍ជើរ (Will Metzger) ដែលមានចំណងជើងថា *Tell the Truth* (បោះពុម្ពដោយ InterVarsity Press)។ ហើយសៀវភៅពីរក្បាលទៀតគឺនិពន្ធដោយលោក អៀន មើរ៉េ (Iain Murray) ដែលមានចំណងជើងថា *The Invitation System* និង *Revival and Revivalism* (បោះពុម្ពដោយ Banner of Truth Trust)។ ហើយសៀវភៅចុងក្រោយជាសៀវភៅរបស់ខ្ញុំផ្ទាល់ ដែលមានចំណងជើងថា *The Gospel and Personal Evangelism*

(បោះពុម្ពដោយ Crossway នឹងចេញឆាប់ៗនេះ) ។

ដូច្នេះ សញ្ញាសម្គាល់ដ៏សំខាន់មួយនៃពួកជំនុំដែលមានសុខភាពល្អ គឺការយល់ និងការអនុវត្តដ៏ត្រឹមត្រូវតាមព្រះគម្ពីរទៅលើការផ្សាយដំណឹងល្អ។ ការរីកចម្រើនដ៏ពិតប្រាកដ គឺជាការរីកចម្រើនដែលមកពីព្រះជាម្ចាស់តាមរយៈរាស្ត្ររបស់ទ្រង់។

ជំពូក១០

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ៖ ការយល់ដ៏ត្រឹមត្រូវពីសមាជិកភាពពួកជំនុំតាមព្រះគម្ពីរ

**តើព្រះគម្ពីរមាន**បានបង្រៀនថា ពួកជំនុំគួរតែមានសមាជិកភាពដែរឬទេ? មើលទៅដូចជា ព្រះគម្ពីរមិនបានចែងដូច្នេះសោះ។ ប្រសិនបើលោកអ្នកបើកមើលព្រះគម្ពីរសញ្ញាថ្មី នោះលោកអ្នកនឹងមិនឃើញមានរឿងរ៉ាវរបស់លោក អ័គីឡា និងប្រពន្ធរបស់គាត់ឈ្មោះ ព្រីស៊ីល ស្តីពីដំណើរផ្លាស់លំនៅទៅទីក្រុងរ៉ូម និងដំណើរដែលពួកគេសាកល្បងចូលរួមក្នុងពួកជំនុំមួយ ហើយសាកល្បងចូលរួមក្នុងពួកជំនុំមួយទៀត ហើយបន្ទាប់មកពួកគេសម្រេចចិត្តចូលរួមក្នុងពួកជំនុំមួយផ្សេងទៀត។ តាមអ្វីដែលយើងដឹងគឺថាគ្មាននរណាម្នាក់ដើរសាកល្បងពីពួកជំនុំមួយទៅពួកជំនុំមួយទៀត

នោះទេ ពីព្រោះនៅសម័យនោះ សហគមន៍មួយមានតែពួកជំនុំមួយប៉ុណ្ណោះ។ នោះហើយជាមូលហេតុដែលយើងមើលទៅដូចជាព្រះគម្ពីរមិនបានលើកឡើងពីសមាជិកភាព ក៏ដូចជាលើកឡើងពីបញ្ជីឈ្មោះសមាជិកពួកជំនុំនោះឡើយ។

ប៉ុន្តែ ពួកជំនុំក្នុងសម័យកាលព្រះគម្ពីរសញ្ញាថ្មី ពិតជាបានរក្សាទុកបញ្ជីឈ្មោះមនុស្សមួយចំនួនដូចជា បញ្ជីឈ្មោះស្ត្រីមេម៉ាយដែលទទួលការផ្គត់ផ្គង់ពីពួកជំនុំជាដើម (១ធីម៉ូថេ ៥)។ សំខាន់ជាងនេះទៅទៀត អត្ថបទគម្ពីរជាច្រើននៅក្នុងព្រះគម្ពីរសញ្ញាថ្មី បានលើកឡើងថា ពួកជំនុំពិតជាបានស្គាល់ពីសមាជិករបស់ពួកគេប្រាកដមែន។ ពួកគេបានដឹងថា នរណាជាសមាជិករបស់ពួកជំនុំពួកគេ និងនរណាមិនមែនជាសមាជិករបស់ពួកជំនុំពួកគេ។

ឧទាហរណ៍ បុរសម្នាក់ក្នុងចំណោមពួកជំនុំទីក្រុងកូរិនថូសបានប្រព្រឹត្តការកំផិត «ដែលមិនដែលទាំងមានឮនិយាយក្នុងសាសន៍ដទៃផង» (១កូរិនថូស ៥:១)។ លោក ប៉ុល បានសរសេរទៅកាន់ពួកជំនុំទីក្រុងកូរិនថូស ហើយលោកបានប្រាប់ពួកគេឲ្យបណ្តេញបុរសនេះចេញពីពួកជំនុំរបស់ខ្លួន។ ឥឡូវ សូមឈប់បន្តិច ដើម្បីគិតអំពីការនេះ៖ យើងមិនអាច*បណ្តេញនរណាម្នាក់*ចេញជាផ្លូវការបាននោះទេ ប្រសិនបើយើងមិនបាន*រាប់ម្នាក់នោះបញ្ចូល*ជាផ្លូវការតាំងពីដំបូងមកទេនោះ។

មើលទៅលោក ប៉ុល បាននិយាយសំដៅលើរឿងរបស់បុរសដដែលនេះម្តងទៀតនៅក្នុងសំបុត្របន្ទាប់របស់គាត់ទៅកាន់ពួកជំនុំទីក្រុងកូរិនថូសថា «ទោសដែលអ្នករាល់គ្នាភាគច្រើនបានធ្វើដល់មនុស្សបែបនេះ» (២កូរិនថូស ២:៦ គកស)។ សូមឈប់បន្តិច ដើម្បីគិតពីពាក្យថា «ភាគច្រើន»។ ហេតុអ្វីបានជាលោក ប៉ុល ហ៊ានប្រើពាក្យនេះ? យើងមិនអាចប្រើពាក្យថា ភាគច្រើន ដូចលោក ប៉ុល បានទេ លុះត្រាតែយើងដឹងយ៉ាងច្បាស់ថា មានមនុស្សប៉ុន្មាននាក់បានធ្វើ ឬមិនបានធ្វើនៅក្នុងក្រុមនោះ។ ហេតុដូច្នេះហើយ នៅពេលដែលលោក ប៉ុល ប្រើពាក្យនេះយើងអាចដឹងបានថា គាត់បានដឹងយ៉ាងច្បាស់ពីចំនួនសមាជិកនៅក្នុងពួកជំនុំកូរិនថូស។

លោក ប៉ុល បានយកចិត្តទុកដាក់ក្នុងកិច្ចការដែលដឹងថា «នរណាជាសមាជិក» ហើយ «នរណាមិនមែនជាសមាជិក»។ លោកបានយកចិត្តទុកដាក់លើការនេះ ដោយព្រោះព្រះអម្ចាស់យេស៊ូវ បានប្រទានសិទ្ធិអំណាចដល់ពួកជំនុំដើម្បីដាក់ដែនកំណត់មួយថា អ្នកណានៅក្នុងក្រុមរបស់ពួកគេ ហើយអ្នកណានៅក្នុងក្រុមរបស់លោកីយ៍។

ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាចងទុកអ្វីៗ
នៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើ

ស្រាយអ្វីៗនៅផែនដី នោះក៏នឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ (ម៉ាថាយ ១៨:១៨; សូមមើលផងដែរនៅ ម៉ាថាយ ១៦:១៩; យ៉ូហាន ២០:២៣)

យើងបាននិយាយរួចហើយថា ពួកជំនុំដែលមានសុខភាពល្អ គឺជាពួកជំនុំដែលបន្តបង្ហាញឲ្យឃើញពី ចរិតលក្ខណៈរបស់ព្រះជាម្ចាស់ច្រើនឡើងៗ។ ដូច្នេះហើយ យើងចង់ឲ្យកំណត់ត្រារបស់យើងនៅផែនដីនេះ ប្រហាក់ប្រហែលគ្នានឹងកំណត់ត្រានៅស្ថានសួគ៌ដែរ តាមដែលយើងអាចធ្វើបាន។ កំណត់ត្រានៅស្ថានសួគ៌នោះ គឺជាបញ្ជីឈ្មោះដែលបានកត់ចុះនៅក្នុងបញ្ជីជីវិតរបស់កូនចៀម (ភីលីព ៤:៣; វិវរណៈ ២១:២៧)។

ពួកជំនុំដែលមានសុខភាពល្អមានបំណងចិត្តនឹងទទួល ឬក៏បណ្តេញ អស់អ្នកណាដែលប្រកាសថា ខ្លួនជាអ្នកជឿ យោងតាមការបង្រៀនអ្នកនិពន្ធកណ្ឌគម្ពីរសញ្ញាថ្មីបានបង្គាប់មក។ នេះមានន័យថា ពួកជំនុំដែលមានសុខភាពល្អ ត្រូវតែប្រាថ្នាឲ្យមានការយល់ដ៏ត្រឹមត្រូវពីសមាជិកភាពពួកជំនុំតាមព្រះគម្ពីរ។

## សមាជិកភាពពួកជំនុំតាមព្រះគម្ពីរត្រូវមានការប្តេជ្ញា

ព្រះវិហារសង់ពីដុំឥដ្ឋ។ ហ្វូងចៀមមានចៀមនៅក្នុងនោះ។ ដើមទំពាំងបាយជូរមានខ្នែងរបស់វា។ រូបកាយមានអវយវៈ។ ហើយ

ពួកជំនុំមានសមាជិក។ នៅក្នុងន័យម្យ៉ាង សមាជិកភាពពួកជំនុំបានចាប់ផ្ដើមលេចឡើង នៅពេលដែលព្រះគ្រីស្ទបានសង្គ្រោះយើង ហើយទ្រង់បានរាប់យើងជាអវយវៈមួយនៃរូបកាយទ្រង់។ ប៉ុន្តែបន្ទាប់មក ការនេះតម្រូវឲ្យអវយវៈនីមួយៗបង្ហាញថា ពួកគេជាអវយវៈរបស់ព្រះគ្រីស្ទតាមរយៈការធ្វើជាសមាជិកពួកជំនុំតាមតំបន់។ ក្នុងន័យនេះ សមាជិកភាពពួកជំនុំចាប់ផ្ដើមមានឡើង នៅពេលដែលយើងប្ដេជ្ញាធ្វើជាសមាជិកនៅក្នុងពួកជំនុំជាក់លាក់ណាមួយ។ ក្នុងនាមយើងជាគ្រីស្ទបរិស័ទ យើងត្រូវតែប្ដេជ្ញាចូលរួមជាមួយនឹងពួកជំនុំណាមួយឲ្យជាក់លាក់។

ដូច្នេះហើយ បានជាព្រះគម្ពីរបង្គាប់ឲ្យយើងប្រជុំគ្នាជាទៀងទាត់ ដើម្បីឲ្យយើងអាចអរសប្បាយជាប្រចាំនៅក្នុងក្ដីសង្ឃឹមរួមរបស់យើង ហើយឲ្យយើងខ្ជាប់ខ្ជួនក្នុងការដាស់តឿនគ្នាទៅវិញទៅមក ឲ្យចេះស្រឡាញ់ ហើយនិងប្រព្រឹត្តការល្អ (ហេព្រើរ ១០:២៣-២៥)។ ការចូលជាសមាជិកភាពពួកជំនុំមិនមែនគ្រាន់តែជាការដែលយើងសរសេរឈ្មោះយើងដាក់ក្នុងសៀវភៅសមាជិកនោះទេ។ វាក៏មិនមែនជាអារម្មណ៍មនោសញ្ចេតនា ហើយក៏មិនមែនជាការសម្ដែងពីសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះកន្លែងណាមួយដែលយើងស្គាល់នោះដែរ។ សមាជិកភាពពួកជំនុំក៏មិនមែនជាការសម្ដែងពីភាពស្មោះស្ម័គ្រ ឬពីភាពមិនស្មោះស្ម័គ្រចំពោះឪពុកម្ដាយនោះ

ដែរ។ សមាជិកភាពពួកជំនុំគួរតែបង្ហាញឲ្យឃើញពីការប្ដេជ្ញាពិតប្រាកដទាំងពាក្យសម្ដី ទាំងការប្រព្រឹត្ត។ បើមិនដូច្នោះទេ វាជាការឥតប្រយោជន៍ ហើយវាជាការគ្រោះថ្នាក់ណាស់។ បន្ថែមទៀត យើងនឹងពិចារណាពីលក្ខណៈនៃការប្ដេជ្ញានេះ។

## សមាជិកភាពពួកជំនុំតាមព្រះគម្ពីរត្រូវមានការទទួលខុសត្រូវ

ការដែលពួកជំនុំបង្ហាញពី ការទទួលខុសត្រូវចំពោះគ្នានឹងគ្នា ហើយស្រឡាញ់គ្នាទៅវិញទៅមក នោះហើយជាអត្ថន័យនៃសមាជិកភាពពួកជំនុំ។ នៅពេលដែលយើងកំណត់អត្តសញ្ញាណខ្លួនយើងជាមួយនឹងពួកជំនុំតាមតំបន់ជាក់លាក់ណាមួយ នោះមានន័យថា យើងកំពុងតែប្រាប់ដល់គ្រូគង្វាល និងសមាជិកដទៃទៀតនៃពួកជំនុំនោះថា យើងមិនគ្រាន់តែប្ដេជ្ញាទៅនឹងពួកគេប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ប្រាប់ពួកគេផងដែរថា យើងប្ដេជ្ញាជាមួយនឹងពួកគេក្នុងការប្រជុំគ្នា ការថ្វាយតង្វាយ ការអធិស្ឋាន និងការបម្រើ។ ការធ្វើបែបនេះ បង្ហាញថាយើងកំពុងតែប្រាប់ពួកគេឲ្យរំពឹងការមួយចំនួនពីយើង ហើយពួកគេអាចជួយកែតម្រង់យើង ប្រសិនបើយើងមិនបានបំពេញតាមការរំពឹងនោះ។ ការចូលរួមជាសមាជិកក្នុងពួកជំនុំមួយ គឺជាការនិយាយថា “ឥឡូវនេះ ខ្ញុំជាទំនួលខុសត្រូវ

របស់អ្នក ហើយអ្នកជាទំនួលខុសត្រូវរបស់ខ្ញុំ»។ (ពិតប្រាកដ ការនេះខុសពីនិស្ស័យបាបរបស់យើង ហើយប្រហែលជាខុសពីវប្បធម៌របស់យើងផងដែរ)។

សមាជិកភាពពួកជំនុំតាមព្រះគម្ពីរមានន័យថា យើងត្រូវទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក។ អត្ថន័យនេះ ចេញមកពីកាតព្វកិច្ចរបស់យើងចំពោះគ្នាទៅវិញទៅមក ដូចដែលមានខគម្ពីរមួយចំនួនបានលើកឡើងក្នុងឃ្លា *គ្នាទៅវិញទៅមក* បែបដូចនេះថា ចូរស្រឡាញ់គ្នាទៅវិញទៅមក ចូរបម្រើគ្នាទៅវិញទៅមក ចូរលើកទឹកចិត្តគ្នាទៅវិញទៅមកជាដើម។ យើងគួរតែដាក់បញ្ចូលសេចក្តីបង្គាប់ទាំងនេះក្នុងលក្ខន្តិកៈនៃពួកជំនុំដែលមានសុខភាពល្អ (សូមមើលសេចក្តីបន្ថែម)។

បើសិនជាពួកជំនុំបានធ្វើតាមសញ្ញាសម្គាល់ទីប្រាំពីររហូតដល់ទីប្រាំបួនរួចហើយ នោះពួកគេនឹងអាចធ្វើតាមសញ្ញាសម្គាល់ទីដប់នេះបានយ៉ាងងាយ។ ពេលនោះសមាជិកនឹងកាន់តែទទួលស្គាល់ពីទំនួលខុសត្រូវរបស់ពួកគេ ចំពោះគ្នាទៅវិញទៅមក ដោយសារពួកគេស្រឡាញ់ដំណឹងល្អ និងទទួលស្គាល់ថា ការក្លាយជាគ្រីស្ទបរិស័ទជាកិច្ចការរបស់ព្រះជាម្ចាស់។ លើសពីនោះទៅទៀត ពួកគេនឹងផ្សាយដំណឹងល្អដោយបង្រៀនដល់ *អ្នកដែលចាប់អារម្មណ៍* ពីព្រះគ្រីស្ទថា គេត្រូវតែពិចារណាពីការលះបង់ជាមុនសិន

មុននឹងទទួលជឿព្រះគ្រីស្ទ។ ពួកគេនឹងលែងគិតថា ពួកគេនឹងទៅចូលរួមជាមួយពួកជំនុំ តែពេលណាដែលពួកគេចង់ចូលរួម ហើយពួកគេនឹងលែងចង់បានអ្វីម៉្យាងពីពួកជំនុំនោះទៀតហើយ។ ជាងនោះទៅទៀត ពួកគេនឹងមិនប្រៀបធៀបការចូលរួមជាមួយពួកជំនុំទៅនឹងការដើរមើលទំនិញល្អនោះឡើយ។ ប៉ុន្តែ ពួកគេនឹងរាប់ពួកជំនុំដូចជារូបកាយ ហើយអវយវៈរបស់រូបកាយនោះ នឹងថែរក្សាគ្នាទៅវិញទៅមក។ ពួកគេនឹងរាប់ពួកជំនុំដូចជាគ្រួសារដ៏ជិតស្និទ្ធរបស់ខ្លួនវិញ។

គួរឲ្យសោកស្ដាយ វាជារឿងសាមញ្ញទៅហើយដែលពួកជំនុំមានអ្នកចុះឈ្មោះក្នុងបញ្ជីសមាជិកភាពជាច្រើននាក់ ប៉ុន្តែមិនមានមនុស្សច្រើនដូចក្នុងបញ្ជីដែលមកចូលរួមថ្វាយបង្គំនោះទេ។ សូមស្រមៃមើល ពួកជំនុំមួយមានសមាជិកដល់ទៅបីរយនាក់ តែមានអ្នកចូលរួមថ្វាយបង្គំជាទៀងទាត់តែហុកសិបនាក់។ សព្វថ្ងៃនេះ មានគ្រូគង្វាលជាច្រើនដែលមានមោទនភាពចំពោះការដែលមានសមាជិកច្រើននៅក្នុងបញ្ជីសមាជិក ជាជាងមានការថប់បារម្ភដោយសារតែចំនួនសមាជិកពួកជំនុំជាច្រើនអត់មកចូលរួមថ្វាយបង្គំ។ យោងទៅតាមការសិក្សាមួយថ្មីៗនេះ ធម្មតាពួកជំនុំសារផើនបាទីស្ទ (Southern Baptist Church) មានសមាជិក២៣៣នាក់

ប៉ុន្តែមានសមាជិកតែ៧០នាក់ប៉ុណ្ណោះដែលចូលរួមថ្វាយបង្គំនៅព្រឹកថ្ងៃអាទិត្យ។

ចុះចំណែកឯការថ្វាយតង្វាយវិញ តើវាមានលក្ខណៈល្អប្រសើរជាងនេះដែរឬទេ? តើមានពួកជំនុំប៉ុន្មានដែលមានសមាជិកបានថ្វាយតង្វាយ១០ភាគរយ ឬលើសពី១០ភាគរយពីប្រាក់ចំណូលរបស់ពួកគេ?

ការដែលសមាជិកពួកជំនុំឈឺអាចជាឧបសគ្គដល់ចំនួនអ្នកចូលរួមថ្វាយបង្គំ ហើយកង្វះខាតថវិកាក៏អាចជាឧបសគ្គដល់ការថ្វាយតង្វាយផងដែរ។ បើមិនអញ្ចឹងទេ ពួកជំនុំងាយនឹងគិតតែពីចំនួនសមាជិក និងចំនួនប្រាក់តង្វាយតែប៉ុណ្ណោះ។ ពួកជំនុំងាយនឹងធ្លាក់ក្នុងការយកចំនួនសមាជិក និងចំនួនតង្វាយធ្វើជាព្រះជំនួសព្រះជាម្ចាស់វិញ ដូចដែលមនុស្សថ្វាយបង្គំរូបព្រះដូច្នោះដែរ ហើយការទោរទន់ទៅលើចំនួនទិន្នន័យសមាជិកពួកជំនុំប្រហែលជាងាយស្រួលជាងគោរពរូបព្រះផងមើលទៅ។ ប៉ុន្តែ ខ្ញុំគិតថា ព្រះជាម្ចាស់នឹងវាយតម្លៃទៅលើជីវិតរបស់យើង និងថ្លឹងថ្លែងលើកិច្ចការងាររបស់យើង ជាជាងរាប់ចំនួនសមាជិក និងប្រាក់តង្វាយពួកជំនុំរបស់យើង។

## សមាជិកភាពពួកជំនុំតាមព្រះគម្ពីរបញ្ជាក់ពីការទទួលសេចក្តីសង្គ្រោះ

តើអ្វីជាគ្រោះថ្នាក់ចំពោះសមាជិកពួកជំនុំដែលមិនចូលរួមថ្វាយបង្គំ និងសមាជិកពួកជំនុំដែលគេចវេសពីទំនួលខុសត្រូវរបស់ខ្លួននោះ? នៅពេលដែលសមាជិកពួកជំនុំដែលមិនចូលរួមក្នុងកិច្ចការណាមួយក្នុងពួកជំនុំ នោះពួកគេធ្វើឲ្យសមាជិកពួកជំនុំដ៏ពិត និងអ្នកមិនជឿយល់ច្រឡំថា តើការធ្វើជាគ្រីស្ទបរិស័ទមានន័យយ៉ាងដូចម្តេច។ ហើយសមាជិកពួកជំនុំដែលសកម្ម មិនបានផ្តល់ប្រយោជន៍អ្វីដល់សមាជិកពួកជំនុំដែលអសកម្មនោះឡើយ នៅពេលដែលពួកជំនុំអនុញ្ញាតឲ្យសមាជិកអសកម្មទាំងនោះនៅតែធ្វើជាសមាជិកពួកជំនុំដដែលនោះ។ ដ្បិតអីការក្លាយជាសមាជិកពួកជំនុំ គឺជាការទទួលស្គាល់ជារួមរបស់ពួកជំនុំទៅលើសេចក្តីសង្គ្រោះរបស់មនុស្សម្នាក់។ តើលោកអ្នកពិតជាយល់ពីការនេះទេ? នៅពេលដែលលោកអ្នករាប់នរណាម្នាក់ថាជាសមាជិកនៃពួកជំនុំរបស់លោកអ្នកនោះលោកអ្នកកំពុងតែទទួលស្គាល់ថា ពួកជំនុំរបស់លោកអ្នកទទួលស្គាល់បុគ្គលនោះថាជាគ្រីស្ទបរិស័ទហើយ។

ដូច្នេះ ប្រសិនបើក្រសែភ្នែករបស់ពួកជំនុំមិនបានសម្លឹងមើលបុគ្គលម្នាក់អស់រយៈពេលជាច្រើនខែ ឬច្រើនឆ្នាំមកហើយនោះអញ្ចឹងតើពួកជំនុំនោះអាចអះអាងថា បុគ្គលនោះបានរត់ប្រណាំង

យ៉ាងស្មោះត្រង់នៅក្នុងពួកជំនុំនោះបានយ៉ាងដូចម្ដេច? ប្រសិនបើបុគ្គលម្នាក់ឈប់មកចូលរួមជាមួយពួកជំនុំ ហើយថែមទាំងមិនបានចូលរួមជាមួយពួកជំនុំណាមួយផ្សេងទៀតទេ នោះប្រហែលបុគ្គលនោះ មិនមែនជាសមាជិកដ៏ពិតនៃពួកជំនុំយើងនោះទេ (យ៉ូហាន ២:១៩)? យើងមិនអាចដឹងបានពី មនុស្សដែលមិនចូលរួមសកម្មភាពក្នុងពួកជំនុំជាគ្រីស្ទបរិស័ទ ឬក៏អត់នោះទេ ប៉ុន្តែយើងគ្រាន់តែមិនអាចអះអាងថា ពួកគេជាគ្រីស្ទបរិស័ទប៉ុណ្ណោះ។ យើងមិនចាំបាច់ប្រាប់បុគ្គលនោះថា “អ្នកនឹងទៅស្ថាននរក” នោះទេ។ យើងគ្រាន់តែនិយាយថា “យើងមិនមានទំនុកចិត្តថាអ្នកនឹងទៅស្ថានសួគ៌នោះទេ”។ នៅពេលដែលមនុស្សម្នាក់មិនបានចូលរួមថ្វាយបង្គំជាយូរមកហើយ ប៉ុន្តែពួកជំនុំនៅតែទទួលស្គាល់ម្នាក់នោះជាសមាជិកពួកជំនុំទៀត នោះមានន័យថា ពួកគេមិនសូវមានប្រាជ្ញា ឬក៏ពួកគេកុហកខ្លួនឯង។

ពួកជំនុំដែលអនុវត្តសមាជិកភាពពួកជំនុំតាមព្រះគម្ពីរ មិនតម្រូវឲ្យសមាជិករបស់ខ្លួនមានលក្ខណៈល្អឥតខ្ចោះនោះទេ ប៉ុន្តែ ពួកជំនុំនោះតម្រូវឲ្យពួកគេមានការបន្ទាបខ្លួន និងភាពស្មោះត្រង់។ ពួកជំនុំនោះមិនបានហៅពួកគេមកឲ្យបង្ហាញពីការសម្រេចចិត្តជឿរបស់ពួកគេទេ ប៉ុន្តែពួកជំនុំនោះហៅពួកគេមកឲ្យធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវវិញ។ ធ្វើដូចនេះ ពួកជំនុំនៅតែឲ្យតម្លៃលើបទពិសោធន៍

ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗជាមួយនឹងព្រះជាម្ចាស់ ហើយពួកគេក៏មិនរំពឹងអ្វីខ្លាំងពេកទៅលើអស់អ្នកដែលមិនទាន់គ្រប់លក្ខណ៍ទាំងនោះដែរ។ អញ្ចឹងហើយបានជា ព្រះគម្ពីរសញ្ញាថ្មីបង្ហាញឲ្យឃើញពីតួនាទីមួយ ដើម្បីទទួលស្គាល់សមាជិកភាពពួកជំនុំជារួមតាមរយៈអស់អ្នកដែលនៅក្នុងការតាំងសញ្ញាជាមួយនឹងព្រះជាម្ចាស់ និងគ្នាទៅវិញទៅមក។

## សមាជិកភាពពួកជំនុំតាមព្រះគម្ពីរពិតជាមានតម្លៃ

ខ្ញុំសង្ឃឹមថាយើងនឹងឃើញស្ថិតិសមាជិកភាពនៅក្នុងពួកជំនុំកាន់តែមានអត្ថន័យខ្លាំងឡើងៗ រហូតទាល់តែសមាជិកពួកជំនុំដែលមាន*ឈ្មោះ*ក្នុងបញ្ជី គឺជាសមាជិកពួកជំនុំដែល*ចូលរួមពិតប្រាកដ*។ ពេលខ្លះ ការធ្វើដូចនេះបណ្ដាលឲ្យពួកជំនុំលុបឈ្មោះមនុស្សមួយចំនួនដែលអសកម្មចេញពីបញ្ជីឈ្មោះសមាជិកពួកជំនុំ ប៉ុន្តែនេះមិនមែនមានន័យថាយើងលុបឈ្មោះគេចេញពីចិត្តរបស់យើងដោយបំភ្លេចគេចោលនោះទេ។ ជាញឹកញាប់ ការធ្វើដូចនេះមានន័យថាពួកជំនុំត្រូវបង្រៀនសមាជិកថ្មីៗពីអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យសម្រាប់ពួកគេ ហើយពួកជំនុំត្រូវរំឭកយ៉ាងខ្ជាប់ខ្ជួនដល់សមាជិកពួកជំនុំដែលចូលរួមបច្ចុប្បន្នពីការប្ដេជ្ញារបស់ពួកគេនៅក្នុងសកម្មភាពផ្សេងៗរបស់ពួកជំនុំ។ នៅក្នុងពួកជំនុំផ្ទាល់របស់ខ្ញុំ យើងធ្វើ

ដូចនេះតាមវិធីផ្សេងៗដូចជា យើងមានបង្រៀនថ្នាក់សមាជិកភាពពួកជំនុំ ហើយយើងឲ្យពួកជំនុំអានលក្ខន្តិកៈពួកជំនុំឲ្យឮៗនៅពេលណាដែលយើងធ្វើពិធីលៀងព្រះអម្ចាស់។

នៅពេលដែលពួកជំនុំរបស់យើងកាន់តែមានសុខភាពល្អ នោះចំនួនមនុស្សចូលរួមនៅព្រឹកថ្ងៃអាទិត្យនឹងកើនឡើងលើសចំនួនឈ្មោះជាផ្លូវការនៅក្នុងបញ្ជីឈ្មោះសមាជិកពួកជំនុំរបស់យើងទៅទៀត។ ពិតប្រាកដណាស់ នេះគួរតែជាបំណងប្រាថ្នារបស់លោកអ្នកសម្រាប់ពួកជំនុំលោកអ្នកផងដែរ។

យើងមិនបង្ហាញពីសេចក្តីស្រឡាញ់របស់យើងចំពោះសមាជិកចាស់ដែលជាទីស្រឡាញ់របស់យើង ក្នុងរបៀបដ៏ត្រឹមត្រូវនោះទេ ប្រសិនបើយើងអនុញ្ញាតឲ្យពួកគេបន្តធ្វើជាសមាជិកនៅក្នុងពួកជំនុំរបស់យើង ដោយសារតែហេតុផលមនោសញ្ចេតនានោះ។ ប៉ុន្តែ យើងស្រឡាញ់ពួកគេ នៅពេលដែលយើងលើកទឹកចិត្តពួកគេឲ្យចូលរួមជាមួយនឹងពួកជំនុំមួយផ្សេងទៀត ដែលពួកគេអាចស្រឡាញ់ និងទទួលសេចក្តីស្រឡាញ់ជារៀងរាល់សប្តាហ៍ ឬជារៀងរាល់ថ្ងៃ។ ដូច្នេះហើយ នៅក្នុងលក្ខន្តិកៈរបស់ពួកជំនុំខ្ញុំ យើងសន្យាថា “នៅពេលដែលយើងចាកចេញពីពួកជំនុំនេះទៅ យើងនឹងចូលរួមជាមួយនឹងពួកជំនុំណាមួយផ្សេងទៀត ដែលយើងអាចបន្តអនុវត្តលក្ខន្តិកៈនេះ ហើយអាចបន្តអនុវត្តនូវគោលការណ៍នៃព្រះបន្ទូល ឲ្យ

បានឆាប់តាមដែលអាចធ្វើបាន»។ ការប្ដេជ្ញាចិត្តនេះ ជាផ្នែកមួយនៃដំណើរការនៃភាពជាសិស្សដែលមានសុខភាពល្អ ជាពិសេសនៅក្នុងសម័យបណ្ដោះអាសន្នយើងនេះ។

ការអនុវត្តសមាជិកភាពពួកជំនុំដោយយកចិត្តទុកដាក់នឹងផ្ដល់នូវអត្ថប្រយោជន៍ជាច្រើន។ ការអនុវត្តបែបនេះនឹងធ្វើឲ្យអ្នកមិនជឿមើលឃើញកាន់តែច្បាស់ពីទីបន្ទាល់នៃពួកជំនុំយើង។ ប្រសិនបើពួកជំនុំនោះអនុវត្តសមាជិកភាព នោះនឹងការពារអ្នកមានជំនឿទន់ខ្សោយពីការស្មានខុសថា ខ្លួនគេបានសង្គ្រោះ ដូច្នេះមិនចាំបាច់មានទម្លាប់ចូលរួមជាមួយពួកជំនុំនោះទេ។ ម្យ៉ាងវិញទៀត ការអនុវត្តសមាជិកភាពពួកជំនុំដោយប្រុងប្រយ័ត្ននឹងជួយឲ្យពួកជំនុំចេះបង្កើតសិស្សដែលកាន់តែមានភាពពេញវ័យខាងឯវិញ្ញាណ។ ការអនុវត្តបែបនេះនឹងជួយដល់អ្នកដឹកនាំពួកជំនុំឲ្យដឹងយ៉ាងប្រាកដថា ពួកគេមានទំនួលខុសត្រូវចំពោះអ្នកណាខ្លះ។ ព្រះជាម្ចាស់នឹងទទួលសិរីល្អតាមរយៈការទាំងអស់នេះ។

សូមអធិស្ឋានឲ្យពួកជំនុំកាន់តែផ្ដល់តម្លៃដល់សមាជិកភាពឲ្យបានល្អប្រសើរជាងបច្ចុប្បន្ននេះទៅទៀត។ តាមវិធីនេះ យើងអាចដឹងកាន់តែច្បាស់ថា យើងគួរអធិស្ឋានឲ្យអ្នកជឿណាខ្លះ លើកទឹកចិត្តដល់អ្នកជឿណាខ្លះ ក៏ដូចជាជំរុញចិត្តអ្នកជឿណាខ្លះ។ សមាជិកភាពពួកជំនុំមានន័យថា យើងមានការរួបរួមគ្នាយ៉ាង

ជាក់លាក់នៅក្នុងរូបកាយព្រះគ្រីស្ទ។ សមាជិកភាពពួកជំនុំមានន័យថា យើងធ្វើដំណើរជាមួយគ្នាប្រៀបដូចជាជនបរទេស និងពួកអ្នកដែលគ្រាន់តែសំណាក់នៅផែនដីនេះ ខណៈដែលយើងតម្រង់ឆ្ពោះទៅផ្ទះដ៏ពិតរបស់យើងនៅឯនគរស្ថានសួគ៌។ ពិតប្រាកដណាស់ សញ្ញាសម្គាល់មួយនៃពួកជំនុំដែលមានសុខភាពល្អ គឺការយល់ដ៏ត្រឹមត្រូវពីសមាជិកភាពពួកជំនុំតាមព្រះគម្ពីរ។

ជំពូក១១

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ៖ ការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ

**ការដាក់វិន័យពួកជំនុំ**តាមព្រះគម្ពីរគឺកើតចេញពីការយល់ដ៏ត្រឹមត្រូវពីសមាជិកភាពពួកជំនុំតាមព្រះគម្ពីរ។ សមាជិកភាពពួកជំនុំគូសបន្ទាត់កំណត់ព្រំខណ្ឌជុំវិញពួកជំនុំ ដោយញែកពួកជំនុំចេញពីលោកីយ៍។ ចំណែកឯ*ការដាក់វិន័យ*គឺជួយពួកជំនុំដែលរស់នៅក្នុងបន្ទាត់កំណត់ព្រំខណ្ឌនោះ ឲ្យនៅតែរក្សាបាននូវភាពស្មោះត្រង់ទៅនឹងបុព្វហេតុដើមដែលនាំឲ្យមានការគូសបន្ទាត់នោះ។ ការដាក់វិន័យពួកជំនុំផ្តល់នូវអត្ថន័យដល់សមាជិកពួកជំនុំ ហើយវាជាសញ្ញាសម្គាល់ដ៏សំខាន់មួយទៀតនៃពួកជំនុំដែលមានសុខភាពល្អ។

តើការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរមានលក្ខណៈយ៉ាងដូចម្ដេច? បើនិយាយឲ្យខ្លីទៅ ការដាក់វិន័យពួកជំនុំជាការមិនរាប់នរណាម្នាក់ដែលប្រកាសខ្លួនថា ជាអ្នកជឿចេញពីសមាជិកភាពពួកជំនុំ ហើយមិនអនុញ្ញាតឲ្យម្នាក់នោះចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ទេ ដោយព្រោះពួកគេមិនព្រមកែប្រែពីអំពើបាបដ៏ធ្ងន់ធ្ងររបស់ខ្លួន។

## ការឆ្លុះបញ្ចាំងឲ្យគេឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់

ដើម្បីយល់ពីការដាក់វិន័យពួកជំនុំ លោកអ្នកអាចរំឭកសារឡើងវិញពីអ្វីដែលខ្ញុំបាននិយាយនៅក្នុងជំពូក៣ ស្ដីអំពីគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការដែលទ្រង់បង្កើតសកលលោក មនុស្សជាតិ ពួកអ៊ីស្រាអែល និងពួកជំនុំ។ ព្រះជាម្ចាស់បានបង្កើតសកលលោកទាំងមូល ដើម្បីបង្ហាញសិរីល្អរបស់ទ្រង់។ បន្ទាប់មក ទ្រង់បានបង្កើតមនុស្សជាតិក្នុងគោលបំណងដូចគ្នា ហើយអ្វីដែលពិសេសនោះគឺទ្រង់បានបង្កើតយើង ដើម្បីឆ្លុះបញ្ចាំងពីរូបអង្គទ្រង់ (លោកុប្បត្តិ ១:២៧)។ មនុស្សជាតិដែលព្រះជាម្ចាស់បានបង្កើតមុនគេគឺលោកអ័ដាម និងនាង អេវ៉ា។ ពួកគេមិនបានបង្ហាញឲ្យឃើញពីសិរីល្អរបស់ទ្រង់ទេ ដូច្នេះទ្រង់បានបណ្ដេញពួកគេចេញពីសួនច្បារអេដែន។

បន្ទាប់មក ព្រះជាម្ចាស់បានត្រាស់ហៅពួកអ៊ីស្រាអែលឲ្យបង្ហាញពីសិរីល្អរបស់ទ្រង់។ ជាពិសេសនោះ ទ្រង់ឲ្យពួកគេបង្ហាញពីភាពបរិសុទ្ធ និងចរិតលក្ខណៈរបស់ទ្រង់ដល់ពួកជាតិសាសន៍ដទៃឲ្យឃើញ ដូចដែលទ្រង់បានបើកសម្ដែងឲ្យឃើញនៅក្នុងក្រឹត្យវិន័យ (សូមមើល លេវីវិន័យ ១៩:២; សុភាសិត ២៤:១, ២៥)។ ចាប់តាំងពីពេលនោះមក ក្រឹត្យវិន័យនេះគឺជាមូលដ្ឋានសម្រាប់កែតម្រង់ និងបណ្ដេញមនុស្សមួយចំនួនចេញពីសហគមន៍ (ដូចជានៅក្នុងជនគណនា ១៥:៣០-៣១)។ ហើយក្រឹត្យវិន័យនេះគឺជាមូលដ្ឋានក្នុងការបណ្ដេញពួកអ៊ីស្រាអែលចេញពីទឹកដី។

ចុងក្រោយ យើងបានរៀបរាប់ថា ព្រះជាម្ចាស់បានបង្កើតពួកជំនុំដើម្បីឲ្យពួកគេអាចនឹងឆ្លុះបញ្ចាំងពីចរិតលក្ខណៈរបស់ទ្រង់ច្រើនឡើងៗ ដូចដែលទ្រង់បើកសម្ដែងឲ្យឃើញពីចរិតលក្ខណៈរបស់ទ្រង់នៅក្នុងព្រះបន្ទូល។ ដូច្នេះ ដូចដែលបានឃើញនៅក្នុងសាច់រឿងជាបន្តបន្ទាប់ក្នុងព្រះគម្ពីរទាំងមូលហើយ ការដាក់វិន័យពួកជំនុំ គឺជាការបណ្ដេញបុគ្គលម្នាក់ដែលនាំភាពអាម៉ាស់ដល់ដំណឹងល្អចេញ រួមទាំងមិនបានបង្ហាញនូវការប្ដេជ្ញាចិត្តក្នុងការនាំកិត្តិយសដល់ដំណឹងល្អផងដែរ។ ការដាក់វិន័យជួយពួកជំនុំឲ្យឆ្លុះបញ្ចាំងពីចរិតលក្ខណៈដ៏ឧត្តមរបស់ព្រះជាម្ចាស់បានយ៉ាងត្រឹមត្រូវ។ ការដាក់វិន័យជួយពួកជំនុំឲ្យរក្សាភាពបរិសុទ្ធខាងឯវិញ្ញាណ។ ការដាក់

វិន័យពួកជំនុំគឺប្រៀបដូចជាការខិតខំដុសខាត់កញ្ចក់ឆ្លុះ ហើយលុបស្នាមប្រឡាក់ចេញ (សូមមើល ២កូរិនថូស ៦:១៤-៧:១; ១៣:២; ១ធីម៉ូថេ ៦:៣-៥; ២ធីម៉ូថេ ៣:១-៥)។ ហេតុអ្វីត្រូវមានការដាក់វិន័យពួកជំនុំ? មូលហេតុនៃការដាក់វិន័យពួកជំនុំគឺដើម្បីឲ្យចរិតលក្ខណៈដ៏បរិសុទ្ធ និងពេញដោយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់អាចលេចឡើងឲ្យឃើញកាន់តែច្បាស់ និងជះពន្លឺកាន់តែភ្លឺឡើងៗដល់លោកីយ៍នេះ។

## តើការដាក់វិន័យពួកជំនុំមានដំណើរការយ៉ាងដូចម្ដេច?

តើដំណើរការនៃការដាក់វិន័យពួកជំនុំមានលំដាប់លំដោយយ៉ាងដូចម្ដេច? ដោយសារតែស្ថានភាពនៃការប្រព្រឹត្តបាបរបស់ពួកជំនុំមានលក្ខណៈខុសៗគ្នា នោះគ្រូគង្វាលចាំបាច់ត្រូវប្រើប្រាជ្ញា ដើម្បីឲ្យដឹងថា ត្រូវដាក់វិន័យពួកជំនុំក្នុងស្ថានភាពនីមួយៗយ៉ាងណានោះ។

ប៉ុន្តែទោះជាយ៉ាងណា ព្រះបន្ទូលរបស់ព្រះយេស៊ូវនៅក្នុងកណ្ឌម៉ាថាយ ១៨:១៥-១៧ បានផ្ដល់នូវលក្ខខណ្ឌទូទៅ ស្ដីពីការដាក់វិន័យពួកជំនុំ។ យោងតាមខគម្ពីរនេះ លោកអ្នកត្រូវចាប់ផ្ដើមដោយការដោះស្រាយជាមួយបងប្អូនដែលធ្វើបាបតែពីរនាក់គាត់ដោយស្ងាត់ៗជាមុនសិន។ ប្រសិនបើអ្នកដែលធ្វើបាបនោះប្រែចិត្ត នោះ

ដំណើរការនៃការដាក់វិន័យត្រូវបញ្ចប់។ ប្រសិនបើអ្នកដែលធ្វើបាបនោះមិនប្រែចិត្តទេ នោះយើងត្រូវដោះស្រាយជាមួយម្នាក់នោះជាលើកទីពីរ ដោយមានអ្នកជឿម្នាក់ផ្សេងទៀតចូលរួម។ ប្រសិនបើម្នាក់នោះនៅតែមិនប្រែចិត្តទៀតនោះ ចូរយើងធ្វើដូចដែលព្រះយេស៊ូវបានមានបន្ទូល «នោះត្រូវតែប្រាប់ដល់ពួកជំនុំ ហើយបើមិនព្រមស្តាប់ពួកជំនុំទៀត នោះត្រូវតែរាប់គាត់ទុកជាអ្នកក្រៅសាសន៍ ឬជាអ្នកយកពន្ធវិញ» (ម៉ាថាយ ១៨:១៧)។ នេះមានន័យថា យើងត្រូវរាប់ម្នាក់នោះទុកដូចជាអ្នកមិនជឿ។

## តើលោកអ្នកគួរតែថ្កោលទោសអ្នកដទៃឬ?

សព្វថ្ងៃនេះ គំនិតទាំងមូលស្តីពីការដាក់វិន័យពួកជំនុំមិនពីរោះស្តាប់ទេចំពោះមនុស្សជាច្រើន។ លើសពីនោះទៀត តើព្រះយេស៊ូវមិនបានហាមសិស្សរបស់ទ្រង់មិនឲ្យថ្កោលទោសអ្នកដទៃទៀតទេឬអី? ហើយតើការដាក់វិន័យលើនរណាម្នាក់នោះមិនមែនជាការថ្កោល-ទោសទេឬអី? ក្នុងន័យម្យ៉ាង ទ្រង់ពិតជាបានហាមពួកគេដោយទ្រង់មានបន្ទូលថា «កុំឲ្យថ្កោលទោសគេឡើយ ដើម្បីមិនឲ្យមានគេថ្កោលអ្នកវិញ» (ម៉ាថាយ ៧:១)។ ប៉ុន្តែ នៅក្នុងកណ្ឌដំណឹងល្អដដែលនោះ ព្រះយេស៊ូវក៏បានបង្រៀនពួកជំនុំឲ្យកែតម្រង់សមាជិករបស់ពួកគេចំពោះអំពើបាបដែលពួកគេបានធ្វើជាសាធារណៈថែមទៀត

ផង (ម៉ាថាយ ១៨:១៥-១៧; លូកា ១៧:៣)។ ដូច្នេះ អត្ថន័យនៃព្រះបន្ទូលរបស់ព្រះយេស៊ូវដែលថា «កុំឲ្យថ្កោលទោសគេឡើយ» គឺមិនមែនមានន័យថា ទ្រង់ហាមឃាត់យើងមិនឲ្យថ្កោលទោសក្នុងគ្រប់ទាំងរឿងនោះទេ។

ពិតប្រាកដណាស់ព្រះជាម្ចាស់ គឺជាមេជំនុំជម្រះ។ ទ្រង់ជំនុំជម្រះលោក អ័ដាម នៅក្នុងសួនអេដែន។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ទ្រង់ជំនុំជម្រះទាំងជាតិសាសន៍ និងទាំងបុគ្គលម្នាក់ៗ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ទ្រង់មានបន្ទូលសន្យាថា ទ្រង់នឹងជំនុំជម្រះគ្រីស្ទបរិស័ទទាំងអស់ទៅតាមទង្វើរបស់ពួកគេ (សូមមើល ១កូរិនថូស ៣)។ ហើយទ្រង់មានបន្ទូលសន្យាថា នៅថ្ងៃចុងក្រោយ ទ្រង់នឹងបើកសម្ដែងរូបអង្គទ្រង់ជាមេជំនុំជម្រះចុងក្រោយលើមនុស្សជាតិទាំងអស់ (សូមមើល វិវរណៈ ២០)។

នៅក្នុងការជំនុំជម្រះរបស់ព្រះជាម្ចាស់ ទ្រង់មិនដែលជំនុំជម្រះខុសនោះទេ។ ទ្រង់សុចរិតជានិច្ច (សូមមើល យ៉ូស្វេ ៧; ម៉ាថាយ ២៣; លូកា ២; កិច្ចការ ៥; រ៉ូម ៩)។ ពេលខ្លះ គោលបំណងរបស់ទ្រង់ក្នុងការជំនុំជម្រះ គឺដើម្បីកែតម្រង់ ជួយសង្គ្រោះ និងស្ដារឡើងវិញ ដូចដែលទ្រង់ដាក់វិន័យកូនរបស់ទ្រង់។ ពេលខ្លះ គោលបំណងរបស់ទ្រង់ក្នុងការជំនុំជម្រះ គឺដើម្បីសងសឹក ហើយការជំនុំជម្រះរបស់ទ្រង់ គឺជាការសម្រេចចុងក្រោយដោយមិនអាចតវ៉ាបាន ដូច

ពេលដែលទ្រង់ចាក់សេចក្តីក្រោធរបស់ទ្រង់ទៅលើពួកមានបាប (សូមមើល ហេព្រើរ ១២)។ ទោះបីក្នុងគោលបំណងណាក៏ដោយ ការជំនុំជម្រះរបស់ព្រះជាម្ចាស់គឺយុត្តិធម៌ជានិច្ច។

នាពេលបច្ចុប្បន្ននេះ មនុស្សខ្លះប្រហែលជាភ្ញាក់ផ្អើល នៅពេលដែលគេដឹងថា ពេលខ្លះព្រះជាម្ចាស់ប្រើមនុស្សដើម្បីជំនុំជម្រះជំនួសទ្រង់។ ព្រះជាម្ចាស់បានផ្តល់តួនាទីដល់រដ្ឋអំណាចដើម្បីជំនុំជម្រះប្រជាពលរដ្ឋរបស់ខ្លួន (សូមមើល រ៉ូម ១៣)។ ទ្រង់បង្គាប់ឲ្យគ្រីស្ទបរិស័ទជំនុំជម្រះខ្លួនឯង (សូមមើល ១កូរិនថូស ១១:២៨; ហេព្រើរ ៤; ២ពេត្រុស ១:៥)។ ពេលខ្លះ ព្រះជាម្ចាស់ថែមទាំងបង្គាប់ឲ្យពួកជំនុំជំនុំជម្រះសមាជិកនៅក្នុងពួកជំនុំទៀតផង ទោះបីជាការជំនុំជម្រះនោះមិនមែនជាការសម្រេចចុងក្រោយដែលមិនអាចតវ៉ាបានដូចជាទ្រង់ជំនុំជម្រះក៏ដោយ។

នៅក្នុងកណ្ឌម៉ាថាយជំពូក១៨ កណ្ឌ១កូរិនថូសជំពូក៥ និងជំពូក៦ និងនៅក្នុងអត្ថបទគម្ពីរផ្សេងទៀត ព្រះជាម្ចាស់បានបង្រៀនពួកជំនុំឲ្យជំនុំជម្រះសមាជិករបស់ខ្លួន។ ការជំនុំជម្រះនេះ គឺក្នុងគោលបំណងជួយសង្គ្រោះ មិនមែនក្នុងគោលបំណងសងសឹកនោះទេ (រ៉ូម ១២:១៩)។ លោក ប៉ុល បានបង្គាប់ដល់ពួកជំនុំនៅទីក្រុងកូរិនថូសឲ្យប្រគល់មនុស្សកំផិតទៅអារក្សសាតាំង “ឲ្យបំផ្លាញនិស្ស័យសាច់ឈាមគេ ប្រយោជន៍ឲ្យព្រលឹងវិញ្ញាណបាន

សង្គ្រោះ» (១កូរិនថូស ៥:៥)។ លោកក៏បានបង្គាប់ដូចគ្នានេះដែរ ដល់លោក ធីម៉ូថេ ទាក់ទងទៅនឹងពួកគ្រូក្លែងក្លាយនៅក្នុងទីក្រុង អេភេសូរ (១ធីម៉ូថេ ១:២០)។

## តើត្រូវបិទទ្វារ ឬបើក?

យើងមិនគួរភ្ញាក់ផ្អើលទេដែលព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យថ្កោលទោស ឬដាក់វិន័យពួកជំនុំក្នុងរូបភាពណាមួយនោះ។ ប្រសិនបើពួកជំនុំរំពឹងចង់បង្រៀនពីរបៀបដែលគ្រីស្ទបរិស័ទ *គួរធ្វើ* នោះពួកគេត្រូវតែបង្រៀនពីរបៀបដែលគ្រីស្ទបរិស័ទ *មិនគួរធ្វើ*ដែរ។ ហើយអ្វីដែលខ្ញុំបារម្ភនោះគឺថា របៀបដែលពួកជំនុំជាច្រើនដែលបានអនុវត្តទៅលើការបង្កើតសិស្សគឺប្រៀបដូចជាការចាក់ទឹកទៅក្នុងធុងដែលធ្លាយអញ្ចឹង ដោយសារពួកគេផ្ដោតការយកចិត្តទុកដាក់ទាំងស្រុងទៅលើតែអ្វីដែលពួកគេចាក់ចូល ប៉ុន្តែ ពួកគេមិនបានគិតដល់របៀបដែលសិស្សទទួល ហើយនិងរក្សាវានោះទេ។ ដូច្នេះហើយបានជានៅបច្ចុប្បន្ននេះ មានពួកជំនុំជាច្រើនលែងដាក់វិន័យលើសមាជិក។

នាពេលថ្មីៗនេះ អ្នកនិពន្ធម្នាក់ដែលសរសេរសៀវភៅទាក់ទងទៅនឹងការរីកចម្រើននៃពួកជំនុំ លោកបានធ្វើការសន្និដ្ឋានពីយុទ្ធសាស្ត្ររបស់លោក លើការធ្វើឲ្យពួកជំនុំរីកចម្រើនដោយនិយាយថា “ចូរបើកទ្វារមុខ ហើយបិទទ្វារក្រោយ”។ និយាយដូច្នេះ លោក

ចង់មានន័យថា ពួកជំនុំគួរតែបង្កើតឲ្យមានភាពរាក់ទាក់ចំពោះអ្នកមិនជឿ ហើយត្រូវមានផែនការថែបំប៉នអ្នកទាំងនោះឲ្យបានល្អ។ ទាំងនេះគឺជាគោលដៅល្អ ហើយសព្វថ្ងៃនេះ ខ្ញុំជឿថា គ្រូគង្វាល និងពួកជំនុំភាគច្រើនប្រាថ្នាចង់ធ្វើដូចនេះរួចទៅហើយ។ ប៉ុន្តែពួកជំនុំខ្លះផ្តោតទៅលើការនេះខ្លាំងពេក។ ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំផ្តល់ជូននូវអ្វីដែលខ្ញុំជឿថា វាជាយុទ្ធសាស្ត្រតាមព្រះគម្ពីរ៖ *យាមទ្វារមុខឲ្យបានហ្មត់ចត់ ហើយបើកចំហទ្វារក្រោយ*។ នេះមានន័យថា យើងត្រូវធ្វើឲ្យអ្នកខាងក្រៅពិបាកចូលជាសមាជិកពួកជំនុំយើង ហើយងាយនឹងបណ្តេញពួកគេចេញវិញ។ ចូរចងចាំថា ផ្លូវដែលនាំទៅរកជីវិត គឺតូចចង្អៀត មិនមែនធំទូលាយនោះទេ។ ខ្ញុំជឿថា ការធ្វើដូចនេះនឹងជួយឲ្យពួកជំនុំស្តារឡើងវិញ នូវលក្ខណៈខុសប្លែករបស់ពួកគេពីលោកីយ៍ដូចដែលព្រះជាម្ចាស់បានកំណត់មក។

ដើម្បីចាប់ផ្តើមដាក់វិន័យពួកជំនុំ យើងត្រូវមានការប្រុងប្រយ័ត្នក្នុងការទទួលសមាជិកថ្មីជាងមុន។ ពួកជំនុំគួរតែសួរគ្រប់ទាំងបុគ្គលដែលចង់ធ្វើជាសមាជិកថា តើអ្វីទៅជាដំណឹងល្អ ហើយសូមឲ្យម្នាក់ៗផ្តល់នូវភស្តុតាងមួយចំនួន ពីការយល់នូវលក្ខណៈនៃជីវិតដែលថ្វាយសិរីល្អដល់ព្រះគ្រីស្ទ។ អ្នកដែលចង់ធ្វើជាសមាជិកនឹងទទួលបាននូវអត្ថប្រយោជន៍នៅពេលដែលពួកគេដឹងថា ពួកជំនុំរំពឹងចង់បានអ្វីពីពួកគេ និងដឹងពីសារៈសំខាន់នៃការប្តេជ្ញាចិត្តចំពោះ

ពួកជំនុំ។ ប្រសិនបើពួកជំនុំកាន់តែមានការប្រុងប្រយ័ត្នទៅលើការទទួលស្គាល់ ក៏ដូចជាការទទួលនូវសមាជិកថ្មីៗ នោះពួកគេនឹងមិននឿយហត់ក្នុងការដាក់វិន័យពួកជំនុំ ដើម្បីកែតម្រង់ពួកគេច្រើនលើកច្រើនសានៅពេលក្រោយនោះទេ។

## ការដាក់វិន័យពួកជំនុំឲ្យសមហេតុសមផល

ចូរប្រយ័ត្ន! ពួកជំនុំអាចដាក់វិន័យសមាជិករបស់ខ្លួនដោយមិនសមហេតុសមផល។ ព្រះគម្ពីរសញ្ញាថ្មីបង្រៀនយើងមិនឲ្យថ្កោលទោសចិត្តគំនិតរបស់អ្នកដទៃ (សូមមើល ម៉ាថាយ ៧:១) ឬក៏ថ្កោលទោសគ្នាទៅវិញទៅមកអំពីកំហុសតូចតាច (សូមមើល រ៉ូម ១៤-១៥)។ នៅក្នុងការដាក់វិន័យពួកជំនុំ យើងមិនត្រូវមានចេតនាចង់សងសឹកនោះទេ ប៉ុន្តែចេតនារបស់យើងត្រូវពេញដោយសេចក្តីស្រឡាញ់ ដោយបង្ហាញនូវ «ចិត្តមេត្តាករុណាដល់មនុស្សឯទៀតទាំងភ័យខ្លាច» (យ៉ូដាស ១:២៣ គកស)។ ជាការពិតណាស់ ការដាក់វិន័យពួកជំនុំពោរពេញដោយបញ្ហាដែលយើងត្រូវដោះស្រាយដោយប្រាជ្ញា និងដោយយកចិត្តទុកដាក់។ ប៉ុន្តែ យើងត្រូវចងចាំថា ជីវិតជាគ្រីស្ទបរិស័ទមិនងាយស្រួលនោះទេ ហើយយើងងាយនឹងធ្វើខុសណាស់។ ប៉ុន្តែ យើងមិនគួរយកលេសដោយមិនព្រមអនុវត្តការណាមួយ ដោយសារការលំបាករបស់យើងនោះឡើយ។

ពួកជំនុំតាមតំបន់នីមួយៗ មានទំនួលខុសត្រូវ ក្នុងការថ្កោលទោសជីវិតរស់នៅរបស់អ្នកដឹកនាំខ្លួន និងសេចក្ដីបង្រៀនរបស់ពួកគាត់ ហើយក៏មានទំនួលខុសត្រូវក្នុងការថ្កោលទោសជីវិតរស់នៅរបស់សមាជិកពួកជំនុំផងដែរ ជាពិសេស នៅពេលដែលអ្នកដឹកនាំឬសមាជិកពួកជំនុំធ្វើឲ្យទីបន្ទាល់របស់ពួកជំនុំខូចឈ្មោះ (សូមមើលកិច្ចការ ១៧; ១កូរិនថូស ៥; ១ធីម៉ូថេ ៣; យ៉ាកុប ៣:១; ២ពេត្រុស ៣; ២យ៉ូហាន)។

ការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ គឺជាការស្ដាប់បង្គាប់ដ៏សាមញ្ញដល់ព្រះជាម្ចាស់ ហើយជាការទទួលស្គាល់ថា យើងត្រូវការជំនួយពីទ្រង់។ សូមលោកអ្នកស្រមៃមើល តើមានអ្វីកើតឡើង ប្រសិនបើព្រះជាម្ចាស់មិនដែលប្រើមនុស្សណាម្នាក់ក្នុងចំណោមយើង ដើម្បីនឹងអនុម័តការជំនុំជម្រះរបស់ទ្រង់ទេនោះ? តើមានអ្វីកើតឡើង ប្រសិនបើឪពុកម្ដាយមិនដែលដាក់វិន័យកូនៗរបស់ខ្លួនទេនោះ? តើមានអ្វីកើតឡើង ប្រសិនបើរដ្ឋអំណាច មិនដែលដាក់ទោសដល់ជនល្មើសច្បាប់សោះនោះ? ចុះ! តើមានអ្វីកើតឡើង ប្រសិនបើពួកជំនុំមិនដែលទូន្មានប្រៀនប្រដៅសមាជិករបស់ខ្លួនទេនោះ? បើដូច្នោះមែន នៅពេលដែលយើងឈរនៅទីជំនុំជម្រះចុងក្រោយ យើងទាំងអស់គ្នានឹងទទួលការជំនុំជម្រះដ៏ខ្លាំងក្លាពីព្រះជាម្ចាស់ ដោយសារយើងមិនដែលទទួលការជំនុំជម្រះដ៏តិចតួច

ណាមួយពីបងប្អូនយើងនៅលើផែនដីនេះទាល់តែសោះ។ នេះហើយជាក្ដីមេត្តាដ៏ធំធេងរបស់ព្រះជាម្ចាស់មាន ចំពោះយើង គឺថាទ្រង់បង្រៀនយើងពីការជំនុំជម្រះនៅផែនដីនាពេលបច្ចុប្បន្ននេះ ដែលការជំនុំជម្រះនេះឆ្លុះបញ្ចាំងពីការជំនុំជម្រះនៅថ្ងៃចុងក្រោយដែលមិនអាចកែប្រែបាន (សូមមើល លូកា ១២:៤-៥)។

ខាងក្រោមនេះជាហេតុផលវិជ្ជមានប្រាំយ៉ាងក្នុងការដាក់វិន័យពួកជំនុំ ក្នុងគោលបំណងកែតម្រង់ពួកគេ។ ការដាក់វិន័យបែបនេះបង្ហាញពីសេចក្ដីស្រឡាញ់៖

១) ដល់ការស្ដារបុគ្គលដែលទទួលការដាក់វិន័យឡើងវិញ

២) ចំពោះគ្រីស្ទបរិស័ទដទៃទៀត ដោយសារពួកគេនឹងមើលឃើញពីផលអវិជ្ជមាននៃអំពើបាប

៣) ដល់សុខភាពនៃពួកជំនុំទាំងមូល

៤) ចំពោះអ្នកមិនជឿនៅក្នុងសហគមន៍យើង ដោយសារពួកជំនុំបានរក្សាទីបន្ទាល់យ៉ាងល្អ

៥) ចំពោះសិរីល្អនៃព្រះជាម្ចាស់។ ភាពបរិសុទ្ធខាងឯវិញ្ញាណរបស់យើងគួរតែឆ្លុះបញ្ចាំងពីភាពបរិសុទ្ធរបស់ទ្រង់

ការដែលក្លាយជាសមាជិកម្នាក់នៅក្នុងពួកជំនុំ គួរតែមានតម្លៃចំពោះយើង មិនមែនសម្រាប់សេចក្ដីអំនួតរបស់យើងនោះទេ ប៉ុន្តែសម្រាប់កិត្តិនាមព្រះជាម្ចាស់វិញ។ ការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ គឺជាសញ្ញាសម្គាល់ដ៏សំខាន់មួយនៃពួកជំនុំដែលមានសុខភាពល្អ។

ជំពូក១២

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ៖ ការបង្កើតសិស្ស និងការលូតលាស់តាមព្រះគម្ពីរ

**សញ្ញាសម្គាល់ដ៏សំខាន់**មួយទៀតនៃពួកជំនុំដែលមានសុខភាពល្អ គឺការដែលពួកជំនុំទាំងមូលប្រាថ្នាចង់បានការរីកចម្រើនតាមរបៀបដែលព្រះគម្ពីរបានចែង។ នេះមានន័យថា សមាជិកពួកជំនុំមានការរីកចម្រើនខាងឯវិញ្ញាណ មិនមែនរីកចម្រើនតែចំនួនសមាជិកប៉ុណ្ណោះទេ។

សព្វថ្ងៃនេះ មនុស្សមួយចំនួនគិតថា បុគ្គលម្នាក់អាចនៅតែជាគ្រីស្ទបរិស័ទក្មេងខ្ចីខាងឯវិញ្ញាណពេញមួយជីវិតក៏បាន។ ពួកគេចាត់ទុកការរីកចម្រើនខាងឯវិញ្ញាណថាជាការចាំបាច់សម្រាប់តែពួកសិស្សដែលមានចិត្តឆេះឆួលប៉ុណ្ណោះ។ ប៉ុន្តែភស្តុតាងនៃជីវិត

ខាងឯវិញ្ញាណ គឺការរីកចម្រើន។ ប្រសិនបើដើមឈើមួយដើមមានជីវិត នោះវានឹងលូតលាស់ធំឡើងជាមិនខាន។ ប្រសិនបើសត្វមួយក្បាលមានជីវិត នោះវានឹងធំធាត់ឡើង។ ការដែលមានជីវិតនោះមានន័យថា មានការរីកចម្រើនលូតលាស់ ហើយការរីកចម្រើនលូតលាស់ គឺមានន័យថា មានការជឿនឡើងទៅមុខ រហូតទាល់តែស្លាប់។

លោក ប៉ុល សង្ឃឹមថា ពួកជំនុំនៅទីក្រុងកូរិនថូសនឹងរីកចម្រើនឡើងខាងឯជំនឿរបស់ពួកគេ (២កូរិនថូស ១០:១៥)។ ហើយលោកក៏សង្ឃឹមផងដែរថា ពួកជំនុំនៅទីក្រុងអេភេសូរនឹង “បានធំឡើង ខាងឯគ្រប់ការទាំងអស់ក្នុងទ្រង់ ដែលទ្រង់ជាសិរសា គឺជាព្រះគ្រីស្ទ” (អេភេសូរ ៤:១៥; កូល៉ុស ១:១០; ២ ថែស្សាឡូនីច ១:៣)។ លោក ពេត្រុស បានដាស់តឿនដល់ពួកអ្នកអានសំបុត្ររបស់លោកថា “ចូរសង្វាតរកទឹកដោះសុទ្ធខាងវិញ្ញាណ ដូចជាទារកដែលទើបនឹងកើត ធ្វើដូច្នោះដើម្បីឲ្យអ្នករាល់គ្នាបានចម្រើនឡើងដរាបដល់ទទួលបានសេចក្តីសង្គ្រោះ» (១ពេត្រុស ២:២ គគខ)។

គ្រូគង្វាល ក៏ដូចជាសមាជិកពួកជំនុំមួយចំនួនខ្វល់តែពីចំនួនមនុស្សដែលទទួលពិធីបុណ្យជ្រមុជទឹក ថ្វាយតង្វាយ និងចំនួនមនុស្សដែលចូលជាសមាជិកពួកជំនុំតែប៉ុណ្ណោះ។ ការរីកចម្រើនប្រភេទនេះ ងាយមើលឃើញផ្ទាល់នឹងភ្នែកណាស់។ ប៉ុន្តែ ស្ថិតិនៃ

ការរីកចម្រើនបែបនេះមានការខ្វះចន្លោះច្រើន មិនដល់កម្រិតនៃការរីកចម្រើនដ៏ពិតប្រាកដដែលអ្នកនិពន្ធនៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានពណ៌នា ហើយក៏មិនដល់កម្រិតដូចដែលព្រះជាម្ចាស់សព្វព្រះហឫទ័យនោះដែរ។

## ការរីកចម្រើនក្នុងភាពបរិសុទ្ធ

តើយើងដឹងថា គ្រីស្ទបរិស័ទរីកចម្រើនក្នុងព្រះគុណបានយ៉ាងដូចម្ដេច? យើងមិនអាចដឹងបានថាពួកគេរីកចម្រើន ឬមិនរីកចម្រើនក្នុងព្រះគុណ ដោយសារតែពួកគេមានចិត្តរំភើប ឬដោយសារពួកគេប្រើភាសាគ្រីស្ទបរិស័ទច្រើន ឬក៏ដោយសារពួកគេមានចំណេះដឹងច្រើនពីព្រះគម្ពីរនោះទេ។ ទោះបើពួកគេបង្ហាញសេចក្ដីស្រឡាញ់កាន់តែច្រើនឡើងៗចំពោះពួកជំនុំ ឬពួកគេបង្ហាញពីទំនុកចិត្តក្នុងជំនឿរបស់ពួកគេ នោះក៏មិនមែនមានន័យថា ពួកគេកំពុងតែរីកចម្រើនក្នុងព្រះគុណនោះដែរ។ យើងថែមទាំងមិនអាចដឹងប្រាកដថា គ្រីស្ទបរិស័ទកំពុងតែរីកចម្រើនក្នុងព្រះគុណ ទោះបើយើងមើលឃើញពីភាពឆេះឆួលដែលគាត់មានចំពោះព្រះជាម្ចាស់ក៏ដោយ។ ការទាំងអស់នេះ*ប្រហែល*ជាភស្ដុតាងបង្ហាញពីការរីកចម្រើនក្នុងព្រះគុណរបស់គ្រីស្ទបរិស័ទដ៏ពិតប្រាកដ។ ទន្ទឹមគ្នានេះដែរ សញ្ញាដ៏សំខាន់បំផុតមួយនៃការរីកចម្រើនដែលគេតែងមើលរំលង ប៉ុន្តែយើង

*ត្រូវតែ*កត់សម្គាល់ពីវា ព្រោះនោះគឺជាការរីកចម្រើនឡើងក្នុងភាពបរិសុទ្ធដែលកើតចេញពីការដែលគ្រីស្ទបរិស័ទលះកាត់ចិត្តខ្លួនឯងចោល (សូមមើល យ៉ាកុប ២:២០-២៤; ២ពេត្រុស ១:៥-១១)។ គេអាចសម្គាល់ពួកជំនុំមួយដែលមានសុខភាពល្អបានតាមរយៈការដែលពួកជំនុំយកចិត្តទុកដាក់ជាខ្លាំងទៅលើភាពបរិសុទ្ធក្នុងជីវិតសមាជិក។

ការដែលយើងធ្វេសប្រហែសនឹងភាពបរិសុទ្ធ គឺវាដូចជាការដែលយើងធ្វេសប្រហែសនឹងការដាក់វិន័យពួកជំនុំយ៉ាងដូច្នោះដែរ ហើយការធ្វើដូចនេះនឹងធ្វើឲ្យពួកជំនុំពិបាកនឹងរីកចម្រើនខាងឯវិញ្ញាណ។ នៅពេលដែលពួកជំនុំអនុញ្ញាតឲ្យអាកប្បកិរិយាមិនបរិសុទ្ធបន្តកើតមានដោយឥតពិនិត្យពិច័យឲ្យបានច្បាស់លាស់ នោះពួកជំនុំនឹងមានការយល់ច្រឡំ ហើយយល់មិនច្បាស់ពីជីវិតដែលថ្វាយសិរីល្អដល់ព្រះគ្រីស្ទឡើយ។ ពួកជំនុំប្រភេទនេះប្រៀបដូចជាសួនច្បារមួយដែលគេមិនដែលដកស្មៅឥតប្រយោជន៍ចោលទាល់តែសោះដែរ ឬប្រៀបដូចជាសួនច្បារមួយដែលគេមិនដែលដាំដើមឈើល្អដូច្នោះដែរ។

# លក្ខណៈនិងអ្វីដែលមិនមែនជាលក្ខណៈនៃការរីកចម្រើន

កាតព្វកិច្ចមួយរបស់ពួកជំនុំ គឺធ្វើជាឧបករណ៍សម្រាប់ព្រះជាម្ចាស់ប្រើ ដើម្បីជួយឲ្យរាស្ត្ររបស់ទ្រង់រីកចម្រើនក្នុងព្រះគុណ។ ព្រះជាម្ចាស់អាចប្រើមនុស្សពេញវ័យខាងឯវិញ្ញាណដែលប្រាថ្នាចង់ញែកខ្លួនជាបរិសុទ្ធ ដើម្បីជួយឲ្យពួកជំនុំរីកចម្រើនខាងឯវិញ្ញាណ។ នៅពេលដែលព្រះជាម្ចាស់សង់រាស្ត្ររបស់ទ្រង់ឡើង ស្របពេលដែលពួកគេរីកចម្រើនជាមួយគ្នាក្នុងភាពបរិសុទ្ធ និងក្នុងសេចក្ដីស្រឡាញ់ដែលចេះលះបង់ នោះពួកគេនឹងបង្កើនសមត្ថភាពក្នុងការដាក់វិន័យពួកជំនុំ ក៏ដូចជាជួយពួកគេក្នុងការបង្កើតសិស្ស។

នៅពេលដែលលោកអ្នកពិនិត្យមើលទៅលើជីវិតពួកជំនុំណាមួយ នោះលោកអ្នកនឹងឃើញថា ការរីកចម្រើនមានច្រើនប្រភេទ។ ខាងក្រោមនេះ គឺជាផ្នែកមួយចំនួនទាក់ទងនឹងការរីកចម្រើនដែលលោកអ្នកអាចមើលឃើញ៖

- ចំនួននៃអ្នកដែលឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ឲ្យចេញទៅធ្វើជាបេសកជនមានការកើនឡើង៖ “ខ្ញុំមានអំណរក្នុងការចែកចាយដំណឹងល្អជាមួយនឹងអ្នកជិតខាងរបស់ខ្ញុំដែលមកពីវៀតណាម។ ខ្ញុំគិតថា ព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឲ្យធ្វើជាបេសកជននៅប្រទេស...”។

- សមាជិកដែលមានវ័យចំណាស់កាន់តែមានចិត្តឆេះឆួលឡើងវិញក្នុងការផ្សាយដំណឹងល្អ និងក្នុងការហ្វឹកហ្វឺនសមាជិកក្មេងខ្ចីខាងឯវិញ្ញាណ៖ «ខ្ញុំសូមអញ្ជើញប្អូនមកញ៉ាំអាហារពេលល្ងាចជាមួយនឹងខ្ញុំម្ដង»។
- សមាជិកដែលមានវ័យក្មេង ទៅចូលរួមពិធីបុណ្យសពរបស់សមាជិកពួកជំនុំវ័យចំណាស់ ដោយសារសេចក្ដីស្រឡាញ់ មិនមែនដោយសារកាតព្វកិច្ចនោះទេ៖ «ក្នុងនាមខ្ញុំជាយុវជនម្នាក់ ខ្ញុំយល់ឃើញថា ជាការល្អណាស់ដែលលោក និងលោកស្រី... យកចិត្តទុកដាក់ចំពោះខ្ញុំ បង្ហាត់បង្រៀនខ្ញុំ»។
- ពួកជំនុំកាន់តែអធិស្ឋានច្រើនឡើងៗ ហើយកាន់តែផ្ដោតការអធិស្ឋានរបស់ពួកគេទៅលើការផ្សាយដំណឹងល្អ និងឱកាសធ្វើព័ន្ធកិច្ច៖ «ខ្ញុំកំពុងតែចាប់ផ្ដើមក្រុមតូចបែបផ្សាយដំណឹងល្អមួយក្រុម នៅកន្លែងធ្វើការរបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ភ័យបន្តិចបន្តួចដែរ។ សូមពួកជំនុំជួយអធិស្ឋានឲ្យ...»។
- សមាជិកកាន់តែចែកចាយដំណឹងល្អជាមួយនឹងអ្នកមិនជឿ។
- សមាជិកពួកជំនុំមិនសូវរំពឹងលើកម្មវិធីរបស់អ្នកដឹកនាំពួកជំនុំទេ ប៉ុន្តែពួកគេបង្កើតឲ្យមានកម្មវិធីជាបេសកកម្មផ្សេងៗដោយខ្លួនឯងផ្ទាល់វិញ៖ «លោកគ្រូ តើលោកគ្រូគិតយ៉ាងម៉េចដែរ ប្រសិនបើខ្ញុំ និងបុប្ផារៀបចំកម្មវិធីណូអែលដោយប្រកបអាហារជាមួយនឹងនារីៗក្នុងពួកជំនុំយើង ដើម្បីយកឱកាសផ្សាយដំណឹងល្អដល់ពួកគេ?»

- យើងកត់សម្គាល់ឃើញមានការសន្ទនាទាក់ទងខាងឯវិញ្ញាណ នៅពេលសមាជិកពួកជំនុំជួបជុំគ្នាជាលក្ខណៈមិនផ្លូវការ ហើយពួកគេហ៊ានសារភាពអំពើបាបដែលខ្លួនបានប្រព្រឹត្តនៅចំពោះមុខគ្នា។ ពេលជាមួយគ្នា ពួកគេនាំបញ្ហាទាំងនោះទៅឯឈើឆ្កាង៖ “បងអើយ! ខ្ញុំកំពុងតែប្រឈមមុខនឹងអំពើបាប...”។
- ការថ្វាយដោយការលះបង់មានការកើនឡើង៖ “អូនសម្លាញ់! តើមានវិធីណាដែលយើងអាចដកលុយ ១00,000រៀលពីថវិកាប្រចាំខែរបស់យើង ដើម្បីនឹងទំនុកបម្រុង...”។
- ផលផ្លែនៃព្រះវិញ្ញាណមានការកើនឡើង។
- សមាជិកពួកជំនុំលះបង់ការងារ ដើម្បីបម្រើពួកជំនុំ៖ “តើឯងមានបានឮទេថា ពូសុខបដិសេធមិនធ្វើការនៅរៀងរាល់ចុងសប្តាហ៍ ដើម្បីឲ្យគាត់មានពេលវេលាគ្រប់គ្រាន់បន្តបម្រើពួកជំនុំទៀត?”
- បុរសជាប្តី ដឹកនាំប្រពន្ធរបស់ពួកគេដោយមានការលះបង់៖ “អូនសម្លាញ់! តើមានការអ្វីខ្លះដែលបងអាចធ្វើ ដើម្បីឲ្យអូនមានអារម្មណ៍ថា បងស្រឡាញ់អូន និងយល់ចិត្តអូន?”
- ស្ត្រីជាប្រពន្ធ ចុះចូលចំពោះប្តីរបស់ខ្លួន៖ “បងសម្លាញ់! តើមានអ្វីខ្លះដែលអូនអាចធ្វើបាននៅថ្ងៃនេះ ដើម្បីជួយសម្រាលបន្ទុករបស់បង?”
- ឪពុកម្តាយ ស្តីបង្ហាត់បង្រៀនកូនៗរបស់ខ្លួនខាងឯជំនឿ៖ “យប់នេះ យើងនឹងអធិស្ឋានឲ្យអ្នកបម្រើព័ន្ធកិច្ចនៅក្នុងប្រទេស...”។

- ពួកជំនុំមានគំនិតរួមក្នុងការដាក់វិន័យដល់អ្នកមិនព្រមកែប្រែពីអំពើបាប និងអ្នកប្រព្រឹត្តបាបជាសាធារណៈ។
- ពួកជំនុំបង្ហាញសេចក្តីស្រឡាញ់រួមចំពោះអ្នកមិនព្រមកែប្រែពីអំពើបាប ដោយព្យាយាមចូលកៀកពួកគេ ហើយប្រាប់ពួកគេឲ្យបែរចេញពីអំពើបាប មុនពេលដែលពួកជំនុំដាក់វិន័យដល់ពួកគេ៖ «ប្រសិនបើអ្នកបានទទួលសារនេះហើយ សូមទូរស័ព្ទមកខ្ញុំវិញ ដ្បិតខ្ញុំចង់ដឹងពីអ្នក»។

ទាំងនេះគ្រាន់តែជាឧទាហរណ៍មួយចំនួន ស្តីពីការរីកចម្រើនរបស់ពួកជំនុំដែលគ្រីស្ទបរិស័ទទូលសូមពីព្រះជាម្ចាស់ ហើយព្យាយាមអនុវត្តតាម។ តើពួកជំនុំដែលមានសុខភាពល្អនឹងកើនចំនួនសមាជិកដែរឬទេ? ជាធម្មតា ពួកជំនុំដែលមានសុខភាពល្អនឹងកើនចំនួនសមាជិកដែរ ដោយព្រោះពួកគេបានបង្ហាញពីទីបន្ទាល់ដែលធ្វើឲ្យអ្នកមិនជឿចាប់អារម្មណ៍ទៅនឹងដំណឹងល្អ។ ប៉ុន្តែ យើងមិនគួរសន្មតថា ពួកជំនុំដែលមានសុខភាពល្អត្រូវតែកើនចំនួនសមាជិកនោះទេ ពីព្រោះពេលខ្លះ ព្រះជាម្ចាស់មានគោលបំណងផ្សេងទៀត ដូចជាទ្រង់បង្រៀនរាស្ត្ររបស់ទ្រង់ឲ្យចេះអត់ធ្មត់។ យើងត្រូវផ្តោតការយកចិត្តទុកដាក់របស់យើងទៅលើភាពស្មោះត្រង់ និងការរីកចម្រើនខាងឯវិញ្ញាណដ៏ពិត។

តើអ្វីទៅជាមូលហេតុដែលបណ្តាលឲ្យមានការរីកចម្រើន

បែបហ្នឹង? មូលហេតុដែលបណ្តាលឲ្យមានការរីកចម្រើនបែបហ្នឹង គឺ៖ ការអធិប្បាយតាមព្រះគម្ពីរ ទេវវិទ្យាតាមព្រះគម្ពីរដ៏ត្រឹមត្រូវ ការយកដំណឹងល្អជាគោល ការយល់ពីការក្លាយជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរ ការយល់ពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ ការយល់ពីសមាជិកភាពពួកជំនុំតាមព្រះគម្ពីរ ការយល់ពីការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ និងការយល់ពីភាពជាអ្នកដឹកនាំតាមព្រះគម្ពីរ។

ប្រសិនបើពួកជំនុំបង្រៀនតែអ្វីដែលជាគំនិតរបស់គ្រូគង្វាល ឬពួកគេមានការសង្ស័យពីព្រះជាម្ចាស់ច្រើនជាងថ្វាយបង្គំទ្រង់ ឬមិនបង្រៀនដំណឹងល្អឲ្យបានត្រឹមត្រូវ ហើយផ្សាយដំណឹងល្អមិនត្រឹមត្រូវ ឬមិនឲ្យតម្លៃដល់សមាជិកពួកជំនុំ ឬពួកគេធ្វើតាមគ្រូគង្វាលជាជាងព្រះជាម្ចាស់ នោះពួកគេពិបាករំពឹងថា ពួកគេនឹងអាចរកបាននូវសហគមន៍មួយដែលរួបរួមគ្នា ឬសហគមន៍មួយដែលចេះស្អាងចិត្តគ្នាណាស់។ ពួកជំនុំបែបនេះនឹងមិនថ្វាយសិរីល្អដល់ព្រះជាម្ចាស់នោះទេ។

## ព្រះជាម្ចាស់ទទួលសិរីល្អតាមរយៈ ការរីកចម្រើននៃពួកជំនុំ

នៅពេលដែលយើងជួបប្រទះពួកជំនុំដែលកាន់តែមានលក្ខណៈដូចជាព្រះគ្រីស្ទនោះ តើអ្នកណាទទួលសិរីល្អ? ព្រះជាម្ចាស់ជា

អ្នកទទួលសិរីល្អ។ ដូចដែលលោក ប៉ុល បានរៀបរាប់ថា «តែព្រះបានធ្វើឲ្យដុះ ដូច្នេះ អ្នកដាំ និងអ្នកដែលស្រោចទឹកមិនមែនជាអ្វីទេ គឺមានតែព្រះដែលធ្វើឲ្យដុះប៉ុណ្ណោះទើបសំខាន់» (១កូរិនថូស ៣:៦-៧; កូល៉ុស ២:១៩ គកស)។

ដូចគ្នានេះដែរ លោក ពេត្រុស ធ្វើសេចក្តីសន្និដ្ឋានក្នុងសំបុត្រទីពីររបស់លោកដែលលោកសរសេរទៅកាន់គ្រីស្ទបរិស័ទដំបូងមួយក្រុមថា «សូមអ្នករាល់គ្នាចម្រើនឡើងក្នុងព្រះគុណ និងការស្គាល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះរបស់យើង។ សូមថ្វាយសិរីល្អដល់ព្រះអង្គ នៅពេលឥឡូវនេះ និងដរាបដល់អស់កល្បជានិច្ច។ អាម៉ែន» (២ពេត្រុស ៣:១៨ គកស)។ យើងប្រហែលជាច្រឡំថា ការរីកចម្រើនរបស់យើងនឹងនាំសិរីល្អដល់ខ្លួនឯង។ ប៉ុន្តែលោក ពេត្រុស បានដឹងច្បាស់ជាងយើង ដោយលោកបានសរសេរថា «ត្រូវប្រព្រឹត្តដោយទៀងត្រង់នៅក្នុងចំណោមពួកសាសន៍ដទៃ ដើម្បីនៅកន្លែងណាដែលគេនិយាយដើមអ្នករាល់គ្នា ទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ នោះគេបានឃើញអំពើល្អរបស់អ្នករាល់គ្នា ហើយលើកតម្កើងព្រះ នៅថ្ងៃដែលទ្រង់យាងមក» (១ពេត្រុស ២:១២ គកស)។ លោក ពេត្រុស ចាំព្រះបន្ទូលរបស់ព្រះយេស៊ូវយ៉ាងច្បាស់ថា «ដូច្នេះ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អរបស់

អ្នករាល់គ្នា *ហើយសរសើរអ្នករាល់គ្នា?»* មិនដូច្នេះទេ! គឺ *សរសើរតម្កើងដល់ព្រះវរបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌*វិញ (ម៉ាថាយ ៥:១៦ គកស)។ ការដែលពួកជំនុំព្យាយាមបង្កើតសិស្ស និងការដែលពួកគេព្យាយាមឲ្យមានការរីកចម្រើន គឺជាសញ្ញាសម្គាល់មួយទៀតនៃពួកជំនុំដែលមានសុខភាពល្អ។

ជំពូក១៣

# សញ្ញាសម្គាល់ដ៏សំខាន់ៗនៃពួកជំនុំដែលមានសុខភាពល្អ ៖ ការដឹកនាំពួកជំនុំតាមព្រះគម្ពីរ

**តើពួកជំនុំដែលមាន**សុខភាពល្អគួរមានការដឹកនាំបែបណា? តើពួកជំនុំមានចំណែកក្នុងការដឹកនាំ ដើម្បីធ្វើឲ្យប្រាកដថា គ្រូគង្វាលអធិប្បាយពីដំណឹងល្អបានត្រឹមត្រូវដែរឬទេ? ពិតប្រាកដណាស់ ពួកជំនុំមានចំណែក (កាឡាទី ១)។ តើអ្នកបម្រើមានចំណែកក្នុងការដឹកនាំជាគំរូក្នុងការធ្វើព័ន្ធកិច្ចពួកជំនុំដែរឬទេ? ជាការពិតណាស់ (កិច្ចការ ៦)។ តើការដឹកនាំពួកជំនុំតាមព្រះគម្ពីរតម្រូវឲ្យមានគ្រូគង្វាលដែលអធិប្បាយព្រះបន្ទូលយ៉ាងស្មោះត្រង់ដែរឬទេ? ជាការពិតណាស់ (២ធីម៉ូថេ ៤)។ ប៉ុន្តែ ព្រះគម្ពីរក៏បានលើកឡើងនូវអំណោយទានផ្នែកដឹកនាំមួយទៀតដល់ពួកជំនុំ ដើម្បីជួយពួកគេឲ្យក្លាយជាពួកជំនុំដែលមានសុខភាពល្អ។ អំណោយទាននោះគឺមុខងារជាចាស់ទុំ។

ប្រាកដណាស់ មានចំណុចសំខាន់ៗជាច្រើនដែលយើងអាចលើកយកមកនិយាយអំពីការដឹកនាំពួកជំនុំដូចដែលបានបង្ហាញនៅក្នុងព្រះគម្ពីរ ប៉ុន្តែខ្ញុំចង់ផ្តោតសំខាន់ទៅលើមុខងារជាចាស់ទុំ ដ្បិតខ្ញុំគិតថា មានពួកជំនុំជាច្រើនមិនបានដឹងថា ពួកគេកំពុងតែបាត់បង់អ្វីខ្លះនោះទេ ដោយសារតែពួកគេពុំមានចាស់ទុំ។ ក្នុងនាមខ្ញុំជាគ្រូគង្វាលម្នាក់ ខ្ញុំអធិស្ឋានសូមឲ្យព្រះជាម្ចាស់ត្រាស់ហៅមនុស្សដែលមានអំណោយទានខាងវិញ្ញាណ និងខាងឯកិច្ចការជាគ្រូគង្វាលឲ្យធ្វើជាពួកចាស់ទុំនៅក្នុងពួកជំនុំ។ សូមព្រះជាម្ចាស់តែងតាំងមនុស្សបែបហ្នឹងឲ្យបានច្រើននាក់!

ប្រសិនបើព្រះជាម្ចាស់ពិតជាបានប្រទានអំណោយទានដល់បុគ្គលណាម្នាក់នៅក្នុងពួកជំនុំដែលមានអត្តចរិតគំរូ មានប្រាជ្ញាបែបជាគ្រូគង្វាល និងមានអំណោយទានខាងការបង្រៀន ហើយប្រសិនបើបន្ទាប់ពីពួកជំនុំអធិស្ឋានឲ្យគាត់រួចហើយ ពួកគេទទួលស្គាល់លក្ខណសម្បត្តិទាំងនេះ នោះពួកគេគួរតែញែកម្នាក់នោះឲ្យធ្វើជាអ្នកចាស់ទុំ។

## តើចាស់ទុំមានលក្ខណៈបែបណា?

នៅក្នុងកណ្ឌកិច្ចការជំពូក៦ ពួកជំនុំដ៏ក្មេងខ្ចីនៅទីក្រុងយេរូសាឡឹមបានចាប់ផ្តើមឈ្លោះគ្នាពីរបៀបដែលគេចែកអាហារដល់ស្ត្រី

មេម៉ាយ។ ដូច្នេះហើយ ពួកសាវ័កបានកោះហៅពួកជំនុំឲ្យជ្រើសរើសមនុស្សមួយចំនួនដែលអាចត្រួតមើលការចែកអាហារនេះឲ្យបានប្រសើរជាង។ ពួកសាវ័កបានផ្ទេរកិច្ចការនេះដល់អ្នកផ្សេងទៀត ដើម្បីឲ្យពួកគេអាច «ខំព្យាយាមក្នុងសេចក្តីអធិស្ឋាន និងការផ្សាយព្រះបន្ទូលវិញ» (កិច្ចការ ៦:៤)។

សរុបសេចក្តីមក ការផ្ទេរការងារបែបនេះបានក្លាយជាការបែងចែកការងាររវាងពួកចាស់ទុំ និងអ្នកជំនួយដែលពួកជំនុំក្រោយៗមកទៀតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានអនុវត្តតាម។ ពួកចាស់ទុំគឺជាអ្នកដែលខំព្យាយាមក្នុងសេចក្តីអធិស្ឋាន និងការផ្សាយព្រះបន្ទូលដល់ពួកជំនុំ ខណៈដែលអ្នកជំនួយមើលការខុសត្រូវលើការរៀបចំកម្មវិធីផ្សេងៗក្នុងពួកជំនុំ។

ពួកជំនុំរាល់គ្នាអើយ! តើអ្នករាល់គ្នាចាប់ផ្តើមមើលឃើញពីអត្ថប្រយោជន៍នៃអំណោយទានដ៏អស្ចារ្យនេះហើយឬនៅ? និយាយឲ្យចំទៅ ព្រះជាម្ចាស់កំពុងមានបន្ទូលថា «យើងនឹងជ្រើសរើសយកមនុស្សមួយចំនួនពីក្នុងចំណោមឯងរាល់គ្នា ហើយយើងនឹងញែកគេទុកដើម្បីឲ្យគេអធិស្ឋានសម្រាប់ឯងរាល់គ្នា និងដើម្បីបង្រៀនឯងរាល់គ្នាអំពីយើង»។

## ពួកចាស់ទុំ និងពួកជំនុំ

គ្រប់ទាំងពួកជំនុំបានជ្រើសរើសបុគ្គលមួយចំនួនទុក ដើម្បីបំពេញមុខងារជាពួកចាស់ទុំរួចទៅហើយ ទោះបើគេហៅងារបុគ្គលទាំងនោះផ្សេងៗគ្នា អ្នកជំនួយ ឬអ្នកដឹកនាំព័ន្ធកិច្ចក៏ដោយ។ ងារសម្រាប់តំណែងនេះមានបីនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាងារដែលគេអាចប្រើផ្លាស់ប្តូរគ្នាបាន។ ងារទាំងនេះក្នុងភាសាក្រិកគឺ ប្រស់ប៊ូថេរស៍ (អ្នកត្រួតត្រា) ផូយមិន (ពួកចាស់ទុំ) និងអេភីសកាផស់ (គ្រូគង្វាល)។ ងារទាំងបីនេះ គឺប្រើសំដៅលើមុខងារតែមួយ (កិច្ចការ ២០:១៧, ២៨)។

យោងតាមប្រវត្តិសាស្ត្រពួកជំនុំ យើងឃើញថា មានពួកជំនុំជាច្រើននិយមយកពួកចាស់ទុំជាអ្នកដឹកនាំ។ និកាយ ខនគ្រេ្គហ្គេហ្សិនណាលីស្ទ៍ (Congregationalists) ដើមដំបូងនៅសតវត្សទី១៦ បានបង្រៀនថា ចាស់ទុំ គឺជាតំណែងមួយសម្រាប់ពួកជំនុំសញ្ញាថ្មី។ នៅសតវត្សទី១៨ និង១៩ យើងក៏ឃើញមានពួកចាស់ទុំនៅក្នុងនិកាយ បាទីស្ទ (Baptist) ជាអ្នកដឹកនាំនៅក្នុងប្រទេសអាមេរិកផងដែរ។ តាមពិត នាយកដំបូងនៃនិកាយ សៅឌើនបាទីស្ទ (Southern Baptist Convention) លោក ដាប់បលយូ. ប៊ី. ចនសុន (W. B. Johnson) បានសរសេរកិច្ចព្រមព្រៀងមួយក្នុងឆ្នាំ១៨៤៦ ដោយស្នើសុំឲ្យពួកជំនុំបាទីស្ទ (Baptist) ទាំងអស់បង្កើត

ឲ្យមានរចនាសម្ព័ន្ធចាស់ទុំ ដ្បិតការអនុវត្តបែបនេះ គឺត្រឹមត្រូវតាមព្រះគម្ពីរ។

និកាយ បាទីស្ទ (Baptist) និងនិកាយ ប្រេសប៊ីធើរាន (Presbyterians) បានខ្វែងគំនិតគ្នាលើចំណុចពីរទាក់ទងទៅនឹងពួកចាស់ទុំ។ ហើយខ្ញុំគិតថា យើងទាំងអស់គ្នាគួរយល់ពីការខ្វែងគំនិតគ្នានេះ ទោះបើយើងមិនមែនជាពួកបាទីស្ទ (Baptist) ឬពួកប្រេស-ប៊ីធើរាន (Presbyterian)។

ទីមួយនិកាយ បាទីស្ទ (Baptists) គឺជាពួកដែលយកពួកជំនុំជាធំ។ ពួកគេជឿថា ព្រះគម្ពីរបង្រៀនថា ការសម្រេចចិត្តចុងក្រោយលើអ្វីៗទាំងអស់ គឺអាស្រ័យលើពួកជំនុំទាំងមូល មិនមែនអាស្រ័យលើពួកចាស់ទុំក្នុងពួកជំនុំ ឬអ្នកផ្សេងដែលមិននៅក្នុងពួកជំនុំនោះទេ។ នៅពេលដែលព្រះយេស៊ូវកំពុងតែបង្រៀនសិស្សរបស់ទ្រង់អំពីការដោះស្រាយជាមួយនឹងបងប្អូនដែលប្រព្រឹត្តបាប ទ្រង់បានមានបន្ទូលថា ពួកជំនុំជាសាលាឧទ្ធរណ៍កាត់ក្តីចុងក្រោយ គឺមិនមែនពួកចាស់ទុំ នាយកសង្ឃ ឬក្រុមប្រឹក្សាភិបាលណាមួយដែលត្រូវកាត់ក្តីចុងក្រោយនោះទេ (ម៉ាថាយ ១៨:១៧)។ នៅពេលដែលពួកសាវ័កស្វែងរកមនុស្សមួយចំនួន ដើម្បីឲ្យធ្វើជាអ្នកជំនួយ នោះពួកគេបានផ្តល់ការសម្រេចចិត្តដល់ពួកជំនុំ ដូចដែលយើងទើបតែបានពិភាក្សាខាងលើ។

ដូចគ្នានេះដែរ នៅក្នុងសំបុត្ររបស់លោក ប៉ុល គាត់ក៏បានសរសេរថា ពួកជំនុំជាអ្នកសម្រេចចិត្តចុងក្រោយ។ កណ្ឌ១កូរិនថូសជំពូក៥ លោកប៉ុល មិនបានស្តីបន្ទោសដល់គ្រូគង្វាល ពួកចាស់ទុំ ឬអ្នកជំនួយនោះទេ ចំពោះការដែលពួកគេអត់ឱនឲ្យបុគ្គលដែលធ្វើបាប ប៉ុន្តែលោកបានស្តីបន្ទោសដល់ពួកជំនុំទាំងមូលទៅវិញ។ នៅក្នុងកណ្ឌ២កូរិនថូសជំពូក២ លោក ប៉ុល បាននិយាយសំដៅទៅលើអ្វីដែលពួកជំនុំភាគច្រើនបានធ្វើ ក្នុងការដែលពួកគេដាក់វិន័យដល់សមាជិកពួកជំនុំដែលប្រព្រឹត្តខុស។ នៅក្នុងកណ្ឌកាឡាទីជំពូក១ លោក ប៉ុល បានកោះហៅពួកជំនុំទាំងមូលឲ្យថ្កោលទោសសេចក្តីបង្រៀនក្លែងក្លាយដែលពួកគេបានឮ។ នៅក្នុងកណ្ឌ២ធីម៉ូថេជំពូក៤ លោក ប៉ុល មិនគ្រាន់តែស្តីបន្ទោសដល់គ្រូបង្រៀនក្លែងក្លាយប៉ុណ្ណោះទេ លោកថែមទាំងស្តីបន្ទោសដល់អស់អ្នកដែលចំណាយលុយឲ្យគ្រូបង្រៀនក្លែងក្លាយទាំងនោះបង្រៀននូវអ្វីដែលត្រចៀកដ៏រមាស់របស់ពួកគេចង់ស្តាប់ឮទៀតផង។ ពួកចាស់ទុំគឺជាអ្នកដឹកនាំពួកជំនុំ ប៉ុន្តែតាមព្រះគម្ពីរ ពួកគេចាំបាច់ត្រូវដឹកនាំក្នុងដែនកំណត់មួយដែលពួកជំនុំទទួលស្គាល់។ នៅក្នុងន័យនោះ ពួកចាស់ទុំ និងក្រុមប្រឹក្សា ឬគណៈកម្មការដទៃទៀតនៅក្នុងពួកជំនុំបាទីស្ទ (Baptist) គឺមាននាទីជាអ្នកផ្តល់យោបល់ដល់ពួកជំនុំប៉ុណ្ណោះ។

ទីពីរ និកាយ បាទីស្ទ (Baptists) និងនិកាយ ប្រេសប៊ីធើរាន (Presbyterians) បានខ្វែងគំនិតគ្នាលើតួនាទី និងទំនួលខុសត្រូវរបស់ពួកចាស់ទុំ។ ហើយការខ្វែងគំនិតគ្នាធំបំផុតនោះ គឺដោយ-សារតែការយល់ខុសគ្នាលើពាក្យមួយចំនួនដែលលោក ប៉ុល បានសរសេរផ្ញើទៅលោក ធីម៉ូថេ៖ «ចាស់ទុំទាំងឡាយណាដែលដឹកនាំបានល្អ នោះត្រូវរាប់ជាស័ក្តិសមនឹងទទួលកិត្តិយសទ្វេដង ជាពិសេស ពួកចាស់ទុំដែលធ្វើការនឿយហត់ក្នុងការប្រកាសព្រះបន្ទូល និងការបង្រៀន» (១ធីម៉ូថេ ៥:១៧ គគខ)។ និកាយ ប្រេសប៊ីធើ-រាន (Presbyterians) យល់ឃើញថា ខគម្ពីរនេះបែងចែកពួកចាស់ទុំជាពីរក្រុម គឺពួកចាស់ទុំដែលដឹកនាំ និងពួកចាស់ទុំដែលបង្រៀនព្រះបន្ទូល។ និកាយ បាទីស្ទ (Baptist) មិនទទួលស្គាល់ការបែងចែកនេះទេ ប៉ុន្តែ ពួកគេយល់ឃើញថា ខគម្ពីរនេះស្នើឡើងថា បុគ្គលមួយចំនួនក្នុងចំណោមក្រុមនៃពួកចាស់ទុំ គឺគ្រាន់តែផ្តោតទៅលើការអធិប្បាយព្រះបន្ទូល និងការបង្រៀនពេញទំហឹងជាងតែប៉ុណ្ណោះ។ ជារួម លោក ប៉ុល បានប្រាប់ដល់លោក ធីម៉ូថេ យ៉ាងច្បាស់នៅដើមសំបុត្រនេះថា លក្ខណសម្បត្តិជាមូលដ្ឋានមួយរបស់ពួកចាស់ទុំគ្រប់រូបគឺថា គាត់ «ប្រសប់នឹងការបង្រៀន» (១ធីម៉ូថេ ៣:២, សូមមើលផងដែរនៅ ទីតុស ១:៩)។ ដូច្នេះ ជាញឹកញាប់និកាយ បាទីស្ទ (Baptist) បដិសេធថា ពួកគេមិនគួរនឹងតែងតាំង

ពួកចាស់ទុំណាដែលមិនប្រសប់នឹងបង្រៀនព្រះបន្ទូលនោះឡើយ។

## ការមានពួកចាស់ទុំ

និកាយ បាទីស្ទ (Baptists) និងនិកាយ ប្រេសប៊ីធើរាន (Presbyterians) ភាគច្រើនបានឯកភាពគ្នានៅសតវត្សទី១៨ថា ពួកជំនុំតាមតំបន់នីមួយៗគួរតែមានចាស់ទុំចាប់ពីពីរនាក់ឡើងទៅ។ ព្រះគម្ពីរសញ្ញាថ្មីមិនដែលលើកឡើងថា ពួកជំនុំគួរតែមានចំនួននៃពួកចាស់ទុំប៉ុន្មាននាក់ក្នុងពួកជំនុំនោះទេ។ ប៉ុន្តែព្រះគម្ពីរសញ្ញាថ្មីបាននិយាយសំដៅលើ “ពួកចាស់ទុំ” នៅក្នុងពួកជំនុំតាមតំបន់ជាទម្រង់ពហុវចនៈ (ឧទាហរណ៍ កិច្ចការ ១៤:២៣; ១៦:៤; ២០:១៧; ២១:១៨; ទីតុស ១:៥; យ៉ាកុប ៥:១៤)។

សព្វថ្ងៃនេះ មិនមែនគ្រាន់តែនិកាយ បាទីស្ទ (Baptist) ទេដែល បានរកឃើញការដឹកនាំដោយពួកចាស់ទុំនៅក្នុងព្រះគម្ពីរលើសពីនេះទៀត មាននិកាយផ្សេងៗ ក៏ដូចជាពួកជំនុំឯករាជ្យជាច្រើន ក៏បានឃើញពីអត្ថប្រយោជន៍នេះដែរ ព្រោះគំនិតនេះស្របតាមព្រះគម្ពីរ។

ការដឹកនាំដោយពួកចាស់ទុំមិនមែនមានន័យថា គ្រូគង្វាលគ្មានតួនាទីអ្វីនោះទេ។ មានខគម្ពីរយោងជាច្រើននៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែលនិយាយសំដៅទៅលើការអធិប្បាយព្រះបន្ទូល និង

គ្រូអធិប្បាយ ហើយខគម្ពីរទាំងនោះមិននិយាយសំដៅទៅលើពួកចាស់ទុំទាំងអស់នៅក្នុងពួកជំនុំនោះទេ។ ឧទាហរណ៍ នៅទីក្រុងកូរិនថូស លោក ប៉ុល បានញែកខ្លួនគាត់ទុកសម្រាប់តែការអធិប្បាយព្រះបន្ទូលនៅក្នុងរបៀបមួយដែលពួកចាស់ទុំដទៃទៀតក្នុងពួកជំនុំមិនអាចធ្វើបាន (កិច្ចការ ១៨:៥; ១កូរិនថូស ៩:១៤; ១ធីម៉ូថេ ៤:១៣; ៥:១៧)។ មើលទៅ គ្រូអធិប្បាយហាក់ដូចជាប្តូរទីតាំងពីកន្លែងមួយទៅកន្លែងមួយក្នុងគោលបំណងអធិប្បាយព្រះបន្ទូល (រ៉ូម ១០:១៤-១៥)។ ប៉ុន្តែ ឯពួកចាស់ទុំវិញមើលទៅគ្រាន់តែនៅក្នុងតំបន់សហគមន៍មួយប៉ុណ្ណោះ (ទីតុស ១:៥)។

ពួកជំនុំ និងពួកចាស់ទុំប្រហែលនឹងរាប់គ្រូអធិប្បាយដែលអធិប្បាយព្រះបន្ទូលយ៉ាងស្មោះត្រង់ជាប្រចាំ ទុកដូចជាអ្នកទីមួយក្នុងចំណោមអ្នកដឹកនាំទាំងអស់ថា គាត់ស័ក្តិសមនឹងទទួលការ “គោរពប្រតិបត្តិជាទ្វេគុណឡើង” (១ធីម៉ូថេ ៥:១៧)។ ទោះជាយ៉ាងណាក៏ដោយ យើងគួរចងចាំថា គ្រូអធិប្បាយ ឬគ្រូគង្វាលគឺគ្រាន់តែជាម្នាក់ក្នុងចំណោមពួកចាស់ទុំដែលមានឋានៈស្មើគ្នា ហើយបានទទួលការតែងតាំងដូចគ្នាពីពួកជំនុំឲ្យធ្វើជាចាស់ទុំម្នាក់។

# អត្ថប្រយោជន៍នៃការមានពួកចាស់ទុំ

តាមបទពិសោធន៍ខ្ញុំផ្ទាល់ជាគ្រូគង្វាលម្នាក់ ខ្ញុំបានឃើញពីអត្ថ-ប្រយោជន៍នៃការអនុវត្តតាមព្រះគម្ពីរសញ្ញាថ្មី ក្នុងការចែករំលែកទំនួលខុសត្រូវចំពោះការដឹកនាំពួកជំនុំតាមតំបន់ជាមួយនឹងអ្នកដែលបានប្ដេជ្ញាបម្រើពួកជំនុំក្នុងនាមជាចាស់ទុំ។

ការសម្រេចចិត្តទាំងឡាយណាដែលទាក់ទងនឹងពួកជំនុំ មិនគួរធ្លាក់លើគ្រូគង្វាលតែម្នាក់ឯងនោះទេ ប្រសិនបើការសម្រេចចិត្តនោះមិនតម្រូវសុំគំនិតយោបល់ពីសមាជិកពួកជំនុំទាំងអស់ទេ។ ប៉ុន្តែការសម្រេចចិត្តនោះគួរតែធ្លាក់លើពួកចាស់ទុំទាំងមូលវិញ។ ពេលខ្លះការធ្វើដូចនេះគឺមានភាពយឺតយ៉ាវ ហើយស្មុគស្មាញបន្តិច ប៉ុន្តែវាមានអត្ថប្រយោជន៍យ៉ាងច្រើន។ វាជួយដុសខាត់អំណោយ-ទានរបស់គ្រូគង្វាល ដោយពួកចាស់ទុំជួយបំពេញបន្ថែមចំពោះចំណុចខ្វះខាតមួយចំនួន និងជាជំនួយដល់ការសម្រេចចិត្តរបស់គាត់។ ការដែលមានពួកចាស់ទុំបង្កើតឲ្យមានការគាំទ្រនៅក្នុងពួកជំនុំក្នុងការសម្រេចចិត្ត ហើយជួយពួកគេឲ្យមានការរួបរួមគ្នាមកតែមួយ ព្រមទាំងការពារអ្នកដឹកនាំមិនឲ្យទទួលរងការរិះគន់ដ៏អយុត្តិធម៌។ ការមានពួកចាស់ទុំ អាចជួយធ្វើឲ្យអ្នកដឹកនាំចាក់ឫសមាំ និងគង់វង្ស ហើយអាចជួយខ្លួនគេឲ្យកាន់តែមានប្រាជ្ញាក្នុង

ការដឹកនាំ។ ការមានពួកចាស់ទុំ អាចជួយជំរុញពួកជំនុំឲ្យមានទំនួលខុសត្រូវកាន់តែច្រើនឡើងចំពោះជីវិតខាងឯវិញ្ញាណរបស់ពួកគេ ហើយថែមទាំងជួយពួកជំនុំ កុំឲ្យពឹងផ្អែកខ្លាំងពេកលើអ្នកដែលទទួលប្រាក់ខែពីពួកជំនុំ។

សព្វថ្ងៃនេះ នៅក្នុងពួកជំនុំបាទីស្ទ (Baptist) មិនសូវមានពួកចាស់ទុំជាអ្នកដឹកនាំច្រើនប៉ុន្មានទេ ប៉ុន្តែនិន្នាការទៅរកការមានពួកចាស់ទុំនេះកំពុងតែរីកដុះដាលនៅក្នុងចំណោមពួកជំនុំបាទីស្ទ (Baptist) ដោយព្រោះការមានពួកចាស់ទុំមានអត្ថប្រយោជន៍ច្រើន។ ពួកជំនុំនីមួយៗក្នុងព្រះគម្ពីរសញ្ញាថ្មីត្រូវការពួកចាស់ទុំ ហើយពួកជំនុំសព្វថ្ងៃនេះក៏ត្រូវការពួកចាស់ទុំដែរ។

## ចុះចំណែកឯអ្នកជំនួយវិញ?

បច្ចុប្បន្ននេះ មានពួកជំនុំជាច្រើនតែងតែយល់ច្រឡំថា ពួកចាស់ទុំគឺជាអ្នកដែលទទួលប្រាក់ខែពីពួកជំនុំ ឬក៏ជាអ្នកជំនួយ។ អ្នកជំនួយក៏ជាមុខតំណែងមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែរ។ នៅក្នុងកណ្ឌកិច្ចការជំពូក៦ យើងឃើញថា អ្នកជំនួយមានតួនាទីជាក់លាក់នៅក្នុងពួកជំនុំ។ ទោះបីវាជាការលំបាកក្នុងការបែងចែកមុខតំណែងទាំងពីរឲ្យដាច់ស្រឡះពីគ្នា ប៉ុន្តែជាទូទៅ អ្នកជំនួយធ្វើការទាក់ទងទៅនឹងការងារលម្អិតក្នុងជីវិតពួកជំនុំដូចជា កិច្ចការ

រដ្ឋបាល ការថែទាំ និងការមើលថែសមាជិកពួកជំនុំដោយទៅសួរសុខទុក្ខពួកគេ នៅពេលពួកគេឈឺ ឬដោយផ្គត់ផ្គង់អាហារដល់ពួកគេ នៅពេលពួកគេខ្វះខាតជាដើម។ល។ នៅក្នុងពួកជំនុំជាច្រើនសព្វថ្ងៃនេះ យើងសង្កេតឃើញថា អ្នកជំនួយជាអ្នកទទួលនាទីមើលការខុសត្រូវជីវិតខាងវិញ្ញាណរបស់ពួកជំនុំ ឬពួកគេទុកការងារនោះទាំងស្រុងទៅក្នុងដៃគ្រូគង្វាលម្នាក់ឯងតែម្តង។ ពួកជំនុំនឹងទទួលបានផលប្រយោជន៍ជាច្រើន ប្រសិនបើពួកគេបែកចែកតួនាទីរបស់ពួកចាស់ទុំ និងតួនាទីរបស់អ្នកជំនួយឲ្យដាច់ដោយឡែកពីគ្នាយ៉ាងច្បាស់លាស់។ សព្វថ្ងៃនេះ ពួកជំនុំពិតជាត្រូវការអ្នកបម្រើទាំងពីរប្រភេទនេះណាស់។

## ការចែករំលែកបន្ទុក និងអភ័យឯកសិទ្ធិ

ក្នុងនាមខ្ញុំជាគ្រូគង្វាល ខ្ញុំមានតំណែងស្របតាមព្រះគម្ពីរជាចាស់ទុំ។ ខ្ញុំជាចាស់ទុំដែលមានតួនាទីចម្បងគឺអធិប្បាយព្រះបន្ទូល។ ប៉ុន្តែ ខ្ញុំធ្វើការរួមជាមួយពួកចាស់ទុំ ដើម្បីស្អាងចិត្តពួកជំនុំ។ ពួកចាស់ទុំមួយចំនួនជាអ្នកទទួលប្រាក់ខែពីពួកជំនុំ ប៉ុន្តែពួកចាស់ទុំភាគច្រើនមិនបានទទួលប្រាក់ខែនោះទេ។ យើងជួបប្រជុំគ្នាជាទៀងទាត់ ដើម្បីអធិស្ឋាន ជជែកពិភាក្សា និងផ្តល់នូវគំនិតយោបល់ខ្លះៗដល់អ្នកជំនួយ ឬដល់ពួកជំនុំទាំងមូល។

ខ្ញុំមានការពិបាកណាស់ក្នុងការរកពាក្យពេចន៍មកពណ៌នាពីរបៀប ដែលពួកចាស់ទុំទាំងនេះបានស្រឡាញ់ខ្ញុំ និងពួកជំនុំទាំងមូល។ ពួកគេបានចែករំលែកបន្ទុកខ្ញុំ និងផ្ដល់អភ័យឯកសិទ្ធិដល់ខ្ញុំក្នុង ការដឹកនាំពួកជំនុំ។ ខ្ញុំអរព្រះគុណដល់ព្រះជាម្ចាស់មិនដាច់ពីមាត់ ដែលទ្រង់បានប្រទានគូកនបម្រើព័ន្ធកិច្ចដូចជាពួកគេទាំងនេះ។

យើងឃើញច្បាស់ណាស់ថា ការមានពួកចាស់ទុំ គឺជាគំនិត មួយស្របតាមព្រះគម្ពីរដែលមានប្រយោជន៍ជាច្រើន។ ប្រសិនបើ យើងតាំងឲ្យមានពួកចាស់ទុំធ្វើជាអ្នកដឹកនាំ ការនេះអាចនឹង ជួយដល់គ្រូគង្វាលយ៉ាងច្រើន ដោយសារពួកចាស់ទុំអាចជួយ ដកបន្ទុកចេញពីស្មារបស់គាត់ ហើយថែមទាំងជួយលុបបំបាត់ របបផ្ដាច់ការរបស់គាត់ចេញពីពួកជំនុំទៀតផង។ លើសពីនេះទៅ ទៀត លក្ខណសម្បត្តិទាំងអស់នៃចាស់ទុំដែលលោក ប៉ុល បាន លើកឡើង (ក្រៅពីភាពប្រសប់ក្នុងការបង្រៀន) ជាលក្ខណសម្បត្តិ ដែលគ្រីស្ទបរិស័ទគ្រប់រូបគួរតែខំតម្រង់ឆ្ពោះទៅរកដែរ (១ធីម៉ូថេ ៣; ទីតុស ១)។ ដូច្នេះ នៅពេលដែលយើងទទួលស្គាល់បុគ្គល មួយចំនួនជាសាធារណៈថា ពួកគេជាមនុស្សគំរូ នោះវាជួយឲ្យ គ្រីស្ទបរិស័ទផ្សេងទៀត ជាពិសេសគ្រីស្ទបរិស័ទប្រុសៗឃើញនូវ គំរូនោះ។ ពិតប្រាកដណាស់ ការអនុវត្តនូវការទទួលស្គាល់បុរស ដែលគួរឲ្យទុកចិត្ត មានតម្រិះ កោតខ្លាចព្រះជាម្ចាស់ ព្រមទាំង

ជាអ្នកដែលមិនទទួលបានប្រាក់ខែពីពួកជំនុំទុកជាចាស់ទុំ គឺជាសញ្ញាសម្គាល់មួយទៀតនៃពួកជំនុំដែលមានសុខភាពល្អ។

# សេចក្ដីបញ្ចប់៖
# ការអនុវត្តជាក់ស្ដែង

**ថ្មីៗនេះ មានចាស់ទុំ**ម្នាក់នៅក្នុងពួកជំនុំរបស់ខ្ញុំបាននិយាយមកខ្ញុំថា៖ «ខ្ញុំមានបំណងចង់ចេញពីពួកជំនុំនេះច្រើនលើកមកហើយ ដោយព្រោះតែគ្រប់ទាំងការពិភាក្សានិយាយតែពីការតយុទ្ធនឹងអំពើបាប និងការបម្រើអ្នកដទៃ។ មិនតែប៉ុណ្ណោះ ខ្ញុំចង់ចេញពីពួកជំនុំនេះ ព្រោះមានមនុស្សជាច្រើនកែតម្រង់ខ្ញុំពេលដែលខ្ញុំធ្វើខុស ហើយពួកគេក៏ប្រព្រឹត្តបាបដែរ»។

គាត់បានបន្តថា «ប៉ុន្តែ ខ្ញុំយល់ឃើញថា ខ្ញុំត្រូវការការទាំងអស់នេះ ពីព្រោះខ្ញុំនៅតែជាមនុស្សប្រព្រឹត្តបាប ហើយខ្ញុំចង់ឲ្យរួចផុតពីបាបនេះ។ ខ្ញុំត្រូវការឲ្យគេជួយកែតម្រង់ខ្ញុំពេលខ្ញុំធ្វើខុស ខ្ញុំត្រូវការឲ្យគេធ្វើជាគំរូ ហើយខ្ញុំត្រូវការសេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់ពីពួកគេ។ សាច់ឈាមរបស់ខ្ញុំស្អប់ការទាំងអស់នេះ ប៉ុន្តែបើអត់មានការទាំងអស់នេះទេ ខ្ញុំប្រហែលជាលែងលះជាមួយនឹង

ប្រពន្ធខ្ញុំហើយ ហើយបន្ទាប់មកលែងលះជាមួយនឹងអ្នកទីពីរ អ្នកទីបី ហើយខ្ញុំប្រហែលនឹងមិនបានរស់នៅជាមួយនឹងកូនៗរបស់ខ្ញុំទេ។ ព្រះជាម្ចាស់បានបង្ហាញនូវព្រះគុណ និងការថែរក្សាបីបាច់របស់ទ្រង់ចំពោះខ្ញុំតាមរយៈពួកជំនុំរបស់ទ្រង់»។

ពួកជំនុំដែលមានសុខភាពល្អ គឺជាពួកជំនុំដែលឆ្លុះបញ្ចាំងឲ្យឃើញពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់*ច្រើនឡើងៗ* ដូចដែលទ្រង់បានបើកសម្ដែងឲ្យឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ទោះបើពួកជំនុំមានសុខភាពល្អក៏ដោយ ពេលខ្លះយើងនៅតែពិបាកនៅជាមួយពួកគេដដែល។ យើងពិបាកប្រហែលមកពីការអធិប្បាយវែង ឬមកពីសេចក្ដីរំពឹងពីអ្នកចូលរួមខ្ពស់។ ចំពោះមនុស្សជាច្រើន គេប្រហែលជាមានអារម្មណ៍ថា ពួកជំនុំបែបនេះនិយាយដដែលៗពីបាបដែលគេប្រព្រឹត្ត។ ហើយនៅពេលប្រកបគ្នា មានអ្នកខ្លះចេះតែសួរសំណួរពីជីវិតផ្ទាល់ខ្លួនច្រើនពេក។ ប៉ុន្តែ ពាក្យដែលសំខាន់ទាក់ទងនឹងពួកជំនុំដែលមានសុខភាពល្អគឺពាក្យ *ច្រើនឡើងៗ*។ ប្រសិនបើយើងឆ្លុះបញ្ចាំងចរិតលក្ខណៈរបស់ព្រះជាម្ចាស់*ច្រើនឡើងៗ* នោះវាបង្ហាញថា ផ្នែកខ្លះនៃជីវិតរបស់យើងម្នាក់ៗ និងជីវិតពួកជំនុំទាំងមូលមិនទាន់បានឆ្លុះបញ្ចាំងពីចរិតលក្ខណៈរបស់ទ្រង់បានយ៉ាងពេញលេញនៅឡើយដែរ។ ជីវិតរបស់យើងប្រៀបដូចជាកញ្ចក់ដែលមានដាមប្រឡាក់ ដូច្នេះហើយយើងត្រូវតែជូតវាឲ្យស្អាត។

ហើយកញ្ចក់នោះច្បាស់ជាមានសភាពកោង ដូច្នេះយើងត្រូវពុតវាឲ្យរាបស្មើ។ ការនេះតម្រូវឲ្យយើងខិតខំប្រឹងប្រែងខ្លាំង។

យោងតាមសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ ទ្រង់បានបង្រៀនឲ្យយើងរស់នៅបង្ហាញពី ជីវិតគ្រីស្ទបរិស័ទជាមួយគ្នា ដោយសារការដែលយើងស្រឡាញ់ ហើយយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក នោះវាឆ្លុះបញ្ចាំងពីសេចក្តីស្រឡាញ់ និងការយកព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់ចំពោះយើង។ ជាទូទៅ ប្រសិនបើបុគ្គលម្នាក់ចង់បានទំនាក់ទំនង ជាមួយបុគ្គលម្នាក់ទៀត បុគ្គលទាំងពីរនាក់នោះត្រូវតែមានការប្តេជ្ញាចំពោះគ្នានឹងគ្នា។ ពិតប្រាកដណាស់ នៅក្នុងពួកជំនុំក៏ត្រូវការប្តេជ្ញាចិត្តបែបដូចនេះដែរ។ ព្រះជាម្ចាស់មិនដែលមានព្រះទ័យឲ្យការរីកចម្រើនខាងឯវិញ្ញាណរបស់យើងកើតឡើងតែម្នាក់ឯងនោះទេ ប៉ុន្តែ ទ្រង់សព្វព្រះទ័យឲ្យយើងរីកចម្រើនជាមួយគ្នានឹងគ្នា។

ដូច្នេះ តើពួកជំនុំដែលមានសុខភាពល្អមានអំណរឬទេ? ពិតប្រាកដណាស់ គេមានអំណរ។ គេមានអំណរពីការផ្លាស់ប្រែដ៏ពិតប្រាកដ។ គេមានអំណរដោយបានរួចពីអំពើបាប។ គេមានអំណរដោយបានប្រកបគ្នាយ៉ាងជិតស្និទ្ធ ហើយបានរួបរួមគ្នាដ៏ពិតប្រាកដ។ ការរួបរួមនោះមិនមែនជាការរួបរួម ដើម្បីតែការរួបរួមនោះទេ ប៉ុន្តែជាការរួបរួមដែលឈរលើសេចក្តីសង្គ្រោះ និងការថ្វាយ

បង្គំព្រះជាម្ចាស់រួមគ្នា។ គេមានអំណរក្នុងការស្រឡាញ់គ្នាទៅវិញទៅមក ដូចដែលព្រះគ្រីស្ទស្រឡាញ់ពួកគេ។ អ្វីដែលជាការអស្ចារ្យបំផុតនោះ គឺគេមានអំណរពីការ “ឆ្លុះឲ្យឃើញពីសិរីរុងរឿងរបស់ព្រះអម្ចាស់” ហើយការ “ផ្លាស់ប្រែពីសិរីរុងរឿងទៅសិរីរុងរឿងឲ្យមានរូបរាងដូចព្រះអង្គ” (២កូរិនថូស ៣:១៨ គគខ)។

នៅក្នុងបញ្ញត្តិទីបី ព្រះជាម្ចាស់ហាមរាស្ត្ររបស់ទ្រង់មិនឲ្យចេញព្រះនាមទ្រង់ជាអាសាឥតការឡើយ (និក្ខមនំ ២០:៧; ចោទិយកថា ៥:១១)។ ទ្រង់មិនគ្រាន់តែចង់មានន័យថា ទ្រង់ហាមយើងមិនឲ្យប្រើពាក្យអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ចង់មានន័យថា ទ្រង់ហាមយើងមិនឲ្យចេញព្រះនាមទ្រង់តាមរយៈជីវិតរបស់យើងជាអាសាឥតការនោះដែរ។ ទ្រង់ហាមមិនឲ្យជីវិតរបស់យើងបង្ហាញរូបភាពខុសអំពីទ្រង់ឡើយ។ នេះក៏ជាបញ្ញត្តិសម្រាប់ពួកជំនុំផងដែរ។

សព្វថ្ងៃនេះ មានពួកជំនុំជាច្រើនមិនមានសុខភាពល្អទេ។ យើងគិតខុសថា ការរីកចម្រើនបែបអាត្មានិយមជាការរីកចម្រើនខាងឯវិញ្ញាណទៅវិញ។ យើងគិតខុសថា ការមានអារម្មណ៍រំជើបរំជួលគឺជាការថ្វាយបង្គំដ៏ពិត។ យើងសប្បាយរីករាយនឹងការទទួលស្គាល់ពីលោកីយ៍ជាជាងការទទួលស្គាល់ពីព្រះជាម្ចាស់ ប៉ុន្តែជាទូទៅដោយសារជីវិតដែលទទួលស្គាល់ពីព្រះជាម្ចាស់ គឺមានការទាស់ប្រឆាំងពីលោកីយ៍។ សព្វថ្ងៃនេះ មិនថាពួកជំនុំមានគ្នាតិចឬច្រើននោះ

ទេ មើលទៅពួកគេភាគច្រើនហាក់ដូចជាមិនខ្វល់ពីសញ្ញាសម្គាល់តាមព្រះគម្ពីរដែលសម្គាល់យ៉ាងជាក់ច្បាស់ពីពួកជំនុំដែលរីកចម្រើន ហើយមានជីវិតរស់ខាងឯវិញ្ញាណ។

គ្រីស្ទបរិស័ទគ្រប់រូបគួរតែយកចិត្តទុកដាក់លើសុខភាពពួកជំនុំជាពិសេស អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យធ្វើជាអ្នកដឹកនាំក្នុងពួកជំនុំ។ ពួកជំនុំរបស់យើងត្រូវតែបង្ហាញឲ្យឃើញព្រះជាម្ចាស់ និងដំណឹងល្អដ៏ឧត្តមរបស់ទ្រង់ដល់អស់ទាំងមនុស្សដែលទ្រង់បង្កើតមក។ យើងត្រូវថ្វាយសិរីល្អដល់ទ្រង់តាមរយៈជីវិតរបស់យើងដែលរស់នៅជាមួយគ្នា។ ការរស់នៅដែលបង្ហាញពីសិរីល្អទ្រង់ គឺជាទំនួលខុសត្រូវដ៏អស្ចារ្យ ហើយជាអភ័យឯកសិទ្ធិមួយដ៏ធំនៅក្នុងជីវិតគ្រីស្ទបរិស័ទ។

ដូច្នេះ ចូរយើងវិលត្រឡប់ទៅចំណុចដែលយើងបានចាប់ផ្ដើមវិញ។ តើលោកអ្នកកំពុងតែស្វែងរកអ្វីនៅក្នុងពួកជំនុំ? តើលោកអ្នកកំពុងតែស្វែងរកពួកជំនុំមួយដែលឆ្លុះបញ្ចាំងពីគុណតម្លៃរបស់លោកអ្នក និងគុណតម្លៃរបស់សហគមន៍លោកអ្នក ឬមួយលោកអ្នកស្វែងរកពួកជំនុំមួយដែលឆ្លុះបញ្ចាំងពីចរិតលក្ខណៈដ៏ឧត្តមរបស់ព្រះជាម្ចាស់ឬ? នៅក្នុងចំណោមជម្រើសទាំងពីរនេះ តើមួយណានឹងបញ្ចេញពន្លឺដល់លោកីយ៍ដែលវង្វេងនៅក្នុងភាពងងឹតនេះប្រសើរជាង?

## ដើម្បីសិក្សាបន្ថែម...

សូមអានសៀវភៅដែលមានចំណងជើងថា *Nine Marks of a Healthy Church* (Crossway, 2004) ដើម្បីពិភាក្សាឲ្យបានពេញលេញទៅលើសញ្ញាសម្គាល់នីមួយៗ ក្នុងចំណោមសញ្ញាសម្គាល់ទាំងប្រាំបួននេះ។ សូមអានសៀវភៅ *The Deliberate Church* ដែលនិពន្ធដោយលោក ប៉ូល អាឡិកហ្សានឌើរ (Paul Alexander) និងខ្ញុំ ដើម្បីទទួលបានការអនុវត្តងាយៗ បន្ថែមទៀតក្នុងការបង្កើតពួកជំនុំដែលមានសុខភាពល្អ ។ សូមអានសៀវភៅ *A Display of God's Glory* (9Marks, 2001) ដើម្បីឲ្យស្គាល់បន្ថែមលើរចនាសម្ព័ន្ធពួកជំនុំ ជាពិសេសការកំណត់សម្គាល់សមាជិកភាពពួកជំនុំ ពួកចាស់ទុំ អ្នកជំនួយ និងរបៀបដឹកនាំដែលយកពួកជំនុំជាធំ ។ ចុងក្រោយ លោកអ្នកប្រហែលជាចង់អានអត្ថបទ សៀវភៅ ឬស្តាប់សេចក្តីអធិប្បាយ ឬទស្សនាការបង្រៀនតាមប្រព័ន្ធអ៊ីនធឺណិតដែលនិយាយពីជីវិតពួកជំនុំនៅគេហទំព័រ www.9marks.org។

---

## បណ្តាំជូនចំពោះសមាជិកពួកជំនុំ

ប្រសិនបើលោកអ្នកបានទទួលការលើកទឹកចិត្ត តាមរយៈសេចក្តីបង្រៀនណាមួយនៅក្នុងសៀវភៅនេះ សូមលោកអ្នកប្រុងប្រយ័ត្ន

ចំពោះរបៀបស្នើសុំដល់គ្រូគង្វាលឲ្យផ្លាស់ប្តូរអ្វីមួយ។ សូមអធិស្ឋាន បម្រើ អត់ធ្មត់ លើកទឹកចិត្ត និងធ្វើជាគំរូល្អក្នុងជីវិតរបស់លោកអ្នក។ ពួកជំនុំដែលមានសុខភាពល្អគឺជារាស្ត្ររបស់ព្រះជាម្ចាស់ដែលចេះស្រឡាញ់គ្នាយ៉ាងត្រឹមត្រូវ។ ហើយជាទូទៅ យើងអាចបង្ហាញសេចក្តីស្រឡាញ់របស់យើងបានល្អបំផុត នៅពេលដែលយើងផ្តល់សេចក្តីស្រឡាញ់នោះក្នុងស្ថានភាពដែលយើងមិនពេញចិត្ត។ អ្នកជឿរាល់គ្នាអើយ! សូមគិតមើលពីរបៀបដែលព្រះជាម្ចាស់បានស្រឡាញ់យើងក្នុងព្រះគ្រីស្ទ។

## បណ្តាំជូនចំពោះគ្រូគង្វាល

ប្រសិនបើលោកគ្រូទទួលការលើកទឹកចិត្តតាមរយៈសេចក្តីបង្រៀនណាមួយនៅក្នុងសៀវភៅនេះ សូមលោកគ្រូប្រុងប្រយ័ត្នចំពោះរបៀបដែលលោកគ្រូចង់ផ្លាស់ប្តូរអ្វីមួយនៅក្នុងពួកជំនុំ។ សូមលោកគ្រូព្យាយាមអត់ធ្មត់ ស្រឡាញ់ពួកជំនុំ និងអធិប្បាយព្រះបន្ទូល។

# សេចក្ដីបន្ថែម៖ លក្ខន្តិកៈដ៏សាមញ្ញក្នុងពួកជំនុំ ដែលមានសុខភាពល្អ

**យើងជឿថា** តាមរយៈព្រះគុណ ព្រះជាម្ចាស់បាននាំយើងឲ្យប្រែចិត្ត ហើយឲ្យជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយទ្រង់បាននាំយើងឲ្យថ្វាយខ្លួនទៅចំពោះទ្រង់ ។ មិនតែប៉ុណ្ណោះ យើងបានទទួលពិធីជ្រមុជទឹកដោយការបញ្ជាក់អះអាងពីជំនឿរបស់យើង ក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធរួចហើយ។ ដូច្នេះ ពេលនេះ យើងខ្ញុំសូមសន្យាយ៉ាងមុតមាំ និងដោយអំណរចំពោះគ្នាទៅវិញទៅមកជាថ្មីឡើងវិញ ដោយពឹងលើជំនួយប្រកបដោយព្រះគុណករុណារបស់ព្រះជាម្ចាស់។

យើងនឹងខិតខំប្រឹងប្រែង ហើយអធិស្ឋាន ដើម្បីឲ្យពួកជំនុំយើងបាននូវភាពរួបរួមខាងឯព្រះវិញ្ញាណនៅក្នុងចំណងនៃមេត្រីភាព។

យើងនឹងដើរជាមួយគ្នាក្នុងសេចក្ដីស្រឡាញ់ជាបងប្អូនក្នុង

ព្រះគ្រីស្ទ នៅពេលដែលយើងក្លាយជាសមាជិកពួកជំនុំ។ យើងនឹងយកចិត្តទុកដាក់ ហើយមើលខុសត្រូវគ្នាទៅវិញទៅមក ថែមទាំងដាស់តឿន ក៏ដូចជាទទូចអង្វរចំពោះគ្នាទៅវិញទៅមកយ៉ាងខ្ជាប់ខ្ជួន នៅពេលដែលកាលៈទេសៈតម្រូវឲ្យយើងធ្វើដូច្នោះ។

យើងនឹងមិនបោះបង់ការប្រជុំគ្នា ឬឈប់អធិស្ឋានសម្រាប់ខ្លួនឯង និងអ្នកដទៃនោះឡើយ។

យើងនឹងខិតខំប្រឹងប្រែងអប់រំ ហើយដាស់តឿនដល់អ្នកដែលយើងមើលថែតាមរបៀបរបស់ព្រះអម្ចាស់។ ហើយគោលបំណងរបស់យើង គឺចង់ឃើញគ្រួសារ និងមិត្តភក្តិទទួលបានសេចក្តីសង្គ្រោះដោយយើងធ្វើជាគំរូ ហើយរស់នៅក្នុងជីវិតបរិសុទ្ធដែលពេញដោយក្តីស្រឡាញ់។

យើងនឹងអរសប្បាយចំពោះសុភមង្គលរបស់គ្នាទៅវិញទៅមក ហើយយើងនឹងពុះពារ ដើម្បីនឹងចែករំលែកបន្ទុក ក៏ដូចជាភាពសោកសៅរបស់គ្នាទៅវិញទៅមក ដោយភាពទន់ភ្លន់ និងការយល់ចិត្តគ្នា។

ដោយមានជំនួយពីព្រះជាម្ចាស់ យើងនឹងខិតខំរស់នៅយ៉ាងប្រុងប្រយ័ត្ននៅក្នុងលោកីយ៍នេះ។ យើងនឹងបដិសេធនូវសេចក្តីទមិទ្បល្មើស ចោល និងភាពត្រេកត្រអាលតាមបែបលោកីយ៍នេះ។ មិនតែប៉ុណ្ណោះ យើងនឹងចងចាំថា ដោយព្រោះយើងស្ម័គ្រចិត្តកប់

ខ្លួនយើងតាមរយៈពិធីបុណ្យជ្រមុជទឹក ហើយបានងើបឡើងវិញពីផ្នូរនិមិត្តរូបរួចហើយ។ ដូច្នេះ ពេលនេះ យើងមានកាតព្វកិច្ចដ៏ពិសេសក្នុងការរស់នៅជាថ្មី ហើយបរិសុទ្ធ។

យើងនឹងធ្វើការរួមគ្នាសម្រាប់និរន្តរភាពនៃព័ន្ធកិច្ចដំណឹងល្អយ៉ាងទៀងត្រង់នៅក្នុងពួកជំនុំនេះ ខណៈដែលយើងរក្សានូវការថ្វាយបង្គំ ពិធីផ្សេងៗក្នុងពួកជំនុំ ការដាក់វិន័យ និងគោលលទ្ធិ។ យើងនឹងថ្វាយតង្វាយដោយអរសប្បាយ និងទៀងទាត់ ដើម្បីជាការផ្គត់ផ្គង់ដល់ព័ន្ធកិច្ច សម្រាប់ការចំណាយផ្សេងៗក្នុងពួកជំនុំ ការជួយដល់អ្នកក្រីក្រ និងសម្រាប់ការផ្សព្វផ្សាយដំណឹងល្អឲ្យដល់ជាតិសាសន៍ផ្សេងៗ។

នៅពេលដែលយើងចេញពីពួកជំនុំនេះទៅ យើងនឹងរួបរួមជាមួយនឹងពួកជំនុំដទៃទៀត ដើម្បីបន្តអនុវត្តលក្ខន្តិកៈនេះ និងគោលការណ៍នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យបានឆាប់តាមដែលយើងអាចធ្វើបាន។

សូមឲ្យព្រះគុណនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងសេចក្តីប្រកបរបស់ព្រះវិញ្ញាណបរិសុទ្ធនៅជាប់ជាមួយយើងទាំងអស់គ្នា! អាម៉ែន។

# ថ្លែងអំណរគុណជាពិសេស

**មានមនុស្សជាច្រើន**បានជួយខ្ញុំឲ្យយល់ ព្រមទាំងផ្តល់ពិសោធន៍អំពីពួកជំនុំដែលមានសុខភាពល្អដល់ខ្ញុំ ប៉ុន្តែមានមនុស្សពីរនាក់បានរួមចំណែកយ៉ាងពិសេសក្នុងសៀវភៅនេះ។

អ្នកទីមួយឈ្មោះលោក ម៉េត ស្មឹកឃើ (Matt Schmucker) បានស្នើសុំឲ្យខ្ញុំប្រមូលសំបុត្រផ្សេងៗដែលខ្ញុំបានផ្ញើទៅពួកជំនុំចងក្រងជាកូនសៀវភៅអានមួយក្បាលជាលើកទីមួយដែលមិនបានផ្សព្វផ្សាយឲ្យទូលាយ។ ក្រោយមក លោកបានលើកទឹកចិត្តខ្ញុំជារឿយៗឲ្យយកសៀវភៅដែលបានចងក្រងលើកទីមួយនោះទៅច្រងក្រងជាសៀវភៅមួយក្បាលនេះ។ បើគ្មានគាត់ទេ សៀវភៅនេះមិនអាចលេចចេញជារូបរាងបានដែរ។

អ្នកទីពីរឈ្មោះលោក ចនណាថាន លីមែន (Jonathan Leeman) គាត់បានជួយច្រើននៅក្នុងសៀវភៅនេះ ដូច្នេះខ្ញុំគិតថាប្រហែលជាការល្អប្រសិនបើខ្ញុំដាក់ឈ្មោះរបស់គាត់នៅលើក្របមុខទន្ទឹមនឹងឈ្មោះខ្ញុំដែរ។ ទីបំផុត ដោយសារសេចក្តីបង្រៀនភាគច្រើន

ជារបស់ខ្ញុំ ហើយសៀវភៅនេះដូចគ្នានឹងកូនសៀវភៅមុនដែលមានចំណងជើងថា 9Marks និងរបៀបដែលខ្ញុំសរសេរសៀវភៅនេះ (“ខ្ញុំ” សំដៅលើខ្ញុំផ្ទាល់ ព្រមទាំងមានឧទាហរណ៍ពីជីវិតរបស់ខ្ញុំ) ដូច្នេះ អ្នកដែលជួយពិនិត្យសៀវភៅនេះក៏សម្រេចចិត្តដាក់ត្រឹមឈ្មោះរបស់ខ្ញុំ។ ខ្ញុំគួរបញ្ជាក់ឲ្យដឹងផងដែរថា លោក ចនណាថានបានសរសេររឿងប្រៀបប្រដូចពីលោកច្រមុះ និងគ្រួសារលោកដៃ ហើយលោកក៏បានសរសេរយ៉ាងវែងពីអ្វីដែលព្រះគម្ពីរសញ្ញាថ្មីរៀបរាប់អំពីការប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ លោកក៏បានសរសេរផ្នែកផ្សេងៗទៀតនៅប៉ុន្មានជំពូកដំបូងដែរ។ មិនតែប៉ុណ្ណោះ លោកបានធ្វើកិច្ចការយ៉ាងល្អ ក្នុងការរៀបចំកូនសៀវភៅចាស់នោះឡើងវិញ ហើយបានកែសម្រួលកូនសៀវភៅនោះឲ្យក្លាយជាទម្រង់ថ្មី ហើយធំមួយនេះ។ ជាមួយគ្នានេះដែរ យើងសង្ឃឹមថា សៀវភៅថ្មីនេះនឹងមានសារប្រយោជន៍ជាងមុន។ លោកជាមនុស្សម្នាក់ដែលមានទេពកោសល្យ ហើយខ្ញុំទទួលបានជំនួយដ៏ធំធេងពីលោក។ តាមរយៈសៀវភៅនេះ លោកអ្នកនឹងទទួលបានផលប្រយោជន៍ច្រើនជាងពីគាត់ផងដែរ។៚

បើលោកអ្នកចង់ដឹងព័ត៌មានពីសៀវភៅគ្រីស្ទបរិស័ទជាភាសាខ្មែរផ្សេងៗទៀត
សូមចូលទៅកាន់គេហទំព័រ៖

Looking for more Christian resources in the Khmer language?

Visit: http://www.cambodianchristianresources.com